ខោនធី Los Angeles

# ផែនការគ្រប់គ្រងការ បោះឆ្នោត

## 2019

**DEAN C. LOGAN**
មន្ត្រីចុះបញ្ជី-កត់ត្រារបស់ខោនធី/ស្មៀនខោនធី

## តារាងមាតិកា


**សេចក្តីផ្តើម ....................................................................................... 3**

**ច្បាប់ជម្រើសរបស់អ្នកបោះឆ្នោត.......................................................................... 3**

**ដំណោះស្រាយនៃការបោះឆ្នោតសម្រាប់ប្រជាជនគ្រប់រូប ........................................ 4**

**ផ្នែកទី 1 – កម្រិតវប្បធម៌អ្នកបោះឆ្នោត និងការរៀបចំផែនការផ្សព្វផ្សាយ.......................... 7**

- **1-A** ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ........................................ **7**
- **1-B** ការពង្រីកការបោះឆ្នោតតាមសំបុត្រ ........................................ **12**
- **1-C** ការចូលរួមផ្នែកសហគមន៍ ........................................ **15**
- **1-D** ព័ត៌មានអំពីគេហទំព័រ ........................................ **44**
- **1-E** ផ្នែកជំនួយភាសា ........................................ **44**
- **1-F** ជំនួយផ្នែកលទ្ធភាពប្រើប្រាស់ ........................................ **47**
- **1-G** កញ្ចប់ថវិកា និងប្រព័ន្ធផ្សព្វផ្សាយ ........................................ **50**
- **1-H** ការរំពឹងទុកពីការសន្សំលើចំណាយ........................................ **51**
- **1-I** សេចក្តីប្រកាសស្តីពីសេវាសាធារណៈ ........................................ **52**
- **1-J** ទំនាក់ទំនងដោយផ្ទាល់........................................ **52**

**ផ្នែកទី 2 – មណ្ឌលបោះឆ្នោត និង បោះឆ្នោតតាមទីតាំងទម្លាក់សំបុត្រ.......................... 53**

- **2-A** គម្រោងកំណត់ទីតាំងមណ្ឌលបោះឆ្នោត ........................................ **53**
- **2-B** មណ្ឌលបោះឆ្នោត........................................ **62**
- **2-C** បោះឆ្នោតតាមទីតាំងទម្លាក់សំបុត្រ ........................................ **65**

**ផ្នែកទី 3 – ប្លង់មណ្ឌលបោះឆ្នោត សម្ភារៈ និងការជ្រើសរើសបុគ្គលិក ............................ 66**

- **3-A** ការជ្រើសរើសបុគ្គលិកផ្នែកគ្រប់គ្រងសត្ថុភារ និងសេវាពហុភាសា........................ **66**
- **3-B** ជំនួយមណ្ឌលបោះឆ្នោត ........................................ **67**
- **3-C** ប្លង់មណ្ឌលបោះឆ្នោត........................................ **68**

**ផ្នែកទី 4 – ផែនការសន្តិសុខ និងការការពារជាយថាភាព.......................................... 69**

- **4-A** បទដ្ឋាន និងវិធីសាស្រ្តការពារសន្តិសុខ........................................ **69**
- **4-B** ជំនួយផ្នែកមណ្ឌលបោះឆ្នោត ........................................ **69**
- **4-C** សន្តិសុខតាមប្រព័ន្ធបច្ចេកវិទ្យា........................................ **70**
- **4-D** ផែនការការពារជាយថាភាព........................................ **70**

**ព័ត៌មានបន្ថែម........................................................................................ 72**

## សេចក្តីផ្តើម

ខោនធី Los Angeles គឺជាយុត្តាធិការបោះឆ្នោត ដែលមានប្រជាជនច្រើនជាងគេបំផុតនៅក្នុងប្រទេស ដែលមានអ្នកចុះឈ្មោះបោះឆ្នោតច្រើនជាង 5.4 លាននាក់ ។ ចាប់តាំងពីឆ្នាំ 2009 មន្ត្រីចុះបញ្ជី-កត់ត្រារបស់ខោនធី/ស្មៀនខោនធី (ក្រសួង) បាននឹងកំពុងធ្វើការកែលម្អបទពិសោធនៃការបោះឆ្នោតតាមរយៈសេចក្តីផ្តួចផ្តើមដំណោះស្រាយក្នុងការបោះឆ្នោតសម្រាប់ពលរដ្ឋគ្រប់រូប (VSAP) ។ ដោយសារតែការដឹងជាមុនអំពីទំហំ ភាពស្មុគស្មាញ និងទម្រង់ប្រជាសាស្ត្ររបស់ខោនធី នោះអាទិភាពចម្បងមួយក្នុងចំណោមអាទិភាពចម្បងនានារបស់ក្រសួងបានលុបបំបាត់រាល់ឧបសគ្គ និងការរាំងស្ទះ ផ្នែកគ្រប់គ្រងដែលបង្កការលំបាកដល់អ្នកបោះឆ្នោត ដើម្បីចូលរួមក្នុងដំណើរការបោះឆ្នោត ។ VSAP ព្យាយាមដើម្បីធានាថា អ្នកបោះឆ្នោតនៅក្នុងខោនធីមានឱកាសកាន់តែច្រើនក្នុងការចូលរួម ដោយធ្វើការផ្តល់ជម្រើសកាន់តែច្រើនសម្រាប់ការបោះឆ្នោតក្នុងលក្ខណៈមួយ ដែលបង្កភាពងាយស្រួល អាចដំណើរការបាន និងមានសុវត្ថិភាព ដែលបានយល់ព្រមទាំងស្រុងជាមួយនឹងកិច្ចខិតខំប្រឹងប្រែងក្នុងបង្កើតជម្រើសចំពោះការបោះឆ្នោតបន្ថែមនៅទូទាំងរដ្ឋ។

ដើម្បីឱ្យមានការចូលរួមកាន់តែច្រើន និងធ្វើទំនើបកម្មការបោះឆ្នោតនៅរដ្ឋ California នោះរដ្ឋក៏បានចាត់វិធានការ ដែលមិនធ្លាប់មានពីមុនមក ដើម្បីកំណត់ឡើងវិញនូវបទពិសោធក្នុងការបោះឆ្នោតរបស់ប្រជាជន ។ ព្រមទាំង ដើម្បីបំពេញតម្រូវការប្រជាជន ដែលមានប្រជាជនចម្រុះ និងភូមិសាស្ត្រស្មុគស្មាញនៃរដ្ឋ California រដ្ឋទទួលស្គាល់ពីតម្រូវការ ដើម្បីផ្តល់នូវបទពិសោធទំនើប និងអាចបត់បែនបាន ហើយផ្តល់ជម្រើសកាន់តែច្រើនដល់អ្នកបោះឆ្នោតឱ្យអាចជ្រើសរើសពីរបៀប ពេលវេលា និងកន្លែង ដែលពួកគេបោះឆ្នោត ។ សេចក្តីព្រាងច្បាប់របស់ព្រឹទ្ធសភាលេខ 450 ច្បាប់ជម្រើសរបស់អ្នកបោះឆ្នោតនៅរដ្ឋ California (VCA) ត្រូវបានបង្កើតឡើង ដើម្បីជួយសម្រួលដល់ការផ្លាស់ប្តូរនេះ ។ ឯកសារនេះពណ៌នាអំពីវិធីសាស្ត្រនៃការចាប់ផ្តើមរបស់ខោនធី ដើម្បីធ្វើការអនុវត្ត VSAP និងច្បាប់ VCA ដែលនឹងធ្វើឱ្យបទពិសោធរបស់អ្នកបោះឆ្នោតមានភាពប្រសើរឡើងចាប់តាំងពីគ្រាដំបូងនៃការបោះឆ្នោតរបស់ពួកគេចំពោះការបោះឆ្នោតបឋមក្នុងការជ្រើសរើសបេក្ខជនប្រធានាធិបតី នៅខែមីនា ឆ្នាំ 2020 ។

## ច្បាប់ជម្រើសរបស់អ្នកបោះឆ្នោត

ច្បាប់ VCA ផ្តល់នូវក្របខណ្ឌមូលដ្ឋានគ្រឹះសម្រាប់ខោនធីនានា ដើម្បីផ្តល់ជូនឱ្យមានជម្រើសកាន់តែទូលំទូលាយដល់អ្នកបោះឆ្នោត ដោយផ្តល់ឱមានភាពបត់បែន និងភាពងាយស្រួលជាងមុនខ្លាំង ។ ធាតុស្នូលនៃគំរូច្បាប់ VCA រួមមានដូចជា ៖

- ជម្រើសបោះឆ្នោតដោយផ្ទាល់ គឺវាមានភាពបត់បែន ដែលអាចឱ្យអ្នកបោះឆ្នោតអាចធ្វើការបោះឆ្នោតនៅមណ្ឌលណាមួយក៏បានក្នុងខោនធីរបស់ពួកគេក្នុងរយៈពេល 11 ថ្ងៃ
- ការធ្វើឱ្យសេវាអ្នកបោះឆ្នោត និងជំនួយការ ដែលបានផ្តល់នៅតាមមណ្ឌលបោះឆ្នោត រួមទាំងការចុះឈ្មោះអ្នកបោះឆ្នោតមានលក្ខខណ្ឌ (CVR) កាន់តែមានភាពប្រសើរឡើង
- ការពង្រីកការបោះឆ្នោតតាមសំបុត្រ (VBM) រួមទាំងទីតាំងទម្លាក់សំបុត្រ VBM ងាយស្រួល ដែលអាចរកបាន 29 ថ្ងៃ នៅមុនពេលថ្ងៃបោះឆ្នោត (សូមមើលផ្នែកទី 2-C) ។

ការប្រតិបត្តិ ដែលទទួលបានជោគជ័យនៃគំរូបោះឆ្នោត VCA តម្រូវឱ្យមានការរើសយកខោនធី ដើម្បីត្រួតពិនិត្យដោយប្រុងប្រយ័ត្នចំពោះលក្ខខណ្ឌ និងដំណើរការនានា ដែលមានស្រាប់របស់ពួកគេ រួមបញ្ចូលទាំងបច្ចេកវិទ្យាបោះឆ្នោត សមត្ថភាពថវិកា ទីតាំងបោះឆ្នោត និងការចូលរួមរបស់សហគមន៍ផងដែរ ។

## ដំណោះស្រាយនៃការបោះឆ្នោតសម្រាប់ប្រជាជនគ្រប់រូប

ដើម្បីអនុវត្ត VCA នៅខោនធី ក្រសួងបានធ្វើការបន្ថែមទៅលើសេចក្តីផ្តួចផ្តើមផ្លាស់ប្តូរ VSAP ដែលមានស្រាប់ ។ ការខិតខំប្រឹងប្រែង ដោយយកអ្នកបោះឆ្នោតខោនធី ជាចំណុចសំខាន់នៃការអភិវឌ្ឍបទពិសោធបោះឆ្នោតថ្មី ដែលមានភាពងាយស្រួល អាចចូលដំណើរការបាន និងមានសុវត្ថិភាព ។

សេចក្តីផ្តួចផ្តើម VSAP ត្រូវបានណែនាំយ៉ាងទូលំទូលាយពីក្រុមអ្នកស្រាវជ្រាវ អ្នករចនា អ្នកជំនាញផ្នែកសន្តិសុខ ដែលអាចប្រើប្រាស់បាន អ្នកដឹកនាំផ្នែកបច្ចេកវិទ្យា និងការអប់រំ និងអ្នកពាក់ព័ន្ធសហគមន៍ជាច្រើនរូប រួមមានទាំងអង្គការប្រចាំសហគមន៍ (CBOs) ក្រុមតស៊ូមតិ និងសមាជិកសាធារណៈ ។ ដោយធ្វើការរួមគ្នាពីក្រុមប្រឹក្សាយោបល់ ការស្ទង់មតិ ក្រុមដែលជ្រើសមកសិក្សា ការវិភាគបច្ចេកទេស និងការធ្វើតេស្តអ្នកប្រើប្រាស់ ក្រសួងបានបង្កើតគំរូ ដែលដឹកនាំដំណើរការនៃការអភិវឌ្ឍចំពោះបទពិសោធបោះឆ្នោតថ្មីដ៏ស្មុគស្មាញ ដែលបំពេញតាមតម្រូវការរបស់រដ្ឋ និងមូលដ្ឋាន បំពេញតាមតម្រូវការរបស់អ្នកបោះឆ្នោត និងលើសពីបទដ្ឋានសុវត្ថិភាពនៃប្រព័ន្ធបោះឆ្នោតជាតិ ។ សមាសធាតុសំខាន់ៗរបស់ VSAP រួមមានទាំងសន្លឹកឆ្នោត VBM ដែលបានរៀបចំឡើងវិញ ឧបករណ៍គូសសន្លឹកឆ្នោត (BMD) ដែលដំណើរការបានពេញលេញ និងមានសុវត្ថិភាព សៀវភៅស្ទង់អេឡិចត្រូនិក (ePollbook) អន្តរកម្មសន្លឹកឆ្នោតគំរូ (ISB) និងប្រព័ន្ធ Tally ដែលមានលក្ខណៈទំនើប (Tally) ការពន្យាររយៈពេលបោះឆ្នោត និងមណ្ឌលបោះឆ្នោត រួមទាំងកម្មវិធីបោះឆ្នោតតាមទូរសព្ទ ។

## សន្លឹកឆ្នោត VBM ដែលបានរៀបចំឡើងវិញ

សន្លឹកឆ្នោត VBM ថ្មីត្រូវបានណែនាំឱ្យអ្នកបោះឆ្នោតខោនធីនៅពេលបោះឆ្នោតសាកល នៅខែវិច្ឆិកា ឆ្នាំ 2018 ។ ទម្រង់សន្លឹកឆ្នោត VBM ដែលមានមុខពេញថ្មី មានទំហំពុម្ពអក្សរធំជាងមុន និងមានការណែនាំកាន់តែច្បាស់ ដែលងាយស្រួលអាន ងាយស្រួលបំពេញ និងងាយស្រួលក្នុងការបញ្ជូនត្រឡប់ទៅវិញផងដែរ ។ លើសពីនេះទៀត ថ្លៃតែមប្រៃសណីយ៍ត្រូវបានបង់ប្រាក់ជាមុនរួចរាល់ ដូច្នេះលែងចាំបាច់ភ្ជាប់ត្រាទៀតនោះទេ ។ អ្នកបោះឆ្នោត ដែលជ្រើសរើសយកការបោះឆ្នោត ដោយបង្ហាញវត្តមានផ្ទាល់អាចធ្វើបាននៅតាមទីតាំងទម្លាក់សំបុត្រឆ្នោតរបស់ VBM ឬមណ្ឌលបោះឆ្នោត នៅទូទាំងខោនធីណាមួយក៏បាន ។

## ឧបករណ៍គូសសន្លឹកឆ្នោត

ឧបករណ៍ BMD ដាក់ជំនួសនូវប្រព័ន្ធការបោះឆ្នោត InkaVote មរតករបស់ខោនធី ។ ឧបករណ៍ BMD អាចឲ្យអ្នកបោះឆ្នោតទាំងអស់ផ្លាស់ប្តូរបទពិសោធន៍របស់ខ្លួនតាមរយៈការអាន និងស្តាប់សំឡេង ដែលមានច្រើនជាងដល់ទៅដប់បីភាសា (សូមមើលផ្នែក 1-E) ហើយនិងផ្តល់ជូនលក្ខណៈពិសេសដែលអាចផ្តល់ភាពងាយស្រួលដល់អ្នកបោះឆ្នោត ដែលជាជនពិការឱ្យមានភាពស្មើគ្នា និងភាពឯករាជ្យក្នុងការបោះឆ្នោត ។ សម្រាប់ការធ្វើសវនកម្ម និងសន្តិសុខ នោះឧបករណ៍ BMD បង្កើតសន្លឹកឆ្នោត ដែលមនុស្សអាចអានបានលើសពីបទដ្ឋានសុវត្ថិភាពនៃប្រព័ន្ធបោះឆ្នោតជាតិ ។

## សៀវភៅស្ទង់អេឡិចត្រូនិក

សៀវភៅ ePollbook ជំនួសសៀវភៅបញ្ជីឈ្មោះ ដែលបានបោះពុម្ព ដែលពីមុនទម្លាក់នៅកន្លែងបោះឆ្នោតសម្រាប់ការចុះឈ្មោះ ។ សៀវភៅស្ទង់អេឡិចត្រូនិកត្រូវបានភ្ជាប់តាមរយៈបណ្តាញឯកជនដែលមានសុវត្ថិភាពទៅកាន់មូលដ្ឋានទិន្នន័យរបស់អ្នកបោះឆ្នោត ដែលមានសិទ្ធិបោះឆ្នោតនៅរដ្ឋ California (សូមមើលផ្នែក 4-C) ។ ប្រការនេះអនុញ្ញាតឱ្យអ្នកបោះឆ្នោតចូលពិនិត្យ និងគូសសន្លឹកឆ្នោតនៅមណ្ឌលបោះឆ្នោតណាមួយក្នុងខោនធីនេះ ។ សៀវភៅស្ទង់អេឡិចត្រូនិកត្រូវបានធ្វើបច្ចុប្បន្នភាពក្នុងពេលជាក់ស្តែង ហើយនឹងបញ្ជាក់ថាតើអ្នកបោះឆ្នោតបានបោះរួចឬនៅ ដែលធានានូវភាពត្រឹមត្រូវនៃការបោះឆ្នោត ។ លើសពីនេះទៀត សៀវភៅស្ទង់អេឡិចត្រូនិកអាចផ្តល់លទ្ធភាពឱ្យអ្នកមានសិទ្ធិបោះឆ្នោតអាចចុះឈ្មោះបោះឆ្នោតនៅមណ្ឌលបោះឆ្នោតណាមួយ ឬធ្វើបច្ចុប្បន្នភាពនៃការចុះឈ្មោះរបស់ពួកគេ ។

## អន្តរកម្មសន្លឹកឆ្នោតគំរូ

ISB គឺជាជម្រើសងាយស្រួលថ្មីមួយ ដើម្បីពន្លឿនបទពិសោធនៃការបោះឆ្នោត ដោយបង្ហាញវត្តផ្ទាល់ ។ ISB អនុញ្ញាតឲ្យអ្នកបោះឆ្នោតគូសសន្លឹកឆ្នោតគំរូតាមប្រព័ន្ធឌីជីថលតាមរយៈកម្មវិធីវិបដែលអាចចូលដំណើរការ

បានតាមរយៈគេហទំព័ររបស់ក្រសួង (សូមមើលផ្នែក 1-F) ។ ពេលបញ្ចប់ការជ្រើសយក នោះនឹងមានបង្ហាញលេខកូដឆ្លើយតបរហ័ស (QR) ដែលបានបង្កើតប័ណ្ណបោះឆ្នោត ដែលអាចព្រីន ឬរក្សាទុកក្នុងឧបករណ៍ចល័ត ដែលបន្ទាប់មកអាចយកទៅកាន់មណ្ឌលបោះឆ្នោតណាមួយ ហើយស្កេនលើឧបករណ៍ BMD ដោយប្រើឧបករណ៍អានកូដ QR ដែលភ្ជាប់មកជាមួយ ។ ការជ្រើសយករបស់អ្នកបោះឆ្នោតនឹងត្រូវនាំបញ្ចូលទៅក្នុង BMD ដែលអាចអនុញ្ញាតឱ្យអ្នកបោះឆ្នោតពិនិត្យមើលការជ្រើសយករបស់ពួកគេម្តងទៀត ហើយធ្វើការផ្លាស់ប្តូរបន្ថែមទៀតមុនពេលបោះឆ្នោត ។

## ប្រព័ន្ធ Tally ទំនើប

ប្រព័ន្ធ Tally គឺជាដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិត សម្រាប់ការស្កេនសន្លឹកឆ្នោត និងការធ្វើតារាងដែលត្រូវបានរៀបចំឡើង ដើម្បីជួយដល់តម្រូវការរបស់ខោនធី ដើម្បីដំណើរការសន្លឹកឆ្នោតរាប់លានសន្លឹក ។ វាប្រើម៉ាស៊ីនស្កេនល្បឿនលឿន ដើម្បីចាប់យករូបភាពសន្លឹកឆ្នោតបានយ៉ាងច្បាស់ និងមានទំហំធំ និងស្ថាបត្យកម្មកម្មវិធីអន្តរការីអានសារ ដើម្បីដំណើរការរូបភាពឌីជីថលក្នុងបរិមាណច្រើនយ៉ាងឆាប់រហ័ស និងត្រឹមត្រូវ ។ ចាប់ពីសន្លឹកឆ្នោតក្រដាសរហូតដល់រូបភាពឌីជីថល និងកំណត់ត្រាបោះឆ្នោតចុងក្រោយ នោះប្រព័ន្ធ Tally ចាប់យកទិន្នន័យអំពីរបៀបអានសន្លឹកឆ្នោតនីមួយៗ និដំណើរការ ដែលអនុញ្ញាតឱ្យមានការតាមដាន និងធ្វើសវនកម្មលើសន្លឹកឆ្នោតនីមួយៗ ដើម្បីផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃលទ្ធផលការបោះឆ្នោត ។

## មណ្ឌលបោះឆ្នោត

មណ្ឌលបោះឆ្នោតនឹងមានទីតាំងនៅពាសពេញខោនធី ។ ពួកគេនឹងឆ្លងកាត់ការស្ទង់មតិ និងការវាយតម្លៃយ៉ាងទូលំទូលាយ ដើម្បីធានាថា ពួកគេបានបំពេញតាមលក្ខខណ្ឌនៃច្បាប់ជនពិការអាមេរិក (ADA) និងលក្ខណៈវិនិច្ឆ័យ និងលក្ខណៈសម្បត្តិគ្រប់គ្រាន់ដូចជាការមានសិទ្ធិចតយានយន្តនៅលើទីតាំង ភាពងាយស្រួលក្នុងការធ្វើដំណើរតាមមធ្យោបាយដឹកជញ្ជូនសាធារណៈ និងម៉ោងប្រតិបត្តិការ (សូមមើលផ្នែកទី 2-A សម្រាប់បញ្ជីលម្អិតអំពីលក្ខណៈវិនិច្ឆ័យ) ។

## កម្មវិធីមណ្ឌលបោះឆ្នោតចល័ត

ក្រសួងនេះក៏នឹងអនុវត្តកម្មវិធីមណ្ឌលបោះឆ្នោតចល័តថ្មី (MVCP) ដើម្បីពង្រីកឱកាសបោះឆ្នោតបន្ថែមទៀតដល់សាធារណៈជន ។ កម្មវិធី MVCP នឹងបំពេញបន្ថែមទៅលើមណ្ឌលបោះឆ្នោត ដែលមានស្រាប់ដែលអាចនឹងមានការកកស្ទះខ្លាំង និងផ្តល់សេវាបោះឆ្នោតដល់សហគមន៍ ដែលស្ថិតនៅទីតាំងភូមិសាស្ត្រដាច់ស្រយាល ឬមិនទទួលបានសេវាត្រឹមត្រូវពីមណ្ឌលបោះឆ្នោតស្តង់ដារ ។ អង្គភាពបោះឆ្នោតចល័តនឹងត្រូវដាក់ពង្រាយនៅតាមមូលដ្ឋាន ដែលបានគ្រោងទុកនៅទូទាំងខោនធី ដើម្បីផ្តល់សេវាបោះឆ្នោតឱ្យបានប្រសើរជាងមុន និងលើកកម្ពស់ដល់ការយល់ដឹងរបស់អ្នកបោះឆ្នោតក្នុងកំលុងពេលបោះឆ្នោត ។

## ផ្នែកទី 1 – កម្រិតវប្បធម៌អ្នកបោះឆ្នោត និងការរៀបចំផែនការផ្សព្វផ្សាយ

ដើម្បីលើកកម្ពស់ការយល់ដឹងក្នុងចំណោមអ្នកបោះឆ្នោតនៃខោនធី Los Angeles ចំពោះបទពិសោធបោះឆ្នោត VSAP ថ្មី ក្រសួងបានប្រតិបត្តិយុទ្ធនាការផ្សព្វផ្សាយ និងជួយសាធារណៈជន ដែលមានលក្ខណៈទូលំទូលាយ និងពហុភាសា ដែលរួមបញ្ចូលទាំងការផ្សាយតាមទូរទស្សន៍ វិទ្យុ បណ្ដាញគេហទំព័រ និងការប្រើកម្មវិធីឌីជីថល ការផ្សាយតាមបណ្តាញសង្គម ការផ្ញើសារដោយផ្ទាល់ ការជូនដំណឹងតាមអ៊ីម៉ែល ការទូរសព្ទដោយស្វ័យប្រវត្តិ និងការភ្ជាប់ទំនាក់ទំនងជួយសាធារណៈជន ។ យុទ្ធនាការនេះត្រូវបានបែងចែកជាច្រើនដំណាក់កាល ដែលនឹងជូនដំណឹងយ៉ាងជាក់លាក់អំពីរបៀបចុះឈ្មោះបោះឆ្នោត របៀបស្នើសុំសន្លឹកឆ្នោត VBM របៀបទាក់ទងក្រសួង និងរបៀប ដែលបទពិសោធបោះឆ្នោតនឹងផ្លាស់ប្តូរតាមរយៈ VSAP និងច្បាប់ VCA ។

ក្រសួងមានទំនាក់ទំនងការងារស្រោប់ជាមួយនឹងបណ្តាញប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ ហើយមានបំណងប្រើប្រាស់ធនធាន ដែលបានបង្កើតឡើងទាំងនេះ ដើម្បីផ្សព្វផ្សាយជាសារទៅដល់អ្នកបោះឆ្នោតបច្ចុប្បន្ន និងអនាគតនៅក្នុងខោនធី ។ ក្រសួងក៏នឹងប្រើប្រាស់បណ្តាញព័ត៌មានក្នុងស្រុកតាមទូរទស្សន៍ ការបោះពុម្ព និងប្រព័ន្ធផ្សព្វផ្សាយឌីជីថល ដើម្បីផ្តល់នូវព័ត៌មានសំខាន់ៗទាក់ទងនឹងការបោះឆ្នោតនៅ តាមវេទិកានីមួយៗរបស់ពួកគេផងដែរ ។

លើសពីនេះទៀត ក្រសួងនឹងបន្តសហការជាមួយដៃគូ ដែលមានជាយូរមកហើយ ដែលរួមមានអង្គការ CBO វិទ្យាល័យ មហាវិទ្យាល័យសហគមន៍ និងសាកលវិទ្យាល័យ ។ តាមរយៈភាពជាដៃគូទាំងនេះ ក្រសួងនឹងលើកកម្ពស់ការយល់ដឹងអំពីបទពិសោធបោះឆ្នោតថ្មី ក៏ដូចជាលើកកម្ពស់ការចូលរួមរបស់ពលរដ្ឋ និងការចូលរួមរបស់អ្នកបោះឆ្នោត ។ អង្គការ CBO ផ្តល់ជំនួយ ដែលមិនអាចកាត់ថ្លៃបានដល់ក្រសួង ដែលត្រូវការចាំបាច់ក្នុងការផ្សព្វផ្សាយទៅដល់សហគមន៍របស់ពួកគេ ឱ្យមានប្រសិទ្ធភាព ដូចជាការយល់ដឹងអំពីតម្រូវការភាសា ទីតាំងដែលសហគមន៍ប្រមូលផ្តុំគ្នា និងរាល់បញ្ហា ឬក្តីបារម្ភនានា ដែលប៉ះពាល់ដល់សហគមន៍នីមួយៗ ។ ពួកគេក៏ផ្តល់ការប្រើប្រាស់បរិក្ខារនានាទាំងសាធារណៈ និងឯកជននៅទូទាំងខោនធីផងដែរ ។

### 1-A ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ

ក្រសួងបានប្រើប្រាស់ទិន្នន័យផ្ទៃក្នុង និងពីខាងក្រៅ ដើម្បីកំណត់បណ្តាញទំនាក់ទំនងចាំបាច់នានា ដើម្បីអាចឈានទៅដល់សហគមន៍ចម្រុះរបស់ខោនធី។ ក្រសួងនឹងបញ្ជូនសេចក្តីប្រកាសព័ត៌មាន ដែលមានព័ត៌មានសំខាន់ៗទាក់ទងនឹងការបោះឆ្នោតនាពេលខាងមុខនេះ ការចុះឈ្មោះអ្នកបោះឆ្នោត និងសេវាដែល

ផ្តល់ជូនទាំងអស់។ រាល់ការចេញផ្សាយព័ត៌មាននឹងមានដាក់បញ្ចូលព័ត៌មានទំនាក់ទំនង ដូចជាបណ្តាញទូរសព្ទជំនួយអ្នកបោះឆ្នោតឥតគិតថ្លៃ និងបណ្តាញភ្ជាប់ទៅគេហទំព័ររបស់ពួកយើង ។

## ប្រព័ន្ធផ្សព្វផ្សាយ

ក្រសួងនឹងធ្វើការជាមួយភ្នាក់ងារព័ត៌មានក្នុងស្រុក និងក្នុងតំបន់ក្នុងការសម្របសម្រួលដល់កិច្ចសម្ភាសន៍ផ្ទាល់មុខជាសាធារណៈ ដែលនឹងផ្សព្វផ្សាយព័ត៌មានអំពីការបោះឆ្នោត និងផ្សព្វផ្សាយព្រឹត្តិការណ៍របស់ក្រសួង ។ លើសពីនេះទៀត ក្រសួងនឹងធ្វើការជាដៃគូជាមួយក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយពហុភាសា ដើម្បីបង្កើត និងដំណើរការផ្នែកព័ត៌មានតាមរលកធាតុអាកាស ដើម្បីលើកកម្ពស់ការយល់ដឹង និងអប់រំប្រជាជនអំពីការបោះឆ្នោតខាងមុខ និងសេវាភាសា ។ ក្រសួងនឹងធ្វើការជាមួយបណ្តាញធំៗដូចខាងក្រោម ប៉ុន្តែអាចមានបន្ថែមទៀត ៖

- ABC
- CBS
- KTLA
- FOX
- NBC
- Telemundo (ភាសាអេស្ប៉ាញ)
- Univision (ភាសាអេស្ប៉ាញ)

### វិទ្យុ

ក្រសួងនេះនឹងធ្វើការជាមួយស្ថានីយ៍វិទ្យុ និងបណ្តាញក្នុងស្រុក និងក្នុងតំបន់ ក្នុងនោះរាប់បញ្ចូលទាំងការផ្សព្វផ្សាយពហុភាសាក្នុងការចេញសេចក្តីប្រកាសសេវាសាធារណៈតាមរលកធាតុអាកាស និងបទសម្ភាសព័ត៌មាន ។ ក្រសួងនឹងធ្វើការជាមួយបណ្តាញវិទ្យុដូចខាងក្រោម ប៉ុន្តែអាចមានបន្ថែមទៀត ៖

- iHeart Media
- POWER 106
- Entercom
- Entravision (និយាយភាសាអេស្ប៉ាញ)
- Liberman Broadcasting (និយាយភាសាអេស្ប៉ាញ)
- KNX
- KPCC
- NPR
- K-ABC

- KFI
- KJLH

## ប្រព័ន្ធបោះពុម្ពផ្សាយ

ក្រសួងនេះនឹងធ្វើការជាមួយអ្នករាយការណ៍ និងអ្នកកាសែតក្នុងស្រុក និងក្នុងតំបន់ ដើម្បីផ្សព្វផ្សាយព្រឹត្តិការណ៍របស់ក្រសួង សម្របសម្រួលកិច្ចសម្ភាសន៍ និងផ្សព្វផ្សាយព័ត៌មានអំពីការបោះឆ្នោត ដែលអាចនឹងត្រូវបោះពុម្ពផ្សាយនៅតាមភ្នាក់ងាររៀងៗខ្លួនរបស់ពួកគេ។ក្រសួងនឹងធ្វើការជាមួយភ្នាក់ងារបោះពុម្ពផ្សាយដូចខាងក្រោម ប៉ុន្តែអាចមានបន្ថែមទៀត ៖

- Los Angeles Times
- LA Daily News
- Daily Breeze
- Pasadena Star News
- Long Beach Press-Telegram
- Whittier Daily News
- San Gabriel Valley Tribune
- LA Sentinel
- La Opinion (ភាសាអេស្ប៉ាញ)
- World Journal (ភាសាចិន)
- The Korea Times (ភាសាកូរ៉េ)

## ប្រព័ន្ធផ្សព្វផ្សាយសង្គម

ក្រសួងនឹងបន្តប្រើប្រាស់វេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីឱ្យពលរដ្ឋនៅក្នុងខោនធីមានការចូលរួម។ នេះនឹងរួមបញ្ចូលទាំងពាណិជ្ជកម្មតាមគោលដៅ ដែលបានបង់ប្រាក់ និងការបង្ហោះសារដោយមិនបង់ប្រាក់ ដែលលើកទឹកចិត្តដល់ប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោត និងអ្នកដែលបានចុះឈ្មោះបោះឆ្នោតឱ្យចូលរួមក្នុងការបោះឆ្នោតនាពេលខាងមុខនេះ។ ឈ្មោះរបស់ក្រសួង ដែលប្រើសម្រាប់គ្រប់វេទិកាទាំងអស់គឺ @lacountyrrcc។ក្រសួងនឹងបន្តប្រើប្រាស់វេទិកាប្រព័ន្ធសង្គមដូចខាងក្រោម ប៉ុន្តែអាចមានបន្ថែមទៀត ៖

- Facebook: facebook.com/LACountyRRCC
- Instagram: @lacountyrrcc
- YouTube: lacountyrrcc
- Twitter: @LACountyRRCC

### ក្រុមហ៊ុន Rideshare/ក្រុមហ៊ុនគមនាគមន៍

ក្រសួងនឹងបន្តសហការជាមួយក្រុមហ៊ុន Uber, Lyft, អាជ្ញាធរគមនាគមន៍ក្រុង (Metro), ក្រសួងការងារសាធារណៈរបស់ខោនធី Los Angeles និងអង្គភាពគមនាគមន៍ដទៃទៀតនៅទូទាំងខោនធី ដើម្បីលើកកម្ពស់ការចុះឈ្មោះ និងព័ត៌មានអ្នកបោះឆ្នោត ដោយមានបំណងផ្តល់សេវាដឹកជញ្ជូន ដោយមានការបញ្ចុះតម្លៃ ឬឥតគិតថ្លៃទៅកាន់មណ្ឌលបោះឆ្នោត ។

### រោងកុន

ក្រសួងនេះនឹងធ្វើជាដៃគូជាមួយក្រុមហ៊ុនផ្សាយពាណិជ្ជកម្មរោងភាពយន្ត ដូចជា National CineMedia និង Screen Vision Media ដើម្បីដាក់បង្ហាញការផ្សាយពាណិជ្ជកម្មនៅតាមរោងភាពយន្តនានាទូទាំងខោនធី ។

### ផ្ទាំងប៉ាណូ/ផ្លូវឆ្លងកាត់

ក្រសួងនឹងប្រើប្រាស់ផ្ទាំងប៉ាណូ និងការផ្សាយពាណិជ្ជកម្មតាមផ្លូវឆ្លងកាត់ ដូចជានៅស្ថានិយ៍ចាំឡានក្រុង និងនៅតាមផ្សារទំនើប ដើម្បីជូនដំណឹងដល់ប្រជាជនអំពីការបោះឆ្នោតនាពេលខាងមុខ ។

### កម្មវិធីទូរសព្ទ

ការផ្សាយពាណិជ្ជកម្មនៅក្នុងកម្មវិធីស្ទ្រីមទូរសព្ទចល័ត កម្មវិធីព័ត៌មាន និងសូម្បីតែកម្មវិធីហ្គេមនៅលើឧបករណ៍ចល័តនឹងជួយឱ្យសារព័ត៌មានរបស់យើងផ្សាយទៅដល់ប្រជាជនវ័យក្មេង ។ កម្មវិធីមួយចំនួនរួមមាន Pandora និងកម្មវិធីទូរសព្ទចល័តតាមគោលដៅផ្សេងទៀត ។

### ម៉ាឃីតធីងតាមអ៊ីម៉ែល

ការកំណត់គោលដៅយុទ្ធនាការធ្វើម៉ាឃីតធីងតាមអ៊ីម៉ែលក៏នឹងត្រូវយកមកប្រើផងដែរ ដើម្បីផ្ញើព័ត៌មានថ្មីៗទាក់ទងនឹងការបោះឆ្នោត ឯកសារព័ត៌មាន និងតំណភ្ជាប់ទៅកាន់គេហទំព័រ ឱ្យទៅអ្នកបោះឆ្នោតជាក់លាក់នៅទូទាំងខោនធី ។

## ការយល់ព្រម

បុគ្គលមានឥទ្ធិពល ដែលមានអ្នកតាមដានច្រើននឹងប្រើវេទិការបស់ពួកគេ ដើម្បីគាំទ្រសាររបស់យើង និងផ្សព្វផ្សាយបទពិសោធបោះឆ្នោតថ្មីរបស់ខោនធី ។ មុខងារសំខាន់ៗរបស់អ្នកគាំទ្រមានដូចខាងក្រោម ប៉ុន្តែអាចមានបន្ថែមទៀត ៖

- បង្ហោះសារនៅលើវេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គមផ្ទាល់ខ្លួន និងអាជីវកម្ម
- ការផ្សាយពាណិជ្ជកម្ម និងសេចក្ដីជូនដំណឹង
- ការបង្កើតវីដេអូ និងសម្ភារៈអប់រំនានា
- ចូលរួម និងផ្សព្វផ្សាយព្រឹត្តិការណ៍ដល់សាធារណៈជន

## ការផ្ញើសំបុត្រដោយផ្ទាល់

ក្រសួងនឹងប្រើសំបុត្រផ្ទាល់ ដើម្បីជូនដំណឹង និងអប់រំអ្នកបោះឆ្នោតអំពី VSAP និងច្បាប់ VCA ។ លើសពីនេះទៅទៀត យុទ្ធនាការផ្ញើសារតាមគោលដៅផ្សេងៗទៀត (ឧទាហរណ៍ដូចជា ការបោះឆ្នោតឆ្លងគណបក្ស) នឹងត្រូវបានបង្កើតឡើងស្របតាមទស្សនិកជន ដែលមានលក្ខណៈពិសេស ។

## យីហោ

ក្រសួងនឹងបន្តប្រើប្រាស់យីហោ “ដំណោះស្រាយបោះឆ្នោតសម្រាប់ប្រជាជនគ្រប់រូប” និងអក្សរកាត់ VSAP ។ រូបសញ្ញា VSAP ត្រូវបានប្រគល់នូវពាណិជ្ជសញ្ញានៅឆ្នាំ 2018 ។ ការដាក់ពាណិជ្ជសញ្ញាលើរូបសញ្ញាបន្ថែមការជឿទុកចិត្ត និងការទទួលស្គាល់យីហោ ខណៈដែលយើងបន្តធ្វើទីផ្សារ និងបង្កើនកិច្ចខិតខំប្រឹងប្រែងការផ្សព្វផ្សាយរបស់យើង សម្រាប់បទពិសោធបោះឆ្នោត VSAP ។

VOTING SOLUTIONS
FOR ALL PEOPLE

## ព្រឹត្តិប័ត្រ VSAP ប្រចាំត្រីមាស ឬរបាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រសួងនឹងបន្តផ្ញើព្រឹត្តិប័ត្រ VSAP ប្រចាំត្រីមាស និងរបាយការណ៍ ដែលត្រូវបានចែកចាយទៅឱ្យអ្នកពាក់ព័ន្ធខាងក្រៅ និងផ្ទៃក្នុង ដូចជាគណៈកម្មាធិការកិច្ចនៃខោនធី Los Angeles, ទីក្រុងចំនួន 88 នៅក្នុងខោនធី និងដៃគូ CBO។ ព្រឹត្តិប័ត្រនេះផ្តល់ព័ត៌មានបច្ចុប្បន្នភាពចំពោះព្រឹត្តិការណ៍សំខាន់ៗ ដែលទាក់ទងទៅ VSAP ទាំងអស់ ។ ព្រឹត្តិប័ត្រព័ត៌មាន VSAP ប្រចាំត្រីមាសអាចរកបាននៅលើគេហទំព័រ៖ https://vsap.lavote.net/reports/

## លទ្ធភាពបោះឆ្នោតតាមប្រៃសណីយ៍ពីនាយ

ក្រសួងនឹងជូនដំណឹងដល់សាធារណជនអំពីលទ្ធភាពបោះឆ្នោតតាមប្រៃសណីយ៍ពីនាយ (RAVBM) ដោយផ្តល់នូវការផ្សាយព័ត៌មាន និងមាតិកាប្រព័ន្ធបណ្តាញទំនាក់ទំនងសង្គមសម្រាប់ចែកចាយដល់បណ្តាញសារព័ត៌មានក្នុងមូលដ្ឋាន តំបន់ និងទូទាំងប្រទេស ។ លើសពីនេះទៀត ព័ត៌មានអំពីលទ្ធភាព និងការប្រើប្រាស់ RAVBM នឹងត្រូវបានផ្តល់ជូននៅក្នុងការចែកចាយផ្ញើសន្លឹកឆ្នោតគំរូទៅឱ្យអ្នកបោះឆ្នោតទាំងអស់ដែលបានចុះឈ្មោះ នៅក្នុងកញ្ចប់ព័ត៌មានអំពីការបោះឆ្នោតតាមសំបុត្រ (VBM) ដែលត្រូវផ្ញើទៅអ្នកបោះឆ្នោត VBM ទាំងអស់ តាមរយៈយុទ្ធនាការអ៊ីមែលគោលដៅ និងបានបង្ហោះនៅលើគេហទំព័ររបស់យើង ៖ lavote.net ។

## 1-B ការពង្រីកការបោះឆ្នោតតាមសំបុត្រ

ដោយអនុលោមទៅតាម VCA នោះខោនធី Los Angeles ក៏នឹងផ្សព្វផ្សាយ និងពង្រីកបន្ថែមនូវជម្រើស VBM ផងដែរ ។ សម្រាប់ក្រុមអ្នកបោះឆ្នោតខាងក្រោម ក្រសួងនឹងផ្ញើសន្លឹកឆ្នោត VBM មួយសន្លឹកទៅកាន់អ្នកបោះឆ្នោតទាំងអស់មុនពេលការបោះឆ្នោតនីមួយៗ ៖

- អ្នកបោះឆ្នោតនៅក្នុងមណ្ឌលដែលបានកំណត់ មានអ្នកបានចុះឈ្មោះបោះឆ្នោតតិចជាង 500 នាក់ ។
- អ្នកបោះឆ្នោតដែលរស់នៅក្នុងស្រុកនៃនីតិប្បញ្ញត្តិ ឬសភា ដែលស្ថិតនៅផ្នែកមួយចំនួននៅក្នុងខោនធី Los Angeles ហើយក៏ស្ថិតនៅក្នុងខោនធីជាប់ព្រំដែន ដែលកំពុងផ្ញើសន្លឹកឆ្នោត VBM មួយសន្លឹកឱ្យទៅអ្នកបោះឆ្នោតរបស់ខ្លួនទាំងអស់ក្រោមបទប្បញ្ញត្តិនៃច្បាប់ VCA (មើលផែនទី A, B និង C)
- អ្នកបោះឆ្នោតដែលរស់នៅក្នុងមណ្ឌល ដែលត្រូវធ្វើដំណើររយៈពេលលើសពី 30 នាទីពីមណ្ឌលបោះឆ្នោត ឬការិយាល័យបោះឆ្នោតពីមុនកាលពីការបោះឆ្នោតសាកលទូទាំងរដ្ឋមានចម្ងាយជាង 15 ម៉ាយពីមណ្ឌលបោះឆ្នោត ដែលនៅជិតបំផុត ។

## ផែនទី A

មណ្ឌលសភារបស់រដ្ឋទី 55



## ផែនទី B

មណ្ឌលព្រឹទ្ធសភារបស់រដ្ឋទី 29, ទី 32, និងទី 34




## ផែនទី C

មណ្ឌលសភា US ទី 38, ទី 39, និងទី 47



ក្រសួងនឹងបន្តផ្សព្វផ្សាយ VBM និងផ្តល់សម្ភារៈអប់រំចំពោះ VBM ដូចជាក្រដាស់ព័ត៌មាន សំណួរគេសួរញឹកញាប់ (FAQ) វីដេអូអប់រំ និងការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលអាចចរាចរ និងចែកចាយដល់អ្នកបោះឆ្នោតខោនធីបាន ។ ក្រសួងនឹងប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសម្រាប់គោលបំណងជូនដំណឹងដល់អ្នកបោះឆ្នោត អំពីជម្រើស VBM ដោយរួមមានការលើកកម្ពស់ការប្រើប្រាស់ VBM របៀបស្នើសុំសន្លឹកឆ្នោត VBM ការណែនាំអំពីរបៀបប្រើសន្លឹកឆ្នោត VBM និងរបៀបពិនិត្យមើលស្ថានភាពនៃសន្លឹកឆ្នោត VBM ។ លើសពីនេះទៅទៀត អ្នកបោះឆ្នោតទាំងអស់ នឹងនៅតែមានជម្រើសក្នុងការចុះឈ្មោះបោះឆ្នោត VBM ជាអចិន្ត្រៃយ៍ (PVBM) នៅពេលពួកគេបំពេញទម្រង់បែបបទចុះឈ្មោះអ្នកបោះឆ្នោត ។

## 1-C ការចូលរួមផ្នែកសហគមន៍

ដើម្បីផ្សព្វផ្សាយដល់សាធារណៈជនប្រកបដោយប្រសិទ្ធភាព និងដើម្បីផ្តល់ព័ត៌មានអំពីដំណោះស្រាយបោះឆ្នោតសម្រាប់ប្រជាពលរដ្ឋទាំងអស់ (VSAP) ក្រសួងនឹងបន្តធ្វើការជាមួយភ្នាក់ងារជាដៃគូនានានៅក្នុងខោនធី ភ្នាក់ងាររដ្ឋាភិបាលផ្សេងទៀត ស្មៀនក្រុង និង CBOs ។ ក្រសួងបានបង្កើតខិតប័ណ្ណផ្សព្វផ្សាយព័ត៌មាន និងប័ណ្ណប្រកាសព័ត៌មានជា ច្រើន ដើម្បីអប់រំ និងជូនដំណឹងដល់សហគមន៍បន្ថែមទៀតអំពី VSAP និងច្បាប់ VCA (សូមមើលឧទាហរណ៍ ដែលភ្ជាប់នៅក្នុងព័ត៌មានបន្ថែម) ។ ក្រសួងនឹងធ្វើបទបង្ហាញ ការជួបជុំបុគ្គលិក ការផ្តល់ការបណ្តុះបណ្តាល និងសម្ភារៈ និងធានាថា សារដែលមានជាបន្តបន្ទាប់នឹងត្រូវបានផ្តល់ជូនដល់សាធារណជនជានិច្ច ។ រាល់សម្ភារៈទាំងអស់ ដែលបានផ្តល់ជូនអង្គភាពទាំងនេះនឹងត្រូវបានដាក់ស្លាកយីហោ VSAP ដែលធានាដល់សាធារណជនថា ព័ត៌មាន គឺមានភាពពាក់ព័ន្ធ និងមានភាពសុក្រឹត ។

### កិច្ចសហការ/អ្នកពាក់ព័ន្ធទូទាំងខោនធី

ការផ្សព្វផ្សាយ និងអប់រំប្រជាពលរដ្ឋ ដែលមានភាពចម្រុះគ្នាច្រើន គឺទាមទារឱ្យមាននូវភាពជាដៃគូពីមន្ត្រីសាធារណៈ (ដែលជាប់ឆ្នោត និងមិនជាប់ឆ្នោត) ភ្នាក់ងាររដ្ឋាភិបាល មន្ទីរខោនធី ទីក្រុង អង្គជំនុំជម្រះពាណិជ្ជកម្ម និងអ្នកពាក់ព័ន្ធក្នុងសហគមន៍ដទៃទៀត ។ អង្គភាពទាំងនេះធ្វើការរួមគ្នា ដើម្បីអប់រំ និងលើកកម្ពស់ការយល់ដឹងអំពីការផ្លាស់ប្តូរបទពិសោធនៃការបោះឆ្នោតតាមរយៈ VSAP និង VCA ។

កិច្ចសហការជាមួយក្រសួងខោនធីផ្សេងទៀតនឹងពង្រីកសមត្ថភាពរបស់ក្រសួង ដើម្បីឈានទៅដល់ និងអប់រំដល់សាធារណជន ។ អង្គភាពខោនធីដូចខាងក្រោមបានជួយដល់ក្រសួងពីមុន ហើយជាគំរូមួយដែលនឹងជួយក្នុងការខិតខំប្រឹងប្រែងផ្សព្វផ្សាយសារ VSAP និងផ្លាកយីហោ ៖

- អ្នកវាយតម្លៃ
- ឆ្នេរ និងកំពង់ផែ
- គណៈកម្មាធិការកិច្ច
- ការិយាល័យនាយកប្រតិបត្តិ
- អតិថិជនប្រើប្រាស់ និងកិច្ចការពាណិជ្ជកម្ម
- ការទំនាក់ទំនងទូទាំងខោនធី
- ឧទ្យាន និងមណ្ឌលកំសាន្ត
- បណ្ណាល័យសាធារណៈ
- សេវាសង្គមសាធារណៈ
- ការងារសាធារណៈ
- ហិរញ្ញិក និង អ្នកប្រមូលពន្ធ
- ការអភិវឌ្ឍកម្លាំងពលកម្ម សេវាសហគមន៍ និងមនុស្សវ័យចំណាស់

## ព្រឹត្តិការណ៍សហគមន៍

តាមរយៈទំនាក់ទំនង CBO និងភាពជាដៃគូប្រព័ន្ធផ្សព្វផ្សាយ ដែលបានបង់ថ្លៃ ឱកាស ដើម្បីធ្វើជាម្ចាស់ផ្ទះ និងសហការឧបត្ថម្ភព្រឹត្តិការណ៍នានានៅទូទាំងខោនធីនឹងបង្កើតនូវមធ្យោបាយដ៏មានតម្លៃមួយសម្រាប់ក្រសួងក្នុងការចូលរួមជាមួយក្រុមមនុស្សជាច្រើនទាក់ទងនឹងគំរូបោះឆ្នោតថ្មីនេះ។ ក្រសួងមានទំនាក់ទំនងដ៏យូរអង្វែងជាមួយអង្គការ និងអ្នកសម្របសម្រួលព្រឹត្តិការណ៍ជាច្រើន ហើយនឹងចំណាយពេលជាច្រើនសប្តាហ៍រៀបចំតុ និងផ្តល់សម្ភារៈទាក់ទងនឹងការបោះឆ្នោតដល់សាធារណជន ។ តារាងទី 1 គូសបញ្ជាក់អំពីការជ្រើសយកព្រឹត្តិការណ៍សំខាន់ៗដែលក្រសួងបានចូលរួមនៅក្នុងឆ្នាំនេះ ហើយនឹងគ្រោងចូលរួមនៅឆ្នាំ 2020 ។ បន្ថែមពីលើព្រឹត្តិការណ៍ទាំងអស់នេះ ក្រសួងបានចូលរួមព្រឹត្តិការណ៍សហគមន៍ចំនួនរាប់រយផ្សេងទៀត ។

## តារាងទី 1. ព្រឹត្តិការណ៍សហគមន៍សំខាន់ៗ

| កាលបរិច្ឆេទ | ព្រឹត្តិការណ៍ | ទីក្រុង |
|---|---|---|
| ថ្ងៃទី 17 ខែកុម្ភៈ ឆ្នាំ 2019 | ពិធីបុណ្យបាញ់កាំជ្រួច Firecracker Festival | Los Angeles |
| ថ្ងៃទី 17 ខែមីនា ឆ្នាំ 2019 | La Feria De Salud | Los Angeles |
| ថ្ងៃទី 31 ខែមីនា ឆ្នាំ 2019 | ពីធីវប្បធម៌ Cherry Blossom Cultural Festival ឆ្នាំ 2019 | Monterey Park |
| ថ្ងៃទី 7 ខែមេសា ឆ្នាំ 2019 | ពីធីវប្បធម៌ Cambodia Town Culture Festival | Long Beach |
| ថ្ងៃទី 13-14 ខែមេសា ឆ្នាំ 2019 | ពិធីបុណ្យសៀវភៅ Los Angeles Times Festival of Books | USC – Los Angeles |
| ថ្ងៃទី 20 ខែមេសា ឆ្នាំ 2019 | LA Zoo Spring Fling | Los Angeles |
| ថ្ងៃទី 5 ខែឧសភា ឆ្នាំ 2019 | VegFest 2019 | Encino |
| ថ្ងៃទី 24-25 ខែឧសភា ឆ្នាំ 2019 | RuPaul's DragCon | Los Angeles |
| ថ្ងៃទី 30 ខែឧសភា ឆ្នាំ 2019 | កិច្ចប្រជុំកំពូលសមធម៌ (Equity Summit) | Los Angeles |
| ថ្ងៃទី 21-22 ខែមិថុនា ឆ្នាំ 2019 | BET Experience | Los Angeles |
| ថ្ងៃទី25 ខែកក្កដា ឆ្នាំ 2019 | 2019 Continuous Improvement Summit | Montebello |
| ថ្ងៃទី 26 ខែកក្កដា ឆ្នាំ 2019 | 2019 LA Veterans Resource Expo | Pomona |
| ថ្ងៃទី 24 ខែសីហា ឆ្នាំ 2019 | I Heart Wilmington's Community Wellness Festival | Wilmington |
| ថ្ងៃទី 29 ខែសីហា ដល់ថ្ងៃទី 22 ខែកញ្ញា ឆ្នាំ 2019 | LA County Fair | Pomona |
| ថ្ងៃទី 8 ខែកញ្ញា ឆ្នាំ 2019 | Festival De Jalisco | Lynwood |
| ថ្ងៃទី 8 ខែកញ្ញា ឆ្នាំ 2019 | ក្បួនដង្ហែរឯករាជ្យម៉ិកស៊ិក | East Los Angeles |
| ថ្ងៃទី 28-29 ខែកញ្ញា ឆ្នាំ 2019 | ការបោះឆ្នោតសាកល្បង VSAP | នៅតាមទីតាំងផ្សេងៗនៅទូទាំងខោនធី |
| ថ្ងៃទី 19 ខែតុលា ឆ្នាំ 2019 | Taste of Soul | Crenshaw |
| ថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2019 | Dia de Los Muertos | East Los Angeles |

## បទបង្ហាញ VSAP

ក្រសួងបន្តផ្តល់បទបង្ហាញ VSAP ដោយបង្ហាញវត្តផ្ទាល់នូវការធ្វើបទបង្ហាញដល់ក្រុមប្រឹក្សាក្រុង មន្ត្រីជាប់ឆ្នោត ភ្នាក់ងាររដ្ឋាភិបាល CBOs អង្គការនយោបាយ និងអ្នកពាក់ព័ន្ធដទៃទៀតនៅទូទាំងខោនធី ។ វិសាលភាពនៃបទបង្ហាញរួមមានដូចខាងក្រោម ៖

- ទិដ្ឋភាពទូទៅរបស់ VSAP និង VCA
- ការពន្យល់អំពី BMD និងសមាសធាតុ VSAP ផ្សេងទៀត
- ការពិនិត្យឡើងវិញនូវដំណើរការជ្រើសរើសមជ្ឈមណ្ឌលបោះឆ្នោត
- ការផ្សព្វផ្សាយ និងឱកាសក្នុងភាពជាដៃគូផ្សេងទៀត
- សម្ភារៈជាព័ត៌មានដែលយកទៅផ្ទះ

រហូតមកទល់បច្ចុប្បន្ននេះ ក្រសួងបានផ្តល់ការធ្វើបទបង្ហាញចំនួន 85 ដល់ភ្នាក់ងាររដ្ឋាភិបាល និងបទបង្ហាញចំនួន 179 ដល់ CBO នានា ។ ក្រសួងនឹងបន្តប្រើប្រាស់បទបង្ហាញ VSAP ដើម្បីទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងប្រជាជននៅក្នុងខោនធី និងអ្នកពាក់ព័ន្ធសំខាន់ៗផ្សេងទៀត ។

## ការបោះឆ្នោតសាកល្បង

ក្រសួងបានរៀបចំការបោះឆ្នោតសាកល្បងនៅថ្ងៃទី 28-29 ខែកញ្ញា ឆ្នាំ 2019 នៅមជ្ឈមណ្ឌលបោះឆ្នោតចំនួន 50 ដែលមានទីតាំងនៅពាសពេញខោនធី ។ គោលបំណងនៃព្រឹត្តិការណ៍នេះ គឺដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងបង្កើនឱ្យមានការស្គាល់ពី VSAP ។ វា គឺជាព្រឹត្តិការណ៍ដ៏សប្បាយរីករាយមួយ ដែលបើកចំហដល់សាធារណជន និងផ្តល់ឱ្យអ្នកចូលរួមបានមើលឃើញការដាក់តាំងបង្ហាញនៅក្នុងមជ្ឈមជ្ឈមណ្ឌលបោះឆ្នោត ក៏ដូចជាបទពិសោធជាក់ស្តែង ដោយការប្រើ BMD (ឯកសារសម្ភារៈផ្សព្វផ្សាយបានភ្ជាប់នៅក្នុងព័ត៌មានបន្ថែម) ។ គ្រប់គ្នា ដែលបានចូលរួមអាចបោះឆ្នោតសាកល្បង ដើម្បីទទួលបានបទពិសោធ VSAP ទាំងស្រុង ។ មានការបង្ហាញខ្លួនតារាល្បីៗ ស្ថានីយវិទ្យុក្នុងស្រុកផ្សាយនៅនឹងកន្លែងផ្ទាល់ និងមានការផ្តល់រង្វាន់ និងការចែកអាហារ ដើម្បីទាក់ទាញអ្នកចេញទៅបោះឆ្នោត ។ ព្រឹត្តិការណ៍នេះទទួលបានការគាំទ្រយ៉ាងខ្លាំងពីសំណាក់សាធារណជនប្រមាណជាង 5,800 នាក់ ដែលសុទ្ធតែបានចូលរួម និងបោះឆ្នោត ។

ការផ្សព្វផ្សាយព័ត៌មានអំពីព្រឹត្តិការណ៍នេះក៏មានលក្ខណៈវិជ្ជមានផងដែរ ហើយក្រសួងបានទទួលអត្ថប្រយោជន៍ពីសហគមន៍ និងឱកាស ដើម្បីសាកល្បងដំណើរការ និងនីតិវិធីសម្រាប់ការធ្វើមាត្រដ្ឋាន និងប្រសិទ្ធភាពឱ្យបានល្អ មុនពេលការផ្សព្វផ្សាយរបស់ខោនធីនៅឆ្នាំ 2020 ។ ព្រឹត្តិការណ៍នេះទទួលបាន

ការចូលរួមច្រើនលើសពីអ្នក ដែលបានចូលមើលគេហទំព័របោះឆ្នោតសាកល្បងទៅទៀត ។ ទំនាក់ទំនងតាមបណ្តាញសង្គមមានសារសំខាន់ ហើយក្រសួងមានទំនាក់ ទំនងផ្ទាល់ជាមួយអ្នកបោះឆ្នោតជាង 1.5 លាននាក់ តាមរយៈទំនាក់ទំនងអ៊ីម៉ែលផ្ទាល់ ការចូលរួមចំនែកនៃប្រព័ន្ធផ្សព្វផ្សាយសំខាន់ៗ និងកិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយផ្សេងទៀត ។

## មជ្ឈមណ្ឌលធ្វើបទបង្ហាញ

ដោយមានការបោះឆ្នោតសាកល្បង ក្រសួងនឹងរៀបចំមជ្ឈមណ្ឌលធ្វើបទបង្ហាញ (បទបង្ហាញ) នៅទូទាំងខោនធី ចាប់ពីខែតុលា ឆ្នាំ 2019 ដល់ ខែមករា ឆ្នាំ 2020 ដើម្បីបន្តយុទ្ធនាការចូលរួម និងការអប់រំជាសាធារណៈរបស់ខ្លួនសម្រាប់កម្មវិធី VSAP ។ មជ្ឈមណ្ឌលធ្វើបទបង្ហាញនឹងអនុញ្ញាតឱ្យសាធារណជនទទួលបានបទពិសោធថា តើមណ្ឌលបោះឆ្នោតនឹងមានសភាពដូចម្តេច ហើយវាអាចផ្តល់នូវឱកាសសិក្សាដោយផ្ទាល់ជាមួយ BMD និងសមាសធាតុ VSAP ផ្សេងទៀត ។ យ៉ាងហោចណាស់ មជ្ឈមណ្ឌលធ្វើបទបង្ហាញចំនួនដប់នឹងត្រូវបានដាក់ជាយុទ្ធសាស្ត្រពាសពេញខោនធី ដោយមានទីតាំងនៅតាមស្រុកត្រួតពិនិត្យនីមួយៗនៃមណ្ឌលចំនួនប្រាំនៅពេលណាមួយជាក់លាក់ (សម្រាប់ទីតាំងនៃមណ្ឌលបោះឆ្នោតសាកល្បង សូមមើលប័ណ្ណផ្សព្វផ្សាយការបោះឆ្នោតសាកល្បង ដែលភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ។

## គម្រោងកំណត់ទីតាំងមណ្ឌលបោះឆ្នោត

គម្រោងកំណត់ទីតាំងមណ្ឌលបោះឆ្នោត (VCPP) ត្រូវបានបង្កើតឡើង ដោយក្រសួង ដើម្បីបំពេញបន្ថែមទៅលើសេចក្តីផ្តួចផ្តើម VSAP ដើម្បីផ្លាស់ប្តូរបទពិសោធអ្នកបោះឆ្នោត ជាពិសេសទាក់ទងនឹងការកំណត់មណ្ឌលបោះឆ្នោត ។ នៅក្នុងមួយផ្នែកធំនៃគម្រោង VCPP គឺជាកិច្ចខិតខំប្រឹងប្រែងរបស់ខោនធី ដើម្បីអនុវត្តច្បាប់ VCA ដោយប្រើប៉ារ៉ាម៉ែត្រនៃនីតិបញ្ញត្តិ ដើម្បីបង្កើតមូលដ្ឋានទិន្នន័យរបស់មណ្ឌលបោះឆ្នោតដែលមានសក្តានុពលជាមួយគ្នានឹងការចូលរួមរបស់សហគមន៍យ៉ាងទូលំទូលាយ ។

ក្រសួងបានសហការជាមួយក្រុមហ៊ុន PlaceWorks នៅក្នុងកិច្ចខិតខំប្រឹងប្រែងនៃការកំណត់មណ្ឌលបោះឆ្នោត ដែលរួមមានការវិភាគភូមិសាស្ត្រ សន្និធិបរិក្ខារ ការវាយតម្លៃទីតាំងដំបូង និងការចូលរួមពីសហគមន៍ និងអ្នកពាក់ព័ន្ធយ៉ាងពេញទំហឹង ។ ការស្ទង់មតិ និងការប្រើក្រុមមកសិក្សាក៏បានធ្វើឡើង ដើម្បីស្វែងយល់អំពីចំណូលចិត្តអ្នកបោះឆ្នោត។ ដើម្បីធានាឲ្យបាននូវធាតុចូល និងការចូលរួមពីសាធារណៈជន ក្រសួងបានរៀបចំកិច្ចប្រជុំសហគមន៍មូលដ្ឋានចំនួនពីរដង (សូមមើលតារាងទី 2 និងទី 3 សម្រាប់ព័ត៌មានលម្អិត) ។ លើសពីនេះទៅទៀត ច្រកអនឡាញអន្តរសកម្ម គឺធ្លាប់បានអភិវឌ្ឍឡើង ដើម្បីផ្តល់ព័ត៌មានអំពីទិន្នន័យ ដែលបានប្រើនៅក្នុងដំណើរការ និងដើម្បីផ្តល់នូវវិធីសាស្ត្រងាយស្រួលសម្រាប់សហគមន៍ក្នុងការ

ដាក់ស្នើយោបល់ និងសំណើនានាទាក់ទងទៅនឹងមណ្ឌលបោះឆ្នោត ដែលមានសក្តានុពល និងទីតាំងទម្លាក់សំបុត្រ VBM ។

កិច្ចប្រជុំសហគមន៍មូលដ្ឋានរួមមានកិច្ចប្រជុំ ដែលធ្វើឡើងជាពិសេសសម្រាប់ជនពិការ និងសហគមន៍ភាសាជនជាតិដើមភាគតិច ។ កិច្ចប្រជុំទាំងនេះបានធ្វើឡើង ដើម្បីពន្យល់អំពីច្បាប់ VCA សេចក្តីផ្តួចផ្តើម VSAP និងរបៀប ដែលគំរូថ្មីបង្កើនភាពបត់បែនរបស់អ្នកបោះឆ្នោត ដើម្បីអាចបោះឆ្នោតបាននៅក្នុងមណ្ឌលណាមួយក្នុងខោនធីក្នុងរយៈពេល 11 ថ្ងៃ ។




*កិច្ចប្រជុំសហគមន៍មូលដ្ឋានទីមួយ ដែលរៀបចំឡើងដោយអង្គការ SBCC Thrive LA នៅទីក្រុង Long Beach, CA នៅថ្ងៃទី 5 ខែធ្នូ ឆ្នាំ 2018 ។*

រាល់កិច្ចប្រជុំសហគមន៍នីមួយៗ គឺធ្វើការផ្តោតទៅលើចំណុចជាក់លាក់មួយ ។ កិច្ចប្រជុំលើកទីមួយ បានផ្តោតទៅលើការពន្យល់អំពីច្បាប់ VCA និងគំរូមណ្ឌលបោះឆ្នោតថ្មី និងសាកសួរយោបល់អំពីធាតុចូលពីសាធារណៈជនទាក់ទងទៅនឹងទីតាំងមណ្ឌលបោះឆ្នោត ។ គោលបំណង គឺដើម្បីកំណត់អាគារមណ្ឌលបោះឆ្នោត ដែលសាធារណៈជនយល់ថា ជាទីតាំងសមរម្យបំផុតនៅក្នុងសហគមន៍របស់ពួកគេ និងនៅទូទាំងខោនធី ។ កិច្ចប្រជុំលើកទីពីរ បានផ្តោតទៅលើការធានាឱ្យអ្នកចូលរួមយល់ពីការផ្លាស់ប្តូរទាំងអស់ជាមួយនឹងបទពិសោធ VSAP ថ្មី និងដើម្បីផ្តល់នូវបញ្ជីនៃមណ្ឌលបោះឆ្នោត និងទីតាំងទម្លាក់សំបុត្រ VBM ដែលបានណែនាំ (ផ្អែកលើកិច្ចប្រជុំលើកទីមួយ) ។ ទិន្នន័យត្រូវបានបង្ហាញដល់អ្នកចូលរួមតាមការប្រើវត្ថុមើលឃើញ ដូចជាការប្រើគំនូសតាង និងផែនទីសាមញ្ញ ។ ជាថ្មីម្តងទៀត អ្នកចូលរួមអាចផ្តល់យោបល់ដល់ក្រសួងដោយប្រើច្រកអនឡាញអន្តរសកម្ម VCPP ឬតាមរយៈប័ណ្ណផ្តល់យោបល់ និងសំណើ ។




*កិច្ចប្រជុំសហគមន៍មូលដ្ឋានទីពីរ ដែលរៀបចំឡើងដោយមូលនិធិអប់រំ NALEO Education Fund នៅទីក្រុង La Verne, CA នៅថ្ងៃទី 22 ខែឧសភា ឆ្នាំ 2019*

ដើម្បីបន្តកិច្ចសហការជាមួយសហគមន៍បន្ថែមទៀត ក្រសួងបានធ្វើជាដៃគូជាមួយនឹងអង្គការ CBO ចំនួន 30 ដើម្បីជួយសម្របសម្រួលដល់កិច្ចប្រជុំសហគមន៍ ។ អង្គការទាំងនេះមានវត្តមានស្រាប់នៅក្នុងសហគមន៍ ទំនាក់ទំនងជាមួយអ្នកដឹកនាំ និងអ្នករៀបចំសហគមន៍ ក៏ដូចជាការយល់ដឹងអំពីវប្បធម៌ទាក់ទងនឹងស្ថានភាព និងក្តីកង្វល់របស់សហគមន៍ ។ ក្រុមទាំងអស់បានទទួលការបណ្តុះបណ្តាលអំពីខ្លឹមសារ VSAP និងច្បាប់ VCA ក៏ដូចជាយុទ្ធសាស្ត្រជួយសាធារណៈជនផ្សេងៗក្នុងការរៀបចំសម្រាប់កិច្ចប្រជុំ ។ ភាពជាដៃគូនេះត្រូវបានរៀបចំឡើង ដើម្បីផ្តល់អំណាចដល់អង្គការ CBO នានាថ្នាក់មូលដ្ឋាន ដើម្បីអាចដឹកនាំការពិភាក្សា និងចូលរួមជាមួយអ្នកបោះឆ្នោតខោនធី ដោយធ្វើការផ្សព្វផ្សាយការយល់ដឹងអំពីការកែលម្អគំរូបោះឆ្នោត និងជម្រើសថ្មីៗជាច្រើន ដែលមានសម្រាប់អ្នកបោះឆ្នោត ។

ដើម្បីលើកកម្ពស់កិច្ចប្រជុំសហគមន៍មូលដ្ឋាននៅទូទាំងខោនធី ក្រសួងបានបង្កើតឯកសារផ្សព្វផ្សាយសាធារណៈជនជាក់លាក់ ដើម្បីផ្តោតសំខាន់ទៅលើកិច្ចប្រជុំនីមួយៗ ។ ឯកសារផ្សព្វផ្សាយសាធារណៈជនទាំងនេះត្រូវបានបកប្រែទៅគ្រប់ភាសាទាំងអស់ ហើយនិងបានចែកចាយឱ្យអង្គការ CBO នានា ភ្នាក់ងារខោនធី ស្មៀនក្រុង និងទីភ្នាក់ងាររដ្ឋាភិបាលដទៃទៀត និងអ្នកពាក់ព័ន្ធក្នុងសហគមន៍ ដើម្បីបង្កើនការចូលរួមក្នុងកិច្ចប្រជុំផ្សេងៗ ។

ក្រសួង និងអង្គការ CBO នានា បានខិតខំព្យាយាមធ្វើការ ដើម្បីផ្សព្វផ្សាយអំពីកិច្ចប្រជុំ និងឱ្យមានការចូលរួមពីក្រុមអ្នកចូលរួមចម្រុះប្រជាសាស្ត្រ ។ ក្រសួងក៏បានប្រើប្រាស់បណ្តាញទំនាក់ទំនងផ្សេងៗ ដើម្បីបង្កើនការចូលរួម ។ ជាសរុប មានប្រជាជនប្រមាណជាង 1.5 លាននាក់បានទាក់ទងតាមអ៊ីម៉ែល ប្រជាជនចំនួន 108,639 នាក់បានឮព័ត៌មាន ហើយប្រជាជនចំនួន 348,950 នាក់បានបង្ហាញការចំណាប់អារម្មណ៍តាម រយៈការផ្សព្វផ្សាយព្រឹត្តិការណ៍លើ Facebook និងមានប្រជាជនចំនួន 797,704 នាក់មានការចាប់អារម្មណ៍តាមរយៈកម្មវិធី Nextdoor (កម្មវិធី ដែលផ្ញើសារដោយផ្ទាល់ទៅកាន់សហគមន៍នានានៅក្នុង ខោនធី) ។ អ្នកចូលរួមប្រមាណជាង 2,300 នាក់បានចូលរួមដោយបង្ហាញវត្តមានផ្ទាល់នៅក្នុងកិច្ចប្រជុំសហគមន៍ចំនួន 67 ហើយក្រសួងបានប្រើប្រាស់ប័ណ្ណផ្តល់យោបល់ ដែលទទួលបានក្នុងពេលប្រជុំសហគមន៍ ដើម្បីជូនដំណឹងអំពីដំណើរការបង្កើតមូលដ្ឋានទិន្នន័យនៃទីតាំងមណ្ឌលបោះឆ្នោតសក្តានុពលចំនួន 2,000 កន្លែង ។




*កិច្ចប្រជុំសហគមន៍មូលដ្ឋានទីមួយ ដែលរៀបចំឡើងដោយក្រុមស្រាវជ្រាវ Disabled Resource Paper នៅទីក្រុង Long Beach, CA ថ្ងៃទី 3 ខែឧសភា ឆ្នាំ 2019 ។*

## *គំរូខិតប័ណ្ណផ្សព្វផ្សាយកិច្ចប្រជុំលើកទីមួយ*







## *គំរូការបង្ហោះលើប្រព័ន្ធផ្សព្វផ្សាយសង្គមលើកទីមួយ*






## *គំរូខិតប័ណ្ណផ្សព្វផ្សាយកិច្ចប្រជុំលើកទីពីរ*






| តារាងទី 2 ៖ មន្ត្រីអត្រានុកូលដ្ឋាន - អ្នកកត់ត្រា/ស្មៀនខោនធី Los Angeles<br>គម្រោងទម្លាក់មណ្ឌលបោះឆ្នោត (VCPP) | | | | |
|---|---|---|---|---|
| **កិច្ចប្រជុំសហគមន៍មូលដ្ឋានគ្រឹះជំហានដំបូង** | | | | |
| **កិច្ចប្រជុំ កាលបរិច្ឆេទ និង ពេលវេលា** | **ទីតាំងប្រជុំ** | **ការបកប្រែ ដំណាលគ្នា និង/ឬ ជំនួយភាសា** | **អង្គភាពឈានមុនគេ** | **តំបន់ផ្តោត** |
| ថ្ងៃសុក្រ ទី 16 ខែ វិច្ឆិកា ឆ្នាំ 2018 ម៉ោង 6:30 ល្ងាច ដល់ម៉ោង 8:30 យប់ | កងទ័ពសង្គ្រោះ<br>736 East Compton Blvd<br>Compton, CA 90221 | ភាសាអេស្ប៉ាញ | SBCC<br>Thrive LA | **ទីក្រុង ៖** Carson, Compton, Gardena, Long Beach, Paramount<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Athens Village, East Gardena, East Rancho Dominguez, Rancho Dominguez, Rosewood, West Carson, West Rancho Dominguez, Willowbrook<br>**សង្កាត់ LA ៖** Century Palms, Cove, Harbor Gateway |
| ថ្ងៃសៅរ៍ ទី 17 ខែ វិច្ឆិកា ឆ្នាំ 2018 ម៉ោង 2:30 រសៀល ដល់ម៉ោង 4:30 រសៀល | មជ្ឈមណ្ឌលកំសាន្ត<br>Petit Park Granada Hills<br>16730 Chatsworth Street<br>Granada Hills, CA 91344 | មិនមាន | California Common Cause/Empower LA | **ទីក្រុង ៖** Santa Clarita<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Oat Mountain, Stevenson Ranch, Twin Lakes<br>**សង្កាត់ LA ៖** Chatsworth, Granada Hills, North Hills, Northridge, Porter Ranch |
| ថ្ងៃពុធ ទី 28 ខែ វិច្ឆិកា ឆ្នាំ 2018 ម៉ោង 6:00 ល្ងាច ដល់ម៉ោង 8:00 យប់ | សាលាក្រុង<br>Pacoima<br>បន្ទប់ផ្សព្វផ្សាយ<br>13520 Van Nuys Blvd<br>Pacoima, CA 91331 | ភាសាអេស្ប៉ាញ | Pacoima Beautiful | **ទីក្រុង ៖** San Fernando<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Kagel, Lopez Canyons<br>**សង្កាត់ LA ៖** Arleta, Granada Hills, Lake View Terrace, Mission Hills, North Hills, Pacoima, Panorama City, Sun Valley, Sylmar |
| ថ្ងៃព្រហស្បតិ៍ ទី 29 ខែវិច្ឆិកា ឆ្នាំ 2018 ម៉ោង 6:00 ល្ងាច ដល់ម៉ោង 8:00 យប់ | មហាវិទ្យាល័យ Mt. San Antonio<br>សាលប្រជុំតន្ត្រី<br>Feddersen<br>1100 North Grand Ave<br>Walnut, CA 91789 | ភាសាអេស្ប៉ាញ | មជ្ឈមណ្ឌលសម្រាប់ជនជាតិអាមេរិកអាស៊ីប្រូបសម្រាប់ការផ្តល់អំណាចផ្ទាល់ខ្លួន (CAUSE) | **ទីក្រុង ៖** Azusa, Covina, City of Industry, Diamond Bar, Glendora, La Puente San Dimas, Walnut, West Covina,<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Avocado Heights, Azusa, Charter Oak, Hacienda Heights, North Whittier, Rowland Heights, San Jose Hills, Valinda, Walnut, West Puente Valley<br>**សង្កាត់ LA ៖** Highland Park |

| តារាងទី 2 ៖ មន្ត្រីអត្រានុកូលដ្ឋាន - អ្នកកត់ត្រា/ស្មៀនខោនធី Los Angeles<br>គម្រោងទម្លាក់មណ្ឌលបោះឆ្នោត (VCPP) | | | | |
|---|---|---|---|---|
| កិច្ចប្រជុំសហគមន៍មូលដ្ឋានគ្រឹះជំហានដំបូង | | | | |
| **កិច្ចប្រជុំ កាលបរិច្ឆេទ និង ពេលវេលា** | **ទីតាំងប្រជុំ** | **ការបកប្រែ ដំណាលគ្នា និង/ឬ ជំនួយភាសា** | **អង្គភាពឈានមុខគេ** | **តំបន់ផ្តោត** |
| ថ្ងៃព្រហស្បតិ៍ ទី 29 ខែវិច្ឆិកា ឆ្នាំ 2018<br>ម៉ោង 6:00 ល្ងាច ដល់ម៉ោង 8:00 យប់ | ស្ថានីយពន្លត់អគ្គីភ័យ Los Angeles<br>7063 Laurel Canyon<br>North Hollywood, CA 91605 | ភាសាអេស្ប៉ាញ | California Common Cause/Empower LA | **ទីក្រុង ៖** Burbank<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Universal City<br>**សង្កាត់ LA ៖** Hollywood Hills, North Hollywood, Shadow Hills, Sherman Oaks, Studio City, Sun Valley, Toluca Lake, Toluca Terrance, Toluca Woods, Valley Village |
| ថ្ងៃសៅរ៍ ទី 1 ធ្នូ ឆ្នាំ 2018<br>ម៉ោង 10:00 ព្រឹក ដល់ម៉ោង 12:00 ថ្ងៃត្រង់ | Westwood Recreation Center<br>1350 South Sepulveda Blvd<br>Los Angeles, CA 90025 | មិនមាន | California Common Cause/Empower LA | **ទីក្រុង ៖** Malibu, Santa Monica<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Santa Monica Mountains, West Los Angeles<br>**សង្កាត់ LA ៖** Bel Air, Beverly Crest, Brentwood, Century City, Mandeville Canyon, Mar Vista, Pacific Palisades, Palisades Highlands, Palms, Rancho Park, Venice |
| ថ្ងៃច័ន្ទ ទី 3 ធ្នូ ឆ្នាំ 2018<br>ម៉ោង 6:00 ល្ងាច ដល់ម៉ោង 8:00 យប់ | មជ្ឈមណ្ឌលមនុស្សពេញវ័យ Sherman Oaks East Valley<br>អគារ A<br>5056 Van Nuys Blvd<br>Sherman Oaks, CA 91403 | ភាសាអេស្ប៉ាញ | California Common Cause | **សង្កាត់ LA ៖** Arleta, Encino, Lake Balboa, North Hills, North Hollywood, Panorama City, Sherman Oaks, Sun Valley, Valley Glen, Van Nuys |
| ថ្ងៃអង្គារ ទី 4 ធ្នូ ឆ្នាំ 2018<br>ម៉ោង 6:00 ល្ងាច ដល់ម៉ោង 8:00 យប់ | មជ្ឈមណ្ឌលសហគមន៍ Albert O. Little<br>18750 Clarkdale Ave<br>Artesia, CA 90701 | ភាសាអេស្ប៉ាញ<br>ភាសាហិណ្ឌី | មជ្ឈមណ្ឌសម្រាប់ជនជាតិអាមេរិកអាស៊ីប្បបសម្រាប់ការផ្តល់អំណាចផ្ទាល់ខ្លួន (CAUSE) | **ទីក្រុង ៖** Bellflower, Cerritos, Downey, Hawaiian Gardens, Lakewood, Long Beach, Norwalk, Paramount<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Cerritos, Long Beach, Lakewood |

| **តារាងទី 2 ៖ មន្ត្រីអគ្រានុកូលដ្ឋាន - អ្នកកត់ត្រា/ស្មៀនខោនធី Los Angeles<br>គម្រោងទម្លាក់មណ្ឌលបោះឆ្នោត (VCPP)** | | | | |
|---|---|---|---|---|
| **កិច្ចប្រជុំសហគមន៍មូលដ្ឋានគ្រឹះដំហានដំបូង** | | | | |
| **កិច្ចប្រជុំ កាលបរិច្ឆេទ និងពេលវេលា** | **ទីតាំងប្រជុំ** | **ការបកប្រែដំណាលគ្នា និង/ឬ ជំនួយភាសា** | **អង្គភាពឈានមុនគេ** | **តំបន់ផ្តោត** |
| ថ្ងៃពុធ ទី 5 ធ្នូ ឆ្នាំ 2018<br>ម៉ោង 4:00 ល្ងាច ដល់ម៉ោង 6:00 យប់ | វិទ្យាល័យពហុបច្ចេកទេស Long Beach<br>1600 Atlantic Ave<br>Long Beach, CA 90813 | ភាសាខ្មែរ<br>ភាសាអេស្ប៉ាញ | SBCC, Thrive LA | **ទីក្រុង ៖ Lakewood, Long Beach, Signal Hill**<br>**សង្កាត់ LA ៖ Wilmington** |
| ថ្ងៃព្រហស្បតិ៍ ទី 6 ធ្នូ ឆ្នាំ 2018<br>ម៉ោង 6:00 ល្ងាច ដល់ម៉ោង 8:00 យប់ | បណ្ណាល័យសាធារណៈ Redondo Beach<br>303 North Pacific Coast Highway<br>Redondo Beach, CA 90277 | ភាសាអេស្ប៉ាញ<br>ភាសាជប៉ុន | California Common Cause | **ទីក្រុង** ៖ El Segundo, Gardena, Hawthorne, Hermosa Beach, Inglewood, Lawndale, Manhattan Beach Palos Verdes Estates, Redondo Beach, Torrance<br>**ខោនធី LA ដែលមិនបានបញ្ចូល** ៖ Del Aire, El Camino Village, Harbor Gateway, Lennox, Hawthorne, Wiseburn<br>**សង្កាត់ LA** ៖ Harbor Gateway |
| ថ្ងៃសៅរ៍ ទី 8 ធ្នូ ឆ្នាំ 2018<br>ម៉ោង 10:00 ព្រឹក ដល់ម៉ោង 12:00 ថ្ងៃត្រង់ | Weingarten East Los Angeles YMCA<br>2900 Whittier Blvd<br>Los Angeles, CA 90023 | ភាសាអេស្ប៉ាញ | មូលនិធិអប់រំ NALEO | **ទីក្រុង** ៖ Alhambra, Commerce, Monterey Park, South Pasadena<br>**ខោនធី LA ដែលមិនបានបញ្ចូល** ៖ City Terrace, East Los Angeles<br>**សង្កាត់ LA** ៖ Boyle Heights, El Sereno, Highland Park, Lincoln Heights, Mt. Washington, Wholesale District, University Hills |
| ថ្ងៃច័ន្ទ ទី 10 ធ្នូ ឆ្នាំ 2018<br>ម៉ោង 5:00 ល្ងាច ដល់ម៉ោង 7:00 យប់ | សាកលវិទ្យាល័យ South Baylo<br>2727 West 6th St<br>Los Angeles, CA 90057 | ភាសាកូរ៉េ<br>ភាសាអេស្ប៉ាញ | ក្រុមចម្រុះអាមេរិកកូរ៉េ<br>*ការប្រជុំបន្ថែមនៅក្នុងតំបន់សិក្សា 4* | **សង្កាត់ LA** ៖ Adams-Normandie, Angelino Heights, Chinatown, City Central, County Club Park, Downtown, East Hollywood, Echo Park, Elysian Park, Hancock Park, Harvard Heights, Historic Filipinotown, Hollywood, Hollywood Hills, Jefferson Park, Koreatown, Little Bangladesh, Little Tokyo, Los Feliz, Melrose, Pico-Union, Silverlake, Temple-Beaudry, Thai Town, University Park, Victoria Park, Westlake, Wilshire Center |

| តារាងទី 2 ៖ មន្ត្រីអគ្រានុកូលដ្ឋាន - អ្នកកត់ត្រា/ស្មៀនខោនធី Los Angeles<br>គម្រោងទម្លាក់មណ្ឌលបោះឆ្នោត (VCPP) | | | | |
|---|---|---|---|---|
| **កិច្ចប្រជុំសហគមន៍មូលដ្ឋានគ្រឹះជំហានដំបូង** | | | | |
| **កិច្ចប្រជុំ កាលបរិច្ឆេទ និង ពេលវេលា** | **ទីតាំងប្រជុំ** | **ការបកប្រែ ដំណាលគ្នា និង/ឬ ជំនួយភាសា** | **អង្គភាពឈានមុនគេ** | **តំបន់ផ្តោត** |
| ថ្ងៃអង្គារ ទី 11 ធ្នូ ឆ្នាំ 2018<br>ម៉ោង 6:00 ល្ងាច ដល់ម៉ោង 8:00 យប់ | សាលាក្រុង Inglewood<br>បន្ទប់សហគមន៍ A<br>1 West Manchester Blvd<br>Inglewood, CA 90302 | ភាសាអេស្ប៉ាញ | California Common Cause | **ទីក្រុង ៖** Culver City, El Segundo, Hawthorne, Inglewood<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Ladera Heights, Lennox, Marina del Rey<br>**សង្កាត់ LA ៖** Baldwin Hills, Del Rey, Hyde Park, Marina Peninsula, Palms, Playa Del Rey, Playa Vista, Venice, View Heights, Westchester, Windsor Hills |
| ថ្ងៃពុធ ទី 12 ធ្នូ ឆ្នាំ 2018<br>ម៉ោង 5:30 ល្ងាច ដល់ម៉ោង 7:30 យប់ | មជ្ឈមណ្ឌលសាកលវិទ្យាល័យ Lancaster<br>45356 Division St Lancaster, CA 93535 | មិនមាន | ក្រុមចម្រុះសម្រាប់សិទ្ធិជនអន្តោប្រវេសន៍របស់មនុស្សនៃ Los Angeles (CHIRLA) | **ទីក្រុង ៖** Lancaster, Palmdale<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Acton, Agua Dulce, Anaverde, Bouquet Canyon, Del Sur, Desert View Highlands, Elizabeth Lake, Leona Valley, North Lancaster, Palmdale, Quartz Hill, White Fence Farms |
| ថ្ងៃព្រហស្បតិ៍ ទី 13 ធ្នូ ឆ្នាំ 2018<br>ម៉ោង 7:00 យប់ ដល់ម៉ោង 9:00 យប់ | មជ្ឈមណ្ឌលយុវជន H&H Jivalagian<br>2242 East Foothill Blvd<br>Pasadena, CA 91107 | អាមេនី | គណៈកម្មាធិការជាតិអាមេនីនៃអាមេរិក, Pasadena Chapter<br>*ការប្រជុំបន្ថែមនៅក្នុងតំបន់សិក្សា *8* | **ទីក្រុង ៖** Alhambra, Arcadia, Pasadena, San Gabriel, San Marino, South Pasadena, San Marino, Sierra Madre, Temple City<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Altadena, Angeles National Forest, Northeast San Gabriel, San Pascual<br>**សង្កាត់ LA ៖** Highland Park |
| ថ្ងៃសុក្រ ទី 14 ខែធ្នូ ឆ្នាំ 2018<br>ម៉ោង 6:00 ល្ងាច ដល់ម៉ោង 8:00 យប់ | មជ្ឈមណ្ឌលយុវជន Glendale<br>211 West Chestnut St<br>Glendale, CA 91204 | ភាសាអេស្ប៉ាញ អាមេនី | គណៈកម្មាធិការជាតិអាមេនីនៃអាមេរិក, Western Region Chapter | **ទីក្រុង ៖** Glendale, La Cañada Flintridge,<br>**សង្កាត់ LA ៖** Atwater Village, Eagle Rock, Echo Park, Elysian Park, Elysian Valley, Glassell Park, Highland Park, Los Feliz, Mt. Washington, Silverlake |

| តារាងទី 2 ៖ មន្ត្រីអត្រានុកូលដ្ឋាន - អ្នកកត់ត្រា/ស្មៀនខោនធី Los Angeles<br>គម្រោងទម្លាក់មណ្ឌលបោះឆ្នោត (VCPP) | | | | |
|---|---|---|---|---|
| កិច្ចប្រជុំសហគមន៍មូលដ្ឋានគ្រះជំហានដំបូង | | | | |
| កិច្ចប្រជុំ កាលបរិច្ឆេទ និង ពេលវេលា | ទីតាំងប្រជុំ | ការបកប្រែ ដំណាលគ្នា និង/ឬ ជំនួយភាសា | អង្គភាពឈានមុនគេ | តំបន់ផ្តោត |
| ថ្ងៃសៅរ៍ ទី 5 មករា ឆ្នាំ 2019<br>ម៉ោង 12:00 ថ្ងៃត្រង់ ដល់ម៉ោង 2:00 រសៀល | សាលប្រជុំមរតកនៅអគារមរតកសម្រាប់មនុស្សវ័យចំណាស់សកម្ម<br>930 East Avenue Q-9<br>Palmdale, CA 93550 | ភាសាអេស្ប៉ាញ | ស្ត្រីស្បែកខ្មៅសម្រាប់សុខុមាលភាព | **ទីក្រុង ៖** Lancaster, Palmdale<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖**<br>Angeles National Forest, East Lancaster, Hi Vista, Lake Los Angeles, Littlerock/Juniper Hills, Littlerock, Llano, Pearblossom, Roosevelt, Southeast Antelope Valley, South Edwards, Sun Village |
| ថ្ងៃសៅរ៍ ទី 5 មករា ឆ្នាំ 2019<br>ម៉ោង 10:00 ព្រឹក ដល់ម៉ោង 12:00 ថ្ងៃត្រង់ | SBCC, Thrive LA<br>540 North Marine Avenue<br>Wilmington, CA 90744 | ភាសាអេស្ប៉ាញ | SBCC<br>Thrive LA | **ទីក្រុង ៖** Avalon, Carson, Lomita, Palos Verdes, Rancho Palos Verdes, Rolling Hills, Rolling Hills Estates, Torrance<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖**<br>Academy Estates, La Rambla, West Carson, Westfield<br>**សង្កាត់ LA ៖** Harbor City, Harbor Gateway, Harbor Pines, San Pedro, Wilmington |
| ថ្ងៃអាទិត្យ ទី 6 មករា ឆ្នាំ 2018<br>ម៉ោង 12:00 ថ្ងៃត្រង់ ដល់ម៉ោង 2:00 រសៀល | មជ្ឈមណ្ឌលសហគមន៍ Newhall<br>22421 Market St<br>Newhall, CA 91321 | មិនមាន | ស្ត្រីស្បែកខ្មៅសម្រាប់សុខុមាលភាព | **ទីក្រុង ៖** Santa Clarita<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Agua Dulce, Bouquet Canyon, Canyon Country, Castaic, Lake Hughes, Newhall, Placentia Canyon, Sand Canyon, San Francisquito Canyon, Saugus, Stevenson Ranch, Valencia, Val Verde, West Antelope Valley |
| ថ្ងៃច័ន្ទ ទី 7 ខែមករា ឆ្នាំ 2019<br>ម៉ោង 7:00 យប់ ដល់ម៉ោង 9:00 យប់ | សាលាក្រុង Malibu<br>បន្ទប់ពហុគោលបំណង<br>23825 Stuart Ranch Rd<br>Malibu, CA 90265 | មិនមាន | សម្ព័ន្ធអ្នកបោះឆ្នោតស្ត្រី Los Angeles | **ទីក្រុង ៖** Agoura Hills, Calabasas, Malibu, Westlake Village<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Santa Monica Mountains |

| តារាងទី 2 ៖ មន្ត្រីអត្រានុកូលដ្ឋាន - អ្នកកត់ត្រា/ស្មៀនខោនធី Los Angeles<br>គម្រោងទម្លាក់មណ្ឌលបោះឆ្នោត (VCPP) | | | | |
|---|---|---|---|---|
| **កិច្ចប្រជុំសហគមន៍មូលដ្ឋានគ្រះជំហានដំបូង** | | | | |
| **កិច្ចប្រជុំ កាលបរិច្ឆេទ និង ពេលវេលា** | **ទីតាំងប្រជុំ** | **ការបកប្រែ ដំណាលគ្នា និង/ឬ ជំនួយភាសា** | **អង្គភាពឈានមុខគេ** | **តំបន់ផ្តោត** |
| ថ្ងៃពុធ ទី 9 ខែ មករា ឆ្នាំ 2019 ម៉ោង 5:30 ល្ងាច ដល់ម៉ោង 7:30 យប់ | ក្រសួងទឹក និង ថាមពល Los Angeles សារវ័នដ្ឋាន<br>4030 Crenshaw Blvd<br>Los Angeles, CA 90008 | ភាសាអេស្ប៉ាញ | ស្ត្រីស្បែកខ្មៅសម្រាប់សុខុមាលភាព | **ទីក្រុង ៖** Hawthorne, Huntington Park, Inglewood, Vernon<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Athens-Westmont, Florence-Firestone, View Park, Windsor Hills<br>**សង្កាត់ LA ៖** Century Palms, City Central, Cove, Exposition Park, Figueroa Park Square, Gramercy Place, Green Meadows, Harbor Gateway, Harvard Park, Hyde Park, Leimert Park, Manchester Square, South Park, Vermont Knolls, Vermont Square, Vermont Vista, Watts, West Vernon |
| ថ្ងៃពុធ ទី 9 ខែ មករា ឆ្នាំ 2019 ម៉ោង 6:00 ល្ងាច ដល់ម៉ោង 8:00 យប់ | មជ្ឈមណ្ឌលសហគមន៍ Alexander Hughes<br>បន្ទប់ Padua<br>1700 Danbury Rd Claremont CA 91711 | ភាសាអេស្ប៉ាញ | មូលនិធិអប់រំ NALEO | **ទីក្រុង ៖** Azusa, Claremont, Diamond Bar, Glendora, La Verne, Pomona, San Dimas, Walnut<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Angeles National Forest, Claremont, Covina, East Covina, Glendora, La Verne, Padua Hills, Pomona |
| ថ្ងៃពុធ ទី 9 ខែ មករា ឆ្នាំ 2019 ម៉ោង 7:00 យប់ ដល់ម៉ោង 9:00 យប់ | បណ្ណាល័យខោនធី La Crescenta<br>2809 Foothill Blvd<br>La Crescenta, CA 91214 | អាមេនី | គណៈកម្មាធិការជាតិអាមេនីនៃអាមេរិក, Cresenta Valley Chapter | **ទីក្រុង ៖** Burbank, Glendale, La Cañada Flintridge Pasadena, Santa Clarita<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Angeles National Forest, Altadena, Kagel, La Cresenta, Lopez Canyons<br>**សង្កាត់ LA ៖** Lakeview Terrace, Sunland, Sun Valley, Tujunga |

| **តារាងទី 2 ៖ មន្ត្រីអគ្រានុកូលដ្ឋាន - អ្នកកត់ត្រា/ស្មៀនខោនធី Los Angeles<br>គម្រោងទម្លាក់មណ្ឌលបោះឆ្នោត (VCPP)** | | | | |
|---|---|---|---|---|
| **កិច្ចប្រជុំសហគមន៍មូលដ្ឋានគ្រឹះជំហានដំបូង** | | | | |
| **កិច្ចប្រជុំ កាលបរិច្ឆេទ និងពេលវេលា** | **ទីតាំងប្រជុំ** | **ការបកប្រែដំណាលគ្នា និង/ឬ ជំនួយភាសា** | **អង្គភាពឈានមុនគេ** | **តំបន់ផ្តោត** |
| ថ្ងៃពុធ ទី 9 ខែមករា ឆ្នាំ 2019<br>ម៉ោង 7:00 យប់ ដល់ម៉ោង 9:00 យប់ | មជ្ឈមណ្ឌលសហគមន៍ Rose Goldwater<br>21710 Vanowen St<br>Canoga Park, CA 91303 | ភាសាអេស្ប៉ាញ | សម្ព័ន្ធអ្នកបោះឆ្នោតស្ត្រី Los Angeles | **ទីក្រុង ៖** Calabasas, Hidden Hills<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Lake Manor, Santa Monica Mountains, West Chatsworth, West Hills<br>**សង្កាត់ LA ៖** Canoga Park, Chatsworth, Winnetka, Woodland Hills |
| ថ្ងៃព្រហស្បតិ៍ ទី 10 ខែមករា ឆ្នាំ 2019<br>ម៉ោង 6:00 ល្ងាច ដល់ម៉ោង 8:00 យប់ | មជ្ឈមណ្ឌលសហគមន៍ Jackie Robinson<br>1020 North Fair Oaks Avenue<br>Pasadena, CA 91103 | មិនមាន | California Common Cause | **ទីក្រុង ៖** Alhambra, Arcadia, Pasadena, San Gabriel, San Marino, South Pasadena, San Marino, Sierra Madre, Temple City<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Altadena, Angeles National Forest, Northeast San Gabriel, San Pascual<br>**សង្កាត់ LA ៖** Highland Park |
| ថ្ងៃព្រហស្បតិ៍ ទី 10 ខែមករា ឆ្នាំ 2019<br>ម៉ោង 6:00 ល្ងាច ដល់ម៉ោង 8:00 យប់ | បណ្ណាល័យសាធារណៈ Arcadia<br>20 West Duarte Rd<br>Arcadia, CA 91006 | ភាសាអេស្ប៉ាញ<br>ភាសាចិន | មជ្ឈមណ្ឌសម្រាប់ជនជាតិអាមេរិកអាស៊ីប៉ូលីសម្រាប់ការផ្តល់អំណាចផ្ទាល់ខ្លួន (CAUSE) | **ទីក្រុង ៖** Arcadia, Baldwin Park, Bradbury, Duarte, City of Industry, El Monte, Irwindale, Monrovia, Rosemead, South El Monte, Temple City, West Covina<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Avocado Heights, Bassett, Bradbury, Duarte, Hacienda Heights, Monrovia, North Whittier, Pellissier Village, Whittier Narrows |

| **តារាងទី 2 ៖ មន្ត្រីអត្រានុកូលដ្ឋាន - អ្នកកត់ត្រា/ស្មៀនខោនធី Los Angeles<br>គម្រោងទម្លាក់មណ្ឌលបោះឆ្នោត (VCPP)** | | | | |
|---|---|---|---|---|
| **កិច្ចប្រជុំសហគមន៍មូលដ្ឋានគ្រឹះជំហានដំបូង** | | | | |
| **កិច្ចប្រជុំ កាលបរិច្ឆេទ និង ពេលវេលា** | **ទីតាំងប្រជុំ** | **ការបកប្រែ ដំណាលគ្នា និង/ឬ ជំនួយភាសា** | **អង្គភាពឈានមុនគេ** | **តំបន់ផ្តោត** |
| ថ្ងៃសុក្រ ទី 11 ខែ មករា ឆ្នាំ 2019<br>ម៉ោង 1:30 រសៀល ដល់ម៉ោង 3:30 រសៀល | United Cerebral Palsy of Los Angeles<br>6110 Washington Blvd<br>Culver City, CA 90232 | មិនមាន | United Cerebral Palsy of Los Angeles, Ventura និង Santa Barbara Counties និង Disability Rights California<br>*ការប្រជុំបន្ថែមនៅក្នុងតំបន់សិក្សា *21* សម្រាប់អ្នកបោះឆ្នោតដែលពិការ | **ទីក្រុង ៖** Beverly Hills, Culver City, West Hollywood<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Franklin Canyon, Miracle Mile<br>**សង្កាត់ LA ៖** Alsace, Baldwin Hills, Beverly Crest, Beverlywood, Brookside, Cadillac-Coming, Carthay, Century City, Cheviot Hills, Cloverdale, Cochran, Country Club Park, Crenshaw District, Crestview, Exposition, Faircrest Heights, Hollywood, Hollywood Hills, Lafayette Square, Longwood, Miracle Mile, Melrose, Park La Brea, South Carthay, Sycamore Square, Regent Square, Reynier Village, St. Elmo Village, Victoria Park, Wellington Square |
| ថ្ងៃសៅរ៍ ទី 12 ខែ មករា ឆ្នាំ 2019<br>ម៉ោង 10:00 ព្រឹក ដល់ម៉ោង 12:00 ថ្ងៃត្រង់ | The Music Center's Dorothy Chandler Pavilion<br>សាល Stern Grand (ជាន់ទី 2)<br>135 North Grand Ave<br>Los Angeles, CA 90012 | ភាសាអេស្ប៉ាញ<br>ភាសាថៃ<br>ភាសាតាកាឡុក | សិល្បៈសម្រាប់ LA | **សង្កាត់ LA ៖** Adams-Normandie, Angelino Heights, Chinatown, City Central, County Club Park, Downtown, East Hollywood, Echo Park, Elysian Park, Hancock Park, Harvard Heights, Historic Filipinotown, Hollywood, Hollywood Hills, Jefferson Park, Koreatown, Little Bangladesh, Little Tokyo, Los Feliz, Melrose, Pico-Union, Silverlake, Temple-Beaudry, Thai Town, University Park, Victoria Park, Westlake, Wholesale District, Wilshire Center |

| តារាងទី 2 ៖ មន្ត្រីអត្រានុកូលដ្ឋាន - អ្នកកត់ត្រា/ស្មៀនខោនធី Los Angeles<br>គម្រោងទម្លាក់មណ្ឌលបោះឆ្នោត (VCPP) | | | | |
|---|---|---|---|---|
| **កិច្ចប្រជុំសហគមន៍មូលដ្ឋានគ្រឹះជំហានដំបូង** | | | | |
| **កិច្ចប្រជុំ កាលបរិច្ឆេទ និង ពេលវេលា** | **ទីតាំងប្រជុំ** | **ការបកប្រែ ដំណាលគ្នា និង/ឬ ជំនួយភាសា** | **អង្គភាពឈានមុនគេ** | **តំបន់ផ្តោត** |
| ថ្ងៃសៅរ៍ ទី 12 ខែ មករា ឆ្នាំ 2019 ម៉ោង 10:00 ព្រឹក ដល់ម៉ោង 12:00 ថ្ងៃត្រង់ | ផ្លាហ្សាសហគមន៍ Liberty<br>14181 Telegraph Rd<br>Whittier, CA 90604 | ភាសាអេស្ប៉ាញ | សម្ព័ន្ធអ្នកបោះឆ្នោតស្ត្រី Whittier | **ទីក្រុង ៖** Cerritos, La Habra Heights, La Mirada, Norwalk, Santa Fe Springs, Pico Rivera, Whittier<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** East La Mirada, East Whittier, Hacienda Heights, Los Nietos, Rowland Heights, South Whittier, West Whittier |
| ថ្ងៃសៅរ៍ ទី 12 ខែ មករា ឆ្នាំ 2019 ម៉ោង 10:00 ព្រឹក ដល់ម៉ោង 12:00 ថ្ងៃត្រង់ | មូលនិធិសហគមន៍អាមេរិកម៉ិចសិក<br>401 North Garfield Ave<br>Montebello, CA 90640 | ភាសាអេស្ប៉ាញ<br>ភាសាចិន<br>ភាសាវៀតណាម | មូលនិធិអប់រំ NALEO | **ទីក្រុង ៖** Alhambra, Commerce, El Monte, Montebello, Monterey Park, Pico Rivera, Rosemead, San Gabriel, South El Monte, Temple City, Whittier<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** East Los Angeles, El Monte, Northeast San Gabriel, Sunrise Village, Whittier Narrows |
| ថ្ងៃសៅរ៍ ទី 12 ខែ មករា ឆ្នាំ 2019 ម៉ោង 1:30 រសៀល ដល់ម៉ោង 3:30 រសៀល | បណ្ណាល័យសាធារណៈ Beverly Hills<br>សាវនដ្ឋាន<br>444 North Rexford Dr<br>Beverly Hills, CA 90210 | ភាសារុស្ស៊ី | ក្រុមប្រឹក្សាជាតិអាមេរិកអ៊ីរ៉ង់ | **ទីក្រុង ៖** Beverly Hills, Culver City, West Hollywood<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Franklin Canyon, Miracle Mile<br>**សង្កាត់ LA ៖** Alsace, Baldwin Hills, Beverly Crest, Beverlywood, Brookside, Cadillac-Coming, Carthay, Century City, Cheviot Hills, Cloverdale, Cochran, Country Club Park, Crenshaw District, Crestview, Exposition, Faircrest Heights, Hollywood, Hollywood Hills, Lafayette Square, Longwood, Miracle Mile, Melrose, Park La Brea, South Carthay, Sycamore Square, Regent Square, Reynier Village, St. Elmo Village, Victoria Park, Wellington Square |

| តារាងទី 2 ៖ មន្ត្រីអត្រានុកូលដ្ឋាន - អ្នកកត់ត្រា/ស្មៀនខោនធី Los Angeles<br>គម្រោងទម្លាក់មណ្ឌលបោះឆ្នោត (VCPP) | | | | |
|---|---|---|---|---|
| **កិច្ចប្រជុំសហគមន៍មូលដ្ឋានគ្រឹះជំហានដំបូង** | | | | |
| **កិច្ចប្រជុំ កាលបរិច្ឆេទ និង ពេលវេលា** | **ទីតាំងប្រជុំ** | **ការបកប្រែ ដំណាលគ្នា និង/ឬ ជំនួយភាសា** | **អង្គភាពឈានមុនគេ** | **តំបន់ផ្តោត** |
| ថ្ងៃច័ន្ទ ទី 14 ខែ មករា ឆ្នាំ 2019<br>ម៉ោង 6:00 ល្ងាច ដល់ម៉ោង 8:00 យប់ | សាជីវកម្ម NewStart Housing<br>3355 East Gage Ave<br>Huntington Park, CA 90255 | ភាសាអេស្ប៉ាញ | ក្រុមចម្រុះសម្រាប់សិទ្ធិជនអន្តោប្រវេសន៍របស់មនុស្សនៃ Los Angeles (CHIRLA) | **ទីក្រុង ៖** Bell, Bell Gardens, Compton, Cudahy, Downey, Huntington Park, Lynwood, Maywood, Paramount, South Gate, Vernon<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖**<br>Bandini Islands, East Rancho Dominguez, Florence-Firestone, Lynwood, Walnut Park, Willowbrook<br>**សង្កាត់ LA ៖** Watts |
| ថ្ងៃសៅរ៍ ទី 19 ខែ មករា ឆ្នាំ 2019<br>ម៉ោង 2:00 រសៀល ដល់ម៉ោង 4:00 រសៀល | មជ្ឈមណ្ឌលកំសាន្ត Reseda<br>18411 Victory Blvd<br>Reseda, CA 91335 | ភាសាហ្វាស៊ី<br>ភាសាអេស្ប៉ាញ | ក្រុមប្រឹក្សាជាតិអាមេរិកអ៊ីរ៉ង់ | **សង្កាត់ LA ៖** Encino, Lake Balboa, Northridge, Reseda, Reseda Ranch, Tarzana, Van Nuys, Winnetka, Woodland Hills |
| **ការបកប្រែដំណាលគ្នា -** មានអ្នកបកស្រាយទៅខ្លឹមសារនៃកិច្ចប្រជុំដោយផ្ទាល់មាត់ក្នុងពេលជាក់ស្តែង ។ អ្នកចូលរួមម្នាក់ទទួលបានកាស ដើម្បីស្តាប់ពេលបកប្រែ ។<br>**ជំនួយភាសា -** មានបុគ្គលិក (នានា) ក្នុងផ្តល់ជំនួយផ្នែកភាសារួម ព្រមទាំងមានភ្ជាប់ជាមួយនូវសម្ភារៈប្រជុំ ដែលបានបកប្រែ ។ | | | | |

| តារាងទី 3 ៖ មន្ត្រីអត្រានុកូលដ្ឋាន - អ្នកកត់ត្រា/ស្មៀនខោនធី Los Angeles<br>គម្រោងទម្លាក់មណ្ឌលបោះឆ្នោត (VCPP) | | | | |
|---|---|---|---|---|
| **កិច្ចប្រជុំសហគមន៍មូលដ្ឋានគ្រឹះដំហានទីពីរ** | | | | |
| **កិច្ចប្រជុំ កាលបរិច្ឆេទ និង ពេលវេលា** | **ទីតាំងប្រជុំ** | **ការបកប្រែ ដំណាលគ្នា និង/ឬ ជំនួយភាសា** | **អង្គភាពឈានមុនគេ** | **តំបន់ផ្តោត** |
| ថ្ងៃព្រហស្បតិ៍ ទី 2 ខែឧសភា ឆ្នាំ 2019<br>ម៉ោង 6:30 ល្ងាច ដល់ម៉ោង 8:30 យប់ | ព្រះវិហារ Shephard<br>19700 Rinaldi St<br>Porter Ranch, CA 91326 | ភាសាអេស្ប៉ាញ | សម្ព័ន្ធអ្នកបោះឆ្នោតស្ត្រី Los Angeles | **ទីក្រុង ៖** Calabasas, Hidden Hills<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Lake Manor, Santa Monica Mountains, West Chatsworth, West Hills<br>**សង្កាត់ LA ៖** Canoga Park, Chatsworth, Winnetka, Woodland Hills |
| ថ្ងៃសុក្រ ទី 3 ខែឧសភា ឆ្នាំ 2019<br>ម៉ោង 10:00 ព្រឹក ដល់ម៉ោង 12:00 ថ្ងៃត្រង់ | ឧទ្យាន McBride<br>1550 Martin Luther King Ave<br>Long Beach, CA 90813 | ភាសាសញ្ញាអាមេរិក (ASL)<br>ភាសាខ្មែរ<br>ភាសាអេស្ប៉ាញ | មជ្ឈមណ្ឌលធនធានជនពិការ | **ទីក្រុង ៖** Lakewood, Long Beach, Signal Hill<br>**សង្កាត់ LA ៖** Wilmington |
| ថ្ងៃសៅរ៍ ទី 4 ខែឧសភា ឆ្នាំ 2019<br>ម៉ោង 12:00 ថ្ងៃត្រង់ ដល់ម៉ោង 2:00 រសៀល | មជ្ឈមណ្ឌលមនុស្សចាស់ Long Beach<br>1150 East 4th St<br>Long Beach, CA 90802 | ភាសាខ្មែរ<br>ភាសាអេស្ប៉ាញ | Long Beach Gray Panthers | **ទីក្រុង ៖** Lakewood, Long Beach, Signal Hill<br>**សង្កាត់ LA ៖** Wilmington |
| ថ្ងៃអង្គារ ទី 7 ខែឧសភា ឆ្នាំ 2019<br>ម៉ោង 6:00 ល្ងាច ដល់ម៉ោង 8:00 យប់ | ឧទ្យាន Virginia Avenue<br>អគារ Thelma Terry<br>2200 Virginia Ave<br>Santa Monica, CA 90404 | មិនមាន | សម្ព័ន្ធអ្នកបោះឆ្នោតស្ត្រី Los Angeles | **ទីក្រុង ៖** Malibu, Santa Monica<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Santa Monica Mountains, West Los Angeles<br>**សង្កាត់ LA ៖** Bel Air, Beverly Crest, Brentwood, Century City, Mandeville Canyon, Mar Vista, Pacific Palisades, Palisades Highlands, Palms, Rancho Park, Venice |
| ថ្ងៃព្រហស្បតិ៍ ទី 9 ខែឧសភា ឆ្នាំ 2019<br>ម៉ោង 7:00 យប់ ដល់ម៉ោង 9:00 យប់ | សហគមន៍ឧទ្យាន និងមជ្ឈមណ្ឌលមនុស្សចាស់ Glassell<br>3750 Verdugo Rd<br>Los Angeles, CA 90065 | អាមេនី<br>ភាសាអេស្ប៉ាញ | សមាគមកែលម្អឧទ្យាន Glassell | **ទីក្រុង ៖** Glendale, La Cañada Flintridge,<br>**សង្កាត់ LA ៖** Atwater Village, Eagle Rock, Echo Park, Elysian Park, Elysian Valley, Glassell Park, Highland Park, Los Feliz, Mt. Washington, Silverlake |

| **តារាងទី 3 ៖ មន្ត្រីអត្រានុកូលដ្ឋាន - អ្នកកត់ត្រា/ស្មៀនខោនធី Los Angeles គម្រោងទម្លាក់មណ្ឌលបោះឆ្នោត (VCPP)** | | | | |
|---|---|---|---|---|
| **កិច្ចប្រជុំសហគមន៍មូលដ្ឋានគ្រឹះជំហានទីពីរ** | | | | |
| **កិច្ចប្រជុំ កាលបរិច្ឆេទ និង ពេលវេលា** | **ទីតាំងប្រជុំ** | **ការបកប្រែ ដំណាលគ្នា និង/ឬ ជំនួយភាសា** | **អង្គភាពឈានមុនគេ** | **តំបន់ផ្តោត** |
| ថ្ងៃសុក្រ ទី 10 ខែឧសភា ឆ្នាំ 2019<br>ម៉ោង 6:00 ល្ងាច ដល់ម៉ោង 8:00 យប់ | ក្រុមចម្រុះសហគមន៍<br>8101 South Vermont Ave<br>Los Angeles, CA 90037 | ភាសាអេស្ប៉ាញ | ស្ត្រីស្បែកខ្មៅសម្រាប់សុខុមាលភាព | **ទីក្រុង ៖** Hawthorne, Huntington Park, Inglewood, Vernon<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Athens-Westmont, Florence-Firestone, View Park, Windsor Hills<br>**សង្កាត់ LA ៖** Century Palms, City Central, Cove, Exposition Park, Figueroa Park Square, Gramercy Place, Green Meadows, Harbor Gateway, Harvard Park, Hyde Park, Leimert Park, Manchester Square, South Park, Vermont Knolls, Vermont Square, Vermont Vista, Watts, West Vernon |
| ថ្ងៃព្រហស្បតិ៍ ទី 16 ខែឧសភា ឆ្នាំ 2019<br>ម៉ោង 6:30 ល្ងាច ដល់ម៉ោង 8:30 យប់ | មជ្ឈមណ្ឌលស៊ីវិល Carson<br>801 East Carson St<br>Carson, CA 90745 | ភាសាអេស្ប៉ាញ | ស្ត្រីស្បែកខ្មៅសម្រាប់សុខុមាលភាព | **ទីក្រុង ៖** Carson, Compton, Gardena, Long Beach, Paramount,<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Athens Village, East Gardena, East Rancho Dominguez, Rancho Dominguez, Rosewood, West Carson, West Rancho Dominguez, Willowbrook<br>**សង្កាត់ LA ៖** Century Palms, Cove, Harbor Gateway |
| ថ្ងៃព្រហស្បតិ៍ ទី 16 ខែឧសភា ឆ្នាំ 2019<br>ម៉ោង 7:00 យប់ ដល់ម៉ោង 9:00 យប់ | សាលប្រជុំ Toyota នៃមជ្ឈមណ្ឌលសិល្បវប្បធម៌ Torrance<br>3330 Civic Center Dr<br>Torrance, CA 90503 | ភាសាជប៉ុន | សម្ព័ន្ធអ្នកបោះឆ្នោតស្ត្រី, តំបន់ Torrance | **ទីក្រុង ៖** El Segundo, Gardena, Hawthorne, Hermosa Beach, Inglewood, Lawndale, Manhattan Beach, Palos Verdes Estates, Redondo Beach, Torrance<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Del Aire, El Camino Village, Harbor Gateway, Lennox, Hawthorne, Wiseburn<br>**សង្កាត់ LA ៖** Harbor Gateway |

| **តារាងទី 3 ៖ មន្ត្រីអគ្រានុកូលដ្ឋាន - អ្នកកត់ត្រា/ស្មៀនខោនធី Los Angeles<br>គម្រោងទម្លាក់មណ្ឌលបោះឆ្នោត (VCPP)** | | | | |
|---|---|---|---|---|
| **កិច្ចប្រជុំសហគមន៍មូលដ្ឋានគ្រឹះដំហានទីពីរ** | | | | |
| **កិច្ចប្រជុំ កាលបរិច្ឆេទ និងពេលវេលា** | **ទីតាំងប្រជុំ** | **ការបកប្រែ ដំណាលគ្នា និង/ឬ ជំនួយភាសា** | **អង្គភាពឈានមុនគេ** | **តំបន់ផ្តោត** |
| ថ្ងៃសុក្រ ទី 17 ខែ ឧសភា ឆ្នាំ 2019 ម៉ោង 1:30 រសៀល ដល់ ម៉ោង 3:30 រសៀល | UCPLA Culver City<br>6110 Washington Blvd<br>Culver City, CA 90232 | ភាសាសញ្ញាអាមេរិក (ASL)<br>ភាសាអេស្ប៉ាញ | United Cerebral Palsy of Los Angeles (UCPLA) និង<br>Disability Rights California | កិច្ចប្រជុំចំណាប់អារម្មណ៍ពិសេសសម្រាប់អ្នកបោះឆ្នោតដែលមានពិការភាពនៅពាសពេញខោនធី *Los Angeles* |
| ថ្ងៃសៅរ៍ទី 18 ខែ ឧសភា ឆ្នាំ 2019 ម៉ោង 9:00 ព្រឹក ដល់ម៉ោង 11:00 ព្រឹក | C. Robert Lee បន្ទប់ មជ្ឈមណ្ឌលសកម្មភាព B<br>21815 Pioneer Blvd Hawaiian Gardens, CA 90716 | ភាសាហិណ្ឌី<br>ភាសាអេស្ប៉ាញ | សេវាកម្មធនធានភាគខាងត្បូងរដ្ឋ California សម្រាប់ការរស់នៅឯករាជ្យ | **ទីក្រុង ៖** Bellflower, Cerritos, Downey, Hawaiian Gardens, Lakewood, Long Beach, Norwalk, Paramount<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Cerritos, Long Beach, Lakewood |
| ថ្ងៃសៅរ៍ទី 18 ខែ ឧសភា ឆ្នាំ 2019 ម៉ោង 10:00 ព្រឹក ដល់ម៉ោង 12:00 ថ្ងៃត្រង់ | មជ្ឈមណ្ឌលមូលនិធិវប្បធម៌អាមេនី<br>11719 Moorpark St Studio City, CA 91604 | ភាសាថៃ<br>ភាសាអេស្ប៉ាញ | គណៈកម្មាធិការជាតិអាមេនីនៃអាមេរិក,<br>Crescenta Valley Chapter | **ទីក្រុង ៖** Burbank<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Universal City<br>**សង្កាត់ LA ៖** Hollywood Hills, North Hollywood, Shadow Hills, Sherman Oaks, Studio City, Sun Valley, Toluca Lake, Toluca Terrance, Toluca Woods, Valley Village |
| ថ្ងៃអង្គារទី 21 ខែ ឧសភា ឆ្នាំ 2019 ម៉ោង 6:00 ល្ងាច ដល់ម៉ោង 8:00 យប់ | Cal State Los Angeles<br>Downtown, ជាន់ទី 6- បន្ទប់ 624<br>801 South Grand Ave<br>Los Angeles, CA 90017 | ភាសាតាកាឡុក<br>ភាសាអេស្ប៉ាញ<br>ភាសាថៃ | វិទ្យាស្ថានកិច្ចការសាធារណៈ Pat Brown នៅ<br>Cal State LA | **សង្កាត់ LA ៖** Adams-Normandie, Angelino Heights, Chinatown, City Central, County Club Park, Downtown, East Hollywood, Echo Park, Elysian Park, Hancock Park, Harvard Heights, Historic Filipinotown, Hollywood, Hollywood Hills, Jefferson Park, Koreatown, Little Bangladesh, Little Tokyo, Los Feliz, Melrose, Pico-Union, Silverlake, Temple-Beaudry, Thai Town, University Park, Victoria Park, Westlake, Wholesale District, Wilshire Center |

| តារាងទី 3 ៖ មន្ត្រីអត្រានុកូលដ្ឋាន - អ្នកកត់ត្រា/ស្មៀនខោនធី Los Angeles<br>គម្រោងទម្លាក់មណ្ឌលបោះឆ្នោត (VCPP) | | | | |
|---|---|---|---|---|
| **កិច្ចប្រជុំសហគមន៍មូលដ្ឋានគ្រឹះដំហានទីពីរ** | | | | |
| **កិច្ចប្រជុំ កាលបរិច្ឆេទ និងពេលវេលា** | **ទីតាំងប្រជុំ** | **ការបកប្រែដំណាលគ្នា និង/ឬជំនួយភាសា** | **អង្គភាពឈានមុនគេ** | **តំបន់ផ្ដោត** |
| ថ្ងៃពុធ ទី 22 ខែឧសភា ឆ្នាំ 2019 ម៉ោង 6:00 ល្ងាច ដល់ម៉ោង 8:00 យប់ | សកលវិទ្យាល័យ La Verne បន្ទប់បរិភោគអាហារប្រតិបត្តិ<br>1950 Third St<br>La Verne, CA 91750 | ភាសាសញ្ញាអាមេរិក (ASL)<br>ភាសាអេស្ប៉ាញ | មូលនិធិអប់រំ NALEO | **ទីក្រុង ៖** Azusa, Claremont, Diamond Bar, Glendora, La Verne, Pomona, San Dimas, Walnut<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Angeles National Forest, Claremont, Covina, East Covina, Glendora, La Verne, Padua Hills, Pomona |
| ថ្ងៃអង្គារទី 28 ខែឧសភា ឆ្នាំ 2019 ម៉ោង 5:30 ល្ងាច ដល់ម៉ោង 7:30 យប់ | បណ្ណាល័យសាធារណៈ Covina<br>234 North Second Ave<br>Covina, CA 91723 | ភាសាអេស្ប៉ាញ | Asian Americans Advancing Justice (AAAJ) | **ទីក្រុង ៖** Azusa, Covina, City of Industry, Diamond Bar, Glendora, La Puente, San Dimas, Walnut, West Covina,<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Avocado Heights, Azusa, Charter Oak, Hacienda Heights, North Whittier, Rowland Heights, San Jose Hills, Valinda, Walnut, West Puente Valley<br>**សង្កាត់ LA ៖** Highland Park |
| ថ្ងៃអង្គារទី 28 ខែឧសភា ឆ្នាំ 2019 ម៉ោង 6:00 ល្ងាច ដល់ម៉ោង 8:00 យប់ | សិល្បៈ Norwalk និងបរិវេនកីឡា<br>13000 Clarkdale Ave<br>Norwalk, CA 90650 | ភាសាអេស្ប៉ាញ | សេវាកម្មធនធានភាគខាងត្បូងរដ្ឋ California សម្រាប់ការរស់នៅឯករាជ្យ | **ទីក្រុង ៖** Cerritos, La Habra Heights, La Mirada, Norwalk, Santa Fe Springs, Pico Rivera, Whittier<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** East La Mirada, East Whittier, Hacienda Heights, Los Nietos, Rowland Heights, South Whittier, West Whittier |
| ថ្ងៃពុធទី 29 ខែឧសភា ឆ្នាំ 2019 ម៉ោង 6:00 ល្ងាច ដល់ម៉ោង 8:00 យប់ | មជ្ឈមណ្ឌលកំសាន្តមនុស្សពេញវ័យ San Gabriel, បន្ទប់ Grapevine<br>324 South Mission Dr<br>San Gabriel, CA 91776 | ភាសាចិន | California Common Cause | **ទីក្រុង ៖** Alhambra, Arcadia, Pasadena, San Gabriel, San Marino, South Pasadena, San Marino, Sierra Madre, Temple City<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Altadena, Angeles National Forest, Northeast San Gabriel, San Pascual |

| តារាងទី 3 ៖ មន្ត្រីអត្រានុកូលដ្ឋាន - អ្នកកត់ត្រា/ស្មៀនខោនធី Los Angeles គម្រោងទម្លាក់មណ្ឌលបោះឆ្នោត (VCPP) | | | | |
|---|---|---|---|---|
| **កិច្ចប្រជុំសហគមន៍មូលដ្ឋានគ្រឹះដំហានទីពីរ** | | | | |
| **កិច្ចប្រជុំ កាលបរិច្ឆេទ និង ពេលវេលា** | **ទីតាំងប្រជុំ** | **ការបកប្រែ ដំណាលគ្នា និង/ឬ ជំនួយភាសា** | **អង្គភាពឈានមុនគេ** | **តំបន់ផ្តោត** |
| ថ្ងៃពុធទី 29 ខែឧសភា ឆ្នាំ 2019 ម៉ោង 7:00 យប់ ដល់ម៉ោង 9:00 យប់ | បណ្ណាល័យកណ្តាល Burbank<br>110 North Glenoaks Blvd<br>Burbank, CA 91502 | អាមេនី<br>ភាសាអេស្ប៉ាញ | គណៈកម្មាធិការជាតិអាមេនីនៃអាមេរិក,<br>Western Chapter | **ទីក្រុង ៖** Burbank, Glendale, La Cañada Flintridge, Pasadena, Santa Clarita<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Angeles National Forest, Altadena, Kagel, La Cresenta, Lopez Canyons<br>**សង្កាត់ LA ៖** Lakeview Terrace, Sunland, Sun Valley, Tujunga |
| ថ្ងៃអង្គារទី 4 ខែមិថុនា ឆ្នាំ 2019 ម៉ោង 6:00 ល្ងាច ដល់ម៉ោង 8:00 យប់ | មជ្ឈមណ្ឌលសន្និបាត Pasadena<br>សាលរបាំ F-G<br>300 East Green St<br>Pasadena, CA 91101 | ភាសាអេស្ប៉ាញ<br>ភាសាចិន | គណៈកម្មាធិការជាតិអាមេនីនៃអាមេរិក,<br>Pasadena Chapter | **ទីក្រុង ៖** Alhambra, Arcadia, Pasadena, San Gabriel, San Marino, South Pasadena, Sierra Madre, Temple City<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Altadena, Angeles National Forest, Northeast San Gabriel, San Pascual<br>**សង្កាត់ LA ៖** Highland Park |
| ថ្ងៃពុធទី 5 ខែមិថុនា ឆ្នាំ 2019 ម៉ោង 6:00 ល្ងាច ដល់ម៉ោង 8:00 យប់ | សភាក្រុមប្រឹក្សាក្រុង West Hollywood<br>625 North San Vicente Blvd<br>West Hollywood, 90069 | ភាសារុស្ស៊ី<br>ភាសាហ្វាស៊ី | California Common Cause | **ទីក្រុង ៖** Beverly Hills, Culver City, West Hollywood<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Franklin Canyon, Miracle Mile<br>**សង្កាត់ LA ៖** Alsace, Baldwin Hills, Beverly Crest, Beverlywood, Brookside, Cadillac-Coming, Carthay, Century City, Cheviot Hills, Cloverdale, Cochran, Country Club Park, Crenshaw District, Crestview, Exposition, Faircrest Heights, Hollywood, Hollywood Hills, Lafayette Square, Longwood, Miracle Mile, Melrose, Park La Brea, South Carthay, Sycamore Square, Regent Square, Reynier Village, St. Elmo Village, Victoria Park, Wellington Square |

| តារាងទី 3 ៖ មន្ត្រីអត្រានុកូលដ្ឋាន - អ្នកកត់ត្រា/ស្មៀនខោនធី Los Angeles<br>គម្រោងទម្លាក់មណ្ឌលបោះឆ្នោត (VCPP) | | | | |
|---|---|---|---|---|
| **កិច្ចប្រជុំសហគមន៍មូលដ្ឋានគ្រឹះដំហានទីពីរ** | | | | |
| **កិច្ចប្រជុំ កាលបរិច្ឆេទ និង ពេលវេលា** | **ទីតាំងប្រជុំ** | **ការបកប្រែ ដំណាលគ្នា និង/ឬ ជំនួយភាសា** | **អង្គភាពឈានមុនគេ** | **តំបន់ផ្តោត** |
| ថ្ងៃព្រហស្បតិ៍ ទី 6 ខែមិថុនា ឆ្នាំ 2019<br>ម៉ោង 6:00 ល្ងាច ដល់ម៉ោង 8:00 យប់ | មជ្ឈមណ្ឌលសេវាកម្ម Centro Maravilla<br>4716 East Cesar Chavez Ave<br>Los Angeles, CA 90022 | ភាសាចិន<br>ភាសាវៀតណាម<br>ភាសាអេស្ប៉ាញ | មូលនិធិអប់រំ NALEO | **ទីក្រុង ៖** Alhambra, Commerce, El Monte, Montebello, Monterey Park, Pico Rivera, Rosemead, San Gabriel, South El Monte, Temple City, Whittier<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** East Los Angeles, El Monte, Northeast San Gabriel, Sunrise Village, Whittier Narrows |
| ថ្ងៃព្រហស្បតិ៍ ទី 6 ខែមិថុនា ឆ្នាំ 2019<br>ម៉ោង 6:00 ល្ងាច ដល់ម៉ោង 8:00 យប់ | ព្រះវិហារ Second Baptist<br>925 South Shamrock Ave<br>Monrovia, CA 91016 | ភាសាអេស្ប៉ាញ<br>ភាសាចិន | កម្មវិធីភាពជាដៃគូតំបន់ Monrovia (MAP) | **ទីក្រុង ៖** Arcadia, Baldwin Park, Bradbury, Duarte, City of Industry, El Monte, Irwindale, Monrovia, Rosemead, South El Monte, Temple City, West Covina<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Avocado Heights, Bassett, Bradbury, Duarte, Hacienda Heights, Monrovia, North Whittier, Pellissier Village, Whittier Narrows |
| ថ្ងៃសុក្រ ទី 7 ខែមិថុនា ឆ្នាំ 2019<br>ម៉ោង 6:00 ល្ងាច ដល់ម៉ោង 8:00 យប់ | មជ្ឈមណ្ឌលវប្បធម៌ Chimbole, បន្ទប់របាំ Manzanita<br>38350 Sierra Highway<br>Palmdale, CA 93550 | ភាសាអេស្ប៉ាញ | ស្ត្រីស្បែកខ្មៅសម្រាប់សុខុមាលភាព | **ទីក្រុង ៖** Lancaster, Palmdale<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Acton, Agua Dulce, Anaverde, Bouquet Canyon, Del Sur, Desert View Highlands, Elizabeth Lake, Leona Valley, North Lancaster, Palmdale, Quartz Hill, White Fence Farms |
| ថ្ងៃសៅរ៍ ទី 8 ខែមិថុនា ឆ្នាំ 2019<br>ម៉ោង 10:00 ព្រឹក ដល់ម៉ោង 12:00 ថ្ងៃត្រង់ | ព្រះវិហារ First AME Plaza Level<br>2270 South Harvard Blvd<br>Los Angeles, CA 90018 | ភាសាកូរ៉េ<br>ភាសាអេស្ប៉ាញ<br>ភាសាថៃ | វិហារគ្រឹស្តសាសនាមេតូឌីសអាហ្រ្វិកដំបូង (FAME) និង Alpha Kappa Alpha (AKA) | **សង្កាត់ LA ៖** Adams-Normandie, Angelino Heights, Chinatown, City Central, County Club Park, Downtown, East Hollywood, Echo Park, Elysian Park, Hancock Park, Harvard Heights, Historic Filipinotown, Hollywood, Hollywood Hills, Jefferson Park, Koreatown, Little Bangladesh, Little Tokyo, Los Feliz, Melrose, Pico-Union, Silverlake, Temple-Beaudry, Thai Town, University Park, Victoria Park, Westlake, Wholesale District, Wilshire Center |

| តារាងទី 3 ៖ មន្ត្រីអត្រានុកូលដ្ឋាន - អ្នកកត់ត្រា/ស្មៀនខោនធី Los Angeles<br>គម្រោងទម្លាក់មណ្ឌលបោះឆ្នោត (VCPP) | | | | |
|---|---|---|---|---|
| កិច្ចប្រជុំសហគមន៍មូលដ្ឋានគ្រឹះជំហានទីពីរ | | | | |
| កិច្ចប្រជុំ កាលបរិច្ឆេទ និងពេលវេលា | ទីតាំងប្រជុំ | ការបកប្រែ ដំណាលគ្នា និង/ឬ ជំនួយភាសា | អង្គភាពឈានមុនគេ | តំបន់ផ្តោត |
| ថ្ងៃអង្គារ ទី 11 ខែមិថុនា ឆ្នាំ 2019 ម៉ោង 6:00 ល្ងាច ដល់ម៉ោង 8:00 យប់ | មជ្ឈមណ្ឌលសហគមន៍ Agoura Hills/ មជ្ឈមណ្ឌលសហគមន៍ Calabasas<br>27040 Malibu Hills Rd<br>Calabasas, CA 91301 | មិនមាន | សម្ព័ន្ធអ្នកបោះឆ្នោតស្ត្រី Los Angeles | **ទីក្រុង ៖** Agoura Hills, Calabasas, Malibu, Westlake Village<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Santa Monica Mountains |
| ថ្ងៃពុធ ទី 12 ខែមិថុនា ឆ្នាំ 2019 ម៉ោង 9:00 ព្រឹក ដល់ម៉ោង 11:00 ព្រឹក | មជ្ឈមណ្ឌលកំសាន្ត Harbor City, បន្ទប់សហគមន៍<br>24901 Frampton Ave<br>Harbor City, CA 90710 | ភាសាអេស្ប៉ាញ | មជ្ឈមណ្ឌលប្រឹក្សាយោបល់ South Bay (SBCC) Thrive LA | **ទីក្រុង ៖** Avalon, Carson, Lomita, Palos Verdes, Rancho Palos Verdes, Rolling Hills, Rolling Hills Estates, Torrance<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Academy Estates, La Rambla, West Carson, Westfield<br>**សង្កាត់ LA ៖** Harbor City, Harbor Gateway, Harbor Pines, San Pedro, Wilmington |
| ថ្ងៃព្រហស្បតិ៍ ទី 13 ខែមិថុនា ឆ្នាំ 2019 ម៉ោង 5:30 ល្ងាច ដល់ម៉ោង 7:30 យប់ | South Gate Girls Club House<br>4940 Southern Ave<br>South Gate, CA 90280 | ភាសាអេស្ប៉ាញ | Southeast Los Angeles (SELA) Collaborative | **ទីក្រុង ៖** Bell, Bell Gardens, Compton, Cudahy, Downey, Huntington Park, Lynwood, Maywood, Paramount, South Gate, Vernon<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Bandini Islands, East Rancho Dominguez, Florence-Firestone, Lynwood, Walnut Park, Willowbrook<br>**សង្កាត់ LA ៖** Watts |
| ថ្ងៃសៅរ៍ទី 15 ខែមិថុនា ឆ្នាំ 2019 ម៉ោង 11:30 ព្រឹក ដល់ម៉ោង 1:30 រសៀល | បណ្ណាល័យសាធារណៈ Old Town Newhall<br>24500 Main St<br>Santa Clarita, CA 91321 | មិនមាន | ស្ត្រីស្បែកខ្មៅសម្រាប់សុខុមាលភាព | **ទីក្រុង ៖** Santa Clarita<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Agua Dulce, Bouquet Canyon, Canyon Country, Castaic, Lake Hughes, Newhall, Placerita Canyon, Sand Canyon, San Francisquito Canyon, Saugus, Stevenson Ranch, Valencia, Val Verde, West Antelope Valley |

| **តារាងទី 3 ៖ មន្ត្រីអគ្រានុកូលដ្ឋាន - អ្នកកត់ត្រា/ស្មៀនខោនធី Los Angeles<br>គម្រោងទម្លាក់មណ្ឌលបោះឆ្នោត (VCPP)** | | | | |
|---|---|---|---|---|
| **កិច្ចប្រជុំសហគមន៍មូលដ្ឋានគ្រឹះដំហានទីពីរ** | | | | |
| **កិច្ចប្រជុំ កាលបរិច្ឆេទ និង ពេលវេលា** | **ទីតាំងប្រជុំ** | **ការបកប្រែ ដំណាលគ្នា និង/ឬ ជំនួយភាសា** | **អង្គភាពឈានមុនគេ** | **តំបន់ផ្តោត** |
| ថ្ងៃអង្គារ ទី 18 ខែ មិថុនា ឆ្នាំ 2019 ម៉ោង 5:30 ល្ងាច ដល់ម៉ោង 7:30 យប់ | បណ្ណាល័យសាខា Encino-Tarzana<br>18231 West Ventura Blvd<br>Tarzana, CA 91356 | ភាសាហ្វាស៊ី<br>ភាសាអេស្ប៉ាញ | អ្នកបោះឆ្នោតជនជាតិហ្វាស៊ី | **សង្កាត់ LA ៖** Encino, Lake Balboa, Northridge, Reseda, Reseda Ranch, Tarzana, Van Nuys, Winnetka, Woodland Hills |
| ថ្ងៃអង្គារ ទី 18 ខែ មិថុនា ឆ្នាំ 2019 ម៉ោង 6:00 ល្ងាច ដល់ម៉ោង 8:00 យប់ | មជ្ឈមណ្ឌលចងចាំ Hawthorne បន្ទប់ Polaris<br>3901 West El Segundo Blvd<br>Hawthorne, CA 90250 | ភាសាអេស្ប៉ាញ | មជ្ឈមណ្ឌលប្រឹក្សាយោបល់ South Bay (SBCC) Thrive LA | **ទីក្រុង ៖** Culver City, El Segundo, Hawthorne, Inglewood<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Ladera Heights, Lennox, Marina del Rey<br>**សង្កាត់ LA ៖** Baldwin Hills, Del Rey, Hyde Park, Marina Peninsula, Palms, Playa Del Rey, Playa Vista, Venice, View Heights, Westchester, Windsor Hills |
| ថ្ងៃពុធ ទី 19 ខែ មិថុនា ឆ្នាំ 2019 ម៉ោង 6:00 ល្ងាច ដល់ម៉ោង 8:00 យប់ | ព្រះវិហារ North Hills United Methodist, បន្ទប់ Fireside<br>15435 Rayen St<br>North Hills, CA 91343 | ភាសាអេស្ប៉ាញ | មជ្ឈមណ្ឌលប្រឹក្សាយោបល់ South Bay (SBCC) Thrive LA | **សង្កាត់ LA ៖** Arleta, Encino, Lake Balboa, North Hills, North Hollywood, Panorama City, Sherman Oaks, Sun Valley, Valley Glen, Van Nuys |
| ថ្ងៃសៅរ៍ទី 22 ខែ មិថុនា ឆ្នាំ 2019 ម៉ោង 3:00 រសៀល ដល់ម៉ោង 5:00 រសៀល | មជ្ឈមណ្ឌលកំសាន្ត Northridge គ្រឹះស្ថានហ្វឹកហាត់<br>18300 Lemarsh St<br>Northridge, CA 91234 | មិនមាន | ស្ត្រីស្បែកខ្មៅសម្រាប់សុខុមាលភាព | **ទីក្រុង ៖** Santa Clarita<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Oat Mountain, Stevenson Ranch, Twin Lakes<br>**សង្កាត់ LA ៖** Chatsworth, Granada Hills, North Hills, Northridge, Porter Ranch |

| តារាងទី 3 ៖ មន្ត្រីអត្រានុកូលដ្ឋាន - អ្នកកត់ត្រា/ស្មៀនខោនធី Los Angeles<br>គម្រោងទម្លាក់មណ្ឌលបោះឆ្នោត (VCPP) | | | | |
|---|---|---|---|---|
| **កិច្ចប្រជុំសហគមន៍មូលដ្ឋានគ្រឹះដំហានទីពីរ** | | | | |
| **កិច្ចប្រជុំ កាលបរិច្ឆេទ និង ពេលវេលា** | **ទីតាំងប្រជុំ** | **ការបកប្រែ ដំណាលគ្នា និង/ឬ ជំនួយភាសា** | **អង្គភាពឈានមុនគេ** | **តំបន់ផ្តោត** |
| ថ្ងៃសៅរ៍ទី 22 ខែមិថុនា ឆ្នាំ 2019<br>ម៉ោង 6:00 ល្ងាច ដល់ម៉ោង 8:00 យប់ | ឧទ្យាន Jackie Robinson<br>8773 East Avenue R<br>Littlerock, CA 93543 | ភាសាអេស្ប៉ាញ | សមាគមឧទ្យាន Lake Los Angeles | **ទីក្រុង ៖** Lancaster, Palmdale<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Angeles National Forest, East Lancaster, Hi Vista, Lake Los Angeles, Littlerock/Juniper Hills, Littlerock, Llano, Pearblossom, Roosevelt, Southeast Antelope Valley, South Edwards, Sun Village |
| ថ្ងៃព្រហស្បតិ៍ ទី 27 ខែមិថុនា ឆ្នាំ 2019<br>ម៉ោង 6:00 ល្ងាច ដល់ម៉ោង 8:00 យប់ | សាលាក្រុង Pacoima<br>13520 Van Nuys Blvd<br>Pacoima, CA 91331 | ភាសាអេស្ប៉ាញ | Pacoima Beautiful | **ទីក្រុង ៖** San Fernando<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** Kagel, Lopez Canyons<br>**សង្កាត់ LA ៖** Arleta, Granada Hills, Lake View Terrace, Mission Hills, North Hills, Pacoima, Panorama City, Sun Valley, Sylmar |
| ថ្ងៃសៅរ៍ ទី 29 ខែមិថុនា ឆ្នាំ 2019<br>ម៉ោង 10:00 ព្រឹក ដល់ម៉ោង 12:00 ថ្ងៃត្រង់ | InnerCity Struggle<br>3467 Whittier Blvd<br>Los Angeles, CA 90023 | ភាសាអេស្ប៉ាញ | InnerCity Struggle | **ទីក្រុង ៖** Alhambra, Commerce, Monterey Park, South Pasadena<br>**ខោនធី LA ដែលមិនបានបញ្ចូល ៖** City Terrace, East Los Angeles<br>**សង្កាត់ LA ៖** Boyle Heights, El Sereno, Highland Park, Lincoln Heights, Mt. Washington, Wholesale District, University Hills |
| **ការបកប្រែដំណាលគ្នា -** មានអ្នកបកស្រាយទៅខ្លឹមសារនៃកិច្ចប្រជុំដោយផ្ទាល់មាត់ក្នុងពេលជាក់ស្តែង ។ អ្នកចូលរួមម្នាក់ទទួលបានកាស ដើម្បីស្តាប់ពេលបកប្រែ ។<br>**ជំនួយភាសា -** មានបុគ្គលិក (នានា) ក្នុងផ្តល់ជំនួយផ្នែកភាសារួម ព្រមទាំងមានភ្ជាប់ជាមួយនូវសម្ភារៈប្រជុំ ដែលបានបកប្រែ ។ | | | | |

## 1-D ព័ត៌មានអំពីគេហទំព័រ

### LAvote.net

នេះគឺជាគេហទំព័ររបស់ក្រសួង www.lavote.net ដែលមានផ្ទុកនូវព័ត៌មានអំពីការបោះឆ្នោតយ៉ាងច្រើន ហើយអាចរកបានជាង 13 ភាសា (សម្រាប់បញ្ជីជាភាសាផ្សេងៗ សូមមើលផ្នែក 1-E) ។ គេហទំព័រនេះត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ ដោយមានព័ត៌មានសំខាន់ៗសម្រាប់អ្នកបោះឆ្នោត និងអ្នកមានសិទ្ធិបោះឆ្នោត ដែលមានព័ត៌មានបោះឆ្នោតបច្ចុប្បន្ន ព័ត៌មានចុះឈ្មោះអ្នកបោះឆ្នោត ជម្រើសបោះឆ្នោត ទិន្នន័យបោះឆ្នោតប្រវត្តិសាស្ត្រ ព័ត៌មានផ្តល់សេវាសាធារណៈនៅតាមសហគមន៍ និងជាច្រើនទៀត ។ មុនការបោះឆ្នោតបឋមជ្រើសរើសប្រធានាធិបតីនៅខែមីនា ឆ្នាំ 2020 ក្រសួងនឹងត្រូវរៀបចំរចនាគេហទំព័រឡើងវិញ ដើម្បីបញ្ចូលឃីហោ VSAP ធ្វើបច្ចុប្បន្នភាពពណ៌ចម្រុះ និងផ្តល់ព័ត៌មាន និងធនធានអប់រំថ្មីៗស្តីពី VSAP និងច្បាប់ VCA។

### គេហទំព័រ VSAP

បន្ថែមលើគេហទំព័រចម្បងរបស់ក្រសួង មានគេហទំព័រ ដែលត្រូវបានចង្អុលបង្ហាញអំពីរាល់ព័ត៌មានទាក់ទងនឹង VSAP https://vsap.lavote.net ។ គេហទំព័រនេះមានព័ត៌មានជាច្រើនអំពីបទពិសោធបោះឆ្នោតថ្មី និងការអភិវឌ្ឍគម្រោង រួមមានប្រភពដើមគម្រោង គណៈកម្មាធិការប្រឹក្សាសហគមន៍ និងបច្ចេកទេសប្រឹក្សារបស់គម្រោង របាយការណ៍គម្រោង ព័ត៌មានលម្អិត វីដេអូព័ត៌មាន និងរឿងរ៉ាវព័ត៌មាន ។ គេហទំព័រក៏មានប្លក់ផងដែរ ដែលត្រូវបានប្រើប្រាស់ ដោយក្រសួង ដើម្បីធ្វើបច្ចុប្បន្នភាពសហគមន៍លើព្រឹត្តិការណ៍ជាក់លាក់ សមិទ្ធិផល ឬការអភិវឌ្ឍទៅ ជំរុញគម្រោងបន្ថែមទៀត និងជូនដំណឹងដល់សហគមន៍អំពីវឌ្ឍនភាពនៃ VSAP ។ ឈានដល់ឆ្នាំ 2020 ព័ត៌មានធនធានសំខាន់ៗជាច្រើន ដែលត្រូវបានបង្ហោះនៅលើគេហទំព័រ VSAP ក៏នឹងត្រូវបញ្ចូលទៅក្នុងគេហទំព័រចម្បងរបស់ក្រសួងផងដែរ ។

## 1-E ផ្នែកជំនួយភាសា

ខោនធី Los Angeles មិនត្រឹមតែជាយុត្តាធិការនៃការបោះឆ្នោតក្នុងតំបន់ ដែលមានចំនួនប្រជាជនច្រើនបំផុតនៅក្នុងប្រទេសប៉ុណ្ណោះទេ វាក៏ជាផ្នែកមួយនៃភាពចម្រុះបំផុតផងដែរ ។ ភាពខុសគ្នានៃវប្បធម៌ និងភាសា គឺជាលក្ខណៈមួយនៃការកំណត់របស់ខោនធី ដែលធ្វើឱ្យអ្នកបោះឆ្នោតមានភាពរស់រវើក និងស្វាហាប់ ។ ដើម្បីគាំទ្រ និងជំរុញដំណើរការបើកចំហរ និងរាប់បញ្ចូលសម្រាប់សហគមន៍ជនជាតិភាគតិចភាសារបស់យើង ក្រសួងផ្តល់នូវឯកសារ ដែលបានបកប្រែ និងជំនួយភាសាដ៏រឹងមាំ ។ ដោយអនុលោម

តាមបទបញ្ញត្តិភាសារបស់រដ្ឋ និងសហព័ន្ធ ក្រសួងផ្តល់ជូននូវឯកសារ និងសេវាកម្មដែលបានបកប្រែជាភាសាដូចខាងក្រោម ៖

- អាមេនី
- ភាសាចិន
- ភាសាខ្មែរ
- ភាសាហ្វាស៊ី
- ភាសាហិណ្ឌី
- ភាសាជប៉ុន
- ភាសាកូរ៉េ
- ភាសារុស្ស៊ី
- ភាសាអេស្ប៉ាញ
- ភាសាតាហ្កាឡុក ឬហ្វីលីពីន
- ភាសាថៃ
- ភាសាវៀតណាម

លើសពីនេះ អ្នកបោះឆ្នោត ដែលជំនាញភាសាអង់គ្លេសមានកម្រិត (LEP) ឥឡូវនេះអាចប្រើសិទ្ធិបោះឆ្នោតរបស់ពួកគេតាមរយៈការចូលទៅកាន់បុគ្គលិកបោះឆ្នោតពហុភាសា នៅមណ្ឌលបោះឆ្នោតបាន ។ ខណៈពេលដែលជំនួយលើភាសាបន្ថែមទាំងនេះ បំពេញកាតព្វកិច្ចស្របច្បាប់របស់ខោនធី ខោនធីទៅហួសពីការអនុវត្តតិចតួចបំផុតដោយផ្តល់ជំនួយភាសាជាភាសាបេងហ្គាល់ ហ្គូចាចារី និងអ៊ូឌាផងដែរ ។

ខោនធីប្តេជ្ញាបន្តវិធីសាស្ត្រដ៏ទូលំទូលាយរបស់ខ្លួនក្នុងការអនុលោមតាមតម្រូវការភាសារបស់រដ្ឋ និងសហព័ន្ធ និងការសម្រេចបាននូវគោលបំណងរបស់ខ្លួនក្នុងការផ្តល់សេវាកម្មបោះឆ្នោតប្រកបដោយយុត្តិធម៌ ដែលអាចចូលដំណើរការបាន និងមានតម្លាភាពសម្រាប់អ្នកបោះឆ្នោតទាំងអស់ ។ តំណភ្ជាប់ទៅកាន់កម្មវិធីសេវាកម្មពហុភាសារបស់ក្រសួងគឺ ៖ https://lavote.net/home/voting-elections/voter-education/multilingual-services-program/multilingual-services-program ។

## ការកំណត់អត្តសញ្ញាណ និងការបម្រើអ្នកបោះឆ្នោតដែលជំនាញភាសាអង់គ្លេសមានកម្រិត (LEP)

នៅពេលមនុស្សម្នាក់ចុះឈ្មោះបោះឆ្នោត ពួកគេអាចស្នើសុំឯកសារបោះឆ្នោតបកប្រែជាភាសាផ្សេងបាន ។ អ្នកបោះឆ្នោតគ្រប់រូប ដែលធ្វើការស្នើសុំនេះនឹងទទួលបានសន្លឹកឆ្នោតគំរូ ដែលបានបកប្រែ និងឯកសារបោះឆ្នោតទាំងអស់ជាភាសាជម្រើសរបស់ពួកគេ ដោយស្វ័យប្រវត្តិ ។ ក្រសួងក៏មានបណ្តាញទូរសព្ទទាន់ហេតុការណ៍ ដែលជាជំនួយពហុភាសាផងដែរ ៖ 1-800-815-2666 (ជម្រើសទី 3) សម្រាប់អ្នកបោះឆ្នោតស្នើសុំសម្ភារៈបោះឆ្នោត ឬព័ត៌មានអំពីទីតាំងមណ្ឌលបោះឆ្នោត ប័ណ្ណចុះឈ្មោះអ្នកបោះឆ្នោតពីរភាសា ពាក្យសុំ VBM ដែលបានបកប្រែ និងកូនសៀវភៅសន្លឹកឆ្នោតគំរូ ។

ក្រសួងបានបង្កើតប្រព័ន្ធទិន្នន័យកំណត់គោលដៅដ៏ទូលំទូលាយមួយ ដែលរួមបញ្ចូលសំណើសុំទិន្នន័យប្រជាសាស្ត្រ និងភាសាពីប្រភពជាច្រើន រួមមានទិន្នន័យពីជំរឿនសហរដ្ឋអាមេរិក ការស្ទង់មតិសហគមន៍អាមេរិក ការដាក់ពាក្យចុះឈ្មោះអ្នកបោះឆ្នោត និងសំណើជំនួយភាសាពីបណ្តាក្រុមសហគមន៍ ។ ពីទិន្នន័យនេះរបាយការណ៍ត្រូវបានបង្កើតឡើង ដើម្បីផ្តល់អាទិភាពដល់បុគ្គលិកពហុភាសានៅមណ្ឌលបោះឆ្នោតផ្អែកលើតម្រូវការជំនួយភាសា ។ ផ្អែកលើទិន្នន័យដែលមានស្រាប់ បុគ្គលិកបោះឆ្នោតនិយាយភាសាអេស្ប៉ាញនឹងត្រូវដាក់នៅគ្រប់មណ្ឌលបោះឆ្នោត ។

### ការអប់រំ និងទំនាក់ទំនងជាមួយសហគមន៍ LEP អំពីមណ្ឌលបោះឆ្នោត

ដើម្បីធានាថា អ្នកបោះឆ្នោត LEP មានការចូលទៅកាន់ដំណើរការចូលរួមសហគមន៍ ក្រសួងបានធ្វើការវិភាគលើការប្រើប្រាស់ភាសា និងសេវាកម្មបកប្រែពេលដំណាលគ្នានៃការប្រជុំសហគមន៍ចំនួនពីរជុំរបស់ខ្លួន ដែលបានយោងទៅនៅក្នុង 1-C ខាងលើ ។ រាល់ការប្រជុំ / សិក្ខាសាលាទាំងអស់ត្រូវបានផ្តល់ជូននូវឯកសារបកប្រែ ។ សូមមើលតារាងទី 2 និង 3 ដែលយោងនៅក្នុង 1-C ខាងលើសម្រាប់បញ្ជីសិក្ខាសាលាដែលរួមមានការបកប្រែពេលដំណាលគ្នា និង/ឬជំនួយភាសា ។

បន្ថែមលើសនេះទៀត គណៈកម្មាធិការប្រឹក្សាលទ្ធភាពចូលប្រើភាសារបស់ក្រសួង (LAAC) ដែលបានបង្កើតឡើងក្នុងឆ្នាំ 2017 ដើរតួនាទីយ៉ាងសំខាន់ក្នុងការអប់រំសហគមន៍ភាសាជនជាតិភាគតិចអំពី VSAP ។ LAAC បានចែកចាយសម្ភារៈបកប្រែនៅក្នុងសហគមន៍របស់ពួកគេ និងបានរៀបចំការប្រជុំសហគមន៍ ។ អង្គការ LAAC មួយចំនួនរួមមាន ៖

- Asian Americans Advancing Justice
- California Common Cause
- CAUSE
- FarsiVote
- ក្រុមចម្រុះអាមេរិកកូរ៉េ

- មូលនិធិអប់រំ NALEO
- ក្រុមប្រឹក្សាជាតិអាមេរិកអ៊ីរ៉ង់

ដោយមានការសហការជាមួយ LAAC និងអង្គការសហគមន៍ ក្រសួងនឹងរៀបចំសិក្ខាសាលាអប់រំអ្នកបោះឆ្នោតជាពីរភាសា ដើម្បីអប់រំ និងផ្សព្វផ្សាយបន្ថែមពីការផ្លាស់ប្តូរដែលទាក់ទងនឹង VCA និង VSAP ដោយមានសិក្ខាសាលាយ៉ាងតិចមួយជាភាសានីមួយៗដូចខាងក្រោម ៖ អាមេនី ចិន ហ្វាស៊ី ហិណ្ឌី ជប៉ុន ខ្មែរ កូរ៉េ រុស្ស៊ី អេស្ប៉ាញ តាហ្កាឡុក ថៃ និងវៀតណាម ។ អ្នកបកប្រែភាសានីមួយៗនឹងមានវត្តមាន ដើម្បីជួយអ្នកចូលរួម ។ ក្រសួងនឹងធានាថា សិក្ខាសាលារៀបចំទីតាំងជាយុទ្ធសាស្ត្រ និងមានបុគ្គលិក ហើយនឹងត្រូវបានដំឡើងឋានៈជាក្រុម និងប្រព័ន្ធផ្សព្វផ្សាយដែលធ្វើការដោយផ្ទាល់ជាមួយក្រុមភាសានីមួយៗ ។ សិក្ខាសាលាទាំងនេះនឹងត្រូវធ្វើឡើងនៅខែកុម្ភៈ ឆ្នាំ 2020 ។

## 1-F ជំនួយផ្នែកលទ្ធភាពប្រើប្រាស់

ក្រសួងខិតខំធ្វើការយ៉ាងខ្លាំង ដើម្បីធានាបាននូវភាពងាយស្រួលនៃការបោះឆ្នោតសម្រាប់ជនពិការ ។ ក្រសួងបានចាត់វិធានការជាច្រើនក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះក្នុងការស្ទង់មតិ ការជ្រើសរើសបុគ្គលិក ការកែសម្រួល និងការរក្សាការរដ្ឋានបោះឆ្នោត ដែលអាចចូលប្រើប្រាស់បាន។ នៅឆ្នាំ 1986 មានតែ 70% នៃការរដ្ឋានបោះឆ្នោតរបស់ខោនធីប៉ុណ្ណោះ ដែលបានបំពេញទៅតាមបទដ្ឋានលទ្ធភាពចូលប្រើប្រាស់បានជាក់ស្តែង ចំណែកឯនៅឆ្នាំ 2018 គឺមានជិតទៅដល់ 90% នៃការស្ទង់មតិរបស់ខោនធីបានបំពេញតាមបទដ្ឋាននៃភាពងាយស្រួលក្នុងការចូលទៅដល់ ។

ក្រសួងបានបង្កើតគណៈកម្មាធិការផ្តល់សេវាសាធារណៈនៅតាមសហគមន៍ និងអ្នកបោះឆ្នោត (CVOC) ជាភាពជាដៃគូរវាងក្រសួង និងប្រជាពលរដ្ឋ សហគមន៍ និងអង្គការតស៊ូមតិ ។ តាមរយៈគណៈកម្មាធិការនោះប្រជាពលរដ្ឋមានតួនាទីសកម្ម និងសហការគ្នាក្នុងការធ្វើការជាមួយក្រសួង ដើម្បីធានាថា ការបោះឆ្នោតមានភាពយុត្តិធម៌អាចចូលដំណើរការបាន និងមានតម្លាភាពសម្រាប់អ្នកបោះឆ្នោតទាំងអស់ ។ បេសកកម្មរបស់គណៈកម្មាធិការ គឺដើម្បីសម្រួលដល់ការប្រាស្រ័យទាក់ទង និងកិច្ចសហការរវាងសហគមន៍ និងក្រសួងអំពីវិធីអប់រំចូលរួម និងផ្តល់សេវាកម្មប្រកបដោយគុណភាព និងធានានូវភាពងាយស្រួលសម្រាប់អ្នកបោះឆ្នោតទាំងអស់ ។ CVOC ធ្វើការក្នុងភាពជាដៃគូជាមួយវិស័យផ្សេងៗនៃសហគមន៍លើការផ្តល់សេវាកម្មល្អប្រសើរជាងមុន ដល់អ្នកបោះឆ្នោត ដែលមានតម្រូវការជាក់លាក់ អ្នកបោះឆ្នោត ដែលមានតម្រូវការជំនួយភាសា និងក្នុងការជួយផ្សព្វផ្សាយព័ត៌មានអំពីបញ្ហាសំខាន់ៗនៃការបោះឆ្នោត ដូចជាសន្លឹកឆ្នោតបណ្តោះអាសន្ន ឯកសារបោះឆ្នោត ដែលបានបកប្រែ និង VSAP ។ សមាជិកភាពរបស់ CVOC រួមមានជាង 120 អង្គការ និងតំណាង 200 នាក់ ដែលចូលរួមកិច្ចប្រជុំប្រចាំត្រីមាសរបស់គណៈកម្មាធិការ ។ ការប្រជុំត្រូវបានបើកចំហសម្រាប់សាធារណជន និងអង្គការដែលចាប់អារម្មណ៍ទាំងអស់ ។

ខោនធីប្តេជ្ញាបន្តវិធីសាស្ត្រដ៏ទូលំទូលាយរបស់ខ្លួនក្នុងការអនុលោមតាមតម្រូវការលទ្ធភាពប្រើប្រាស់របស់រដ្ឋ និងសហព័ន្ធ និងការសម្រេចបាននូវគោលបំណងរបស់ខ្លួនក្នុងការផ្តល់សេវាបោះឆ្នោតប្រកបដោយយុត្តិធម៌ ដែលអាចចូលដំណើរការបាន និងមានតម្លាភាពសម្រាប់អ្នកបោះឆ្នោតទាំងអស់ ។ គំរូមណ្ឌលបោះឆ្នោតថ្មីនេះ ត្រូវបានរៀបចំឡើង ដើម្បីឱ្យអ្នកបោះឆ្នោតទាំងអស់អាចចូលទៅកាន់បាន ដោយធានាថាមណ្ឌលបោះឆ្នោត ដែលមានទីតាំងស្ថិតនៅជិតនឹងអ្នកបោះឆ្នោត ដែលមានពិការភាព ។ នៅក្នុងការវាយតម្លៃមណ្ឌលបោះឆ្នោត មធ្យោបាយនានា ដែលត្រូវបានគេចាត់ទុកជាការិយាល័យបោះឆ្នោតចាំបាច់ត្រូវបំពេញតម្រូវការ

កន្លែងចតរថយន្ត ដែលមានភាពងាយស្រួលបន្ថែមលើលក្ខណៈវិនិច្ឆ័យផ្សេងទៀត ។ ក្រសួងបានចូលរួមសហគមន៍មិនត្រឹមតែតាមរយៈ CVOC ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងតាមរយៈជំនួយពី គណៈកម្មាធិការប្រឹក្សាយោបល់អំពីភាពងាយស្រួលក្នុងការបោះឆ្នោត (VAAC) ផងដែរ ។ VAAC ខោនធីត្រូវបានបង្កើតឡើងក្នុងឆ្នាំ 2006 ដើម្បីជួយក្រសួងក្នុងការអនុវត្តយុទ្ធសាស្ត្រច្នៃប្រឌិត ដែលធ្វើឱ្យប្រសើរឡើងនូវភាពងាយស្រួល និងការចូលរួម ។ VAAC បានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយដល់ក្រសួងទាំងនៅក្នុងសកម្មភាពមុនការបោះឆ្នោត និងក្រោយការបោះឆ្នោត ។ នៅក្នុងភាពជាដៃគូជាមួយ VAAC ក្រសួងបានចេញសេចក្តីប្រកាសស្តីពីសេវាសាធារណៈចំនួនពីរ (ជាមួយភាសាសញ្ញាអាមេរិក និងចំណងជើងបិទ) ដើម្បីណែនាំបទពិសោធន៍បោះឆ្នោតថ្មី និងជម្រើសបោះឆ្នោត ដែលអាចរកបានតាមរយៈ VCA លៃអ្នកប ពះប្មោតផែលមានពិការភាព ។ លើសពីនេះទៀត ការប្រជុំសហគមន៍ចំនួនប្រាំមួយដែលបានធ្វើឡើងក្នុងឆ្នាំ 2019 ផ្តោតជាពិសេសលើការជូនដំណឹងដល់សហគមន៍ជនពិការនៅ VCA, VSAP និងមណ្ឌលបោះឆ្នោត ។ កិច្ចប្រជុំនាពេលអនាគតដែលនឹងគ្រោងធ្វើឡើងនៅឆ្នាំ 2020 ក៏នឹងរួមបញ្ចូលផងដែរនូវការបង្ហាញផ្ទាល់ជាមួយ BMD ហើយត្រូវបានបញ្ចូលក្នុងតារាងខាងក្រោម ៖

| អង្គការម្ចាស់ផ្ទះ | ទីតាំង | ការស្នាក់នៅ | កាលបរិច្ឆេទ |
|---|---|---|---|
| មជ្ឈមណ្ឌល **United Cerebral Palsy** នៃ **Los Angeles** | **Culver City** | **ASL** | 01/11/2019 |
| មជ្ឈមណ្ឌលធនធានជនពិការ | **Long Beach** | **ASL** | 5/03/2019 |
| **United Cerebral Palsy of Los Angeles** និង **Disability Rights California** | **Culver City** | **ASL** | 5/17/2019 |
| សេវាកម្មធនធានភាគខាងត្បូងរដ្ឋ **California** សម្រាប់ការរស់នៅឯករាជ្យ | **Hawaiian Gardens** | មិនមាន | 5/18/2019 |
| សេវាកម្មធនធានភាគខាងត្បូងរដ្ឋ **California Norwalk** សម្រាប់ការរស់នៅឯករាជ្យ **CA 90650** | **Norwalk** | មិនមាន | 5/28/2019 |
| មជ្ឈមណ្ឌលប្រចាំតំបន់ **LA** ខាងកើត | **Alhambra** | ពុម្ពអក្សរធំ | 11/11/2019 |
| អង្គការ **Eye-DAS** ៖ ជំងឺភ្នែកធ្ងន់ធ្ងរ | **West Covina** | អក្សរជនពិការភ្នែក និងពុម្ពអក្សរធំ | 01/02/2020 |
| **California Council of the Blind** | **Burbank** | អក្សរជនពិការភ្នែក និងពុម្ពអក្សរធំ | 01/04/2020 |
| **California Council of the Blind Greater LA Chapter** | **Los Angeles** | អក្សរជនពិការភ្នែក និងពុម្ពអក្សរធំ | 01/18/2020 |
| **California Council of the Blind Long Beach** | **Long Beach** | អក្សរជនពិការភ្នែក និងពុម្ពអក្សរធំ | 02/08/2020 |

## សេវាកម្មដែលអាចចូលប្រើបាន – ISB, RAVBM, VBM និង BMD

អន្តរកម្មសន្លឹកឆ្នោតគំរូថ្មី (ISB) របស់ក្រសួង និងលទ្ធភាពបោះឆ្នោតតាមប្រៃសណីយ៍ពីនាយ (RAVBM) គឺជាជម្រើសពីរបន្ថែមទៀត ដែលផ្តល់នូវការចូលប្រើ និងភាពងាយស្រួលបន្ថែមដល់អ្នកបោះឆ្នោតដែលពិការ ។

ISB អាចចូលប្រើបានតាមរយៈកម្មវិធីផ្នែកលើវិបនៅលើគេហទំព័ររបស់ក្រសួង ដែលអនុញ្ញាតឲ្យអ្នកប្រើប្រាស់គូសសន្លឹកឆ្នោតគំរូរបស់ពួកគេ និងបង្កើតប័ណ្ណបោះឆ្នោតដែលអាចព្រីន ឬទាញយកបាននៅលើឧបករណ៍ចល័ត ។ ការចុះឈ្មោះបោះឆ្នោតនឹងពន្លឿនបទពិសោធនៃការបោះឆ្នោតនៅមណ្ឌលបោះឆ្នោតមួយដោយអនុញ្ញាតឱ្យអ្នកបោះឆ្នោតផ្ទេរសន្លឹកឆ្នោតគំរូរបស់ពួកគេទៅក្នុង BMD យ៉ាងឆាប់រហ័ស និងបញ្ចប់ដំណើរការនៃការបោះឆ្នោត ។

RAVBM គឺជាជម្រើសងាយស្រួលមួយផ្សេងទៀតដែលមានលក្ខណៈផ្តាច់មុខសម្រាប់អ្នកបោះឆ្នោតដែលជាជនពិការ តាមរយៈដំណើរការស្រដៀងគ្នានឹង ISB ដែលក្នុងនោះអ្នកបោះឆ្នោតអាចចូលមើលពាក្យសុំតាមគេហទំព័រដែលស្ថិតនៅលើគេហទំព័ររបស់ក្រសួង ដើម្បីទទួលបានសន្លឹកឆ្នោតក្នុងទម្រង់ដែលអាចអានបានលើអេក្រង់ ។ អ្នកបោះឆ្នោតអាចប្រើឧបករណ៍ជំនួយរបស់ពួកគេ ដើម្បីអាន និងគូសសម្គាល់ការជ្រើសរើសរបស់ពួកគេ បោះពុម្ពសន្លឹកឆ្នោតរបស់ពួកគេ ដាក់វានៅក្នុងស្រោមសំបុត្រផ្ញើត្រលប់មកវិញបន្ទាប់មកចុះហត្ថលេខា និងប្រគល់ស្រោមសំបុត្រ VBM វិញ ។ ជម្រើសទាំងពីរផ្តល់នូវបទពិសោធន៍បោះឆ្នោតដោយឯករាជ្យ ឯកជន និងសុវត្ថិភាពសម្រាប់អ្នកបោះឆ្នោតជាជនពិការជាច្រើននាក់ ដើម្បីបោះឆ្នោតតាមសំបុត្រ ។ លើសពីនេះទៀត ការបោះឆ្នោតតាមចិញ្ចើមថ្នល់នឹងនៅតែជាជម្រើសមួយ និងមានផ្តល់ជូននៅទីតាំងមណ្ឌលបោះឆ្នោតណាមួយ ។

សន្លឹកឆ្នោត និងស្រោមសំបុត្រ VBM ថ្មីរបស់ក្រសួងមានការកែលម្អដូចខាងក្រោម ៖

- សន្លឹកឆ្នោតមានទំហំធំជាង និងពេញមុខ
- កាន់តែងាយស្រួលអាន
- កាន់តែងាយស្រួលក្នុងការបំពេញ
- កាន់តែងាយយល់
- សន្លឹកឆ្នោតពហុភាសា
- មិនតម្រូវឲ្យមានតែម
- អ្នកបោះឆ្នោតអាចយកទៅដាក់នៅតាមមណ្ឌលបោះឆ្នោតណាមួយក្នុងកំឡុងពេលបោះឆ្នោតដែលមានរយៈពេល 11 ថ្ងៃ ឬក៏ទីតាំងមួយដែលមានទីតាំងយ៉ាងងាយស្រួលដែលចាប់ផ្តើមពីថ្ងៃទី 29 មុនថ្ងៃបោះឆ្នោត ។

អ្នកបោះឆ្នោត ដែលមានពិការភាពអាចស្នើសុំសន្លឹកឆ្នោត VBM ដោយប្រើវិធីដូចខាងក្រោម ៖

- ស្នើសុំលើបណ្តាញនៅ www.lavote.net
- ផ្តាច់ និងប្រគល់ពាក្យសុំ VBM ដែលមាននៅក្នុងសន្លឹកឆ្នោតគំរូ

- ផ្ញើលិខិតដែលចុះហត្ថលេខាដោយស្នើសុំសន្លឹកឆ្នោត VBM
- ហៅទូរសព្ទទៅលេខ (800) 815-2666, ជម្រើសលេខ 2 ។

ប្រសិនបើអ្នកបោះឆ្នោតបានធ្វើឲ្យខូចខាត ឬបាត់សន្លឹកឆ្នោត VBM របស់ខ្លួន អ្នកបោះឆ្នោតអាចស្នើសុំសម្ភារៈជំនួសរហូតដល់ 7 ថ្ងៃមុនថ្ងៃបោះឆ្នោត ។ ប្រសិនបើការជំនួសត្រូវបានស្នើសុំ ក្រសួងនឹងផ្ញើកញ្ចប់ VBM ថ្មី ។ ប្រសិនបើតិចជាង 7 ថ្ងៃមុនថ្ងៃបោះឆ្នោត អ្នកបោះឆ្នោតអាចទាក់ទងក្រសួង ដើម្បីទទួលបានជម្រើសផ្សេងដើម្បីទទួលបានសន្លឹកឆ្នោត VBM ជំនួស រួមទាំងទៅយកសន្លឹកឆ្នោតថ្មីនៅទីស្នាក់ការក្រសួងក្នុងទីក្រុង Norwalk ។

ចុងក្រោយ BMD ទាំងអស់ផ្តល់ជូនមុខងារពិសេសជាច្រើន ដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកបោះឆ្នោតដែលមានពិការភាព ។ BMD នីមួយៗមានកន្លែងទំនេរគ្រប់គ្រាន់សម្រាប់អ្នកបោះឆ្នោតអង្គុយលើកៅអីរុញ ឬអ្នកដើរ ។ ការបង្ហាញអេក្រង់ប៉ះអាចត្រូវបានកែតម្រូវសម្រាប់អ្នកបោះឆ្នោត ទោះបីស្ថិតក្នុងជំហរអង្គុយ ឬឈរក៏ដោយ ។ សម្រាប់អ្នក ដែលមិនអាចប្រើអេក្រង់ប៉ះបាន វាក៏មានឧបករណ៍បញ្ជាគ្រាប់ចុចដោយកាយវិញ្ញាញមួយ ដែលមានប៊ូតុង ដើម្បីធ្វើការជ្រើសរើស ។ អ្នកបោះឆ្នោតក៏អាចកែសម្រួលទំហំអក្សរពណ៌ និងភាពផ្ទុយគ្នារបស់អេក្រង់នៅលើអេក្រង់ ដើម្បីងាយស្រួលមើល ។ BMD នីមួយៗមានកាសស្តាប់សំឡេងដែលភ្ជាប់មកជាមួយ ដែលអាចឱ្យអ្នកបោះឆ្នោតកែសម្រួលល្បឿនអាន និងសំឡេងបាន ។ លើសពីនេះ អ្នកបោះឆ្នោតអាចជ្រើសរើស 13 ភាសា ដើម្បីស្តាប់ ឬអានការជ្រើសរើសសន្លឹកឆ្នោត ។ អ្នកបោះឆ្នោតដែលមានពិការភាពលែងត្រូវការបោះឆ្នោតលើឧបករណ៍ដាច់ដោយឡែក ប៉ុន្តែអាចបោះឆ្នោតលើឧបករណ៍តែមួយនៅក្នុងតំបន់តែមួយនៃមណ្ឌលបោះឆ្នោត ដូចអ្នកបោះឆ្នោតទាំងអស់ដែរ ។

រាល់ព័ត៌មានអំពីមធ្យោបាយងាយស្រួលដែលបានផ្តល់ជូនខាងលើរួមទាំងសេវាកម្មបន្ថែមដែលមានសម្រាប់អ្នកបោះឆ្នោតដែលជាជនពិការ (ឧទាហរណ៍ជំនួយដែលបានផ្តល់នៅមណ្ឌលបោះឆ្នោត សម្ភារៈបោះឆ្នោតដែលអាចចូលដំណើរការបាន ការបោះឆ្នោតតាមចិញ្ចើមថ្នល់) អាចរកបាននៅលើគេហទំព័ររបស់យើងនៅអាសយដ្ឋាន [www.lavote.net](http://www.lavote.net) ។

## 1-G កញ្ចប់ថវិកា និងប្រព័ន្ធផ្សព្វផ្សាយ

កញ្ចប់ថវិកា និងប្រព័ន្ធផ្សព្វផ្សាយរបស់ក្រសួងសម្រាប់ឆ្នាំសារពើពន្ធ 19-20 គឺ $7,492,000 ដែលរាប់បញ្ចូល $775,000 សម្រាប់ការផ្សាយពាណិជ្ជកម្មទូទៅ និង $6,717,000 សម្រាប់ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ និងការអប់រំនៅលើ VSAP និង VCA ។ តារាងទី 4 បង្ហាញពីការប្រៀបធៀបការចំណាយ ដែលចាប់ផ្តើមពីឆ្នាំសារពើពន្ធ 2015-2016 រហូតដល់ឆ្នាំ 2019-2020 ។

| តារាងទី 4 ៖ ការប្រៀបធៀបការចំណាយសម្រាប់ឆ្នាំសារពើពន្ធ | | | | | | |
|---|---|---|---|---|---|---|
| ឆ្នាំសារពើពន្ធ | ប្រព័ន្ធផ្សព្វផ្សាយ | | | ការផ្តល់សេវាសាធារណៈ | | |
| | ថវិកា | ការចំណាយ | វ៉ារ្យង់ | ថវិកា | ការចំណាយ | វ៉ារ្យង់ |
| ឆ្នាំសារពើពន្ធ 15-16 | $100,000 | $376,978 | $ (276,978) | $ 24,000 | $28,479 | $ (4,479) |
| ឆ្នាំសារពើពន្ធ 16-17 | $750,000 | $1,043,587 | $(293,587) | $42,000 | $20,907 | $21,096 |
| ឆ្នាំសារពើពន្ធ 17-18 | $850,000 | $488,656 | $361,344 | $25,000 | $29,773 | $(4,773) |
| ឆ្នាំសារពើពន្ធ 18-19 | $1,500,000 | $587,216 | $912,784 | $25,000 | $62,216 | $(37,216) |
| ឆ្នាំសារពើពន្ធ 19-20 | $7,467,000 | $360,269 | $7,106,731 | $25,000 | $1,001 | $23,999 |

## 1-H ការរំពឹងទុកពីការសន្សំលើចំណាយ

តាមការអនុញ្ញាតពីច្បាប់ VCA ខោនធីនឹងរៀបចំការបោះឆ្នោតបឋមជ្រើសរើសប្រធានាធិបតី នៅខែមីនា ឆ្នាំ 2020 ដោយប្រើប្រាស់គំរូមណ្ឌលបោះឆ្នោត ស្របតាមច្បាប់ VSAP ។ ខណៈពេល ដែលមានការរំពឹងទុកថា ការចំណាយពេលបោះឆ្នោតរបស់ខោនធីក្នុងការចុះឈ្មោះបោះឆ្នោតក្រោមច្បាប់ VCA អាចត្រូវបានកាត់បន្ថយ ដើមទុនឈានមុខ និងចំណាយប្រតិបត្តិការ ដើម្បីអនុវត្តទាំង VSAP និង VCA គឺពិតជាមានសារៈសំខាន់ ។ នេះមិនមែនជាការរំពឹងទុកទេ ជាមួយនឹងការផ្លាស់ប្តូរយ៉ាងច្រើនចំពោះបទពិសោធនៃការបោះឆ្នោតក្នុងយុត្តាធិការបោះឆ្នោតដែលធំ និងមានលក្ខណៈស្មុគស្មាញ ។ ការសន្សំរយៈពេលវែង គួរឱ្យកត់សម្គាល់អាចបណ្តាលមកពីការកាត់បន្ថយការងារ និងការផ្គត់ផ្គង់កម្លាំងពលកម្ម ដើម្បីបំពេញភារកិច្ចទាំងនេះ បើប្រៀបធៀបទៅនឹងការងារ ដែលបានផ្តល់បច្ចុប្បន្ន ។ លើសពីនេះទៀត ការសន្សំការចំណាយបន្ថែមអាចត្រូវបានដឹងតាមរយៈការកាត់បន្ថយចំនួនបុគ្គលិកបោះឆ្នោត និងទីតាំងបោះឆ្នោត ។ ក្រសួងនឹងបន្តចាត់ចែងការបោះឆ្នោតក្នុងនាមយុត្តាធិការ ដែលមានទីតាំងនៅក្នុងខោនធី ។ យុត្តាធិការដែលពង្រឹងការបោះឆ្នោតរបស់ពួកគេជាមួយខោនធីនឹងបន្តត្រូវបានទូទាត់តាមសមាមាត្រសម្រាប់ការចំណាយទាំងអស់ដែលអនុញ្ញាតដោយច្បាប់ ។វិធីសាស្រ្តទូទាត់ថ្មី ត្រូវបានបញ្ជូនទៅយុត្តាធិការទាំងអស់សម្រាប់គោលបំណងផែនការ និងថវិកា ។ ក្រសួង នឹងមានការយល់ដឹងកាន់តែប្រសើរអំពីការបង្កើនការសន្សំការចំណាយបន្ទាប់ពីការបោះឆ្នោតបឋមសិក្សាខែមីនាឆ្នាំ 2020 និងជាមួយការបោះឆ្នោតបន្ទាប់នីមួយៗ ។

វាគួរតែត្រូវបានគេកត់សម្គាល់ផងដែរថា ការកែលម្អបន្ថែមនៃការសន្សំការចំណាយសំខាន់ៗអាចត្រូវបានប៉ះពាល់យ៉ាងខ្លាំង ដោយសារតែការផ្លាស់ប្តូរសក្តានុពលនៃគំរូបោះឆ្នោតរបស់ខោនធីម្តងទៀត នៅឆ្នាំ 2024 ។ ក្រោម VCA ខោនធីអាចនឹងផ្លាស់ប្តូរទៅរកការបោះឆ្នោតសន្លឹកឆ្នោត VBM ទាំងអស់ក្រោមបទប្បញ្ញត្តិនៃលេខកូដ 4005 លើកលែងតែច្បាប់ VCA ត្រូវបានធ្វើវិសោធនកម្មមុនឆ្នាំ 2024 ។ ការផ្លាស់ប្តូរនេះនឹងតម្រូវឱ្យមានការផ្លាស់ប្តូរដ៏សំខាន់មួយផ្សេងទៀតសម្រាប់ក្រសួង ហើយនឹងប៉ះពាល់ដល់ការវិភាគបន្ថែមទៀតនៃការសន្សំការចំណាយសំខាន់ៗ ។

## 1-I សេចក្តីប្រកាសស្តីពីសេវាសាធារណៈ

### ខ្សែយពហុភាសា និងការស្តាប់ ឬការមើលឃើញ

ក្រសួងនឹងរៀបចំកម្មវិធី PSA ជាច្រើនដល់អ្នកបោះឆ្នោតខោនធីតាមរយៈវិទ្យុទូរទស្សន៍និងប្រព័ន្ធផ្សព្វផ្សាយបោះពុម្ព ដែលរួមមានអ្នកបោះឆ្នោតដែលថ្លង់ ឬពិបាកស្តាប់ ពិការភ្នែក ឬមើលមិនឃើញច្បាស់ ឬពលរដ្ឋដែលមិននិយាយភាសាអង់គ្លេស ឬចេះនិយាយភាសាអង់គ្លេសតិចតួច (មានជាភាសាដែលបានចែង និងកំណត់ទាំងអស់) ។ PSA របស់ក្រសួងនឹងរាប់បញ្ចូលព័ត៌មានស្តីពីការបោះឆ្នោតនាពេលខាងមុខ ជម្រើសបោះឆ្នោត សេវាកម្មភាពងាយស្រួលក្នុងការចូលទៅដល់ និងព័ត៌មានទំនាក់ទំនងតាមរយៈបណ្តាញទូរសព្ទជំនួយអ្នកបោះឆ្នោតឥតគិតថ្លៃ និងគេហទំព័រ ។ បណ្តាញទូរសព្ទឥតគិតថ្លៃគឺលេខ (800) 815-2666 ហើយគេហទំព័រគឺ LAvote.net ។

ខាងក្រោមនេះជាតំណភ្ជាប់ទៅនឹង PSA បច្ចុប្បន្នរបស់ក្រសួង ៖

ប្រព័ន្ធបោះឆ្នោត ៖ https://www.youtube.com/watch?v=H63nyzOoRHY

ជម្រើសបោះឆ្នោត ៖ https://www.youtube.com/watch?v=n6CYNdJMCXY

## 1-J ទំនាក់ទំនងដោយផ្ទាល់

បន្ថែមលើសន្លឹកឆ្នោតគំរូ និងសន្លឹកឆ្នោត VBM ក្រសួងនឹងទាក់ទងដោយផ្ទាល់ដល់អ្នកបោះឆ្នោត ដែលបានចុះឈ្មោះតាមរយៈទំនាក់ទំនងផ្សេងទៀតជាច្រើន រួមមានការផ្ញើសំបុត្រដោយផ្ទាល់ ការជូនដំណឹងតាមអ៊ីម៉ែល និងខលដោយស្វ័យប្រវត្តិ ។ ទំនាក់ទំនងដោយផ្ទាល់ (តិចបំផុតពីរនាក់) នឹងរាប់បញ្ចូលទាំងព័ត៌មានអំពី VCA និង VSAP ជម្រើសបោះឆ្នោត ព័ត៌មានបោះឆ្នោតសំខាន់ៗ និងព័ត៌មានទំនាក់ទំនងដូចជាបណ្តាញទូរសព្ទជំនួយបន្ទាន់ដល់អ្នកបោះឆ្នោតដោយឥតគិតថ្លៃតាមលេខ (800) 815-2666 និងគេហទំព័រ ។

លើសពីនេះ រាល់អ្នកបោះឆ្នោតដែលបានចុះឈ្មោះហើយដែលបានផ្តល់អ៊ីមែល និង/ ឬលេខទូរស័ព្ទរបស់ពួកគេនឹងទទួលបានការជូនដំណឹងយ៉ាងតិចចំនួនពីរ (2) លើកដែលមានព័ត៌មានអំពីវិធីដែលពួកគេអាចទទួលបាន និងប្រគល់សន្លឹកឆ្នោតបោះតាមសំបុត្រ វិធីដែលពួកគេអាចរកមណ្ឌលបោះឆ្នោត ឬទីតាំងទម្លាក់សន្លឹកឆ្នោតបោះតាមសំបុត្រ និងព័ត៌មានស្តីពីបទពិសោធន៍ថ្មីនៃការបោះឆ្នោតរបស់ខោនធី ។

# ផ្នែកទី 2 – មណ្ឌលបោះឆ្នោត និង បោះឆ្នោតតាមទីតាំងទម្លាក់សំបុត្រ

## 2-A គម្រោងកំណត់ទីតាំងមណ្ឌលបោះឆ្នោត

ការកំណត់ទីតាំងការិយាល័យបោះឆ្នោត ដែលសមស្របបំផុតតម្រូវឱ្យមានដំណើរការជំរុញទិន្នន័យយ៉ាងរឹងមាំ ដែលរួមបញ្ចូលតម្រូវការរបស់រដ្ឋ និងមូលដ្ឋានជាមួយស្ថានភាពសេដ្ឋកិច្ច និងសង្គមក្នុងតំបន់ខណៈពេល ដែលព្យាករណ៍ពីអាកប្បកិរិយា និងគំរូរបស់មនុស្ស ។ ក្រសួងបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុន PlaceWorks ដែលជាក្រុមហ៊ុនមួយដែលមានបទពិសោធន៍យ៉ាងទូលំទូលាយក្នុងការធ្វើផែនការ ការស្រាវជ្រាវ និងវិភាគបរិស្ថាន ដើម្បីអនុវត្តគម្រោងរៀបចំដាក់ទីតាំងមណ្ឌលបោះឆ្នោត (VCPP) ។ VCPP ត្រូវបានផ្តោតជុំវិញការវិភាគតម្រូវការដែលមានមូលដ្ឋានគ្រឹះ ដើម្បីធានាថា មណ្ឌលបោះឆ្នោត និងទីតាំងទម្លាក់ VBM ត្រូវបានចែកចាយដោយស្មើភាពគ្នានៅទូទាំងខោនធី ( សូមមើលឧបសម្ព័ន្ធអំពីរបាយការណ៍ VCPP លម្អិត – យុទ្ធសាស្ត្ររបស់មណ្ឌលបោះឆ្នោត ) ។

ខោនធី Los Angeles រួមមានទីក្រុងចំនួន 88 ដែលមានបញ្ចូល និងលាតសន្ធឹងលើផ្ទៃដី 4,100 ម៉ាយការ៉េ ។ ភាគច្រើននៃប្រជាជនជាង 10 លាននាក់រស់នៅខោនធីរស់នៅក្នុងទីក្រុង ដែលបានបញ្ចូលក្នុងសាជីវកម្ម និងប្រហែល 1 លាននាក់រស់នៅក្នុងតំបន់ ដែលមិនមានមិនបានបញ្ចូលក្នុងសាជីវកម្ម ។ ដើម្បីធានាថា សហគមន៍នៅទូទាំងខោនធីទទួលបានតំណាង ដែលមានភាពស្មើគ្នាក្នុងការដាក់មណ្ឌលបោះឆ្នោត និងដើម្បីពិនិត្យលក្ខខណ្ឌនៅកម្រិតកាន់តែច្រើន ខោនធីត្រូវបានបែងចែកទៅជាតំបន់សិក្សាផ្អែកលើសហគមន៍ ដែលក្រោយមកត្រូវបានបែងចែកដោយផ្តោតតាមតំបន់ ។ ការវិភាគបច្ចេកទេសទាំងអស់ត្រូវបានធ្វើឡើងនៅកម្រិតសិក្សា ។ តំបន់ផ្តោត ត្រូវបានប្រើ ដើម្បីកំណត់ការចែកចាយការប្រជុំសហគមន៍ ។ ព្រំប្រទល់ភូមិសាស្ត្រទាំងនេះត្រូវបានបង្កើតឡើង ដោយប្រើដំណើរការផ្អែកលើ GIS ដែលបានពិចារណាអំពីដែនសមត្ថកិច្ចដែលមានស្រាប់ ដូចជាស្រុកអ្នកត្រួតពិនិត្យព្រំដែនទីក្រុង និងតំបន់ផែនការខោនធីក៏ដូចជាដង់ស៊ីតេ និងការចែកចាយរបស់ប្រជាជន ។

ផ្នែកខាងក្រោមពន្យល់អំពីវិធីសាស្ត្រ ដែលត្រូវបានប្រើសម្រាប់ស្រទាប់នីមួយៗ ដែលត្រូវបានប្រើ ដើម្បីកំណត់តំបន់ ដែលមណ្ឌលបោះឆ្នោត គួរត្រូវបានរៀបចំ ។ រួមបញ្ចូលគ្នាស្រទាប់ទាំងនេះរាប់បញ្ចូលលក្ខខ័ណ្ឌ និងឧបសគ្គនានា ដែលជះឥទ្ធិពលដល់ឥរិយាបទអ្នកបោះឆ្នោតនៅទូទាំងសហគមន៍ប្លែកៗរបស់ខោនធី ។

## សហគមន៍ភូមិសាស្ត្រដាច់ស្រយាល

ដើម្បីធានាថា អ្នកបោះឆ្នោតទាំងអស់មានឱកាសស្មើភាពគ្នាក្នុងការបោះឆ្នោត ទីតាំងជិតៗមណ្ឌលបោះឆ្នោត ទៅតំបន់ភូមិសាស្ត្រដាច់ស្រយាលត្រូវបានពិចារណាយ៉ាងយកចិត្តទុកដាក់ ។ ដង់ស៊ីតេនៃអ្នកបោះឆ្នោត ដែលមានសិទ្ធិបោះឆ្នោតទាំងអស់នៅក្នុងសហគមន៍ដាច់ស្រយាល រួមទាំងអ្នកបោះឆ្នោត ដែលមិនបានចុះឈ្មោះត្រូវបានគូសវាសនៅទូទាំងខោនធី ។ តំបន់ទីក្រុង និងទីប្រជុំជនពីសហគមន៍ដាច់ស្រយាលទៅតំបន់ ដែលមានប្រជាជនច្រើននៃខោនធី ត្រូវបានគេបង្ហាញ និងប្រើនៅក្នុងការវិភាគតម្រូវការ ដើម្បីធានាបាននូវការចូលប្រើ ។ ទិន្នន័យផ្នែកផ្លូវពីក្រសួង ត្រូវបានប្រើប្រាស់រួមគ្នាជាមួយអ្នកមានសិទ្ធិបោះឆ្នោត ដែលបានពង្រីក ដើម្បីកំណត់ និងសម្គាល់សហគមន៍ដាច់ស្រយាល ។

## សហគមន៍ប្រាក់ចំណូលទាប

ក្រសួងប្តេជ្ញាចិត្ត ដើម្បីបំពេញតម្រូវការនៃភាពចម្រុះប្លែកៗពាសពេញខោនធី ជាពិសេសអ្នក ដែលត្រូវបានតំណាងជាប្រវត្តិសាស្ត្រនៅក្នុងដំណើរការប្រជាធិបតេយ្យ ។ ការទទួលបានការយល់ដឹងកាន់តែច្បាស់អំពីអាយុទាំងនេះ គឺមានសារៈសំខាន់ណាស់ នៅពេលកំណត់កន្លែងបោះឆ្នោត ដែលអាចចូលដំណើរការបានច្រើនបំផុត ។ ដើម្បីកំណត់កន្លែង ដែលមណ្ឌលបោះឆ្នោត អាចចូលដំណើរការបានច្រើនបំផុត ដើម្បីទទួលបានប្រាក់ចំណូលទាបក្រុមប្លុកជំរឿនត្រូវបានពិនិត្យឡើងវិញ និងរៀបចំផែនការ ដើម្បីកំណត់ភាគរយនៃចំនួនប្រជាជនរបស់ខោនធី ដែលជាកម្មសិទ្ធិរបស់ក្រុមគ្រួសារ ដែលមានប្រាក់ចំណូលទាប ។

## សហគមន៍និយាយភាសាអង់គ្លេសមានកម្រិត និងប្រើភាសាភាគតិច

ចំនួនប្រជាជន ដែលត្រូវបានគេចាត់ថ្នាក់ជាភាសាភាគតិចត្រូវបានគេគូសផែនទី ដើម្បីបង្ហាញសហគមន៍ដែលមានសមាមាត្រខ្ពស់នៃអ្នកនិយាយភាសាអង់គ្លេស ដែលមិនស្ទាត់ជំនាញ ។ ទិន្នន័យជំរឿនបង្ហាញពីចំនួនប្រជាជន ដែលមានអាយុចាប់ពី 5 ឆ្នាំឡើងទៅ ដែលនិយាយភាសាផ្សេងៗ និងនិយាយភាសាអង់គ្លេសបានល្អតិចតួច ត្រូវបានគេប្រើ ដើម្បីគណនាភាគរយ និងដង់ស៊ីតេក្នុងមួយហិកតានៃសហគមន៍ជនជាតិភាគតិច ។

## សហគមន៍ម្ចាស់យានយន្តទាប

ភាពជិតស្និទ្ធនឹងសហគមន៍ ដែលមានម្ចាស់យានយន្តទាបត្រូវបានគេវិភាគ ដើម្បីកំណត់ឧបសគ្គ ដែលអាចធ្វើឱ្យវាកាន់តែពិបាកក្នុងការចូលទៅកាន់មណ្ឌលបោះឆ្នោត ។ ការវិភាគតម្រូវការបានសិក្សាពីភាគរយនៃអង្គភាពលំនៅដ្ឋាន ដែលបានកាន់កាប់នៅក្នុងក្រុមធ្វើជំរឿននីមួយៗនៅក្នុងខោនធី ដោយគ្មានការចូលប្រើយានយន្ត ដែលបង្ហាញពីសហគមន៍ ដែលមានចំនួនប្រជាជនខ្ពស់ ដែលមិនមានយានជំនិះ ។

ទិន្នន័យជំរឿន ដែលបង្ហាញពីភាគរយនេះត្រូវបានប្រើ ដើម្បីគណនាភាគរយ និងដង់ស៊ីតេក្នុងមួយហិចតាក្នុងក្រុមប្លុក នីមួយៗខណៈក្រុមប្លុក ដែលគ្មានអង្គភាពលំនៅដ្ឋានកាន់កាប់មិនត្រូវបានគូសផែនទី ។

## មជ្ឈមណ្ឌលចំនួនប្រជាជនអ្នកបោះឆ្នោត

**3.3 កិច្ចប្រជុំសហគមន៍នៅទូទាំងខោនធី........ 32**
3.3.1 អង្គការដៃគូ........ 32
3.3.2 ការប្រើប្រាស់ភាសា........ 32
3.3.3 ការចូលរួមសហគមន៍នៅជុំទីមួយ ........ 35
3.3.4 ការចូលរួមសហគមន៍នៅជុំទីពីរ........ 38
3.3.5 លទ្ធផល ........ 38
**4.0 ការផ្តល់អនុសាសន៍នៃមណ្ឌលបោះឆ្នោតនៅខោនធី LOS ANGELES COUNTY........38**
**4.1 គំរូដែលបានផ្តល់អនុសាសន៍៖ លំនៅដ្ឋានជាប់នឹងកន្លែងធ្វើការ/កន្លែងធ្វើការ 38**
**4.2 ឧបសម្ព័ន្ធ I ការបោះឆ្នោតដែលបានផ្តល់អនុសាសន៍តាមទីតាំងបោះឆ្នោតផ្ញើតាមប្រៃសណីយ៍ ........ 40**
**4.3 ទីតាំងមណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍ ........ 41**
**4.4 វិធានការជ្រើសរើសមណ្ឌលបោះឆ្នោតនាពេលអនាគត ........ 56**


## APPENDICES


| | |
|---|---|
| **Appendix A** | Methodology for Vote Center Dimension |
| **Appendix B** | Methodology for Demand Analysis |
| **Appendix C** | VSAP Advisory Committee and Technical Advisory Committee |
| **Appendix D** | Key Findings for Focus Groups and Surveys |
| **Appendix E** | Partner Questionnaire and Invitation Letter-Round One |
| **Appendix F** | Partner Questionnaire and Invitation Letter-Round Two |
| **Appendix G** | Methodology for Language Access |
| **Appendix H** | Community Meetings Round One Outcomes |
| **Appendix I** | Recommended Vote by Mail Drop-off Locations |
| **Appendix J** | Recommended Vote Centers |
| **Appendix K** | Vote Center and Vote by Mail Drop-off Database- Metadata |

# 1.0 ច្បាប់ស្តីពីការជ្រើសរើសរបស់អ្នកបោះឆ្នោតរដ្ឋកាលីហ្វ័រញ៉ា CALIFORNIA (VCA)

ដើម្បីបង្កើនចំនួនអ្នកទៅបោះឆ្នោតនៅរដ្ឋកាលីហ្វ័រញ៉ា California នោះ រដ្ឋនេះកំពុងខិតខំប្រឹងប្រែងមិនធ្លាប់មានពីមុន ដើម្បីកំណត់ឡើងវិញនូវរបៀបដែលប្រជាពលរដ្ឋមានបទពិសោធន៍បោះឆ្នោត។ ដើម្បីបំពេញតម្រូវការតាមចំនួនប្រជាពលរដ្ឋដែលជាអ្នកបោះឆ្នោតមានសិទ្ធិស្របច្បាប់ដែលមានលក្ខណៈស្មុគស្មាញតាមភូមិសាស្ត្រនិងលក្ខណៈចម្រុះផ្សេងគ្នារបស់រដ្ឋកាលីហ្វ័រញ៉ា California នោះ រដ្ឋនេះបានទទួលស្គាល់ពីតម្រូវការដើម្បីផ្តល់ជូនបទពិសោធន៍ដែលអាចផ្លាស់ប្តូរបាននិងទំនើបថែមទៀត ដែលផ្តល់ជូនអ្នកបោះឆ្នោតនូវជម្រើសកាន់តែច្រើនថែមទៀតអំពីរបៀប ពេលវេលា និងទីកន្លែងដែលពួកគេបោះឆ្នោត។ ច្បាប់ស្តីពីការជ្រើសរើសរបស់អ្នកបោះឆ្នោតរដ្ឋកាលីហ្វ័រញ៉ា California (Senate Bill 450/VCA) បានបង្កើតឡើងដើម្បីសម្របសម្រួលដល់ការផ្លាស់ប្តូរនេះនៅទូទាំងរដ្ឋ។ ឯកសារនេះពិពណ៌នាអំពីវិធីសាស្ត្របើកការដ្ឋានរបស់ខោនធី Los Angeles County ក្នុងការអនុវត្តច្បាប់ VCA ដែលនឹងផ្លាស់ប្តូរបទពិសោធន៍របស់អ្នកបោះឆ្នោត ដែលបោះឆ្នោតរបស់ពួកគេសម្រាប់ការបោះឆ្នោតបឋមជ្រើសរើសប្រធានាធិបតីនៅឆ្នាំ 2020 ។

## 1.1 ទិដ្ឋភាពទូទៅ

ច្បាប់ស្តីពីការជ្រើសរើសរបស់អ្នកបោះឆ្នោតរដ្ឋកាលីហ្វ័រញ៉ា California (VCA) ផ្តល់ជូនគោលការណ៍ជាមូលដ្ឋានគ្រឹះសម្រាប់ខោនធីនានានៅទូទាំងរដ្ឋនេះ ដើម្បីអភិវឌ្ឍប្រព័ន្ធបោះឆ្នោតទំនើបដែលបង្កើនបទពិសោធន៍បោះឆ្នោតតាមរយៈការផ្តល់ជូនភាពអាចបត់បែនបាននិងភាពងាយស្រួលកាន់តែច្រើនឡើង។ ធាតុសំខាន់ៗដែលចាំបាច់ ដើម្បីផ្តល់ជូនបទពិសោធន៍ថ្មីៗសម្រាប់ខោនធី Los Angeles County រួមមាន៖

- ការបោះឆ្នោតតាមទីកន្លែងបោះឆ្នោតដែលផ្ញើតាមប្រៃសណីយ៍ អាចមានដំណើរការ 29 ថ្ងៃ មុនថ្ងៃបោះឆ្នោត។
- បង្កើនការបោះឆ្នោតដោយផ្ទាល់ជាមុន ដូច្នេះការស្ទង់មតិត្រូវបើកដំណើរការរយៈពេល 10 ថ្ងៃ មុនថ្ងៃបោះឆ្នោត។
- អនុញ្ញាតឱ្យអ្នកបោះឆ្នោត ដើម្បីបោះឆ្នោតនៅទីតាំងមណ្ឌលបោះឆ្នោតណាមួយនៅខោនធីនៃទីលំនៅរបស់ពួកគេ។

ដើម្បីអនុវត្តគំរូបោះឆ្នោតថ្មីដោយជោគជ័យនោះ យុត្តាធិការនៅទូទាំងរដ្ឋដែលត្រូវការចាំបាច់ ត្រូវគិតពិចារណាដោយប្រុងប្រយ័ត្នអំពីលក្ខខណ្ឌនិងដំណើរការដែលមានស្រាប់របស់ពួកគេ ជាពិសេសបញ្ហាទាក់ទងនឹងបច្ចេកវិទ្យាបោះឆ្នោត ឧបសគ្គថវិកា ទីកន្លែងបោះឆ្នោត និងការចូលរួមរបស់សហគមន៍។ ដើម្បីឆ្លើយតបទៅនឹងការគិតពិចារណាទាំងនេះ ខោនធី Los Angeles County បានបង្កើតវិធីសាស្ត្រប្រកបដោយច្នៃប្រឌិតក្នុងការអភិវឌ្ឍបទពិសោធន៍អ្នកបោះឆ្នោតថ្មី ដែលរួមបញ្ចូលវិធីសាស្ត្របោះឆ្នោតទំនើប ដើម្បីធ្វើការផ្លាស់ប្តូររបៀបដែលប្រជាពលរដ្ឋបោះឆ្នោត។

## 1.2 ដំណោះស្រាយបោះឆ្នោតសម្រាប់ប្រជាពលរដ្ឋទាំងអស់

ដើម្បីអនុវត្តច្បាប់ស្តីពីការជ្រើសរើសរបស់អ្នកបោះឆ្នោតរដ្ឋកាលីហ្វ័រញ៉ា California នៅខោនធី Los Angeles County, អ្នកចុះឈ្មោះ - អ្នកកត់ត្រា/ស្មៀនខោនធី Los Angeles (RR/CC) បានអនុវត្តគំនិតផ្តួចផ្តើមមួយប្រភេទដែលគេស្គាល់ថា ជាដំណោះស្រាយបោះឆ្នោតសម្រាប់ប្រជាពលរដ្ឋទាំងអស់ (VSAP) ។ ការខិតខំប្រឹងប្រែងនេះ ធ្វើឱ្យអ្នកបោះឆ្នោតខោនធី Los Angeles County នៅមណ្ឌលនេះ មានបទពិសោធន៍បោះឆ្នោតដែលងាយស្រួល អាចចូលប្រើបាន និងមានសុវត្ថិភាព។

ក្រុមការងារគម្រោង VSAP បានទទួលការណែនាំពីអង្គការមិនស្វែងរកប្រាក់ចំណេញ អ្នកជំនាញសិក្សា អ្នកបោះឆ្នោតដែលបានចុះឈ្មោះនិងអ្នកមានសិទ្ធិបោះឆ្នោត និងអ្នកពិគ្រោះយោបល់ផ្នែកឯកជន។ តាមរយៈការប្រើប្រាស់រួមបញ្ចូលគ្នានៃក្រុមអ្នកផ្តល់យោបល់ ការស្ទង់មតិ ក្រុមចាប់អារម្មណ៍ និងការវិភាគបច្ចេកទេសនោះ អ្នកចុះឈ្មោះឬអ្នកកត់ត្រា/ស្មៀនខោនធី RR/CC បានកំណត់ការវិនិច្ឆ័យជាគំរូដែលដឹកនាំដំណើរការស្មុគស្មាញនៃការបង្កើតប្រព័ន្ធបោះឆ្នោតថ្មីមួយ ដែលបំពេញតាមតម្រូវការទាមទាររបស់រដ្ឋនិងមូលដ្ឋាន ឆ្លើយតបនឹងតម្រូវការរបស់អ្នកបោះឆ្នោត និងធានាបានការទុកចិត្តពីសាធារណជន។

### 1.2.1 បទពិសោធន៍អ្នកបោះឆ្នោតថ្មីនៅខោនធី Los Angeles County

ខោនធី Los Angeles County បានចូលរួមជាមួយសាធារណជនចាប់តាំងពីការចាប់ផ្តើមគម្រោងដែលចាប់ផ្តើមដំណើរការរៀបចំផ្តោតសំខាន់លើប្រជាពលរដ្ឋ ដែលអនុញ្ញាតឱ្យអ្នកបោះឆ្នោតដែលមានប្រវត្តិខុសគ្នា និងត្រូវការផ្តល់មតិយោបល់ដែលអាចប្រើប្រាស់ដើម្បីជូនដំណឹងអំពីចំណុចសំខាន់ៗដែលរៀបចំតាមបច្ចេកវិទ្យាជាក់លាក់សម្រាប់ឧបករណ៍គូសសម្គាល់សន្លឹកឆ្នោតថ្មី។ ការចូលរួមជាសាធារណៈបានបន្តដំណើរការនៅទូទាំងគម្រោង ដើម្បីជួយកំណត់ទីតាំងមណ្ឌលបោះឆ្នោតដែលមានសក្តានុពល និងបានចូលរួមចំណែកក្នុងការអភិវឌ្ឍបទពិសោធន៍អ្នកបោះឆ្នោតថ្មីដែលគួរឱ្យរំភើបចិត្ត។

*ឧបករណ៍គូសសម្គាល់សន្លឹកឆ្នោត*

ឧបករណ៍គូសសម្គាល់សន្លឹកឆ្នោត (BMD) គឺជាវិធីសាស្ត្រដែលអភិវឌ្ឍថ្មីឡើងវិញសម្រាប់ការចាប់សន្លឹកឆ្នោតដែលជំនួសប្រព័ន្ធ InkaVote។ ឧបករណ៍នេះមានការបង្ហាញអេក្រង់ចុចដែលអាចលៃតម្រូវបានទំនើប ដើម្បីផ្តល់ជូនសន្លឹកឆ្នោតដែលងាយស្រួលប្រើ។ សន្លឹកឆ្នោតអាចអានឬស្តាប់ 13 ភាសា កាសស្តាប់នឹងត្រចៀក ដែលផ្តល់ជូនបទពិសោធន៍បោះឆ្នោតផ្ទាល់ខ្លួន និងអាចចូលដំណើរការបានសម្រាប់លោកអ្នកទាំងអស់។ លក្ខណៈពិសេសដែលអាចប្រើបាន ដើម្បីផ្តល់ជូនបទពិសោធន៍បោះឆ្នោតឯករាជ្យ រួមមានសមត្ថភាពកែតម្រូវទំហំអក្សរ ពណ៌ និងកម្រិតពណ៌ និងល្បឿនអេក្រង់ ហើយប្រអប់ឆ្នោតដែលរួមបញ្ចូលគ្នា ការពារសិទ្ធិឯកជនភាពរបស់អ្នកបោះឆ្នោត។ ឧបករណ៍ BMD ជាឧបករណ៍ដែលដាក់បញ្ឈរតែឯង ដែលមិនភ្ជាប់អ៊ីនធឺណិត ឬបណ្តាញផ្សេងទៀត។ បន្ទាប់ពីការចូលក្នុងការជ្រើសរើសបោះឆ្នោតនោះ ឧបករណ៍ BMD ព្រីនឬបោះពុម្ពសន្លឹកឆ្នោតដែលអាចផ្ទៀងផ្ទាត់ជាក់ស្តែងដោយអ្នកបោះឆ្នោតមុនពេលបោះឆ្នោត។ សន្លឹកឆ្នោតនេះ ត្រូវបានរក្សាទុកក្នុងប្រអប់ឆ្នោតដែលរួមបញ្ចូលគ្នានៅក្នុងឧបករណ៍នេះ។ ឧបករណ៍នេះលុបចោលជំហានបន្ថែមនៅក្នុងដំណើរការនៃការទម្លាក់សន្លឹកឆ្នោតនៅក្នុងប្រអប់ឆ្នោតកណ្តាលដាច់ដោយឡែកពីឧបករណ៍ BMD ។

*សន្លឹកឆ្នោតគំរូដែលផ្លាស់ប្តូរព័ត៌មានតាមកុំព្យូទ័រ*

អ្នកបោះឆ្នោតមានជម្រើសក្នុងការពិនិត្យមើល និងគូសលើសន្លឹកឆ្នោតគំរូរបស់ពួកគេនៅលើឧបករណ៍ចល័ត ឬកុំព្យូទ័រ—នៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលា។ សន្លឹកឆ្នោតគំរូដែលផ្លាស់ប្តូរព័ត៌មានតាមកុំព្យូទ័រ (ISB) បង្កើតប័ណ្ណបោះឆ្នោត (Poll Pass) នៅពេលមានការជ្រើសរើសត្រូវបានធ្វើឡើង។ ប័ណ្ណបោះឆ្នោត Poll Pass អាចព្រីនឬបោះពុម្ពឬរក្សាទុកនៅក្នុងឧបករណ៍ចល័ត ដើម្បីជួយបង្កើនល្បឿនដំណើរការបោះឆ្នោតនៅនឹងកន្លែងនៅមណ្ឌលបោះឆ្នោត។ ឧបករណ៍ BMD មានកម្មវិធីអានលេខកូដ QR ដែលមានភ្ជាប់មកជាមួយ ដែលអនុញ្ញាតឱ្យអ្នកបោះឆ្នោតស្កេនប័ណ្ណបោះឆ្នោត Poll Pass និងនាំចូលទៅការជ្រើសរើសសន្លឹកឆ្នោត។ បន្ទាប់មកអ្នកបោះឆ្នោតអាចផ្ទៀងផ្ទាត់ ឬធ្វើការផ្លាស់ប្តូរចំពោះការជ្រើសរើសរបស់ពួកគេមុនពេលបោះឆ្នោតរបស់ពួកគេ។

*សៀវភៅបោះឆ្នោតអេឡិចត្រូនិក*

សៀវភៅបោះឆ្នោតអេឡិចត្រូនិក នឹងអនុញ្ញាតឱ្យអ្នកបោះឆ្នោតអាចបោះឆ្នោតរបស់ពួកគេនៅទីតាំងមណ្ឌលបោះឆ្នោតណាមួយនៅខោនធី Los Angeles County ។ សៀវភៅបោះឆ្នោតអេឡិចត្រូនិក ជំនួសឱ្យបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលបានព្រីនឬបោះពុម្ពដែលប្រើប្រាស់ដោយបុគ្គលិកមណ្ឌលបោះឆ្នោត ដើម្បីផ្ទៀងផ្ទាត់ភាពមានសិទ្ធិស្របច្បាប់នៃការចុះបញ្ជីឈ្មោះអ្នកបោះឆ្នោតតាមពេលវេលាជាក់ស្តែង។ សៀវភៅបោះឆ្នោតអេឡិចត្រូនិក នឹងបង្ហាញ ប្រសិនបើអ្នកបោះឆ្នោតម្នាក់បានបោះឆ្នោតរួចហើយនៅកន្លែងណាមួយនៅខោនធី ដើម្បីហាមឃាត់ការបោះឆ្នោតនៅទីតាំងជាច្រើនទៀត។ ឧបករណ៍នេះនឹងអនុញ្ញាតឱ្យមានការចុះបញ្ជីឈ្មោះអ្នកបោះឆ្នោតដោយមានលក្ខខណ្ឌដែលនឹងអនុញ្ញាតឱ្យបុគ្គលម្នាក់ចុះឈ្មោះបោះឆ្នោត និងបោះឆ្នោតនៅថ្ងៃតែមួយ។

*ការបោះឆ្នោតដែលធ្វើឱ្យប្រសើរឡើងដោយការបោះឆ្នោតផ្ញើតាមប្រៃសណីយ៍*

សន្លឹកឆ្នោតដែលរៀបចំថ្មីឡើងវិញ និងពេញមុខ ដែលបានចាប់ផ្តើមនៅខែវិច្ឆិកា ឆ្នាំ 2018 បង្ហាញពុម្ពអក្សរធំជាងនិងការណែនាំកាន់តែច្បាស់ ដើម្បីបង្កើនភាពងាយស្រួលនិងភាពអាចចូលដំណើរការបានក្នុងការបោះឆ្នោតតាមដំណើរការបោះឆ្នោតផ្ញើតាមប្រៃសណីយ៍ (VBM)។ អ្នកបោះឆ្នោតខោនធី Los Angeles County អាចផ្ញើតាមប្រៃសណីយ៍ជាសន្លឹកឆ្នោត VBM ដោយមិនតម្រូវឱ្យមានថ្លៃតែមឡើយ។ អ្នកបោះឆ្នោតអាចទម្លាក់សន្លឹកឆ្នោតរបស់ពួកគេនៅឯប្រអប់បោះឆ្នោត VBM ណាមួយនៅទីតាំងដែលងាយស្រួលនៅទូទាំងខោនធី ដែលមានរយៈពេល 29 ថ្ងៃមុនថ្ងៃបោះឆ្នោតផងដែរ។ សន្លឹកឆ្នោត VBM នឹងត្រូវទទួលយកនៅទីតាំងមណ្ឌលបោះឆ្នោតណាមួយនៅអំឡុងពេលបោះឆ្នោត។

*រយៈពេលបោះឆ្នោតដែលពន្យាពេលបន្ត*

មណ្ឌលបោះឆ្នោតនឹងអាចមានរយៈពេល 10 ថ្ងៃបន្ថែមទៀតមុនថ្ងៃបោះឆ្នោត ដែលអនុញ្ញាតឱ្យអ្នកបោះឆ្នោតមានពីរសប្តាហ៍ ដើម្បីបោះឆ្នោតនៅទីតាំងមណ្ឌលបោះឆ្នោតណាមួយនៅខោនធី LA County។ មណ្ឌលបោះឆ្នោតនឹងត្រូវបើកដំណើរការរយៈពេលអប្បបរមា 8 ម៉ោងក្នុងមួយថ្ងៃ។ ឱកាសបន្ថែមទៀតមានមណ្ឌលបោះឆ្នោតចល័ត និងលេចចេញជាចាំបាច់ ដើម្បីជួយអ្នកបោះឆ្នោតនៅអំឡុងពេលបោះឆ្នោតដែលពន្យាពេល។

*ទីតាំងមណ្ឌលបោះឆ្នោត*

មណ្ឌលបោះឆ្នោតជំនួសកន្លែងបោះឆ្នោត ដូច្នេះអ្នកបោះឆ្នោតមិនត្រូវបានកំណត់កន្លែងបោះឆ្នោត ដែលមានរៀបចំនៅជិតផ្ទះរបស់ពួកគេទៀតទេ។ គំរូមណ្ឌលបោះឆ្នោតបង្កើនភាពអាចបត់បែនបានដោយអនុញ្ញាតឱ្យអ្នកបោះឆ្នោត អាចបោះឆ្នោតបាននៅកន្លែងដែលពួកគេរស់នៅ ធ្វើការ សិក្សា ទិញទំនិញ ឬលេង រហូតដល់ 10 ថ្ងៃមុនថ្ងៃបោះឆ្នោត។ មណ្ឌលបោះឆ្នោតនឹងមានទីតាំងយ៉ាងងាយស្រួលទៅតាមប្រភេទអគារផ្សេងៗគ្នា ដូចជាមជ្ឈមណ្ឌលលក់ទំនិញ មជ្ឈមណ្ឌលការងារ សាលារៀន សិល្បៈសហគមន៍ និងមជ្ឈមណ្ឌលវប្បធម៌ កន្លែងកម្សាន្ត អគាររដ្ឋ និងកន្លែងគោរពបូជា។

## 1.3 តម្រូវការទាមទារសម្រាប់មណ្ឌលបោះឆ្នោត

កិច្ចខិតខំប្រឹងប្រែងច្នៃប្រឌិតថ្មីៗទ្រង់ទ្រាយធំមួយ ដែលមានឥទ្ធិពលដល់កម្រិតនិងគុណភាពនៃការចូលរួមរបស់ប្រជាពលរដ្ឋនៅទូទាំងរដ្ឋ អំពាវនាវឱ្យមានគោលការណ៍ណែនាំដែលបង្កើតស្តង់ដារគុណភាព ដើម្បីធានាបាននូវការប្រគល់ជូនបទពិសោធន៍អ្នកបោះឆ្នោតដែលចង់បាន។ តម្រូវការទាមទារច្បាប់ VCA នេះ ជួយសម្រួលដល់បទពិសោធន៍ដែលរៀបចំនៅកម្រិតរដ្ឋ និងបទពិសោធន៍ផ្ទាល់ខ្លួននៅថ្នាក់តំបន់។ ដើម្បីសម្រេចគោលដៅនេះ ច្បាប់ស្តីពីការជ្រើសរើសរបស់អ្នកបោះឆ្នោត បានបង្កើតឡើងតាមតម្រូវការទាមទារជាក់លាក់សម្រាប់យុត្តាធិការនានាដោយផ្អែកលើដង់ស៊ីតេប្រជាជន។ តម្រូវការទាមទារខាងក្រោមនេះ អនុវត្តចំពោះខោនធី Los Angeles County

### 1.3.1 តម្រូវការទាមទារច្បាប់ស្តីពីការជ្រើសរើសរបស់អ្នកបោះឆ្នោតសម្រាប់ខោនធី LA County

**ការបោះឆ្នោតផ្ញើតាមប្រៃសណីយ៍**

ច្បាប់ VCA ទទួលស្គាល់ថាសន្លឹកឆ្នោត VBM និងទីតាំងបោះឆ្នោត មានសារៈសំខាន់ណាស់ក្នុងការផ្តល់ជូនលទ្ធភាពកាន់តែច្រើនដល់អ្នកបោះឆ្នោត ជាពិសេសអ្នកដែលរស់នៅតាមទីជនបទ ដែលធ្វើដំណើរញឹកញាប់ និងអ្នកដែលធ្វើការនៅតាមបណ្តាខោនធីផ្សេងទៀត។ ច្បាប់ VCA លើកកម្ពស់បទពិសោធន៍នៃការបោះឆ្នោតផ្ញើតាមប្រៃសណីយ៍

ដោយតម្រូវឱ្យមាន៖

- អ្នកបោះឆ្នោតដែលបានចុះឈ្មោះទាំងអស់ នឹងទទួលបានការបោះឆ្នោតតាមសន្លឹកឆ្នោតផ្ញើតាមប្រៃសណីយ៍ (VBM) នៅត្រឹមឆ្នាំ 2024 ។ នៅពេលនោះអ្នកបោះឆ្នោតដែលស្នាក់នៅក្នុងតំបន់ដែលមានរយៈពេលធ្វើដំណើរលើសពី 30 នាទីពីមណ្ឌលបោះឆ្នោតឬកន្លែងបោះឆ្នោតកាលពីមុនរបស់ពួកគេដែលមានចម្ងាយ 15 ម៉ាយពីមណ្ឌលបោះឆ្នោត ត្រូវទទួលបានការបោះឆ្នោតតាម VBM ផ្ញើតាមប្រៃសណីយ៍។
- អ្នកបោះឆ្នោតទាំងអស់ដែលរស់នៅមណ្ឌលនីតិបញ្ញត្តិឬសភាដែលស្ថិតនៅផ្នែកខ្លះនៃខោនធី County of LA ហើយដែលស្ថិតនៅក្នុងខោនធីផ្សេងទៀតផងដែរ ដែលកំពុងធ្វើការបោះឆ្នោតនោះ ត្រូវទទួលបានការបោះឆ្នោតផ្ញើតាមប្រៃសណីយ៍។
- ទីតាំងបោះឆ្នោតមួយមានប្រអប់បោះឆ្នោតដែលមានសុវត្ថិភាព អាចចូលដំណើរការបាន និងមានចាក់សោ ដែលស្ថិតជិតបំផុតតាមដែលអាចមានផ្លូវធ្វើដំណើរសាធារណៈដែលបានរៀបចំឡើង។
- ទីតាំងបោះឆ្នោតមានចំនួនតិចបំផុតពីរកន្លែងក្នុងដែនសមត្ថកិច្ចមួយ ឬ
- ទីតាំងបោះឆ្នោតមានចំនួនតិចបំផុតមួយសម្រាប់រាល់អ្នកចុះឈ្មោះបោះឆ្នោត VBM អចិន្ត្រៃយ៍ចំនួន 15,000 នាក់ក្នុងដែនសមត្ថកិច្ចមួយ។
- ទីតាំងបោះឆ្នោតនៅតែបើកដំណើរការយ៉ាងហោចណាស់នៅពេលម៉ោងធ្វើការធម្មតា ដែលចាប់ផ្តើមមិនតិចជាង 28 ថ្ងៃមុន និងរាប់បញ្ចូលទាំងថ្ងៃបោះឆ្នោតផងដែរ។
- យ៉ាងហោចណាស់មានទីតាំងបោះឆ្នោតមួយកន្លែង ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចមួយ ត្រូវមានប្រអប់ឆ្នោតផ្នែកខាងក្រៅដែលអាចចូលដំណើរការបាននិងមានសុវត្ថិភាព ដែលមានរយៈពេលយ៉ាងតិច 12 ម៉ោងក្នុងមួយថ្ងៃ រួមទាំងម៉ោងធ្វើការធម្មតាផងដែរ។

**ការចូលប្រើមណ្ឌលបោះឆ្នោត**

ភាពខុសគ្នានៃភូមិសាស្ត្រ ដង់ស៊ីតេប្រជាជន និងការធ្វើចរាចរណ៍ប្រចាំថ្ងៃរបស់ Angelenos បង្កើតឱ្យមានតម្រូវការខ្ពស់សម្រាប់ទីតាំងបោះឆ្នោតច្រើនជាងខោនធីផ្សេងទៀតនៃរដ្ឋកាលីហ្វ័រញ៉ា California counties។ ច្បាប់ VCA ជួយសម្របសម្រួលដល់ការកើនឡើងនូវតម្រូវការមណ្ឌលបោះឆ្នោតដោយបង្កើតតាមតម្រូវការទាមទារដោយផ្អែកលើប្រជាពលរដ្ឋ។ តម្រូវការទាមទារដែលត្រូវអនុវត្តនៅខោនធី Los Angeles County រួមមាន៖

- មណ្ឌលបោះឆ្នោតមានទីតាំងដែលមានរយៈពេលធ្វើដំណើរសមរម្យសម្រាប់អ្នកបោះឆ្នោតដែលបានចុះឈ្មោះ។
- ត្រូវមានមណ្ឌលបោះឆ្នោតមួយយ៉ាងតិច ត្រូវផ្តល់ជូនដល់ទីក្រុងនីមួយៗ ដែលមានអ្នកបោះឆ្នោតដែលបានចុះឈ្មោះយ៉ាងតិច 1,000 នាក់។
- ត្រូវមានមណ្ឌលបោះឆ្នោតមួយយ៉ាងតិច ត្រូវផ្តល់ជូនសម្រាប់រាល់អ្នកបោះឆ្នោតដែលបានចុះឈ្មោះចំនួន 7,500 នាក់ នៅថ្ងៃបោះឆ្នោត និងបីថ្ងៃមុន។
- ត្រូវមានមណ្ឌលបោះឆ្នោតមួយយ៉ាងតិច ត្រូវផ្តល់ជូនសម្រាប់រាល់អ្នកបោះឆ្នោតដែលបានចុះឈ្មោះចំនួន 30,000 នាក់ ដែលចាប់ផ្តើមដប់ថ្ងៃមុនការបោះឆ្នោត។

ច្បាប់ VCA ផ្តល់ការណែនាំដើម្បីធានាថាមណ្ឌលបោះឆ្នោតត្រូវបែងចែកដោយស្មើភាពគ្នានៅទូទាំងខោនធី និងមានឧបករណ៍បោះឆ្នោតដែលអាចចូលដំណើរការបានសម្រាប់បុគ្គលដែលមានមានពិការភាព។ តម្រូវការទាមទារអប្បបរមាដែលត្រូវគិតពិចារណានៅពេលកំណត់កន្លែង ដើម្បីរកទីតាំងមណ្ឌលបោះឆ្នោត រួមមាន៖

- នៅជិតមធ្យោបាយធ្វើដំណើរសាធារណៈ
- នៅជិតមជ្ឈមណ្ឌលប្រជាពលរដ្ឋ
- នៅជិតសហគមន៍ដែលមានប្រាក់ចំណូលទាប
- ចំណតយានយន្តដែលអាចប្រើបាន និងឥតគិតថ្លៃ
- ចម្ងាយនិងពេលវេលាដែលអ្នកបោះឆ្នោតម្នាក់ ត្រូវធ្វើដំណើរដោយរថយន្ត ឬតាមមធ្យោបាយសាធារណៈ

### 1.3.2 តម្រូវការទាមទារប្រតិបត្តិការនៅខោនធី Los Angeles County

បន្ថែមលើតម្រូវការទាមទាររបស់រដ្ឋ ខោនធី Los Angeles County បានបង្កើតលក្ខណៈវិនិច្ឆ័យមណ្ឌលបោះឆ្នោតបន្ថែមដើលទាក់ទងនឹងទំហំអគារ តម្រូវការថាមពល ការតភ្ជាប់បណ្តាញ ភាពអាចប្រើបានតាមច្បាប់ ADA, លទ្ធភាពទទួលបានភាសា និងការដាក់បញ្ចូលសហគមន៍ដាច់ស្រយាល។ លក្ខណៈវិនិច្ឆ័យទាំងនេះ បានអនុវត្តដោយកម្មវិធី PlaceWorks ដើម្បីផ្តល់អាទិភាពដល់ទីតាំងមណ្ឌលបោះឆ្នោតដែលមានសក្តានុពល និងកំណត់អគារដែលមិនមានតម្រូវការទាមទារចាំបាច់។ ផ្នែកខាងក្រោមនៃរបាយការណ៍នេះ ពិពណ៌នាអំពីវិធីដែលរដ្ឋនិងតម្រូវការប្រតិបត្តិទាំងនេះ បានអនុវត្តនៅពេលជ្រើសរើសទីតាំងមណ្ឌលបោះឆ្នោតដែលមានសក្តានុពល។

## 2.0 គម្រោងកំណត់ទីតាំងមណ្ឌលបោះឆ្នោត

ខោនធី Los Angeles County នឹងផ្លាស់ប្តូរបទពិសោធន៍អ្នកបោះឆ្នោតដោយជំនួសកន្លែងបោះឆ្នោតដោយមណ្ឌលបោះឆ្នោតដែលជម្រុញឱ្យមានជម្រើសដែលអាចផ្លាស់ប្តូរបាន ដោយចាប់ផ្តើមនៅការបោះឆ្នោតបឋមជ្រើសរើសប្រធានាធិបតីឆ្នាំ 2020 ។ ដើម្បីសម្រេចគោលដៅនេះ អ្នកចុះឈ្មោះ - អ្នកកត់ត្រា/ស្មៀនខោនធី Los Angeles County (RR/CC) បានសហការជាមួយកម្មវិធី PlaceWorks ដើម្បីធ្វើការវិភាគភូមិសាស្រ្ត វាយតម្លៃទីតាំង និងការចូលរួមសហគមន៍។ កិច្ចសហការនេះបានដឹកនាំកិច្ចខិតខំប្រឹងប្រែងក្នុងការជ្រើសរើសទីតាំងមណ្ឌលបោះឆ្នោតដែលអាចសម្រេចបានយ៉ាងច្រើនបំផុត ដើម្បីបំពេញតាមតម្រូវការទាមទាររបស់រដ្ឋនិងមូលដ្ឋាន នៅខណៈពេលបំពេញសេចក្តីត្រូវការអ្នកបោះឆ្នោតដែលបញ្ហាស្មុគស្មាញ។

## 2.1 លក្ខណៈមណ្ឌលបោះឆ្នោតនៅខោនធី LOS ANGELES COUNTY

មានហួសពីតម្រូវការទាមទារ និងការគិតពិចារណាអំពីច្បាប់ VCA នោះ ខោនធី Los Angeles County បានបង្កើតតម្រូវការទាមទារនិងស្តង់ដារបន្ថែម ដែលលើកកម្ពស់គុណភាពមណ្ឌលបោះឆ្នោតតាមរយៈការបង្កើតបទពិសោធន៍ដែលធ្វើតាមតម្រូវការសម្រាប់អ្នកបោះឆ្នោតខោនធី Los Angeles County ។

ខោនធី Los Angeles County ព្យាយាមលើកទឹកចិត្តដល់ការចូលរួមរបស់ពលរដ្ឋក្នុងចំណោមអ្នកដែលមានសមត្ថភាពខាងរាងកាយឬយល់ដឹងមានកម្រិត ហើយទទួលស្គាល់ថាអគារនៃមណ្ឌលបោះឆ្នោតត្រូវតែមានលទ្ធភាពសម្របសម្រួលដល់អ្នកបោះឆ្នោតទាំងនេះ។ ដើម្បីសម្រេចគោលដៅនេះ RR/CC បានអនុម័តនូវតម្រូវការទាមទារតាមច្បាប់ស្តីពីជនជាតិអាមេរិកមានពិការភាព (ADA) ដូចខាងក្រោម ដើម្បីកំណត់អគារដែលសមស្រប៖

- ផ្លូវធ្វើដំណើរដែលអាចប្រើប្រាស់បានតាមច្បាប់ ADA ពីការធ្វើដំណើរតាមដងផ្លូវ/ផ្លូវឆ្លងកាត់សាធារណៈ ឬចំណតយានយន្តដែលមាននៅទ្វារខាងមុខ
- ចំណតយានយន្តដែលកំណត់ដោយច្បាប់ ADA នៅនឹងកន្លែង
- ទ្វារចេញចូលមានទទឹងទំហំ 32 អ៊ីញ
- គ្មានឧបសគ្គនៅខាងក្នុង ដែលរារាំងការប្រើប្រាស់កៅអីរុញជនពិការ

Figure 1. ប្លង់មណ្ឌលបោះឆ្នោតគំរូដែលមានទំហំធំ




**ទំហំនិងសមាសធាតុផ្សំនៃអគារ**

ទំហំនិងប្រភេទអគារដែលល្អបំផុតសម្រាប់បំពេញតាមតម្រូវការអ្នកបោះឆ្នោត នឹងមានខុសគ្នាទៅតាមតំបន់ភូមិសាស្រ្ត និងដង់ស៊ីតេប្រជាជន ប៉ុន្តែចំណុចទាំងអស់នេះនឹងមានលក្ខណៈរួមមួយចំនួន។ មណ្ឌលបោះឆ្នោតទាំងអស់ នឹងមានកន្លែងផ្សេងគ្នាចំនួនប្រាំមួយ៖

- ការឈរជាជួររបស់អ្នកបោះឆ្នោត/កន្លែងឈរបន្តជាជួរ
- កន្លែងចុះឈ្មោះបោះឆ្នោត
- កន្លែងឧបករណ៍គូសសម្គាល់សន្លឹកឆ្នោត
- ការបោះឆ្នោតតាមកន្លែងដែលផ្ញើតាមប្រៃសណីយ៍

ដោយផ្អែកលើតម្រូវការចំនួនប្រជាជននិងភាពអាចមានអគារនៅតាមតំបន់ភូមិសាស្រ្តនីមួយៗនោះ មណ្ឌលបោះឆ្នោតអាចចាត់ទុកថាមានទំហំតូច មធ្យម ឬធំ ដែលសំដៅទៅលើសមត្ថភាពឧបករណ៍គូសសម្គាល់សន្លឹកឆ្នោត (BMDs) និងសៀវភៅបោះឆ្នោតអេឡិចត្រូនិកនិងតម្រូវការទំហំដែលទាក់ទងនឹងអគារនៃមណ្ឌលបោះឆ្នោត។ តារាង 1 បង្ហាញពីការកំណត់ទំហំដែលបានប្រើដោយអ្នកស្រាវជ្រាវគម្រោង ដើម្បីកំណត់ថាតើកន្លែងមួយមានទំហំធំល្មម ដើម្បីសម្របសម្រួលដល់ចំនួនប្រជាជនបោះឆ្នោតនៅដែនសមត្ថកិច្ចមួយ។ រូបភាព 1 បង្ហាញពីប្លង់គំរូសម្រាប់មណ្ឌលបោះឆ្នោតធំ។ សូមមើលឧបសម្ព័ន្ធ A សម្រាប់វិធីសាស្រ្តនៃទំហំបន្ទប់ពេញលេញ។

Table 1. ច្រកទ្វារចេញចូលមណ្ឌលបោះឆ្នោត

| ទំហំមណ្ឌលបោះឆ្នោត | ទំហំហ្វីតការ៉េដែលត្រូវការ | ឧបករណ៍ BMDs បានដំណើរការ |
|---|---|---|
| **តូច** | **<1,999** | **<10** |
| **តូច/មធ្យម** | **2,000-2,449** | **10** |
| **មធ្យម** | **2,450-3,849** | **30** |
| **ធំ** | **>3,850** | **50** |

អ្នកចុះឈ្មោះឬអ្នកកត់ត្រា/ស្មៀនខោនធី RR/CC បានប្រើប្រាស់តម្រូវការទាមទារនិងការគិតពិចារណារបស់រដ្ឋនិងប្រតិបត្តិការទាំងនេះ ដើម្បីធ្វើការវិភាគទិន្នន័យស្មុគស្មាញដែលនាំឱ្យមានរង្វាស់ដែលអាចកំណត់បរិមាណបានដែលអគារនានាអាចវាយតម្លៃនិងជ្រើសរើសជាមណ្ឌលបោះឆ្នោតដែលមានសក្តានុពល។

## 2.2 ការវិភាគអំពីតម្រូវការ

ការកំណត់ទីតាំងមណ្ឌលបោះឆ្នោតដែលសមស្របបំផុត តម្រូវឱ្យមានដំណើរការទិន្នន័យដែលរឹងមាំ ដែលរួមបញ្ចូលតម្រូវការទាមទាររបស់រដ្ឋនិងមូលដ្ឋាន ដោយមានលក្ខខណ្ឌសេដ្ឋកិច្ចសង្គមនិងទំហំអគារនៅមូលដ្ឋាននៅខណៈពេលព្យាករណ៍ពីអាកប្បកិរិយានិងគំរូរបស់ប្រជាពលរដ្ឋ។ គម្រោងកំណត់ទីតាំងមណ្ឌលបោះឆ្នោត (VCPP) បានផ្តោតសំខាន់លើ

ការវិភាគពីតម្រូវការដែលផ្អែកលើទំហំអគារជុំវិញ ដើម្បីធានាថាមណ្ឌលបោះឆ្នោតនិងការបោះឆ្នោតតាមទីតាំងបោះឆ្នោតផ្ញើតាមប្រៃសណីយ៍ត្រូវបានបែងចែកដោយស្មើភាពគ្នានៅទូទាំងខោនធី។

### 2.2.1 **តំបន់សិក្សានិងផ្តោតសំខាន់**

ខោនធី Los Angeles County មានទីក្រុងចំនួន 88 និងមានផ្ទៃដីដែលមិនរួមបញ្ចូលគ្នាជាង 2,600 ម៉ាយការ៉េ។ ភាគច្រើននៃប្រជាពលរដ្ឋចំនួន 10 លាននាក់នៅខោនធីនេះរស់នៅក្នុងទីក្រុងដែលរួមបញ្ចូលគ្នា ហើយមានប្រជាពលរដ្ឋប្រមាណ 1 លាននាក់រស់នៅក្នុងតំបន់ដែលមិនរួមបញ្ចូលគ្នា។ ដើម្បីធានាថាសហគមន៍នានានៅទូទាំងខោនធីទទួលបានក្រុមអ្នកតំណាងដែលមានភាពស្មើគ្នាក្នុងការកំណត់ទីតាំងមណ្ឌលបោះឆ្នោត និងដើម្បីពិនិត្យមើលលក្ខខណ្ឌតាមកម្រិតដែលមានកាន់តែច្រើននោះ ខោនធីនេះត្រូវបានបែងចែកទៅជាតំបន់សិក្សាផ្អែកលើសហគមន៍ដែលក្រោយមកបានដាក់ជាតំបន់ផ្តោតសំខាន់ប្រចាំតំបន់។ ការវិភាគបច្ចេកទេសទាំងអស់ត្រូវបានធ្វើឡើងតាមកម្រិតតំបន់សិក្សា តំបន់ផ្តោតសំខាន់ត្រូវបានប្រើដើម្បីកំណត់ការបែងចែកដែលស្មើភាពគ្នានៃកិច្ចប្រជុំសហគមន៍។

ព្រំប្រទល់ភូមិសាស្ត្រទាំងនេះ បានបង្កើតឡើងដោយប្រើដំណើរការផ្អែកលើប្រព័ន្ធ GIS ដែលបានគិតពិចារណាអំពីដែនសមត្ថកិច្ចដែលមានស្រាប់ ដូចជាមណ្ឌលត្រួតពិនិត្យ ព្រំប្រទល់ទីក្រុង និងតំបន់ផែនការខោនធី ក៏ដូចជាដង់ស៊ីតេនិងការបែងចែកចំនួនប្រជាជនផងដែរ។ តំបន់សិក្សាសរុបចំនួន 189 ត្រូវបានកំណត់ពីដើមដំបូង ប៉ុន្តែក្រោយមកសហគមន៍ដែលមិនបានរួមបញ្ចូលគ្នាមួយបានលុបចោល ដោយសារការបញ្ចូលទៅក្នុងទីក្រុង Santa Clarita ដែលនាំមកនូវតំបន់សិក្សាចុងក្រោយសរុបដល់ 188 ។ ព្រំប្រទល់តំបន់សិក្សា ត្រូវបានបង្ហាញនៅលើរូបភាព 3 ។

*វិធីសាស្ត្រ*

ដំណើរការនៃការកំណត់តំបន់សិក្សា បានចាប់ផ្តើមដោយការកំណត់ទីក្រុងដែលបានរួមបញ្ចូលគ្នាទៅក្នុងតំបន់សិក្សាតែមួយ។ ទីក្រុងដែលមានប្រជាជនជាង 150,000 នាក់ ត្រូវបានបែងចែកជាពីរតំបន់សិក្សាឬតំបន់សិក្សាច្រើនជាងនេះ ដើម្បីបង្កើតការបែងចែកចំនួនប្រជាជនកាន់តែច្រើនថែមទៀតក្នុងចំណោមតំបន់សិក្សា។ ទីក្រុងធំៗនីមួយៗត្រូវបានបម្រុងទុកតំបន់សិក្សាមួយចំនួនដោយផ្អែកលើចំនួនប្រជាជនសរុបរបស់ពួកគេ៖

- City of Los Angeles: 43 តំបន់សិក្សា
- City of Long Beach: 5 តំបន់សិក្សា
- City of Glendale: 2 តំបន់សិក្សា
- City of Santa Clarita: 2 តំបន់សិក្សា
- City of Lancaster: 2 តំបន់សិក្សា
- City of Palmdale: 2 តំបន់សិក្សា
- City of Pomona: 2 តំបន់សិក្សា
- City of Torrance: 2 តំបន់សិក្សា
- City of Pasadena: 2 តំបន់សិក្សា

តំបន់សិក្សាសម្រាប់សហគមន៍ដែលមិនរួមបញ្ចូលគ្នានៅក្នុងខោនធី ត្រូវបានបង្កើតឡើងដោយផ្អែកលើដង់ស៊ីតេប្រជាជន និងទីតាំងភូមិសាស្ត្រ។ តំបន់ដែលមិនរួមបញ្ចូលគ្នានីមួយៗ ត្រូវបានដោះស្រាយដូចខាងក្រោម៖

- សហគមន៍ដាច់ស្រយាលតាមភូមិសាស្ត្រដែលមានចំនួនប្រជាជនតិច ត្រូវបានបន្ថែមទៅនឹងតំបន់សិក្សានៃទីក្រុងដែលនៅជិតបំផុត។
- មណ្ឌល និង/ឬ សហគមន៍ដាច់ស្រយាលតាមភូមិសាស្ត្រដែលមានចំនួនប្រជាជនច្រើន បានក្លាយជាតំបន់សិក្សាដោយឡែក។ សហគមន៍ណាមួយក្នុងចំណោមសហគមន៍ទាំងនេះ ដែលមានប្រជាជនច្រើនជាង 150,000 នាក់ ត្រូវបានបែងចែកជាតំបន់សិក្សាចំនួនពីរ ដូចជាទីក្រុងធំៗ។
- សហគមន៍ជាប់គ្នាតាមភូមិសាស្ត្រដែលមានចំនួនប្រជាជនតិច ត្រូវបានចែកជាក្រុម ដោយយោងតាមឈ្មោះសហគមន៍ និងភូមិសាស្ត្រ ការបែងចែកចំនួនប្រជាជន និងតំបន់ស្ថិតិ។
- តំបន់សិក្សានីមួយៗ ត្រូវបានកំណត់លេខអត្តសញ្ញាណពិសេសមួយដែលបង្ហាញនៅក្នុងតារាង 2 ។

Figure 2. វិធីសាស្ត្រសម្រាប់តំបន់សិក្សា



Figure 3. តំបន់សិក្សាទូទាំងខោនធី ខាងជើង



Figure 4. តំបន់សិក្សាទូទាំងខោនធី ខាងត្បូង



Table 2. ចំណុចសំខាន់ៗនៃផែនទីតំបន់សិក្សា

| លេខសម្គាល់ ID # | ឈ្មោះតំបន់សិក្សា |
|---|---|
| **1** | City of Hidden Hills |
| **2** | City of Rolling Hills |
| **3** | City of Vernon / Uninc. Vernon |
| **4** | Unincorporated Covina - San Dimas |
| **5** | Unincorporated Covina Islands |
| **6** | Unincorporated Leona Valley-Lake Hughes |
| **7** | City of Bradbury / Uninc. Bradbury |
| **8** | City of San Marino |
| **9** | Unincorporated Acton/ Uninc. South Antelope Valley |
| **10** | Unincorporated Agua Dulce - Angeles National Forest- Canyon Country |
| **11** | Unincorporated Charter Oak Islands |
| **12** | Unincorporated Compton |
| **13** | Unincorporated Del Aire |
| **14** | Unincorporated La Crescenta - Montrose |
| **15** | Unincorporated Lennox |
| **16** | Unincorporated Malibu |
| **17** | Unincorporated Northeast Antelope Valley |
| **18** | Unincorporated Northwest Antelope Valley |
| **19** | Unincorporated Quartz Hill -Lancaster |
| **20** | Unincorporated San Jose Hills |
| **21** | Unincorporated Walnut Park |
| **22** | Unincorporated West Athens-Westmont |
| **23** | Unincorporated West Carson |
| **24** | Unincorporated West Rancho Dominguez |
| **25** | City of Industry |
| **26** | City of LA - Bel Air - Beverly Crest/ Uninc. Hollywood Hills |
| **27** | City of La Puente |
| **28** | City of Temple City |

| លេខសម្គាល់ ID # | ឈ្មោះតំបន់សិក្សា |
|---|---|
| **29** | Unincorporated Angeles National Forest |
| **30** | Unincorporated East Los Angeles - Southeast |
| **31** | Unincorporated East Rancho Dominguez |
| **32** | Unincorporated East San Gabriel - Arcadia |
| **33** | Unincorporated Monrovia |
| **34** | Unincorporated Hawthorne - Alondra Park |
| **35** | Unincorporated Lake Los Angeles - Pearblossom - Liano - Valyermo |
| **36** | Unincorporated Littlerock |
| **37** | Unincorporated San Pasqual - East Pasadena |
| **38** | Unincorporated Santa Monica Mountains - Triunfo Canyon |
| **39** | Unincorporated Valinda |
| **40** | City of Artesia |
| **41** | City of Hawaiian Gardens |
| **42** | City of La Habra Heights |
| **43** | City of LA - Harbor Gateway |
| **44** | City of LA - Van Nuys - North Sherman Oaks |
| **45** | City of LA - Westwood / Unincorporated Sawtelle VA Center |
| **46** | City of Palos Verdes Estates |
| **47** | Unincorporated Altadena |
| **48** | Unincorporated Ladera Heights / View Park - Windsor Hills |
| **49** | Unincorporated Stevenson - Newhall Ranch |
| **50** | Unincorporated Bassett - West Puente Valley |
| **51** | Unincorporated Pellissier Village - Avocado Heights |
| **52** | Unincorporated Sunrise Village - South San Gabriel - Whittier Narrows |
| **53** | City of Avalon - Channel Islands North |
| **54** | City of Baldwin Park |
| **55** | City of Commerce |
| **56** | City of Cudahy |
| **57** | City of Irwindale |

| លេខសម្គាល់ ID # | ឈ្មោះតំបន់សិក្សា |
|---|---|
| **58** | City of LA - Canoga Park - Winnetka |
| **59** | City of LA - Central City North |
| **60** | City of LA - Northridge |
| **61** | City of LA - Valley Glen - North Sherman Oaks |
| **62** | City of Lomita |
| **63** | Unincorporated Marina del Rey |
| **64** | Unincorporated Topanga Canyon - Topanga |
| **65** | Unincorporated West Whittier - Los Nietos |
| **66** | City of La Canada Flintridge |
| **67** | City of LA - Westchester - Playa del Rey - Los Angeles International Airport |
| **68** | City of LA - Wilshire - Koreatown |
| **69** | City of Lancaster - Eastside |
| **70** | Unincorporated East Los Angeles - Northwest |
| **71** | City of Bell |
| **72** | City of Huntington Park |
| **73** | City of LA - Granada Hills - Knollwood |
| **74** | City of Lawndale |
| **75** | City of Malibu |
| **76** | City of Maywood |
| **77** | City of Monrovia |
| **78** | City of South El Monte/ Uninc. El Monte - Whittier Narrows |
| **79** | City of Westlake Village |
| **80** | Unincorporated Florence-Firestone |
| **81** | City of Agoura Hills |
| **82** | City of Alhambra |
| **83** | City of LA - Baldwin Hills - Leimert - Hyde Park |
| **84** | City of LA - Sherman Oaks - Studio City - Toluca Lake - Cahuenga Pass / Uninc. Universal City |
| **85** | City of LA - West Los Angeles |
| **86** | City of Rolling Hills Estates / Unincorporated Westfield |

| លេខសម្គាល់ ID # | ឈ្មោះតំបន់សិក្សា |
|---|---|
| **87** | City of San Fernando |
| **88** | City of South Gate |
| **89** | City of South Pasadena |
| **90** | City of West Hollywood |
| **91** | Unincorporated Castaic |
| **92** | Unincorporated Rowland Heights |
| **93** | City of Covina |
| **94** | City of LA - North Hollywood - Valley Village |
| **95** | City of LA - Reseda - West Van Nuys |
| **96** | City of LA - Sylmar |
| **97** | City of Long Beach Central |
| **98** | City of Rosemead |
| **99** | Unincorporated - Hacienda Heights - Whittier |
| **100** | City of Bellflower |
| **101** | City of Calabasas |
| **102** | City of Gardena |
| **103** | City of LA - Hollywood - North |
| **104** | City of LA - Hollywood - South |
| **105** | City of LA - Palms - Mar Vista - Del Rey |
| **106** | City of LA - Venice |
| **107** | City of LA - West Adams |
| **108** | City of LA - Wilshire - West |
| **109** | City of Lynwood - Uninc. Lynwood |
| **110** | City of Pico Rivera |
| **111** | City of San Gabriel |
| **112** | City of Sierra Madre |
| **113** | Unincorporated Willowbrook |
| **114** | City of Bell Gardens |
| **115** | City of El Monte |

| លេខសម្គាល់ ID # | ឈ្មោះតំបន់សិក្សា |
|---|---|
| **116** | City of Inglewood |
| **117** | City of LA - Arleta - Pacoima |
| **118** | City of LA - Central City |
| **119** | City of LA - South Los Angeles |
| **120** | City of LA - Sun Valley - La Tuna Canyon |
| **121** | City of LA - Wilmington - Harbor City / City of LA Port of Los Angeles |
| **122** | City of Lancaster - Westside |
| **123** | City of Long Beach North |
| **124** | City of Palmdale - Eastside / Uninc. South Antelope Valley |
| **125** | City of Palmdale - Westside |
| **126** | City of Santa Fe Springs |
| **127** | Unincorporated Azusa |
| **128** | City of Hermosa Beach |
| **129** | City of LA - Brentwood - Pacific Palisades |
| **130** | City of LA - Mission Hills - Panorama City - North Hills |
| **131** | City of Montebello |
| **132** | City of Pasadena - Eastside / Uninc. Kinneloa Mesa |
| **133** | City of Walnut |
| **134** | Unincorporated South Whittier - East La Mirada |
| **135** | City of LA - Boyle Heights |
| **136** | City of LA - Encino - Tarzana |
| **137** | City of La Mirada |
| **138** | City of LA - Silver Lake - Echo Park - Elysian Valley |
| **139** | City of LA - Sunland - Tujunga - Lake View Terrace - Shadow Hills |
| **140** | City of Paramount |
| **141** | City of Signal Hill |
| **142** | City of Compton |
| **143** | City of Duarte |
| **144** | City of Glendora / Unincorporated Glendora |

| លេខសម្គាល់ ID # | ឈ្មោះតំបន់សិក្សា |
|---|---|
| **145** | City of Hawthorne |
| **146** | City of LA - West Hills - Woodland Hills \ Uninc. Canoga Park - West Hills |
| **147** | City of LA - Westlake |
| **148** | City of Monterey Park |
| **149** | City of Norwalk |
| **150** | City of Pomona - Southside |
| **151** | Santa Clarita - South |
| **152** | City of LA - Chatsworth - Porter Ranch / Uninc. Northridge - Canoga Park - Oat Mtn. |
| **153** | City of Lakewood / Unincorporated Lakewood |
| **154** | City of Long Beach West |
| **155** | City of Pomona - Northside |
| **156** | City of San Dimas / Unincorporated San Dimas |
| **157** | City of Diamond Bar |
| **158** | City of El Segundo |
| **159** | City of La Verne / Unincorporated La Verne - Claremont |
| **160** | City of West Covina |
| **161** | City of Carson |
| **162** | City of Downey |
| **163** | City of LA - Southeast Los Angeles |
| **164** | City of LA - Exposition Park - University Park - Vermont Square |
| **165** | City of Long Beach East / Unincorporated Long Beach |
| **166** | City of Arcadia |
| **167** | City of Beverly Hills |
| **168** | City of Glendale - Southside |
| **169** | City of LA - Southeast Los Angeles - North |
| **170** | City of Rancho Palos Verdes |
| **171** | City of Claremont / Unincorporated Claremont |
| **172** | City of Culver City |
| **173** | City of Pasadena - Westside |

| លេខសម្គាល់ ID # | ឈ្មោះតំបន់សិក្សា |
|---|---|
| **174** | City of Torrance - North |
| **175** | City of Azusa |
| **176** | City of Burbank |
| **177** | City of LA - Northeast Los Angeles - South |
| **178** | City of Manhattan Beach |
| **179** | Santa Clarita - North |
| **180** | City of Glendale - Northside |
| **181** | City of Torrance - South |
| **182** | City of Santa Monica |
| **183** | City of LA - Northeast Los Angeles - North |
| **184** | City of Cerritos \ Unincorporated Cerritos |
| **185** | City of LA - San Pedro - LA Port of Los Angeles - Uninc. La Rambla |
| **186** | City of Redondo Beach |
| **187** | City of Whittier |
| **188** | City of Long Beach South |

### 2.2.2 **មូលដ្ឋានទិន្នន័យ**

បន្ទាប់ពីបង្កើតតំបន់សិក្សាមូលដ្ឋានទិន្នន័យសំខាន់ៗ ត្រូវបានអនុវត្តដើម្បីកំណត់ទីតាំងមណ្ឌលបោះឆ្នោតសម្រាប់ការបោះឆ្នោតឆ្នាំ 2020 ត្រូវមានទីតាំងតាមគោលការណ៍ណែនាំខាងក្រោមតាមច្បាប់ VCA និងតម្រូវការបន្ថែមដែលបានបង្កើតឡើងដោយបុគ្គលិកបោះឆ្នោតខោនធី។ ដោយសារមូលដ្ឋានទិន្នន័យទូលំទូលាយ តម្រូវឱ្យមានទាំងនៅថ្នាក់រដ្ឋនិងមូលដ្ឋាននោះ វាមានសារៈសំខាន់ណាស់ដែលទិន្នន័យដែលបានប្រើប្រាស់នៅក្នុងការវិភាគនីមួយៗអាចមានភាពត្រឹមត្រូវ និងទាន់សម័យបំផុត។ ទិន្នន័យដែលបានទទួលពីប្រភពជាក់លាក់ដោយមានការដាក់បញ្ចូលរបស់គណៈកម្មាធិការផ្តល់យោបល់ផ្នែកបច្ចេកទេស VSAP ងគណៈកម្មាធិការផ្តល់យោបល់ដែលផ្តល់ជូនការចូលប្រើមូលដ្ឋានទិន្នន័យបច្ចុប្បន្នយ៉ាងទូលំទូលាយ។

មូលដ្ឋានទិន្នន័យនីមួយៗតម្រូវឱ្យមានប្រភពទិន្នន័យផ្សេងៗគ្នានិងវិធីសាស្ត្រពិសេសក្នុងការវិភាគ។ ការវិភាគនេះបានជួយអ្នកស្រាវជ្រាវពិនិត្យមើលទំនាក់ទំនងរវាងសេដ្ឋកិច្ចសង្គម លំនៅដ្ឋានជាប់នឹងកន្លែងធ្វើការ/កន្លែងធ្វើការ អ្នកបោះឆ្នោត និងកត្តាមធ្យោបាយធ្វើដំណើរ។ គោលដៅនៃការពិនិត្យមើលមូលដ្ឋានទិន្នន័យដែលបានជ្រើសរើសគឺដើម្បីកំណត់អត្តសញ្ញាណវត្តមាននិងការបែងចែកភូមិសាស្ត្រតាមលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ VCA និងតម្រូវការទាមទារនៅមូលដ្ឋាន។ ការគិតពិចារណាលើទិន្នន័យត្រូវបានបង្ហាញនៅក្នុងតារាង 3 និង 4។ ការពិពណ៌នាលម្អិតអំពីវិធីសាស្ត្រ អាចរកឃើញនៅក្នុងឧបសម្ព័ន្ធ B។

Table 3. មូលដ្ឋានទិន្នន័យដែលតម្រូវឱ្យមានតាមច្បាប់ VCA

| ការគិតពិចារណាអំពីមណ្ឌលបោះឆ្នោតដែលត្រូវការអប្បបរមា និងការកំណត់ទីតាំងបោះឆ្នោតក្រោមច្បាប់ VCA |
|---|
| • នៅជិតមធ្យោបាយធ្វើដំណើរសាធារណៈ |
| • ចម្ងាយនិងពេលវេលា ដើម្បីទៅដល់មណ្ឌលបោះឆ្នោត VC/ប្រអប់សន្លឹកបោះឆ្នោត ដោយរថយន្ត/ការធ្វើដំណើរឆ្លងកាត់សាធារណៈ |
| • ការបង្ហាញឱ្យឃើញថាការធ្វើចរាចរណ៍តាមផ្លូវណានៅជិតមណ្ឌលបោះឆ្នោត VC និងប្រអប់ឆ្នោត |
| • នៅជិតមជ្ឈមណ្ឌលប្រជាពលរដ្ឋ |
| • នៅជិតប្រជាពលរដ្ឋដាច់ស្រយាលតាមភូមិសាស្ត្រ |
| • នៅជិតសហគមន៍ដែលមានប្រាក់ចំណូលទាប |
| • នៅជិតអ្នកបោះឆ្នោតដែលមានពិការភាព |
| • នៅជិតសហគមន៍ដែលប្រើភាសាជនជាតិភាគតិច |
| • នៅជិតសហគមន៍ដែលមានកម្មសិទ្ធិយានយន្តកម្រិតទាប |
| • នៅជិតអ្នកមានសិទ្ធិបោះឆ្នោតដែលមិនបានចុះឈ្មោះ |
| • នៅជិតសហគមន៍ដែលមានការបោះឆ្នោតជាប្រវត្តិសាស្ត្រកម្រិតទាបតាមការបោះឆ្នោតផ្ញើតាមប្រៃសណីយ៍ |

Table 4. ការគិតពិចារណាអំពីទិន្នន័យនៅខោនធី Los Angeles County បន្ថែម

| ការគិតពិចារណាអំពីទិន្នន័យបន្ថែម |
|---|
| • នៅជិតមជ្ឈមណ្ឌលការងារ |
| • នៅជិតកន្លែងដែលមានដង់ស៊ីតេអ្នកបោះឆ្នោតខ្ពស់ |
| • នៅជិតសកម្មភាពអតិថិជន |
| • នៅជិតកន្លែងជិះយានយន្តដែលមានសកម្មភាពរួមគ្នា |
| • នៅជិតប្រជាពលរដ្ឋវ័យក្មេង (អាយុ 18 ដល់ 24 ឆ្នាំ) |
| • នៅជិតសង្កាត់ដែលអាចដើរបាន |
| • នៅជិតចំណតយានយន្តដែលអាចប្រើបានដោយឥតគិតថ្លៃ/បញ្ចុះតម្លៃ |
| • នៅជិតនឹងឧបសគ្គដែលគេដឹង (បញ្ហាខ្លាំងនៃការប៉ះទង្គិចរាងកាយ កង់ និងអ្នកថ្មើរជើង) |
| • សកម្មភាពតំបន់ប្រភពដើម/គោលដៅ |

ផ្នែកខាងក្រោមពន្យល់អំពីវិធីសាស្ត្រដែលបានប្រើប្រាស់សម្រាប់មូលដ្ឋានទិន្នន័យនីមួយៗដែលបានប្រើប្រាស់ ដើម្បីកំណត់កន្លែងដែលមណ្ឌលបោះឆ្នោត ត្រូវដាក់នៅទីនោះ។ ដោយរួមបញ្ចូលមូលដ្ឋានទិន្នន័យទាំងនេះ ផ្តល់ព័ត៌មានល្អិតអំពីលក្ខខណ្ឌនិងឧបសគ្គនានាដែលមានឥទ្ធិពលដល់គំរិយាបទអ្នកបោះឆ្នោតនៅទូទាំងសហគមន៍ចម្រុះនៃខោនធី Los Angeles County ។

**លក្ខណៈវិនិច្ឆ័យសេដ្ឋកិច្ចសង្គម**

*សហគមន៍ដាច់ស្រយាលតាមភូមិសាស្ត្រ*

ដើម្បីធានាថាអ្នកបោះឆ្នោតទាំងអស់មានឱកាសស្មើភាពគ្នាក្នុងការបោះឆ្នោតនោះ ត្រូវបានគិតពិចារណាយ៉ាងយកចិត្តទុកដាក់អំពីភាពនៅជិតមណ្ឌលបោះឆ្នោតសម្រាប់ប្រជាពលរដ្ឋដែលនៅដាច់ស្រយាលតាមភូមិសាស្ត្រ។ ដង់ស៊ីតេអ្នកមានសិទ្ធិបោះឆ្នោតទាំងអស់នៅក្នុងសហគមន៍ដែលនៅដាច់ស្រយាល ដែលរួមទាំងអ្នកមានសិទ្ធិបោះឆ្នោតដែលមិនបានចុះឈ្មោះ ត្រូវបានរៀបចំផែនទីនៅទូទាំងខោនធីផងដែរ។ តំបន់ទីក្រុងនិងចម្ងាយពីសហគមន៍ដែលដាច់ស្រយាលទៅតំបន់ដែលមានប្រជាពលរដ្ឋច្រើននៅខោនធី ត្រូវបានបង្ហាញនិងបានប្រើនៅក្នុងការវិភាគអំពីតម្រូវការ ដើម្បីធានាបាននូវការចូលប្រើ។ ទិន្នន័យតាមចំណែកផ្លូវពីអ្នកចុះឈ្មោះឬអ្នកកត់ត្រា/ស្មៀនខោនធី RR/CC ត្រូវបានប្រើប្រាស់រួមគ្នាជាមួយប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត ដើម្បីកំណត់និងដោះស្រាយសហគមន៍ដែលដាច់ស្រយាល។

*សហគមន៍ដាច់ស្រយាល*ត្រូវបានកំណត់ថាជាចំណែកផ្លូវដែលបំពេញតាមតម្រូវការដូចតទៅ៖

- មានអ្នកមានសិទ្ធិបោះឆ្នោត 1 នាក់ ឬច្រើននាក់
- មានចម្ងាយឆ្ងាយជាង 2 ម៉ាយពីផ្លូវហាយវេណាមួយ
- មានចម្ងាយឆ្ងាយជាង 2 ម៉ាយពី "តំបន់ទីក្រុង" ដូចដែលបានកំណត់នៅក្នុងជំរឿនប្រជាជនឆ្នាំ 2010

ទីកន្លែងដែលមានចម្ងាយ 0.25 ម៉ាយ ត្រូវបានប្រើនៅជុំវិញចំណែកផ្លូវដែលបានបំពេញតាមលក្ខណៈវិនិច្ឆ័យនេះ ដែលបានបង្កើតកន្លែងផ្សេងគ្នាជាច្រើន។ ការបែងចែកអ្នកមានសិទ្ធិបោះឆ្នោតនិងដង់ស៊ីតេអ្នកបោះឆ្នោតសរុបសម្រាប់កន្លែងនីមួយៗ ត្រូវបានគណនា។ ចម្ងាយពីសហគមន៍ដាច់ស្រយាល ត្រូវបានកំណត់ជាក្រុមដែលមានចម្ងាយពី 0.25 ដល់ 1 ម៉ាយ, 1 ដល់ 5 ម៉ាយ, 5 ដល់ 10 ម៉ាយ, និងច្រើនជាង 10 ម៉ាយ។ ចម្ងាយទាំងនេះ ត្រូវបានប្រើប្រាស់ ដើម្បីជូនដំណឹងដល់ការគិតពិចារណាពិសេស ដើម្បីធានាដល់ការចូលប្រើបានសម្រាប់អ្នកបោះឆ្នោតដែលជួបប្រទះឧបសគ្គភូមិសាស្ត្រក្នុងការបោះឆ្នោត។

*សហគមន៍ដែលមានប្រាក់ចំណូលទាប*

អ្នកចុះឈ្មោះឬអ្នកកត់ត្រា/ស្មៀនខោនធី RR/CC ប្តេជ្ញាចិត្តបំពេញតាមតម្រូវការរបស់ប្រជាជនផ្សេងៗគ្នានៅទូទាំងខោនធី Los Angeles County ជាពិសេសអ្នកដែលត្រូវបានផ្តល់ជូនក្រុមអ្នកតំណាងមិនគ្រប់គ្រាន់នៅក្នុងដំណើរការប្រជាធិបតេយ្យជាប្រវត្តិសាស្ត្រ។ ការទទួលបានការយល់ដឹងកាន់តែប្រសើរឡើងអំពីចំនួនប្រជាជនទាំងនេះ មានសារៈសំខាន់ណាស់នៅពេលកំណត់ទីតាំងមណ្ឌលបោះឆ្នោតដែលអាចប្រើបានច្រើនបំផុត។

ដើម្បីកំណត់កន្លែងណ្ឌលបោះឆ្នោតអាចប្រើបានច្រើនបំផុតសម្រាប់ប្រជាជនដែលមានប្រាក់ចំណូលទាបនោះ ក្រុមប្លុកជំរឿនប្រជាជនត្រូវបានពិនិត្យឡើងវិញនិងរៀបចំផែនការដើម្បីកំណត់ភាគរយនៃចំនួនប្រជាជនរបស់ខោនធី ដែលក្រុមគ្រួសារមានប្រាក់ចំណូលទាប។ យោងតាមក្រសួងអភិវឌ្ឍលំនៅដ្ឋាននិងទីក្រុង (HUD) គឺថា*ក្រុមគ្រួសារដែលមានប្រាក់ចំណូលទាប*ត្រូវបានកំណត់ថាជាក្រុមគ្រួសារដែលមានប្រាក់ចំណូលមិនលើសពី 80 ភាគរយនៃប្រាក់ចំណូលគ្រួសារមធ្យម ដែលមានចំនួនទឹកប្រាក់ $64,300 ដុល្លារសម្រាប់ខោនធី Los Angeles County ។ ទិន្នន័យប្រជាពលរដ្ឋដែលមានប្រាក់ចំណូលទាបសរុប ដែលផ្តល់ជូនដោយក្រសួង HUD និងទិន្នន័យជំរឿនប្រជាជនសរុប ត្រូវបានប្រើប្រាស់ដើម្បីគណនាភាគរយនៃចំនួនប្រជាពលរដ្ឋនៅក្នុងក្រុមចំណាត់ថ្នាក់ដែលមានប្រាក់ចំណូលទាបសម្រាប់ក្រុមប្លុកជំរឿននីមួយៗ។ ដោយដឹងពីកន្លែងដែលក្រុមគ្រួសារមានប្រាក់ចំណូលទាបទាំងនេះ បានប្រាប់អ្នកស្រាវជ្រាវអំពីកន្លែងដែលត្រូវស្វែងរកមណ្ឌលបោះឆ្នោតដែលមានសក្តានុពលនៅជិតក្រុមគ្រួសារទាំងនេះ។

*សហគមន៍និយាយភាសាជនជាតិភាគតិច*

ដើម្បីធានាថាបទពិសោធន៍បោះឆ្នោតថ្មី បំពេញតាមតម្រូវការរបស់អ្នកបោះឆ្នោតផ្សេងៗគ្នារបស់ខោនធី ដែលរួមមានអ្នកបោះឆ្នោតមានដើមកំណើតមកពីប្រទេសជាង 180 នោះ អ្នកចុះឈ្មោះឬអ្នកកត់ត្រា/ស្មៀនខោនធី RR/CC នឹងបន្តផ្តល់ជូនការគាំទ្រផ្នែកភាសា 12 ភាសា ដែលស្ថិតក្រោមគំរូមណ្ឌលបោះឆ្នោត។ ចំនួនប្រជាជនដែលត្រូវបានចាត់ថ្នាក់ជាក្រុមនិយាយភាសាជនជាតិភាគតិច ត្រូវបានរៀបចំផែនទីដើម្បីបង្ហាញសហគមន៍ដែលមានចំនួនប្រជាជនច្រើនជាងដែលជាអ្នកមិននិយាយភាសា

អង់គ្លេសមិនស្ទាត់ជំនាញ។ ចំណាត់ថ្នាក់និងនិយមន័យនៃជំរឿនប្រជាជននៅសហរដ្ឋអាមេរិក ដែលបានប្រើប្រាស់ក្នុងការវិភាគនេះ កំណត់*សហគមន៍និយាយភាសាជនជាតិភាគតិច*ថាជាការនិយាយភាសាមួយផ្សេងទៀត ហើយនិយាយភាសាអង់គ្លេស "កម្រិតតិចជាងល្អ" ។ ទិន្នន័យជំរឿនបង្ហាញពីចំនួនប្រជាជនដែលមានអាយុចាប់ពី 5 ឆ្នាំឡើង ដែលនិយាយភាសាផ្សេងទៀត នឹងនិយាយភាសាអង់គ្លេសកម្រិតតិចជាងល្អ ដែលបានប្រើប្រាស់ដើម្បីគណនាភាគរយនិងដង់ស៊ីតេសហគមន៍និយាយភាសាជនជាតិភាគតិចក្នុងផ្ទៃដីមួយអេកឃើ។

### *សហគមន៍ដែលមានកម្មសិទ្ធិយានយន្តកម្រិតទាប*

ការយល់ដឹងអំពីឧបសគ្គនានាចំពោះការធ្វើចរាចរណ៍និងការគាំទ្រមធ្យោបាយដឹកជញ្ជូនដែលមានជម្រើស គឺមានសារៈសំខាន់ណាស់នៅពេលរៀបចំផែនការសម្រាប់មណ្ឌលបោះឆ្នោតដែលអាចចូលដំណើរការបាន។ នៅជិតសហគមន៍សហគមន៍ដែលមានកម្មសិទ្ធិយានយន្តកម្រិតទាប ត្រូវបានគេវិភាគដើម្បីកំណត់ឧបសគ្គជាសក្តានុពល ដែលអាចធ្វើឱ្យការធ្វើចរាចរណ៍កាន់តែពិបាកចូលទៅមណ្ឌលបោះឆ្នោត។ ការវិភាគតម្រូវការបានសិក្សាពីភាគរយនៃក្រុមលំនៅដ្ឋានដែលបានកាន់កាប់នៅក្នុងក្រុមប្លុកជំរឿននីមួយៗ នៅក្នុងខោនធីដោយគ្មានការចូលប្រើយានយន្ត ដែលបង្ហាញពីសហគមន៍ដែលមានចំនួនប្រជាជនច្រើនដែលមិនមានការប្រើប្រាស់យានយន្ត។ ទិន្នន័យជំរឿនបង្ហាញពីភាគរយនេះត្រូវបានប្រើដើម្បីគណនាភាគរយនិងដង់ស៊ីតេក្នុងមួយអេកឃើ នៅក្នុងក្រុមប្លុកនីមួយៗនៅខណៈក្រុមប្លុកដែលគ្មានក្រុមលំនៅដ្ឋានកាន់កាប់ មិនត្រូវបានរៀបចំផែនទី។

## **លក្ខណៈវិនិច្ឆ័យលើលំនៅដ្ឋានជាប់នឹងកន្លែងធ្វើការ/កន្លែងធ្វើការ**

### *មណ្ឌលដែលមានចំនួនប្រជាពលរដ្ឋរស់នៅជាអ្នកបោះឆ្នោត*

ដោយមិនគិតពីស្ថានភាពសេដ្ឋកិច្ចសង្គមពិសេសរបស់ពួកគេនោះ ដើម្បីជួបជាមួយប្រជាពលរដ្ឋដែលពួកគេរស់នៅទីតាំងជិតមណ្ឌលបោះឆ្នោតទៅកាន់មជ្ឈមណ្ឌលប្រជាពលរដ្ឋគឺស្ថិតនៅលំដាប់ជួរមុខនៃការវិភាគអំពីតម្រូវការ។ ដោយសារការបែងចែកចំនួនប្រជាជនមិនស្មើគ្នានៅទូទាំងខោនធីនោះ មជ្ឈមណ្ឌលប្រជាពលរដ្ឋមិនអាចវាស់វែងបានត្រឹមត្រូវពីទិន្នន័យជំរឿនតែមួយទេ។ ទោះបីជាទិន្នន័យជំរឿនបង្ហាញដង់ស៊ីតេប្រជាជនត្រឹមត្រូវនៅតាមតំបន់ទីក្រុងក៏ដោយ ក៏តំបន់ជនបទដែលមានព្រំប្រទល់ភូមិសាស្ត្រធំៗ និងចំនួនប្រជាជនតិច មិនមានកត្តាវិភាគត្រឹមត្រូវទេ។ ដូចនេះ មជ្ឈមណ្ឌលប្រជាពលរដ្ឋត្រូវបានកំណត់ពីដង់ស៊ីតេអ្នកមានសិទ្ធិបោះឆ្នោត ដោយប្រើប្រាស់ទិន្នន័យអ្នកបោះឆ្នោតជាក់លាក់ ហើយការបែងចែកចំនួនប្រជាជនត្រូវបានបង្ហាញតាមការប្រើប្រាស់តំបន់ភូមិសាស្ត្រដែលបានរៀបចំជំរឿន។

អ្នកមានសិទ្ធិបោះឆ្នោតតាមក្រុមប្លុកជំរឿន ត្រូវបានគណនាពីទិន្នន័យរបស់អ្នកចុះឈ្មោះឬអ្នកកត់ត្រា/ស្មៀនខោនធី RR/CC ដែលបង្ហាញទាំងអ្នកមានសិទ្ធិបោះឆ្នោតដែលបានចុះឈ្មោះ និងមិនបានចុះឈ្មោះ ដើម្បីគាំទ្រគំរូបោះឆ្នោតបច្ចុប្បន្ននិងអនាគត។ ដើម្បីគណនាដង់ស៊ីតេអ្នកតំណាងតំបន់ដែលមានប្រជាជនប្រហាក់ប្រហែល នៅក្នុងប្លុកជំរឿននីមួយៗ ត្រូវបានអនុវត្ត។ វិធីសាស្ត្រនេះ មិនរាប់បញ្ចូលតំបន់ដែលគ្មានអ្នកមានសិទ្ធិបោះឆ្នោត (អ្នកមានសិទ្ធិបោះឆ្នោតតិចជាង 0.25 នាក់ក្នុងមួយអេកឃើ) នៅក្នុងក្រុមប្លុកធំៗនៅភាគខាងជើងនិងខាងលិចនៃខោនធី នៅខណៈពេលកំពុងគិតពិចារណាអំពីអ្នកបោះឆ្នោតនៅតំបន់ដែលមានប្រជាជនតិច។ វិធីសាស្ត្រនេះ ធានាថាការវិភាគអំពីតម្រូវការដែលបានបង្ហាញត្រឹមត្រូវនៅជិតមជ្ឈមណ្ឌលប្រជាពលរដ្ឋនៅទូទាំងភូមិសាស្ត្ររបស់ប្រជាជនផ្សេងៗគ្នារបស់ខោនធី។

### *នៅជិតមជ្ឈមណ្ឌលការងារ*

ការផ្លាស់ប្តូរទៅជាគំរូមណ្ឌលបោះឆ្នោត ផ្តល់ជូនអ្នកបោះឆ្នោតនូវសេរីភាពចំពោះការបោះឆ្នោតនៅឯមណ្ឌលបោះឆ្នោតណាមួយក្នុងខោនធី ហើយគេសន្មតថាជាចំណែកមួយនៃអ្នកបោះឆ្នោតដែលត្រូវការបោះឆ្នោតនៅជិតកន្លែងដែលពួកគេធ្វើការ ឬនៅតាមផ្លូវធ្វើដំណើរទៅវិញទៅមក។ ដើម្បីវិភាគកន្លែងធ្វើការរបស់អ្នកបោះឆ្នោតខោនធី Los Angeles County នោះ អ្នកស្រាវជ្រាវបានវិភាគលើប្រជាពលរដ្ឋនៅពេលថ្ងៃដោយប្រើប្រាស់ទិន្នន័យការងារដែលផ្តល់ជូនដោយសមាគមនៃរដ្ឋ California ភាគខាងត្បូង (SCAG)។ អ្នកស្រាវជ្រាវបានរៀបចំផែនទីដង់ស៊ីតេការងារ ដើម្បីបង្ហាញតំបន់ដែលមានមជ្ឈមណ្ឌលការងារដែលមានដង់ស៊ីតេទាបនិងខ្ពស់នៅខោនធី។

ដើម្បីវិភាគមជ្ឈមណ្ឌលការងារនៅខោនធី Los Angeles County តំបន់ដីគោកនោះ ទិន្នន័យការងារនៅតំបន់វិភាគមធ្យោបាយធ្វើដំណើរថ្នាក់ទីមួយ (Transportation Analysis Zone (TAZ) Tier 1 level) ត្រូវបានប្រើប្រាស់ដើម្បីគណនាដង់ស៊ីតេការងារក្នុង TAZ នីមួយៗ។

ដើម្បីវិភាគមជ្ឈមណ្ឌលការងារនៅកោះ Santa Catalina Island នោះ ដង់ស៊ីតេការងារត្រូវបានគណនាដោយការបូកសរុបទិន្នន័យ LODES (ស្ថិតិការងារតាមទិសដៅប្រភពដើម ) ទៅនឹងកម្រិតប្លុកជំរឿន។

## **លក្ខណៈវិនិច្ឆ័យអ្នកបោះឆ្នោត**

### *អ្នកបោះឆ្នោតដែលមានពិការភាព*

ប្រព័ន្ធបោះឆ្នោតថ្មីរបស់ខោនធី Los Angeles County ត្រូវបានរៀបចំឡើងដើម្បីឱ្យអ្នកបោះឆ្នោតទាំងអស់អាចប្រើប្រាស់បាន ដោយធានាថាឧបករណ៍បោះឆ្នោតដែលអាចចូលដំណើរការបាននៅគ្រប់មណ្ឌលបោះឆ្នោត ដែលមណ្ឌលបោះឆ្នោតត្រូវបំពេញតាមតម្រូវការទាមទារភាពអាចប្រើបានតាមច្បាប់ ADA ហើយការគិតពិចារណានោះត្រូវផ្តល់ជូននៅជិតមណ្ឌលបោះឆ្នោតសម្រាប់អ្នកបោះឆ្នោតដែលមានពិការភាព។ ការប្រើប្រាស់ទិន្នន័យពីការស្ទង់មតិសហគមន៍អាមេរិកឆ្នាំ 2016 នោះ ចំនួនពលរដ្ឋដែលមានពិការភាពដែលមានអាយុចាប់ពី 16 ឆ្នាំឡើង និងភាគរយនិងដង់ស៊ីតេពលរដ្ឋដែលមានពិការភាពនៅតំបន់ជំរឿននីមួយៗអាចត្រូវបានគណនា។ ភាគរយនៃចំនួនពលរដ្ឋដែលមានពិការភាពរបស់ខោនធីនៅតំបន់ជំរឿននីមួយៗ ត្រូវបានរៀបចំផែនទីកំណត់សហគមន៍ដែលមានសមាមាត្រនៃពលរដ្ឋដែលមានពិការភាពកម្រិតខ្ពស់ជាងមុន ដូច្នេះអ្នកស្រាវជ្រាវអាចស្វែងរកមណ្ឌលបោះឆ្នោតនៅជិតកន្លែងដែលអ្នកបោះឆ្នោតទាំងនេះរស់នៅ។

### *អ្នកមានសិទ្ធិបោះឆ្នោតដែលមិនបានចុះឈ្មោះ*

RR/CC ប្តេជ្ញាចិត្តដើម្បីសម្រួលដល់អ្នកបោះឆ្នោតដែលបានចុះឈ្មោះនាពេលបច្ចុប្បន្ន នៅខណៈពេលកំពុងគិតអំពីតម្រូវការរបស់ប្រជាពលរដ្ឋដែលជាអ្នកបោះឆ្នោតនាពេលអនាគត។ ការបញ្ចូលការគិតនេះទៅក្នុងការកំណត់ទីតាំងមណ្ឌលបោះឆ្នោត គឺមានគោលបំណងបង្កើនការចូលរួមរបស់អ្នកបោះឆ្នោតតាមរយៈភាពងាយស្រួលនៃការចូលប្រើប្រាស់ និងដំណើរការប្រកបដោយប្រសិទ្ធភាព ដែលធ្វើឱ្យប្រសើរឡើងនូវការចូលរួមនិងកាត់បន្ថយឧបសគ្គតាមពេលវេលាកន្លងទៅ។

ដើម្បីយល់ដឹងអំពីការបែងចែកពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត ប៉ុន្តែមិនបានចុះឈ្មោះនាពេលបច្ចុប្បន្ននោះ ដង់ស៊ីតេនៃអ្នកមានសិទ្ធិបោះឆ្នោតដែលមិនបានចុះឈ្មោះនៅក្នុងក្រុមប្លុកជំរឿននីមួយៗ ត្រូវបានរៀបចំផែនទីដោយប្រើទិន្នន័យរបស់អ្នកចុះឈ្មោះឬអ្នកកត់ត្រា/ស្មៀនខោនធី RR/CC ដែលបង្ហាញអ្នកបោះឆ្នោតដែលមិនបានចុះឈ្មោះនៅតាមដងផ្លូវ។ មានតែក្រុមប្លុកប៉ុណ្ណោះ ដែលស្ថិតនៅក្នុងចំណែកផ្លូវនៅជុំវិញកន្លែងដែលមានទំហំមួយភាគបួនម៉ាយ ដែលមានអ្នកមានសិទ្ធិបោះឆ្នោតដែលមិនបានចុះឈ្មោះមួយឬច្រើននាក់ ត្រូវបានវិភាគ។ វិធីសាស្ត្រនេះ បានជួយមិនរាប់បញ្ចូលតំបន់ដែលគ្មានអ្នកបោះឆ្នោតដែលមិនបានចុះឈ្មោះនៅក្នុងក្រុមប្លុកធំៗនៅភាគខាងជើងនិងខាងលិចនៃខោនធី នៅខណៈពេលកំពុងគិតពិចារណាអំពីអ្នកបោះឆ្នោតដែលមិនបានចុះឈ្មោះនៅតំបន់ ដែលមានប្រជាជនតិចទាំងនេះ។

### *ការបោះឆ្នោតមានកម្រិតទាបតាមរយៈការប្រើប៉ុស្តិ៍ប្រៃសណីយ៍*

ដើម្បីគាំទ្រដល់គោលដៅរបស់ច្បាប់ VCA ក្នុងការបង្កើនការចូលរួមបោះឆ្នោតផ្ញើតាមប្រៃសណីយ៍នៅទូទាំងរដ្ឋនោះ វាមានសារៈសំខាន់ដើម្បីកំណត់សហគមន៍ដែលមានការប្រើប្រាស់ការបោះឆ្នោតផ្ញើតាមប្រៃសណីយ៍ VBM ទាបជាប្រវត្តិសាស្ត្រ ដើម្បីធានាថាពួកគេនៅជិតទីតាំងបោះឆ្នោត VBM ដែលងាយស្រួលនៅឡើយនោះ ត្រូវមានការចូលប្រើប្រាស់មណ្ឌលបោះឆ្នោតបាន។ ការណ៍នេះ បង្កើនជម្រើសបោះឆ្នោតនៅខណៈពេលមានការគាំទ្រដល់ចំណូលចិត្តដែលបានបង្ហាញជាប្រវត្តិសាស្ត្រសម្រាប់ការបោះឆ្នោតដោយផ្ទាល់។ ការប្រើប្រាស់ VBM ដែលបានប៉ាន់ស្មានតាមទីក្រុងនៅក្នុងការបោះឆ្នោតឆ្នាំ 2020 ត្រូវបានប្រើប្រាស់ ដើម្បីវិភាគលក្ខណៈវិនិច្ឆ័យតម្រូវការអ្នកបោះឆ្នោតនេះ។

### *អ្នកបោះឆ្នោតដែលបានចុះឈ្មោះ មានទំនោរកម្រិតខ្ពស់*

ដើម្បីធានាថាអ្នកបោះឆ្នោតដែលមានមានទំនោរកម្រិតខ្ពស់ ដើម្បីចូលរួមក្នុងការបោះឆ្នោតបន្តការចូលរួមរបស់ពួកគេនោះ អ្នកស្រាវជ្រាវបានរកឃើញនិងរៀបចំផែនទីដង់ស៊ីតេអ្នកបោះឆ្នោតក្នុងក្រុមប្លុកនីមួយៗ។ មានតែក្រុមប្លុកប៉ុណ្ណោះ ដែលស្ថិតនៅក្នុងចំណែកផ្លូវនៅជុំវិញកន្លែងដែលមានទំហំមួយភាគបួនម៉ាយ ដែលមានអ្នកបោះឆ្នោតមានទំនោរកម្រិតខ្ពស់មួយឬច្រើននាក់ ត្រូវបានពណ៌នានៅក្នុងការវិភាគរៀបចំផែនទី។ វិធីសាស្ត្រនេះ បំពេញមុខងារមិនរាប់បញ្ចូលតំបន់ដែលគ្មានអ្នកបោះឆ្នោតដែលមិនបានចុះឈ្មោះនៅក្នុងក្រុមប្លុកធំៗនៅភាគខាងជើងនិងខាងលិចនៃខោនធី នៅខណៈពេលកំពុងគិតពិចារណាអំពីអ្នកបោះឆ្នោតនៅតំបន់ ដែលមានប្រជាជនតិចទាំងនេះ។

*អ្នកបោះឆ្នោតដែលបង្ហាញឱ្យឃើញ*

ដង់ស៊ីតេអ្នកបោះឆ្នោតដែលបង្ហាញឱ្យឃើញ (ពលរដ្ឋដែលមានអាយុពី 15 ដល់ 17 ឆ្នាំ) ត្រូវបានធ្វើវិភាគដោយប្រើតំបន់ក្រុមប្លុកជំរឿនដែលបានផ្តល់ជូនណាមួយ ដែលស្ថិតនៅចំណែកផ្លូវដែលបានកំណត់នៅជុំវិញកន្លែងដែលមានទំហំមួយភាគបួនម៉ាយ ដែលមានអ្នកមានសិទ្ធិបោះឆ្នោតមួយឬច្រើននាក់ នៅក្នុងក្រុមប្លុកជំរឿននីមួយៗ។ ទិន្នន័យជំរឿន ត្រូវបានប្រើដើម្បីគណនាចំនួនពលរដ្ឋដែលមានអាយុពី 15 ដល់ 17 ឆ្នាំនៅក្នុងក្រុមប្លុកជំរឿននីមួយៗ។ វិធីសាស្ត្រនេះ បានជួយមិនរាប់បញ្ចូលតំបន់ដែលគ្មានអ្នកបោះឆ្នោតនៅក្នុងក្រុមប្លុកធំៗនៅភាគខាងជើងនិងខាងលិចនៃខោនធី នៅខណៈពេលកំពុងគិតពិចារណាអំពីអ្នកបោះឆ្នោតនៅតំបន់ ដែលមានប្រជាជនតិចទាំងនេះ។

**លក្ខណៈវិនិច្ឆ័យមធ្យោបាយធ្វើដំណើរ**

*ការប្រើប្រាស់ការធ្វើដំណើរឆ្លងកាត់*

ការប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈ គឺជាកត្តាសំខាន់ដែលបានគិតពិចារណានៅក្នុងការកំណត់ជាយុទ្ធសាស្ត្រនៃមណ្ឌលបោះឆ្នោត ដើម្បីធានាបាននូវភាពងាយស្រួលនិងភាពអាចប្រើប្រាស់បានសម្រាប់អ្នកបោះឆ្នោតទាំងអស់។ ការប្រើប្រាស់មធ្យោបាយធ្វើដំណើរជាញឹកញាប់ពឹងផ្អែកលើសហគមន៍ដែលមានប្រាក់ចំណូលទាប ហើយអ្នកបោះឆ្នោតដែលបង្ហាញឱ្យឃើញ

កំពុងបង្ហាញនូវចំណង់ចំណូលចិត្តចំពោះការប្រើប្រាស់មធ្យោបាយធ្វើដំណើរតាមការជ្រើសរើសជាជាងតាមតម្រូវការ។ ក្រុមអ្នកស្រាវជ្រាវបានវិភាគអំពីភាពជិតនៃអ្នកបោះឆ្នោតបច្ចុប្បន្ននិងអនាគត និងមណ្ឌលបោះឆ្នោតដែលមានសក្តានុពល និងទីតាំងបោះឆ្នោតតាម VMB ទៅកាន់បណ្តាញមធ្យោបាយធ្វើដំណើរសាធារណៈនៅមូលដ្ឋាន ដើម្បីយល់ដឹងអំពីការធ្វើចរាចរណ៍និងឧបសគ្គរបស់អ្នកបោះឆ្នោតក្នុងការចូលទៅដល់ទីតាំងដែលមានសក្តានុពល។

ទិន្នន័យត្រូវបានប្រមូលពីអាជ្ញាធរដឹកជញ្ជូនទីក្រុងឡូសអាន់ជេលេស (Los Angeles Metropolitan Transportation Authority (METRO)) ដែលទាក់ទងនឹងចំណតឈប់រថយន្តតាមផ្លូវដែលកំណត់ទាំងអស់។ ចំណតធ្វើដំណើរឆ្លងកាត់ត្រូវបានគេចាត់ថ្នាក់ថាមានគុណភាពខ្ពស់ ឬគុណភាពទាប ដោយផ្អែកលើចន្លោះភាពញឹកញាប់សេវាកម្មមានតិចជាងឬច្រើនជាង 15 នាទីដោយឡែកពីគ្នា។ ការប្រើប្រាស់ការធ្វើដំណើរឆ្លងកាត់នៅទូទាំងខោនធី ត្រូវបានចាត់ថ្នាក់ពីការប្រើប្រាស់ការធ្វើដំណើរឆ្លងកាត់ដ៏ប្រសើរបំផុតទៅនឹងគ្មានការប្រើប្រាស់ការធ្វើដំណើរឆ្លងកាត់។ ពិន្ទុដ៏ល្អប្រសើរសំដៅលើតំបន់ដែលស្ថិតនៅចម្ងាយដើរមួយភាគបួនម៉ាយពីចំណតធ្វើដំណើរឆ្លងកាត់ដែលមានគុណភាពខ្ពស់។ ចំពោះកម្រិតវាយតម្លៃផ្សេងទៀតនោះ កន្លែងគំរូមួយត្រូវបានបង្កើតឡើងនៅជុំវិញចំណតធ្វើដំណើរឆ្លងកាត់ដោយប្រើចម្ងាយនានានៅតារាង 5 ។

Table 5. ចំណាត់ថ្នាក់នៃការប្រើប្រាស់ការធ្វើដំណើរឆ្លងកាត់

| | |
|---|---|
| **ល្អណាស់** | កន្លែងស្ថិតនៅចម្ងាយ 0.25 ម៉ាយ នៃចំណតធ្វើដំណើរឆ្លងកាត់ដែលមានគុណភាពខ្ពស់ |
| **ល្អ** | កន្លែងស្ថិតនៅចម្ងាយ 0.5 ម៉ាយ នៃចំណតធ្វើដំណើរឆ្លងកាត់ដែលមានគុណភាពខ្ពស់ |
| **មធ្យម** | កន្លែងស្ថិតនៅចម្ងាយ 0.25 ម៉ាយ នៃចំណតធ្វើដំណើរឆ្លងកាត់ដែលមានគុណភាពទាប |
| **ខ្សោយ** | កន្លែងស្ថិតនៅចម្ងាយ 0.5 ម៉ាយ នៃចំណតធ្វើដំណើរឆ្លងកាត់ដែលមានគុណភាពទាប |
| **គ្មាន** | កន្លែងស្ថិតនៅចម្ងាយលើសពី 0.5 ម៉ាយ នៃចំណតធ្វើដំណើរឆ្លងកាត់ណាមួយ |

*ការស្ទះចរាចរណ៍ និងការបង្ហាញឱ្យឃើញថាទៅតាមផ្លូវណា*

ដោយដឹងថាការបង្ហាញឱ្យឃើញថាការធ្វើចរាចរណ៍តាមផ្លូវណា និងឧបសគ្គនៃការប្រើប្រាស់ បង្ហាញនូវបញ្ហាប្រឈមចំពោះការបោះឆ្នោតនោះ អ្នកស្រាវជ្រាវបានវិភាគការស្ទះចរាចរណ៍នឹងការធ្វើចរាចរណ៍ដោយមានការរៀបចំផែនទីគិតក្នុងមួយម៉ាយនៃចម្ងាយផ្លូវក្នុងតំបន់វិភាគមធ្យោបាយធ្វើដំណើរនីមួយៗ។ ទិន្នន័យផ្លូវពីខោនធី Los Angeles County ត្រូវបានប្រើប្រាស់ដើម្បីគណនាចម្ងាយផ្លូវសរុបជាម៉ាយនៅក្នុងតំបន់វិភាគមធ្យោបាយធ្វើដំណើរ TAZ នីមួយៗ ហើយ Esri បានផ្តល់ទិន្នន័យដែលត្រូវបានប្រើប្រាស់ដើម្បីការគណនាចំនួនចរាចរណ៍សរុបក្នុងមួយតំបន់ TAZ ។ ការគណនាចំនួនចរាចរណ៍ដែលកត់ត្រាសរុប ត្រូវបានបែងចែកតាមចម្ងាយផ្លូវសរុបនៅក្នុងតំបន់ TAZ នីមួយៗ។ ការវិភាគនេះ បានជួយអ្នកស្រាវជ្រាវឱ្យចៀសវាងកន្លែងដែលមានការស្ទះចរាចរណ៍ខ្លាំងនៅពេលកំណត់ទីតាំងមណ្ឌលបោះឆ្នោត។

*ចំណតយានយន្តដែលអាចប្រើប្រាស់បានជាសាធារណៈ*

ដើម្បីទទួលបានការចូលរួមពីអ្នកបោះឆ្នោត វាមានសារៈសំខាន់ណាស់ដែលអ្នកបោះឆ្នោតអាចចូលទៅដល់មណ្ឌលបោះឆ្នោតដែលខ្លួនបានជ្រើសរើសដោយងាយស្រួល ដោយមិនត្រូវមានបញ្ហាខ្វះចំណតយានយន្តដែលបានកំណត់ ជាពិសេសសម្រាប់អ្នកដែលត្រូវការចំណតយានយន្តដែលអាចប្រើប្រាស់បានតាមច្បាប់ ADA ។ អ្នកស្រាវជ្រាវបានស្វែងរកការធានាភាពងាយស្រួលដល់អ្នកបោះឆ្នោត ដោយផ្តល់អាទិភាពដល់ចំណតយានយន្តឥតគិតថ្លៃ និងចំណតយានយន្តដែលអាចប្រើប្រាស់បានតាមតម្រូវការទាមទារកម្រិតអប្បបរមាពីមណ្ឌលបោះឆ្នោតសមរម្យ។

ទិន្នន័យចំណតយានយន្តត្រូវបានប្រមូល ដើម្បីធ្វើការវិភាគដង់ស៊ីតេដែលបានគិតពិចារណាថាតើកន្លែងចំណតយានយន្តនីមួយៗមានលក្ខណៈសមរម្យយ៉ាងដូចម្តេច។ ការវិភាគនេះ បានផ្តល់នូវការទាញយកហ្វ៊ូមលើផែនទីបន្ថែមទៀតចំពោះចំណតយានយន្តដែលអាចប្រើបានជាសាធារណៈ និងឥតគិតថ្លៃ។ ការវិភាគនេះ បង្ហាញពីដង់ស៊ីតេទីកន្លែងចំណតយានយន្តដែលអាចប្រើប្រាស់បានជាសាធារណៈនៅទូទាំងខោនធី; ទោះយ៉ាងណាក៏ដោយ ក៏មិនបានពិនិត្យមើលកន្លែងដែលអាចចូលដំណើរការបានរបស់ ADA ដែលបានវាយតម្លៃតាមរយៈដំណើរការពិនិត្យឡើងវិញតាមកុំព្យូទ័រដេសថប និងការវាយតម្លៃមណ្ឌលបោះឆ្នោតនៅនឹងកន្លែង។

Figure 5. មូលដ្ឋានទិន្នន័យ ផ្នែក 1

*ការរៀបចំផែនទីដំណើររឿង*

ដើម្បីផ្តល់នូវតម្លាភាពនិងវិធីសាស្ត្រដោះស្រាយដែលអាចចែករំលែកបាន ដើម្បីយល់ដឹងអំពីការវិភាគស្មុគស្មាញនៃដំណើរការកំណត់ទីតាំងមណ្ឌលបោះឆ្នោតនោះ អ្នកពិគ្រោះយោបល់ផ្នែកបច្ចេកទេសបានបង្កើតផែនទីដំណើររឿងតាមអ៊ីនធឺណិតដែលបានផ្តល់ជូនការបង្ហាញដែលអាចមើលឃើញមូលដ្ឋានទិន្នន័យនីមួយៗដែលបានប្រើប្រាស់ ដើម្បីវិភាគលក្ខខណ្ឌនៅខោនធី។ ភាពងាយស្រួលក្នុងការប្រើប្រាស់កម្មវិធីអនឡាញ ក៏ផ្តល់ជូនសេចក្តីសង្ខេបនៃវិធីសាស្ត្រ ប្រភពទិន្នន័យ និងការគិតពិចារណាផ្សេងទៀត ដែលត្រូវបានប្រើប្រាស់នៅអំឡុងពេលដំណើរការកំណត់ទីតាំងមណ្ឌលបោះឆ្នោតផងដែរ។

រូបភាព 5 និង 6 បង្ហាញពីតម្រូវការដែលបានកំណត់តាមលក្ខណៈវិនិច្ឆ័យ ដែលបានប្រើប្រាស់នៅក្នុងមូលដ្ឋានទិន្នន័យនីមួយៗ។ ពណ៌ងងឹតបង្ហាញពីការផ្តោតខ្លាំងលើលក្ខណៈវិនិច្ឆ័យនីមួយៗ។ ពណ៌ស្រាលបំផុត បង្ហាញពីការមិនប្រព្រឹត្តទៅ ឬការផ្តោតតិចតួចលើលក្ខណៈវិនិច្ឆ័យនីមួយៗ។



**2.3 ការវាយតម្លៃអគារ**

ដើម្បីកំណត់ទីតាំងមណ្ឌលបោះឆ្នោតដែលមានសក្តានុពលនោះ កម្មវិធី PlaceWorks

Figure 6. មូលដ្ឋានទិន្នន័យ ផ្នែក 2




បានធ្វើការពិនិត្យឡើងវិញយ៉ាងទូលំទូលាយលើកន្លែងបោះឆ្នោតថ្មីៗនិងជាប្រវត្តិសាស្ត្រ ដើម្បីដឹងថាតើកន្លែងណាអាចបង្កើតមណ្ឌលបោះឆ្នោតដ៏ល្អមួយ។ កម្មវិធី PlaceWorks

ក៏បានកំណត់អគារដែលមិនមានលក្ខណ:ប្រពៃណី ដែលមិនធ្លាប់ប្រើសម្រាប់ការបោះឆ្នោត។ ដោយប្រើមូលដ្ឋានទិន្នន័យដែលបានកំណត់នៅក្នុងផ្នែក 2.2.2, អគារបន្ថែមដែលមិនធ្លាប់ប្រើជាកន្លែងបោះឆ្នោត ក៏ត្រូវបានកំណត់និងវាយតម្លៃសម្រាប់ភាពសមស្របផងដែរ។ ដំណើរការពិនិត្យឡើងវិញនូវអគារទាំងនេះ តម្រូវឱ្យមានការចំណាយពេលប្រមាណប្រាំបីខែសម្រាប់ការស្រាវជ្រាវតាមអ៊ីនធឺណិត ការវិភាគភូមិសាស្ត្រ ការធ្វើបទសម្ភាសន៍តាមទូរស័ព្ទ ការវាយតម្លៃនៅទីវាល និងការចូលរួមរបស់ភាគីពាក់ព័ន្ធ ដែលនាំទៅដល់មូលដ្ឋានទិន្នន័យនៃទីតាំងមណ្ឌលបោះឆ្នោតដែលមានសក្តានុពលជាង 10,000 កន្លែង។

### 2.3.1 ការចូលរួមរបស់ភាគីពាក់ព័ន្ធ

ដើម្បីស្វែងយល់ព័ត៌មានលម្អិតអំពីស្ថានភាពអគារនោះ កម្មវិធី PlaceWorks បានសហការជាមួយម្ចាស់អគារ ប្រតិបត្តិករ និងអ្នកប្រើប្រាស់ដែលមានបទពិសោធន៍ខាងអគារជាញឹកញាប់ និងយល់ដឹងច្រើនបំផុតអំពីលក្ខខណ្ឌដែលមានស្រាប់របស់ខ្លួន។ ការចូលរួមរបស់ភាគីពាក់ព័ន្ធ ត្រូវធ្វើឡើងដើម្បីសម្របសម្រួលដល់ចំណូលចិត្តនិងភាពអាចប្រព្រឹត្តទៅបានរបស់ភាគីពាក់ព័ន្ធ។ ការសហការគ្នាមានទម្រង់ផ្សេងៗគ្នា ប៉ុន្តែអ្នកទាំងអស់គ្នាដែលបានស្វែងរកការផ្ទៀងផ្ទាត់លក្ខខណ្ឌ ដូចជា៖

- ម៉ោងប្រតិបត្តិការ
- ទំនាក់ទំនងអគារ
- ភាពអាចប្រើបានតាមច្បាប់ ADA
- ចំណតយានយន្ត និងការចូលប្រើទូទៅ
- ទំហំបន្ទប់អគារ
- លក្ខណ:ពិសេសនៃសុវត្ថិភាព
- ថាមពលនិងការភ្ជាប់បណ្តាញ
- ការរៀបចំកម្មវិធីកំពុងបន្ត

**ស្មៀនក្រុង**

ស្មៀនក្រុងមានតួនាទីយ៉ាងសំខាន់ក្នុងការផ្ទៀងផ្ទាត់លក្ខខណ្ឌអគារដែលភ្ជាប់អ្នកស្រាវជ្រាវទៅនឹងទំនាក់ទំនងរបស់អគារ និងការចូលរួមពីសាធារណជនទូទៅ ដើម្បីលើកទឹកចិត្តឱ្យមានការចូលរួម និងការផ្តល់មតិយោបល់។ កម្មវិធី PlaceWorks បានចូលរួមជាមួយស្មៀននៅកិច្ចប្រជុំកំពូលស្មៀនក្រុងរបស់អ្នកចុះឈ្មោះ - អ្នកកត់ត្រា/ស្មៀនខោនធីប្រចាំឆ្នាំ និងបានបង្ហាញការប្រមូលផ្តុំព័ត៌មានអំពីតំបន់ផ្តោតសំខាន់ ដែលរួមមានបញ្ជីអគារដែលមានសក្តានុពល និងផែនទីដែលត្រូវគ្នា។ បន្ទាប់ពីកិច្ចប្រជុំកំពូល ស្មៀនបានឧទ្ទិសខ្លួនឯងចំពោះការពិនិត្យឡើងវិញនិងការផ្តល់មតិយោបល់អំពីកម្មវិធីសៀវភៅបញ្ជី (customized spreadsheets) ដែលបានប្រើប្រាស់ដោយអ្នកស្រាវជ្រាវកំណត់ពីភាពសមស្របនៃទីតាំងលើកដំបូង។

ក្នុងករណីខ្លះ ស្មៀនក្រុង ក៏បានប្រើប្រាស់បណ្តាញនៅមូលដ្ឋានរបស់ពួកគេផងដែរ ដើម្បីភ្ជាប់អ្នកស្រាវជ្រាវទៅនឹងអ្នកគ្រប់គ្រងអគារ ម្ចាស់អាជីវកម្ម និងទំនាក់ទំនងទីភ្នាក់ងារផ្សេងទៀត ដែលមានការយល់ដឹងបន្ថែមអំពីលក្ខខណ្ឌនៃទីបរិវេណ។

**ទីភ្នាក់ងារសាធារណ:**

ទីភ្នាក់ងារសាធារណ:មានតួនាទីយ៉ាងសំខាន់ក្នុងការផ្ទៀងផ្ទាត់លក្ខខណ្ឌអគារ ដោយសារអគារដែលអាចប្រើប្រាស់បានជាច្រើន ដូចជាបណ្ណាល័យ មជ្ឈមណ្ឌលសហគមន៍ និងសាលាក្រុង ត្រូវបានកាន់កាប់កម្មសិទ្ធិដោយរដ្ឋ។ ទីភ្នាក់ងារនានាបានសហការជាមួយអ្នកស្រាវជ្រាវ ដើម្បីពិនិត្យឡើងវិញនូវកម្មវិធីសៀវភៅបញ្ជី (custom-made spreadsheets) នៃអគារទាំងអស់ ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ពួកគេ។ ក្នុងករណីខ្លះអ្នកដឹកនាំទីភ្នាក់ងារអាចផ្ទៀងផ្ទាត់ព័ត៌មានសម្រាប់គ្រប់អគារទាំងអស់; ហើយអ្នកផ្សេងទៀតនោះ អ្នកស្រាវជ្រាវត្រូវបានភ្ជាប់ទៅនឹងអ្នកគ្រប់គ្រងអគារ ដើម្បីផ្តល់ការយល់ដឹងផ្ទាល់ខ្លួន និងជួយក្នុងការជួបនៅទីតាំងដែលមានកម្មវិធីគ្រោងទុក។ ទីភ្នាក់ងារសាធារណ:ដែលទទួលបានការពិគ្រោះយោបល់ក្នុងកិច្ចខិតខំប្រឹងប្រែងនេះ រួមមាន៖

- ការថែទាំនិងការគ្រប់គ្រងសត្វខោនធី LA County
- ក្រសួងឧទ្យាននិងការកម្សាន្តខោនធី LA County
- ក្រសួងធនធានទឹកនិងថាមពលខោនធី LA County
- នាយកដ្ឋានអភិវឌ្ឍកម្លាំងពលកម្ម ភាពចាស់ជរា និងសេវាកម្មសហគមន៍ខោនធី LA County
- បណ្ណាល័យខោនធី LA County
- ក្រសួងផែនការទីក្រុង City of Los Angeles
- ក្រសួងសាធារណការ City of Los Angeles
- ក្រសួងការកម្សាន្តនិងឧទ្យាន City of Los Angeles
- បណ្ណាល័យសាធារណ: City of Los Angeles
- ក្រសួងសេដ្ឋកិច្ចនិងកម្លាំងពលកម្ម City of Los Angeles
- មណ្ឌលសិក្សាធិការ
- អាជ្ញាធរដឹកជញ្ជូនក្រុង Los Angeles County (Metro)

**ក្រុមប្រឹក្សាអន្តរជាតិនៃមជ្ឈមណ្ឌលផ្សារទំនើប**

RR/CC និងអ្នកស្រាវជ្រាវគម្រោងបានកំណត់វិធីសាស្ត្រប្រកបដោយភាពច្នៃប្រឌិត ដើម្បីជួបជាមួយអ្នកបោះឆ្នោតដែលពួកគេប្រមូលផ្តុំគ្នារួចហើយដោយស្វែងរកហាងទំនិញលក់រាយតាមយុទ្ធសាស្ត្រដែលបំពេញតាមតម្រូវការទាមទារអគារនិងបង្កើតបរិយាកាសទាក់ទាញនិងងាយស្រួលសម្រាប់អ្នកបោះឆ្នោត ដើម្បីបោះឆ្នោតរបស់ពួកគេ។ ការកំណត់ទីតាំងលក់រាយសមរម្យ គឺជាដំណើរការស្មុគស្មាញមួយដែលបានគិតពិចារណាលើកន្លែងទំនេរ ការបង្ហាញបន្ទប់សហគមន៍ និងសមត្ថភាពទៅដល់អគារដែលសមស្របបំផុតជាមួយអាជ្ញាធរ ដើម្បីចូលរួមក្នុងដំណើរការនេះ។

ដើម្បីឈានដល់ទំនាក់ទំនងអគារសំខាន់ៗនៃទីតាំងលក់រាយនោះ អ្នកចុះឈ្មោះឬអ្នកកត់ត្រា/ស្មៀនខោនធី RR/CC បានចូលរួមក្នុងសន្និសីទនិងកិច្ចព្រមព្រៀងលើកម្មវត្ថុនៅភាគខាងលិច ដែលរៀបចំដោយក្រុមប្រឹក្សាអន្តរជាតិនៃមជ្ឈមណ្ឌលផ្សារទំនើប។ ព្រឹត្តិការណ៍នេះ បានប្រមូលផ្តុំអ្នកដឹកនាំក្នុងវិស័យអចលនទ្រព្យ រួមទាំងភ្នាក់ងារអចលនៈទ្រព្យ ឈ្មួញកណ្តាល និងអ្នកគ្រប់គ្រងអចលនទ្រព្យដែលចាប់អារម្មណ៍នឹងនិន្នាការនិងតម្រូវការអចលនទ្រព្យប្រចាំតំបន់។ តាមរយ:ការចូលរួមក្នុងព្រឹត្តិការណ៍នេះ អ្នកចុះឈ្មោះឬអ្នកកត់ត្រា/ស្មៀនខោនធី RR/CC និងកម្មវិធី PlaceWorks អាចទាក់ទងអ្នកពាក់ព័ន្ធសំខាន់ៗដែលអាចផ្ទៀងផ្ទាត់ភាពអាចមាននិងលក្ខខណ្ឌអគារ។

**សាធារណជនទូទៅ - វិបសាយតំណភ្ជាប់តាមអនឡាញ ( VCPP ONLINE PORTAL)**

វិបសាយតំណភ្ជាប់ការកំណត់ទីតាំងមណ្ឌលបោះឆ្នោត (Vote Center Placement Portal) គឺជាវិធីសាស្ត្រផ្អែកលើវិបសាយដែលអាចចូលដំណើរការបានជាសាធារណ: ដែលអនុញ្ញាតឱ្យសមាជិកនៃសាធារណជនផ្តល់មតិយោបល់អំពីទីតាំងមណ្ឌលបោះឆ្នោតដែលមានសក្តានុពលដោយប្រើផែនទីអន្តរកម្ម។ វិបសាយតំណភ្ជាប់បានអនុញ្ញាតឱ្យអ្នកចូលរួមផ្តល់យោបល់អំពីអគារ ដោយបង្ហាញទីតាំងជាក់លាក់មួយនៅលើផែនទី ដើម្បីកំណត់ទីតាំងមណ្ឌលបោះឆ្នោតដែលមានសក្តានុពល និងផ្តល់ព័ត៌មានលម្អិតអំពីទីតាំង ដូចជាឈ្មោះ ព័ត៌មានទំនាក់ទំនង រូបថត និងលក្ខណ:ពិសេសរបស់វា ដែលអាចធ្វើឱ្យវាមានទីតាំងល្អ។ អ្នកចូលរួមនានាអាចពិនិត្យឡើងវិញនិងផ្តល់មតិយោបល់អំពីទីតាំងដែលបានស្នើសុំ ដើម្បីចែករំលែកការយល់ដឹងអំពីលក្ខណ:ពិសេសនិងលក្ខខណ្ឌអគារ ដូចជាភាពជិតកន្លែងឆ្លងកាត់សាធារណ: ភាពអាចប្រើបានតាមច្បាប់ ADA, ម៉ោងប្រតិបត្តិការ ភាពអាចប្រើបាននិងលក្ខខណ្ឌចំណតយានយន្ត សុវត្ថិភាពដែលអាចយល់ដឹងបាន និងលក្ខណ:ពិសេសនៃសង្កាត់ជិតខាងទាំងមូល ។

Figure 7. វិបសាយតំណភ្ជាប់តាមអនឡាញ (VCPP Online Portal)




ដើម្បីលើកទឹកចិត្តឱ្យមានការចូលរួមជាមួយវិបសាយតំណភ្ជាប់នោះ កិច្ចការនេះត្រូវបានរៀបចំឡើង ដើម្បីងាយស្រួលចូលប្រើកុំព្យូទ័រដេសថប ថេប្លេត និងឧបករណ៍ចល័ត។ ដើម្បីបង្កើតកម្មវិធីដែលងាយស្រួលសម្រាប់អ្នកប្រើ ដែលមានមុខងារ ក្រាហ្វិក និងរៀបចំដោយសមហេតុផលនោះ កម្មវិធីនេះត្រូវបានរៀបចំឡើងតាមគោលបំណងដើម្បីជួយសម្រួលដល់អ្នកប្រើប្រាស់សមត្ថភាពទាំងអស់ និងរួមបញ្ចូលលក្ខណៈពិសេសនៃភាពអាចប្រើបាន ដូចជាពុម្ពអក្សរងាយស្រួលអាន ពណ៌ និងការអានលើអេក្រង់មានភាពងាយស្រួល។ វិបសាយតំណភ្ជាប់បានអនុញ្ញាតិឱ្យអ្នកប្រើប្រាស់ដែលមិនងាយស្រួលដល់ការមើលផែនទី ដើម្បីទាញយកឯកសារអគារដែលបានស្នើឡើងជាទម្រង់បញ្ជី។

ដើម្បីគាំទ្រដល់ការចូលរួមពហុវប្បធម៌និងពហុភាសានោះ វិបសាយតំណភ្ជាប់ត្រូវបានបកប្រែជា 13 ភាសា៖

- អាមេនី | Հայերեն
- ចិន | 中文
- អង់គ្លេស
- ហ្វាស៊ី | فارسی
- ហ៊ីនឌី | Հայերեն
- ជប៉ុន | 日本語
- ខ្មែរ | ភាសាខ្មែរ
- កូរ៉េ | 한국어
- រុស្ស៊ី | русский
- អេស្ប៉ាញ | Español
- តាហ្គាឡុក
- ថៃ | ไทย
- វៀតណាម | TiếngViệt

វិបសាយតំណភ្ជាប់ការកំណត់ទីតាំងមណ្ឌលបោះឆ្នោត (Vote Center Placement Portal) អាចរកបានចាប់ពីខែឧសភា ឆ្នាំ 2018 ដល់ខែមីនា ឆ្នាំ 2019 ។ ក្នុងរយៈពេលជាង 10 ខែនេះ កម្មវិធី PlaceWorks បានពិនិត្យឡើងវិញនូវមតិយោបល់និងសំណូមពរប្រមាណ 1,700 ដែលបានដាក់ជូនពិនិត្យដោយសមាជិកនៃសាធារណជន។

**សាធារណជនទូទៅ៖ កិច្ចប្រជុំសហគមន៍**

បន្ថែមលើការចូលរួមតាមអនឡាញតាមរយៈវិបសាយតំណភ្ជាប់នោះ អ្នកចុះឈ្មោះឬអ្នកកត់ត្រា/ស្មៀនខោនធី RR/CC បានចូលរួមជាមួយសមាជិកនៃសាធារណជនតាមរយៈកិច្ចខិតខំប្រឹងប្រែងចូលរួមសហគមន៍ដ៏រឹងមាំមួយ ដែលរួមបញ្ចូលកិច្ចប្រជុំចំនួន 67 ក្នុងរយៈពេលជាងប្រាំបីខែ។ គំនិតផ្តួចផ្តើមនៅទូទាំងខោនធីនេះ បានអប់រំដល់សមាជិកនៃសាធារណជនអំពីច្បាប់ស្តីពីការជ្រើសរើសរបស់អ្នកបោះឆ្នោតនិងគម្រោងកំណត់ទីតាំងមណ្ឌលបោះឆ្នោត នៅពេលអញ្ជើញពួកគេឱ្យផ្តល់មតិយោបល់និងស្នើសុំទីតាំងមណ្ឌលបោះឆ្នោត។

អ្នកចូលរួមកិច្ចប្រជុំបានទស្សនាស្ថានីយ៍បើកចំហ ដែលពួកគេបានជួបជាមួយអ្នកតំណាងអង្គការសហគមន៍ អ្នកពិគ្រោះយោបល់ផ្នែកបច្ចេកទេស ឬបុគ្គលិកខោនធី និងបានទទួលការបង្ហាញបង្រៀនអំពីការប្រាស្រ័យទាក់ទងដើម្បីណែនាំពួកគេតាមរយៈមុខងារផ្សេងៗរបស់វិបសាយតំណភ្ជាប់នេះ។ ពួកគេអាចផ្តល់មតិយោបល់និងសំណូមពរតាមពេលវេលាជាក់ស្តែងតាមរយៈវិបសាយតំណភ្ជាប់ VCPP Portal ឬតាមប័ណ្ណផ្តល់មតិយោបល់ផងដែរ។ ប័ណ្ណផ្តល់មតិយោបល់និងប័ណ្ណស្នើសុំ ដែលទទួលបាននៅអំឡុងពេលកិច្ចប្រជុំសហគមន៍ ក្រោយមកទៀតត្រូវបានបញ្ចូលទៅក្នុងវិបសាយតំណភ្ជាប់ ដើម្បីធានាបាននូវមតិយោបល់និងសំណូមពរដែលបានធ្វើឡើងនៅកិច្ចប្រជុំសហគមន៍ ដែលសាធារណជនអាចមើលឃើញ។

អ្នកសម្របសម្រួលកិច្ចប្រជុំក៏បានចែកកាតប៉ុស្តាល់ដែលព្រីន ដោយមានលេខកូដ QR ភ្ជាប់ទៅនឹងវិបសាយតំណភ្ជាប់ដើម្បីផ្តល់ជូនអ្នកចូលរួមអាចចូលទៅកាន់វិបសាយតំណភ្ជាប់បានយ៉ាងងាយស្រួលតាមរយៈឧបករណ៍ចល័តរបស់ពួកគេនៅអំឡុងពេលកិច្ចប្រជុំ ឬពេលលំហែកាយផ្ទាល់ខ្លួនរបស់ពួកគេ។ ព័ត៌មានបន្ថែមទាក់ទងនឹងកិច្ចប្រជុំសហគមន៍ អាចមាននៅក្នុងផ្នែក 3.3 ។




Figure 8. ខិត្តប័ណ្ណមានទំហំប៉ុនកាតប៉ុស្តាល់

## 2.3.2 ការវាយតម្លៃទីតាំង - ការពិនិត្យឡើងវិញតាមកុំព្យូទ័រដេសថប

### វិធីសាស្ត្រ

ដំណាក់កាលនៃការពិនិត្យឡើងវិញតាមកុំព្យូទ័រដេសថបចំពោះការវាយតម្លៃអគារ បានអនុញ្ញាតឱ្យមានការវាយតម្លៃតាមអនឡាញនៃទីតាំងដែលមានសក្តានុពល ដែលធ្វើឡើងតាមការធ្វើបទសម្ភាសន៍តាមទូរស័ព្ទ ដែលជាលទ្ធផលធ្វើឱ្យមានការប្រាស្រ័យទាក់ទងលើកដំបូងដោយមានអគារនានានៅក្នុងដំណើរការវាយតម្លៃនេះ។ ដំណាក់កាលនៃការវិភាគនេះ ពាក់ព័ន្ធនឹងការពិនិត្យឡើងវិញយ៉ាងខ្លាំងនិងការកែសម្រួលឡើងវិញនូវកំណត់ត្រាទីតាំងដែលមានស្រាប់ និងត្រូវបានគេប្រើប្រាស់ដើម្បីលុបបំបាត់កន្លែងដែលមិនបានបំពេញតាមតម្រូវការទាមទារកម្រិតអប្បបរមា មានកំណត់ត្រាឯកសារស្ទួន ឬមិនមានទៀតទេ។

ការពិនិត្យឡើងវិញតាមកុំព្យូទ័រដេសថប ព័ត៌មានដែលទទួលបានតាមរយៈដំណើរការការពិនិត្យឡើងវិញតាមកុំព្យូទ័រដេសថប ត្រូវបានបញ្ចូលទៅក្នុងកម្មវិធីអនឡាញ (ArcGIS Online Application), កម្មវិធីស្ទង់មតិមណ្ឌលបោះឆ្នោត (Vote Center Desktop Survey Application) ហើយក្រោយមកត្រូវបានប្រើប្រាស់ដោយអ្នកស្រាវជ្រាវនៅទីវាល ដើម្បីពិនិត្យឡើងវិញនិងផ្ទៀងផ្ទាត់ព័ត៌មានលម្អិតអំពីទីតាំងនិងព័ត៌មានទំនាក់ទំនង នៅខណៈពេលធ្វើការវាយតម្លៃទីតាំងនៅនឹងកន្លែង។

Figure 9. វិបសាយតំណភ្ជាប់ការពិនិត្យឡើងវិញតាមកុំព្យូទ័រដេសថប




### ការពិនិត្យទិន្នន័យឡើងវិញ

ដំណាក់កាលដំបូងនៃការពិនិត្យឡើងវិញតាមកុំព្យូទ័រដេសថប រួមមានការត្រួតពិនិត្យឡើងវិញជាបឋម និងពិន្ទុនៃអគារនីមួយៗដោយប្រើឧបករណ៍រៀបចំផែនទីផ្អែកលើវិបសាយ កំណត់ត្រាសាធារណៈ មូលដ្ឋានទិន្នន័យ GIS នៅខោនធី សៀវភៅអាជីវកម្មនៅមូលដ្ឋាន និងការស្រាវជ្រាវតាមអនឡាញទូទៅ។ គោលបំណងនៃការស្រាវជ្រាវនេះ គឺដើម្បីកំណត់ថាតើអគារមួយបានបំពេញតាមតម្រូវការកម្រិតអប្បបរមាឬទេ ហើយត្រូវលើកឡើងនូវដំណាក់កាលនៃការវិភាគបន្ទាប់ ឬប្រសិនបើគោលបំណងនេះ ត្រូវលុបចោលដោយសារទីតាំងមិនសមស្រប។ តម្រូវការកម្រិតអប្បបរមានេះ បានគិតពិចារណា៖

- ការបង្ហាញនិងទីតាំងចំណតយានយន្ត - ដែលអាចប្រើបានតាមច្បាប់ ADA និងចំណតយានយន្តទូទៅ
- ចម្ងាយទៅកន្លែងឆ្លងកាត់
- ភាពអាចប្រើបានតាមច្បាប់ ADA
- ស្ថានភាពអគារ (ឈប់ធ្វើកិច្ចការជំនួញ ការរុះរើ ការផ្លាស់ប្តូរនៃការប្រើប្រាស់ ជាដើម)
- ម៉ោងប្រតិបត្តិការទូទៅ
- ព័ត៌មានទំនាក់ទំនងដែលអាចទុកចិត្តបាន
- បំណងប្រាថ្នាចូលរួម

### ការធ្វើបទសម្ភាសន៍តាមទូរស័ព្ទ

អគារនានាដែលបានបំពេញតាមតម្រូវការបឋម ដែលកំណត់ដំណើរការទៅមុខចំពោះដំណាក់កាលនៃការវិភាគបន្ទាប់ ដែលពាក់ព័ន្ធនឹងការធ្វើបទសម្ភាសន៍តាមទូរស័ព្ទដែលមានគោលបំណងប្រមូលព័ត៌មានលម្អិតអំពីអគារបន្ថែម ដើម្បីកំណត់ថាតើទីតាំងនេះ អាចចូលរួមដំណើរការមណ្ឌលបោះឆ្នោត និងបំពេញតាមតម្រូវការសម្រាប់ការចុះពិនិត្យទីតាំងឬអត់។ ការសន្ទនាទាំងនេះច្រើន តែងតែបានណែនាំអំពីច្បាប់ស្តីពីការជ្រើសរើសរបស់អ្នកបោះឆ្នោត និងគំរូបោះឆ្នោតថ្មី ហើយបានចាប់ផ្តើមជំហានដំសំខាន់មួយ ដើម្បីបង្កើតទំនាក់ទំនងសំខាន់រវាងអ្នកគ្រប់គ្រងមណ្ឌល និងបុគ្គលិកបោះឆ្នោតខោនធី។

ក្រុមអ្នកស្រាវជ្រាវបានណែនាំអំពីគោលដៅគម្រោង និងលក្ខណៈនៃមណ្ឌលបោះឆ្នោតតាមគោលដៅ និងបានព្យាយាមបំពេញចន្លោះប្រហោងចំពោះទិន្នន័យដែលបានកំណត់នៅអំឡុងពេលដំណាក់កាលការពិនិត្យឡើងវិញតាមកុំព្យូទ័រដេសថប។ ព័ត៌មានលម្អិតអំពីទីតាំងជាក់លាក់ មិនអាចរកបានគ្រប់ពេលតាមរយៈការធ្វើបទសម្ភាសន៍តាមទូរស័ព្ទទេ ពីព្រោះប្រជាពលរដ្ឋដែលបានជួបនោះ ជារឿយៗមិនដឹងអំពីព័ត៌មានលម្អិតផ្នែកបច្ចេកទេស ដូចជាការភ្ជាប់បណ្តាញ ទំហំបន្ទប់ និងដំណើរការជាន់គ្នាលើការរៀបចំកម្មវិធី។ ប្រសិនបើទំនាក់ទំនងអគារមិនអាចផ្តល់ព័ត៌មានលម្អិតបន្ថែម ប៉ុន្តែមានឆន្ទៈចូលរួមនោះ កម្មវិធី PlaceWorks បានកំណត់អគារនានាចូលទៅដំណាក់កាលវិភាគបន្ទាប់។ នៅអំឡុងពេលធ្វើបទសម្ភាសន៍នេះ ត្រូវបានស្នើសុំឱ្យផ្ទៀងផ្ទាត់ទំនាក់ទំនង៖

- បន្ទប់ដែលអាចមាន (អាហារដ្ឋានបម្រើខ្លួនឯង បន្ទប់ប្រជុំ កន្លែងហាត់ប្រាណ ជាដើម)
- ទំហំបន្ទប់ (ហ្វីតការ៉េ ឬទំហំ បើអាចមាន)
- ចំនួនព្រីភ្លើងនៅក្នុងបន្ទប់
- បណ្តាញ នឹងការតភ្ជាប់អ៊ីនធឺណិត
- សមត្ថភាពផ្ទុក
- ឧបសគ្គនានាចំពោះការចូលប្រើបានតាមច្បាប់ ADA
- បំណងប្រាថ្នារបស់អគារដែលត្រូវចូលរួម

អគារនានាដែលបានកំណត់ដំណើរការទៅមុខចំពោះដំណាក់កាលនៃការវិភាគបន្ទាប់បានទទួលការហៅទូរស័ព្ទលើកទីពីរ ដើម្បីចាប់ផ្តើមដំណើរការចុះពិនិត្យទីតាំង។ ក្នុងករណីខ្លះ ការហៅទូរស័ព្ទលើកទីពីរទាំងនេះ គ្រាន់តែជាការក្រើនរំលឹកពីគម្រោងប៉ុណ្ណោះ ហើយអ្នកស្រាវជ្រាវអាចរៀបចំកម្មវិធីគ្រោងទុកសម្រាប់ដំណើរការចុះពិនិត្យទីតាំងបានយ៉ាងងាយស្រួល។ ក្នុងករណីផ្សេងទៀត ការហៅទូរស័ព្ទលើកទីពីរ បានជួបអាថ្កូធរកម្រិតខ្ពស់ ដែលបង្ហាញពីការមិនចង់ចូលរួម ដែលបណ្តាលឱ្យមានការលុបចោលកន្លែងដែលមានសក្តានុពល។ ក្នុងករណីដែលអ្នកស្រាវជ្រាវមិនអាចធ្វើការទាក់ទងតាមទីតាំងសមស្រប ដើម្បីផ្ទៀងផ្ទាត់ព័ត៌មានលម្អិត និងកំណត់ពេលវេលាទស្សនាទីតាំងនោះ អ្នកស្រាវជ្រាវបានធ្វើការវាយតម្លៃខាងក្រៅនៅឯអគារទាំងនោះ។

ពិធីការតាមស្តង់ដារ គឺត្រូវហៅទូរស័ព្ទទៅអគារនីមួយៗរហូតដល់បីដង រហូតដល់មានទំនាក់ទំនងត្រូវបានធ្វើឡើង។ ប្រសិនបើសារជាសម្លេងអាចប្រើបាននោះ សារអត្ថបទមួយត្រូវបានទុកជូន ហើយក្នុងករណីជាច្រើនការព្យាយាមចុងក្រោយក្នុងការទាក់ទងត្រូវធ្វើឡើងតាមរយៈអ៊ីម៉ែល។

### លទ្ធផល

បន្ទាប់ពីការពិនិត្យឡើងវិញតាមកុំព្យូទ័រដេសថប និងការធ្វើបទសម្ភាសន៍តាមទូរស័ព្ទនោះ អគារនីមួយៗត្រូវបានកំណត់ជាផ្នែកមួយនៃផ្នែកនានា ដូចខាងក្រោម៖

- បានទទួលយក៖ ទីតាំងនានាដែលបំពេញតាមតម្រូវការកម្រិតអប្បបរមា ហើយមានចំណាប់អារម្មណ៍ចំពោះការធ្វើឱ្យមានមណ្ឌលបោះឆ្នោត។

- កំពុងដំណើរការ៖ ទីតាំងនានាដែលត្រូវបានវាយតម្លៃតាមអនឡាញតាមរយៈការស្វែងរកតាមអ៊ីនធឺណិត ប៉ុន្តែមិនត្រូវបានវាយតម្លៃតាមរយៈការធ្វើបទសម្ភាសន៍តាមទូរស័ព្ទទេ។
- រង់ចាំ/មិនបានកំណត់៖ ទីតាំងនានាដែលមិនបានពិនិត្យឡើងវិញ ដោយសារចំនួនគោលដៅនៅក្នុងតំបន់សិក្សានោះ បានទៅដល់ហើយ។
- បានបដិសេធ (ADA)៖ ទីតាំងនានាដែលមិនបានបំពេញតាមតម្រូវការទាមទារតាមច្បាប់ ADA ។
- បានបដិសេធ (ទីតាំងស្ទួន)៖ កំណត់ត្រាស្ទួន ឬភាន់ច្រឡំ។
- បានបដិសេធ (បញ្ហាផ្សេងៗ)៖ ទីតាំងនានាដែលបានគេកំណត់ថាមិនសមស្របសម្រាប់ហេតុផលនានា ដែលរួមមានទំហំបន្ទប់មិនគ្រប់គ្រាន់ ដំណើរការជាន់គ្នាលើការរៀបចំកម្មវិធី កន្លែងមិនមានទៀត កន្លែងមិនចង់ចូលរួម ឬមិនបានទទួលស្គាល់ដោយទីភ្នាក់ងារដៃគូ និងស្មៀនក្រុងជាកន្លែងសមស្រប។

អគារនានាដែលត្រូវបានចាត់ថ្នាក់ថា "បានទទួលយក" ឬ "កំពុងដំណើរការ" ត្រូវបានកំណត់ដំណើរការទៅមុខចំពោះដំណាក់កាលវិភាគបន្ទាប់ ដើម្បីរៀបចំកម្មវិធីគ្រោងទុកសម្រាប់ការចុះពិនិត្យទីតាំង។ អគារនានាដែលចាត់ថ្នាក់ថាជា "ការរង់ចាំ" ត្រូវបានរក្សាទុកជាឯកសារ។ កន្លែងដែលបដិសេធត្រូវបានរក្សាទុកជាឯកសារថា មិនសមរម្យ។ ទីតាំងទាំងនេះអាចមានលក្ខណៈសមរម្យនៅពេលមានតម្រូវការទាមទារអគារតាមច្បាប់ ADA ត្រូវបានធ្វើឡើង ឬបើទីតាំងទាំងនេះ មានបំណងចូលរួម។

### *តំបន់សិក្សាផ្អែកលើចំនួនប្រជាជនតាមគោលដៅលទ្ធផល*

ក្រុមអ្នកស្រាវជ្រាវបានវិភាគលើតំបន់សិក្សាចំនួន 188 កន្លែង ដែលមានទីតាំងសក្តានុពលជាង 10,000 កន្លែង ដោយមានគោលដៅបង្រួមបញ្ជីទៅជាកន្លែងដែលសមរម្យបំផុតចំនួន 2,300 កន្លែង។ ដោយប្រើព័ត៌មានពីចំនួនប្រជាជននិងមូលដ្ឋានទិន្នន័យនៃមជ្ឈមណ្ឌលការងារនោះ អ្នកស្រាវជ្រាវអាចបង្កើតរូបមន្តមួយ ដើម្បីកំណត់ថាតើមណ្ឌលបោះឆ្នោតចុងក្រោយគួរតែបែងចែកយ៉ាងដូចម្តេចនៅទូទាំងខោនធី។ រូបមន្តនេះ ត្រូវបានប្រើប្រាស់ ដើម្បីបង្កើតចំនួនគោលដៅនៃមណ្ឌលបោះឆ្នោតនៅតំបន់សិក្សានីមួយៗ ដោយយោងតាមតម្រូវការទាមទារផ្អែកលើចំនួនប្រជាជនតាមច្បាប់ VCA ។

ការអនុវត្តរូបមន្តនេះ បានជួយអ្នកស្រាវជ្រាវបង្រួមមូលដ្ឋានចំនួន 10,000 កន្លែង ដោយស្វែងរកទីតាំងតាមយុទ្ធសាស្ត្រ ដែលមិនស្ថិតនៅជិតជាងមួយភាគបួនម៉ាយពីកន្លែងមួយទៅកន្លែងមួយទៀត នៅខណៈពេលជួយគាំទ្រដល់តម្រូវការទាមទារផ្អែកលើចំនួនប្រជាជនតាមច្បាប់ VCA (សូមមើលផ្នែក 1.3.1) ដែលធានាបាននូវឱកាសស្មើភាពគ្នាក្នុងការបោះឆ្នោតនៅតាមមណ្ឌលបោះឆ្នោតទូទាំងខោនធី។ ។

ដោយខិតខំប្រឹងប្រែង ដើម្បីអនុវត្តលើសពីតម្រូវការទាមទារតាមច្បាប់ VCA នោះ អ្នកស្រាវជ្រាវបានបង្កើនចំនួនគោលដៅនៃមណ្ឌលបោះឆ្នោតសម្រាប់តំបន់សិក្សានីមួយៗ ចំនួន 2.2 ដើម្បីផ្តល់ជូនអ្នកចុះឈ្មោះឬអ្នកកត់ត្រា/ស្មៀនខោនធី RR/CC នូវទីតាំងដែលមានសក្តានុពលច្រើនជាងតម្រូវការ ដែលអនុញ្ញាតឱ្យមានភាពបត់បែនបាននៅពេលសម្របសម្រួលការបោះឆ្នោតជាមួយនឹងភាពអាចមាននិងដំណើរការនៃអគារ។

នៅពេលគោលដៅនៃតំបន់សិក្សាដែលបានកែសម្រួល ត្រូវបានរៀបចំហើយនោះ អគារនានាត្រូវបានត្រៀមរៀបចំកម្មវិធីគ្រោងទុករួចរាល់សម្រាប់ការចុះពិនិត្យទីតាំងដែលមានគោលបំណងស្វែងរកលទ្ធផលការពិនិត្យឡើងវិញតាមកុំព្យូទ័រដេសថប "ការប្រមូលព័ត៌មានតាមការពិនិត្យផ្ទាល់" - មានន័យថាផ្ទៀងផ្ទាត់លទ្ធផលទាំងនោះដោយផ្ទាល់ និងកំណត់អនុសាសន៍ចុងក្រោយសម្រាប់ភាពសមស្របរបស់អគារថាជាមណ្ឌលបោះឆ្នោតដែលមានសក្តានុពល។

### 2.3.3 ការពិនិត្យឡើងវិញនៅទីវាល/ការប្រមូលព័ត៌មានតាមការពិនិត្យផ្ទាល់ វិធីសាស្ត្រ

អគារនានាដែលបានលើកឡើងនៅដំណាក់កាលពិនិត្យឡើងវិញចុងក្រោយនៃការវិភាគ បានទទួលការចុះពិនិត្យទីតាំង ដើម្បីផ្ទៀងផ្ទាត់លក្ខខណ្ឌនៅនឹងកន្លែង។ អ្នកស្រាវជ្រាវបានប្រើឱកាសនេះ ដើម្បីផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃការស្រាវជ្រាវ បំពេញចន្លោះប្រហោងនៅក្នុងទិន្នន័យនិងកំណត់លក្ខខណ្ឌដែលមិនបានរំពឹងទុក ដែលអាចផ្លាស់ប្តូរភាពសមស្របរបស់ទីតាំង។ គោលដៅនៅដំណាក់កាលនៃដំណើរការនេះ គឺដើម្បីកំណត់ថាតើមណ្ឌលណាមួយដែលសមស្របបំផុត ដែលនាំឱ្យមានអនុសាសន៍ចុងក្រោយសម្រាប់មណ្ឌលបោះឆ្នោតដែលមានសក្តានុពលចំនួន 1,000 កន្លែង។ អ្នកត្រួតពិនិត្យឡើងវិញបានវាយតម្លៃលើលក្ខខណ្ឌដូចខាងក្រោម៖

- ភាពអាចប្រើបានទូទៅ
- ការបង្ហាញឧបសគ្គផ្ទៃក្នុង
- ចំណតយានយន្តដែលកំណត់ដោយច្បាប់ ADA
- ទំហំបន្ទប់និងកន្លែងផ្ទុកមានគ្រប់គ្រាន់
- សមត្ថភាពថាមពលនិងអគ្គិសនី
- ការភ្ជាប់បណ្តាញដែលមានសុវត្ថិភាព

ក្នុងរយៈពេលប្រាំមួយខែ ក្រុមការងារអ្នកស្រាវជ្រាវនៅតាមទីវាល បានពិនិត្យមើលទីតាំង 2,300 កន្លែងនៅទូទាំងខោនធី Los Angeles County ។ ដោយគិតជាមធ្យមអ្នកស្រាវជ្រាវចំណាយពេល 15 ទៅ 30 នាទី នៅតាមកន្លែងនីមួយៗ បានបើកបរចម្ងាយប្រមាណ 20,000 ម៉ាយ ហើយទីបំផុតបានចំណាយពេលវេលាប្រមាណ 4,000 ម៉ោង ដើម្បីវាយតម្លៃអគារ។

*បានរៀបចំពេលវេលាគ្រោងទុក*

ដើម្បីសម្របសម្រួលម្ចាស់និងអ្នកគ្រប់គ្រងទីបរិវេណនោះ អ្នកស្រាវជ្រាវបានចាប់ផ្តើមដំណើរការពិនិត្យឡើងវិញនៅទីវាល ដោយធ្វើការហៅទូរស័ព្ទ ដើម្បីផ្តល់ជូនដំណឹងជាមុនមុនពេលចុះពិនិត្យទីតាំង និងអនុវត្តការវាយតម្លៃនៅទីវាល។ វិធីសាស្ត្រកំណត់កម្មវិធីគ្រោងទុកតាមអនឡាញ ត្រូវបានបង្កើតឡើង ដើម្បីពិនិត្យមើលការព្យាយាមប្រាស្រ័យទាក់ទងយ៉ាងខ្លាំង និងការសម្របសម្រួលដំណើរការចុះពិនិត្យទីតាំងជាង 2,000 កន្លែង។

ក្នុងករណីចាំបាច់ កម្មវិធី PlaceWorks បានសហការជាមួយស្មៀនក្រុងនិងអ្នកគ្រប់គ្រងរដ្ឋបាលមណ្ឌលសិក្សាធិការ ដើម្បីកំណត់កម្មវិធីគ្រោងទុកសម្រាប់ការវាយតម្លៃ ដើម្បីជួយសម្រួលដល់ការរៀបចំកម្មវិធីនិងការកំណត់កម្មវិធីគ្រោងទុកសម្រាប់បុគ្គលិក។ ជារឿយៗស្មៀនក្រុងបានជួយសម្រួលដល់ការសន្ទនាតាមរយៈការផ្ញើសារក្រើនរំលឹក ការផ្ទៀងផ្ទាត់ព័ត៌មានទំនាក់ទំនង ហើយក្នុងករណីខ្លះមានការជួយដល់ការចូលប្រើប្រាស់អគារនានា។ កម្មវិធី PlaceWorks បានព្យាយាមកាត់បន្ថយការរំខាន និងការបែងចែកប្រតិបត្តិការនិងការរៀបចំកម្មវិធីធម្មតា និងការចុះពិនិត្យមើលទីតាំងតាមពេលវេលាគ្រោងទុក ដើម្បីជួយសម្រួលកន្លែងដែលស្នើសុំនៅពេលណាអាចធ្វើទៅបាន។

ក្នុងករណីផ្សេងទៀតកន្លែងដែលមិនមានម៉ោងធ្វើការធម្មតានោះ ដំណើរការចុះពិនិត្យទីតាំងត្រូវបានធ្វើឡើងតាមយុទ្ធសាស្ត្រនៅអំឡុងម៉ោងធ្វើការដោយមានសង្ឃឹមពីការទាក់ទងថ្នាក់ដឹកនាំផ្នែកគ្រប់គ្រងអគារ។ វិធីសាស្ត្រនេះ មានសារៈសំខាន់ ជាពិសេសនៅពេលវាយតម្លៃកន្លែងគោរពបូជាដែលពិបាកជួបអ្នកគ្រប់គ្រងនៅអំឡុងពេលធ្វើការនៅថ្ងៃប្រចាំសប្តាហ៍។

ក្នុងករណីអ្នកពិនិត្យឡើងវិញ មិនអាចធ្វើការទាក់ទងតាមទីតាំងបានទេ បន្ទាប់ពីការព្យាយាមហៅទូរស័ព្ទ ឬការផ្ញើអ៊ីម៉ែលលើកទីបីនោះ ការវាយតម្លៃខាងក្រៅត្រូវបានអនុវត្ត។ ការវាយតម្លៃខាងក្រៅទាំងនេះ ត្រូវបានកំណត់ចំពោះការផ្ទៀងផ្ទាត់ចំណតយានយន្តនិងភាពអាចប្រើបានតាមច្បាប់ ADA ប៉ុន្តែជាទូទៅត្រូវបានបំពេញបន្ថែមដោយទិន្នន័យដែលបានប្រមូលនៅដំណាក់កាលវិភាគការពិនិត្យឡើងវិញតាមកុំព្យូទ័រដែលសថប។ ទោះជាយ៉ាងណាក៏ដោយ ក៏ការចុះពិនិត្យមើលទីតាំង ត្រូវបានធ្វើឡើងផងដែរ។

*ការប្រមូលទិន្នន័យ*

ដើម្បីប្រមូលទិន្នន័យដែលរៀបចំនៅទីវាលប្រកបដោយប្រសិទ្ធភាពនោះ អ្នកស្រាវជ្រាវបានប្រើប្រាស់កម្មវិធី (custom-built), កម្មវិធី (web-based tools) ដូចជា Survey123 និង Workforce សម្រាប់កម្មវិធី ArcGIS ដែលអាចដំណើរការបានជាមួយឧបករណ៍ណាមួយដែលមានភ្ជាប់បណ្តាញទូរស័ព្ទចល័ត ឬកម្មវិធីរុករកតាមវិបសាយ។ ឧបករណ៍ថ្មីប្រឌិតទាំងនេះ បានអនុញ្ញាតឱ្យអ្នកស្រាវជ្រាវអាច៖

- កំណត់ពេលគ្រោងទុកដើម្បីចុះពិនិត្យមើលទីតាំងសម្រាប់អ្នកស្រាវជ្រាវម្នាក់ៗ
- ចុះពិនិត្យមើលទីតាំងដែលបានកំណត់
- រៀបចំផែនការផ្លូវបើកបរដោយផ្អែកលើភាពជិតនៃទីតាំងដែលបានគ្រោងទុក
- បំពេញសំណុំបែបបទវាយតម្លៃអគារ
- ផ្តល់ឯកសារកំណត់ហេតុអគារ
- ថតរូប និងរក្សាទុករូបថតអគារ

### *លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ*

ក្នុងករណីនៅទីវាល អ្នកស្រាវជ្រាវបានផ្តោតសំខាន់លើការខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការបំពេញចន្លោះប្រហោងនៅក្នុងទិន្នន័យដែលមិនបានផ្ទៀងផ្ទាត់នៅអំឡុងពេលដំណើរការពិនិត្យឡើងវិញតាមកុំព្យូទ័រដេស៍ថប និងការធ្វើកំណត់សម្គាល់អំពីការផ្លាស់ប្តូរ ឬភាពមិនសមស្របណាមួយចំពោះលទ្ធផលនៃការស្រាវជ្រាវតាមកុំព្យូទ័រដេសថប។ លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃសម្រាប់ភាពអាចប្រើបានតាមច្បាប់ ADA គឺផ្អែកលើតារាងផ្ទៀងផ្ទាត់ ADA សម្រាប់កន្លែងបោះឆ្នោតដែលបានរៀបចំឡើងដោយក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក។ លក្ខណៈទីតាំងខាងក្រោមនេះ ត្រូវបានវាយតម្លៃយ៉ាងប្រុងប្រយ័ត្ន៖

1. ចំណតយានយន្ត
   - ទីតាំងនិងចំនួនកន្លែងចំណតយានយន្តនៅនឹងកន្លែង (ទាំងចំណតយានយន្តធម្មតា និង ADA)
     - ចំណតយានយន្ត ADA ត្រូវមានទីតាំងស្ថិតនៅលើផ្លូវដែលអាចចូលទៅដល់ ដែលនៅជិតបំផុតទៅនឹងច្រកដែលអាចចេញចូលបាន។
   - ទីធ្លាចំណតយានយន្ត ADA
     - កន្លែងចំណតយានយន្ត ADA ត្រូវមានទីធ្លារឹងមាំ មិនស្រុត និងមិនរអិល និងមិនមានស្នាមប្រេះខ្លាំង និងការក្រាលថ្មដែលខូច។
   - ជម្រាលនៅកន្លែងចំណតយានយន្ត ADA (ប្រវែងផ្តេកនិងជម្រាលពីខ្នងផ្លូវទៅគែមសងខាង)
     - ជម្រាលត្រូវមានតិចជាង 2.08 ភាគរយតាមទិសដៅណាមួយ។
   - កន្លែងអ្នកធ្វើដំណើរចុះនិងឡើង
     - ក្នុងករណីមានកន្លែងដាក់អ្នកធ្វើដំណើរចុះច្រើនកន្លែង ត្រូវមានកន្លែងចុះមួយយ៉ាងតិច ដែលអាចប្រើបាន។
2. ផ្លូវធ្វើដំណើរដែលអាចចូលបានពីចំណតយានយន្តដែលអាចប្រើបាននៅជិតបំផុតទៅនឹងច្រកចេញចូលធំ
   - ទីតាំងចិញ្ចើមផ្លូវកាត់ និងភាពខ្វះចន្លោះសំខាន់ៗ
   - ជណ្តើរឡើងចុះជម្រាល៖ ជម្រាល និងកន្លែងឈប់
     - ជណ្តើរជម្រាលត្រូវបំពេញតាមតម្រូវការជម្រាល ទទឹង កន្លែងចូលចត បង្កាន់ដៃ និងការការពារគែម។
     - ជណ្តើរជម្រាលត្រូវមានកន្លែងចូលចតនៅផ្ទៃរាបស្មើនៅផ្នែកខាងក្រោម ខាងលើ និងនៅជណ្តើរជម្រាលផ្លាស់ប្តូរទិសដៅ។
   - ទីធ្លានៅតាមបណ្តោយផ្លូវ
     - ទីធ្លាត្រូវតែរឹងមាំ មិនស្រុត និងមិនរអិល។
   - ការផ្លាស់ប្តូរកម្ពស់ភ្លាមៗ ឬវត្ថុដែលលយចេញ
     - ផ្លូវមិនត្រូវមានការផ្លាស់ប្តូរភ្លាមៗនៅផ្ទៃរាបស្មើ កាំជណ្តើរ ផ្លូវចូលខ្ពស់ ឬផ្លូវដើរដែលមានជម្រាលចោទ។
     - វត្ថុដែលទ្រេតទៅលើផ្លូវថ្មើរជើង ត្រូវមានចម្ងាយយ៉ាងតិច 80 អ៊ីញនៅពីលើផ្លូវ ហើយលយចេញតិចជាង 12 អ៊ីញ ចូលក្នុងផ្លូវ។
     - វត្ថុដែលលយចេញទៅខាងក្រៅ រួមមានផ្លាកសញ្ញាបង្ហាញផ្លូវចេញចូលភ្ជាប់នឹងជញ្ជាំង ឬផ្លាកសញ្ញាណែនាំ និងមែកឈើដែលធ្លាក់មកទាបៗ។
     - វត្ថុដែលលយចេញពីខាងក្នុងផ្ទះ រួមមានបំពង់ពន្លត់អគ្គីភ័យ ប្រអប់ ឬទូដាក់បង្ហាញភ្ជាប់នឹងជញ្ជាំង ជណ្តើរនិងបង្កាន់ដៃបើកចំហ ផ្លាកសញ្ញាច្រកចេញ ផ្លាកសញ្ញានៅលើក្បាលតាមផ្លូវ បដា និងខ្លោងទ្វារចូលរាងកោង។
   - ការគិតពិចារណាបន្ថែម
     - ផ្លូវដែលអាចចូលដំណើរការបានមានទទឹង 36 អ៊ីញ និងគ្មានកាំជណ្តើរ និងចិញ្ចើមផ្លូវដែលគ្មានជណ្តើរជម្រាល។
     - ប្រសិនបើមានលក្ខណៈពិសេសចំពោះផ្លូវដែលអាចចូលដំណើរការបាន ដែលមិនអាចធ្វើឱ្យធូរស្រាលផ្លូវដែលមាននោះ ផ្លូវជំនួសមួយត្រូវបានជ្រើសរើសនិងវាយតម្លៃ។
     - ក្នុងករណីទីកន្លែងចំណតយានយន្តដែលនៅជិតបំផុត មិនស្ថិតនៅប្លុកតែមួយឬដែលស្ថិតនៅជិតអគារទេ ផ្លូវធ្វើដំណើរពីចំណតយានយន្តមិនត្រូវបានវាយតម្លៃឡើយ។
3. ផ្លូវធ្វើដំណើរដែលអាចចូលបានពីចំណតឆ្លងកាត់នៅជិតបំផុតទៅនឹងច្រកចេញចូលធំ
   - ទីតាំងចិញ្ចើមផ្លូវកាត់ និងភាពខ្វះចន្លោះសំខាន់ៗ
   - ជម្រាលនៅច្រកចេញចូលជណ្តើរជម្រាល
   - ទីធ្លានៅតាមបណ្តោយផ្លូវ
   - ការផ្លាស់ប្តូរកម្ពស់ភ្លាមៗណាមួយ
   - ព័ត៌មានលម្អិតបន្ថែមនៅតាមបណ្តោយផ្លូវដែលអាចចូលប្រើបានដែលអាចមានបញ្ហាបារម្ភ

ប្រសិនបើចំណតឆ្លងកាត់ជិតបំផុត មិនស្ថិតនៅប្លុកតែមួយឬដែលស្ថិតនៅជិតអគារទេ ផ្លូវធ្វើដំណើរពីការឆ្លងកាត់នោះ មិនត្រូវបានវាយតម្លៃឡើយ។

4. ច្រកចេញចូលអាគារដែលអាចចូលប្រើបាន
   - ទទឹងទ្វារច្រកចេញចូលធំ
     - ទ្វារមួយនៅច្រកចេញចូលដែលអាចប្រើបាន ត្រូវមានទទឹងអប្បបរមា 32 អ៊ីញ នៅពេលបើកអាចដល់ 90 ដឺក្រេ។
5. ព័ត៌មានលម្អិតអំពីបន្ទប់
   - ចំនួនបន្ទប់ដែលអាចមាន និងទំហំរបស់វា
     - សូមមើលតារាង 1 សម្រាប់ការបែងចែកទំហំបន្ទប់ និងសមត្ថភាព
     - បន្ទប់ច្រើនអាចបញ្ចូលគ្នា ប្រសិនបើមានការមើលឃើញច្បាស់រវាងបន្ទប់នានា។
   - ចំនួនព្រីភ្លើង
   - សមត្ថភាពបន្ទប់ដែលត្រូវចាក់សោ

6. ជណ្តើរយន្តធំនិងតូច
   - ប្រសិនបើកន្លែងបោះឆ្នោតមិនមានផ្ទៃរាបស្មើដូចច្រកចេញចូលទេ ត្រូវតែមានជណ្តើរយន្តធំឬតូចដែលអាចដំណើរការបានដោយខ្លួនឯង ដើម្បីផ្តល់ជូនផ្លូវដែលអាចប្រើបាន។
     - ទ្វារចូលទៅក្នុងជណ្តើរយន្តធំឬតូច និងកន្លែងនៅខាងក្នុង ត្រូវតែមានទំហំធំល្មមអាចផ្ទុករទេះកង់រុញជនពិការ និងឧបករណ៍ចល័តផ្សេងទៀត។
7. ព័ត៌មានលម្អិតអំពីអគារផ្សេងៗ
   - ការភ្ជាប់បណ្តាញ
     - បន្ទប់ទាំងអស់ លើកលែងតែបន្ទប់ដាក់សម្ភារៈ ត្រូវមានអ៊ីនធឺណិត
   - ម៉ោងប្រតិបត្តិការ

### *លទ្ធផល*

ដំណើរការវាយតម្លៃនៅទីវាលបានផ្តល់ការយល់ដឹងយ៉ាងច្រើនអំពីលក្ខខណ្ឌនៃអគារ និងបានបង្ហាញថាអគារដែលបានពិនិត្យប្រហែល 84 ភាគរយ ត្រូវបានគេចាត់ទុកថាមានលក្ខណៈសមរម្យជាមណ្ឌលបោះឆ្នោតដែលមានសក្តានុពល។ នៅសល់ 16 ភាគរយទៀតមិនបានបំពេញតាមតម្រូវការទាមទារ ហើយមិនត្រូវបានគេចាត់ទុកថាមានលក្ខណៈសមរម្យជាមណ្ឌលបោះឆ្នោតដែលមានសក្តានុពលឡើយ។ អគារទាំងនេះ ត្រូវបានរក្សាទុកឯកសារក្នុងមូលដ្ឋានទិន្នន័យសម្រាប់ខោនធី ដើម្បីប្រើជាឯកសារយោងនាពេលអនាគតនៅពេលមានការកែសម្រួលអគារដែលអាចប្រើបានតាមច្បាប់ ADA នោះ ត្រូវបានធ្វើឡើង ហើយអ្នកគ្រប់គ្រងមណ្ឌលកែសម្រួលទៅជាគំរូបោះឆ្នោតថ្មី។

មូលហេតុទូទៅថាហេតុអ្វីទីតាំងនានាត្រូវបានបដិសេធ៖

- ភាពអាចប្រើបានតាមច្បាប់ ADA។ ទីតាំងនានាដែលមិនបានផ្តល់ជូនភាពអាចប្រើបានតាមច្បាប់ ADA បានខកខានចំពោះការផ្តល់ជូនការចូលប្រើដែលស្មើភាពសម្រាប់អ្នកទាំងអស់គ្នា ដូច្នេះហើយមិនបានបំពេញតាមតម្រូវការអប្បបរមាទេ។
- ទំហំបន្ទប់ បន្ទប់នៅក្នុងអគារនានាមានទំហំតូចពេក មិនអាចដាក់សម្ភារៈដែលត្រូវការ។ ចំពោះគំរូបោះឆ្នោតថ្មីនេះ ទំហំបន្ទប់សមរម្យអប្បបរមា គឺប្រហែល 1,000 ហ្វីតការ៉េ។ ទំហំបន្ទប់សមរម្យអប្បបរមា មានតូចៗដោយសារតែកង្វះខាតកន្លែងដែលមានបន្ទប់ធំៗនៅតាមតំបន់សិក្សាមួយចំនួន។ អគារនានាដែលបានទទួលយក ប៉ុន្តែស្ថិតនៅក្រោមតម្រូវការទាមទារទំហំដើម ដែលមានទាំងអគារសាធារណៈឬអគារនានាដែលធ្លាប់បម្រើសេវាជាកន្លែងបោះឆ្នោតកាលពីមុន។

- បានបដិសេធការចូលប្រើប្រាស់។ អ្នកត្រួតពិនិត្យឡើងវិញនៅទីវាលត្រូវបានគេបដិសេធមិនឱ្យចូលប្រើប្រាស់កន្លែងនោះ ទោះបីជាមានកិច្ចព្រមព្រៀងដែលមានកម្មវិធីគ្រោងទុកកាលពីមុនក៏ដោយ។
- បានបដិសេធការចូលរួម។ ទំនាក់ទំនងទីតាំងមិនមានបំណងចង់ចូលរួមនៅក្នុងដំណើរការនេះ ប៉ុន្តែក្នុងខណ្ឌនៃអគារបានបង្ហាញពីដំណើរការជាន់គ្នាលើភាពអាចមាន។ ក្នុងករណីខ្លះបន្ទប់ដែលបានប្រើសម្រាប់ការបោះឆ្នោតនាពេលកន្លងមកមិនអាចប្រើបានទៀតទេ ដោយសារតែការផ្លាស់ប្តូរការរៀបចំកម្មវិធី ឬភាពជាម្ចាស់កម្មសិទ្ធិ។

អគារខ្លះមិនបានបំពេញតាមតម្រូវការទាមទារចំពោះភាពសមស្របរបស់មណ្ឌលបោះឆ្នោតទេ ប៉ុន្តែបានបង្ហាញនូវគុណសម្បត្តិដែលគួរឱ្យចង់បាន ហើយត្រូវបានគេណែនាំឱ្យជាការបោះឆ្នោតផ្ញើតាមប្រៃសណីយ៍។ ដោយសារហេដ្ឋារចនាសម្ព័ន្ធចាស់ៗនិងការផ្លាស់ប្តូរគោលនយោបាយនាពេលថ្មីៗនេះ អគារជាច្រើននៅទូទាំងប្រទេសមិនបំពេញតាមតម្រូវការទាមទារតាមច្បាប់ ADA ជាមូលដ្ឋានឡើយ។

### *វិធានការណ៍ជួយសម្រួលភាពអាចប្រើបានតាមច្បាប់ ADA*

ដើម្បីអនុញ្ញាតឱ្យមានភាពបត់បែនបានក្នុងយុគសម័យនៃការធ្វើទំនើបកម្មអគារនោះ កម្មវិធី PlaceWorks បានវាយតម្លៃអគារដែលមិនបានបំពេញភាពអាចប្រើបានតាមច្បាប់ ADA ដើម្បីកំណត់វិធានការណ៍កាត់បន្ថយដែលមានសក្តានុពល ដែលអាចធ្វើឱ្យប្រសើរឡើងភាពអាចប្រើបានងាយស្រួលនិងរហ័ស។ អគារនានាដែលមានឱកាសដែលត្រូវបានគេស្គាល់សម្រាប់ការជួយសម្រួលនោះ មិនត្រូវបានបដិសេធទេ ប្រសិនបើមិនមានកន្លែងដែលសមរម្យពេញលេញនិងអាចប្រើបានតាមច្បាប់ ADA ផ្សេងទៀតដែលស្ថិតនៅជិតប្រជាជនរៀងៗខ្លួន។ យោងតាមតារាងផ្ទៀងផ្ទាត់ ADA សម្រាប់កន្លែងបោះឆ្នោតនោះ បានគាំទ្រវិធានការជួយសម្រួល រួមមាន៖

- ឧបករណ៍រាងសាជីសម្គាល់សញ្ញាចរាចរណ៍៖ បករណ៍រាងសាជីសម្គាល់សញ្ញាចរាចរណ៍អាចប្រើសម្គាល់កន្លែងចំណតយានយន្តនិងកន្លែងផ្លូវអ្នកដំណើរ ដើម្បីដាក់ស្លាកសញ្ញាចំណតយានយន្តបណ្តោះអាសន្ន និងដើម្បីជូនដំណឹងប្រុងប្រយ័ត្នចំពោះវត្ថុលយចេញណាមួយ។
- ស្លាកសញ្ញាចំណតយានយន្ត៖ ស្លាកសញ្ញាចំណតយានយន្តបណ្តោះអាសន្នអាចដាក់នៅលើឧបករណ៍រាងសាជី ដើម្បីកំណត់កន្លែងចំណតយានយន្តដែលអាចចូលប្រើបាននិងរថយន្តដឹកតូចៗអាចចូលប្រើបាន។
- ស្លាកសញ្ញាប្រាប់ទិសផ្លូវ៖ ស្លាកសញ្ញាប្រាប់ទិសផ្លូវអាចប្រើបង្ហាញទិសផ្លូវ ច្រកចេញចូលដែលអាចចូលប្រើបាន និងកន្លែងបោះឆ្នោត ប្រសិនបើផ្លូវធ្វើដំណើរមិនច្បាស់លាស់។
- ជណ្តើរជម្រាលចល័ត៖ ជណ្តើរជម្រាលចល័តដែលគ្មានបង្កាន់ដៃ អាចប្រើដើម្បីផ្តល់ជូនការចូលប្រើចិញ្ចើមផ្លូវ ដើម្បីបិទរន្ធឬចន្លោះប្រហោងនៅតាមផ្លូវ។ ជណ្តើរជម្រាលចល័តដែលមានបង្កាន់ដៃ អាចប្រើដើម្បីផ្តល់ជូនការចូលប្រើទៅកាន់ជណ្តើរធំៗ។
- ស្នៀតស៊ក៖ ស្នៀតស៊កអាចផ្តល់ជូនការចូលប្រើដោយធ្វើឱ្យមានការផ្លាស់ប្តូរបន្តិចបន្តួចតាមផ្លូវរាបស្មើនោះ។
- ប្រដាប់ទល់ទ្វារ៖ ប្រដាប់កល់ទ្វារអាចប្រើដើម្បីដាក់ទល់បើកទ្វារ ប្រសិនបើទំហំទទឹងនៃទ្វារមិនគ្រប់គ្រាន់សម្រាប់ការចូលប្រើនៅមុំ 90 ដឺក្រេ។
- របារទ្វារដែលអាចដកចេញបាន៖ របារណ្តាលរវាងទ្វារអាចដកចេញបាន ក្នុងករណីខ្លះដើម្បីផ្តល់ជូនទំហំទទឹងដែលត្រូវការអប្បបរមាសម្រាប់រទេះកង់រុញជនពិការ ឬឧបករណ៍ចល័តផ្សេងទៀត។

Figure 10. ឧទាហរណ៍អំពីវិធានការណ៍ជួយសម្រួលភាពអាចប្រើបានតាមច្បាប់ ADA




*ប្រភព៖ https://www.ada.gov/votingchecklist.pdf*

### *ឧបសគ្គចំពោះការចូលរួម*

អគារនានាដែលធ្លាប់បម្រើការជាកន្លែងបោះឆ្នោតកាលពីមុន បានផ្តល់ជូនការយល់ដឹងអំពីបញ្ហាប្រឈមជាប្រវត្តិសាស្ត្រនៃការអនុវត្តការបោះឆ្នោត និងបានបង្ហាញនូវបញ្ហាលំបាកដែលរំពឹងទុកមុន ដែលអាចកើតឡើងដោយសារតែគំរូបោះឆ្នោតថ្មីនេះ។ ក្នុងករណីខ្លះការលំបាកទាំងនេះ បានបង្កជាឧបសគ្គដល់ការចូលរួម។ ឧបសគ្គដែលបានរាយការណ៍ រួមមាន៖

- ឧបសគ្គនៃការរៀបចំកម្មវិធី៖ បន្ទប់ដែលសមរម្យនៅតាមកន្លែងនានាជារឿយៗត្រូវបានកាន់កាប់ដោយកម្មវិធីដំណើរការបន្ត ដែលអាចរកប្រាក់ចំណូលឬផ្តល់សេវាកម្មដល់សហគមន៍។ ការផ្អាកឬលុបចោលកម្មវិធីទាំងនេះ ដើម្បីជួយសម្រួលដល់ការបោះឆ្នោត បង្ហាញពីការអាក់អន់ចិត្តដល់អគារនានា និងសមាជិកសហគមន៍ដែលពឹងផ្អែកលើសេវាកម្មទាំងនោះ។
- ម៉ោងប្រតិបត្តិការទូទៅ៖ អគារនានាមិនអាចផ្តល់ជូនបុគ្គលិកដែលត្រូវការ និងការចំណាយដែលកើនឡើង ដែលទាក់ទងនឹងប្រតិបត្តិការអគារលើសពីម៉ោងប្រតិបត្តិការធម្មតា។
- ភាពអាចប្រើបានតាមច្បាប់ ADA៖ អគារនានាដែលមានភាពអាចប្រើបានតាមច្បាប់ ADA មិនគ្រប់គ្រាន់នោះ ធ្វើឱ្យមានការលំបាកចំពោះអ្នកបោះឆ្នោតដែលជាជនពិការក្នុងការចូល និងប្រើប្រាស់កន្លែងនេះ។
- សញ្ញាសម្គាល់មិនច្បាស់៖ ក្នុងករណីសញ្ញាសម្គាល់អចិន្ត្រៃយ៍មិនមានទេនោះ អ្នកបោះឆ្នោតមានបញ្ហាលំបាកក្នុងការកំណត់ទីតាំងបន្ទប់ដែលបានកំណត់នៅក្នុងអគារ។ ការមើលឃើញសញ្ញាសម្គាល់ខាងក្រៅដែលមានកំណត់នោះ ធ្វើឱ្យមានការលំបាកសម្រាប់អ្នកបោះឆ្នោតក្នុងការរកទីតាំង រួមទាំងចំណតយានយន្ត និងច្រកចេញចូលដែលបានកំណត់ផងដែរ។

### *អគារនានាដែលបានទទួលយក*

ដើម្បីទទួលយកបានពេញលេញនូវភាពអាចបត់បែនបាន ដែលបានផ្តល់ជូនតាមរយៈគំរូមណ្ឌលបោះឆ្នោតនោះ កម្មវិធី PlaceWorks បានស្វែងរកកំណត់ប្រភេទកន្លែងទូលាយ ដែលអាចផ្តល់នូវប្រភេទអគារគ្រប់គ្រាន់ ដើម្បីបំពេញបំណងតាមចំណង់ចំណូលចិត្តផ្សេងៗគ្នារបស់អ្នកបោះឆ្នោតនៅរដ្ឋ Los Angeles ។

ប្រភេទអគារទូទៅដែលបានទទួលយកជាមណ្ឌលបោះឆ្នោតដែលមានសក្តានុពល គឺសាលារដ្ឋ កន្លែងគោរពបូជា និងកន្លែងសាធារណៈ ដូចជាបណ្ណាល័យ និងមជ្ឈមណ្ឌលកម្សាន្តសហគមន៍។ ដំណើរការនេះ ស្របទៅនឹងលទ្ធផលពីក្រុមគោលដៅ និងការស្ទង់មតិសហគមន៍ដែលបង្ហាញថា ជាទូទៅអ្នកបោះឆ្នោតចូលចិត្តបោះឆ្នោតនៅកន្លែងដែល

ធ្លាប់ស្គាល់ ដូចជានៅបណ្ណាល័យ សាលារៀន សហគមន៍ ឬមជ្ឈមណ្ឌលកម្សាន្ត និងសាលាក្រុង។ អគារដែលបានទទួលយកទាំងនេះ បានធ្វើឱ្យយល់ដឹងច្រើនឡើងអំពីឧបករណ៍កំណត់ភាពសមស្របនៃទីតាំងមណ្ឌលបោះឆ្នោត (Vote Center Site Suitability Tool) ដើម្បីកំណត់មណ្ឌលបោះឆ្នោតចំនួន 1,000 កន្លែង ដែលសមស្របបំផុតសម្រាប់ការផ្តល់អនុសាសន៍ចុងក្រោយ។

## 2.3 ឧបករណ៍កំណត់ភាពសមស្របនៃទីតាំងមណ្ឌលបោះឆ្នោត (VOTE CENTER SITE SUITABILITY TOOL)

ដើម្បីគាំទ្រគោលការណ៍ណែនាំពីច្បាប់ VCA និងតម្រូវការប្រតិបត្តិការផ្សេងទៀត នៅខណៈពេលរៀបចំអនុសាសន៍ស្តីពីមណ្ឌលបោះឆ្នោតចុងក្រោយនោះ ឧបករណ៍កំណត់ភាពសមស្របនៃទីតាំងមណ្ឌលបោះឆ្នោត ត្រូវបានបង្កើតឡើង។ ឧបករណ៍នេះ បានអនុញ្ញាតឱ្យអ្នកស្រាវជ្រាវធ្វើវិភាគបន្ថែមនូវទីតាំងដែលទទួលយកចំនួន 2,300 កន្លែង និងកំណត់ទីតាំងល្អបំផុតចំនួន 1,000 កន្លែង ដែលត្រូវប្រើនៅក្នុងការបោះឆ្នោតបឋមប្រធានាធិបតីឆ្នាំ 2020 និងការបោះឆ្នោតបន្ទាប់ទៀត។ គោលដៅនេះ គឺដើម្បីទទួលយកកន្លែងច្រើនជាងតម្រូវការ នៅអំឡុងពេលវាយតម្លៃទីតាំង ដើម្បីប្រើប្រាស់មូលដ្ឋានទិន្នន័យដែលត្រូវការនិងលក្ខណៈវិនិច្ឆ័យផ្សេងទៀត ដើម្បីកំណត់ចំណាត់ថ្នាក់និងដាក់ពិន្ទុលើទីតាំងដែលទទួលយកទាំងនេះ។ ឧបករណ៍កំណត់ភាពសមស្របនៃទីតាំងមណ្ឌលបោះឆ្នោត បានអនុញ្ញាតឱ្យអ្នកស្រាវជ្រាវស្វែងយល់ពីសេណារីយោផ្សេងៗគ្នាដោយផ្តោតសំខាន់ទៅលើមូលដ្ឋានទិន្នន័យដែលត្រូវការផ្សេងៗទៀត។

សេណារីយោទាំងនេះ មានបួនប្រភេទធំៗ គឺសេដ្ឋកិច្ចសង្គម លំនៅដ្ឋានជាប់នឹងកន្លែងធ្វើការ/កន្លែងធ្វើការ អ្នកបោះឆ្នោត និងមធ្យោបាយធ្វើដំណើរ ហើយប្រភេទសំខាន់ៗនីមួយៗ មានប្រភេទរងផងដែរ។ សូមមើលផ្នែក 2.2.2 សម្រាប់ការពិពណ៌នាលម្អិតបន្ថែមទៀតអំពីមូលដ្ឋានទិន្នន័យដែលត្រូវការនីមួយៗ។

Figure 11. ឧបករណ៍ VSAP




### 2.3.1 ដំណើរការអភិវឌ្ឍឧបករណ៍

ឧបករណ៍កំណត់ភាពសមស្របនៃទីតាំងមណ្ឌលបោះឆ្នោត ត្រូវបានបង្កើតឡើងដោយប្រើកម្មវិធីវិបសាយដែលអ្នកប្រើប្រាស់ងាយស្រួលប្រើ ដើម្បីអនុញ្ញាតឱ្យមានភាពបត់បែនបាន ដើម្បីចែករំលែកព័ត៌មាននិងពិភាក្សាអំពីវិធីសាស្ត្រជាមួយសមាជិកគណៈកម្មាធិការពិគ្រោះយោបល់ផ្នែកបច្ចេកទេស VSAP, គណៈកម្មាធិការពិគ្រោះយោបល់ គណៈកម្មាធិការប្រតិបត្តិអចិន្ត្រៃយ៍ និងបុគ្គលិកអ្នកចុះឈ្មោះឬអ្នកកត់ត្រា/ស្មៀនខោនធី RR/CC ទាំងអស់។

ឧបករណ៍កំណត់ភាពសមស្របនៃទីតាំងមណ្ឌលបោះឆ្នោត មានសមាសធាតុសំខាន់ៗចំនួនបួន៖

- **ការណែនាំ។** បានផ្តល់ឱ្យអ្នកប្រើប្រាស់នូវការណែនាំទូទៅ អំពីរបៀបប្រើឧបករណ៍ និងពិពណ៌នាអំពីរបៀបប្រើសញ្ញា ដែលបានប្រើនៅក្នុងផែនទីលទ្ធផលចុងក្រោយ។
- **ផែនទី។** បានបង្ហាញលទ្ធផលនៃសេណារីយោគំរូនៃភាពសមស្រប និងលទ្ធផលចុងក្រោយនៃឧបករណ៍ជ្រើសរើសទីតាំងនេះ។ លទ្ធផលបានបង្ហាញពីទីតាំងដែលពេញចិត្តដោយផ្អែកលើការទាញយកហ្សូមលើផែនទីដែលបានជ្រើសរើស និងអគារដែលមាននិមិត្តសញ្ញាតាមទំហំបន្ទប់។
- **កម្មវិធីគំរូភាពសមស្រប (Suitability Modeler)។** ឧបករណ៍ដែលជួយអ្នកប្រើប្រាស់រៀបចំគំរូភាពសមស្របរបស់ពួកគេ តាមរយៈការជ្រើសរើសនឹងការទាញយកហ្សូមលើផែនទីនៃមូលដ្ឋានទិន្នន័យដែលត្រូវការផ្អែកសេដ្ឋកិច្ចសង្គមនិង ប្រជាសាស្ត្រតាមភាគរយ នឹងដំណើរការវិភាគ ដើម្បីបង្កើតលទ្ធផលផែនទីដែលបង្ហាញពីវិសាលភាពនៃភាពសមស្របចំពោះមណ្ឌលបោះឆ្នោតនៅទូទាំងខោនធី។ ឧទាហរណ៍ ដើម្បីកំណត់មណ្ឌលបោះឆ្នោតដែលសមស្របបំផុតនៅជិតចំណតធ្វើដំណើរឆ្លងកាត់ អ្នកប្រើដែលបានបង្កើតគំរូនេះ និងបានផ្តល់ភាគរយខ្ពស់ដល់មូលដ្ឋានទិន្នន័យ "មធ្យោបាយធ្វើដំណើរ - ការប្រើប្រាស់ការធ្វើដំណើរឆ្លងកាត់" ដោយប្រៀបធៀបនឹងកន្លែងផ្សេងទៀត។ ឧបករណ៍នេះ អនុញ្ញាតឱ្យអ្នកស្រាវជ្រាវដំណើរការសេណារីយោផ្សេងៗ ដើម្បីពិនិត្យមើលថាតើការទាញយកហ្សូមលើផែនទីអាចមានផលប៉ះពាល់យ៉ាងណាដល់ការបែងចែកមណ្ឌលបោះឆ្នោតដែលស្មើគ្នា។
- **ឧបករណ៍ជ្រើសរើសទីតាំង។** បានអនុវត្តសេណារីយោដែលបានកំណត់ដោយកម្មវិធីគំរូភាពសមស្រប (suitability modeler) ចំពោះអគារដែលអាចមាន ដើម្បីកំណត់ពីរបៀបនៃការជ្រើសរើសទីតាំងសមស្រប នឹងអាចបែងចែកស្មើគ្នានៅទូទាំងខោនធី។ ឧបករណ៍នេះ អនុញ្ញាតឱ្យអ្នកស្រាវជ្រាវមើលឃើញពីរបៀបនៃការទាញយកហ្សូមលើផែនទីនៃមូលដ្ឋានទិន្នន័យ មានផលប៉ះពាល់យ៉ាងណាដល់ការបែងចែកមណ្ឌលបោះឆ្នោតដែលស្មើគ្នានៅទូទាំងខោនធី។
  ឧទាហរណ៍ប្រសិនបើតំបន់ជាក់លាក់មួយ មានអគារជាច្រើនអាចប្រើបានតាមច្បាប់ ADA ហើយអ្នកស្រាវជ្រាវអនុវត្តសេណារីយោដែលផ្តល់អាទិភាពដល់ការទាញយកហ្សូមលើផែនទីពីភាពអាចប្រើបានតាមច្បាប់ ADA នោះ មណ្ឌលបោះឆ្នោតអាចបញ្ចប់ការរៀបចំនៅតំបន់ជាក់លាក់នោះ ដែលអាចជាសេណារីយោមួយដែលអាចមើលឃើញចំនួនប្រជាជន និងតម្រូវការសេដ្ឋកិច្ចសង្គមផ្សេងទៀត។
    - លក្ខណៈវិនិច្ឆ័យលើការដាក់ពិន្ទុអគារ/បន្ទប់ ការដាក់ពិន្ទុត្រូវបានផ្តល់ជូនមណ្ឌលបោះឆ្នោតនីមួយៗ ដោយផ្អែកលើទំហំបន្ទប់ គុណភាពចំណតយានយន្ត ប្រភេទអគារ និងភាពអាចប្រើបានតាមច្បាប់ ADA ។ ព័ត៌មានលម្អិតអំពីលក្ខណៈវិនិច្ឆ័យលើការដាក់ពិន្ទុអាចរកបាននៅក្នុងតារាង 6 ។ ក្រុមអ្នកស្រាវជ្រាវនិងក្រុមអ្នកផ្តល់មតិយោបល់ អាចធ្វើតាមតម្រូវការគំរូនៃការជ្រើសរើសទីតាំង ដើម្បីបង្កើតពិន្ទុនៃភាពសមស្រប។
    - សេចក្តីសម្រេចលេខ 1320 Rule (សេចក្តីសម្រេចចម្ងាយ 1/4 ម៉ាយ)។ ដើម្បីធានាបាននូវឱកាសស្មើភាពគ្នាក្នុងការបោះឆ្នោតនៅតាមមណ្ឌលបោះឆ្នោតទូទាំងខោនធីនោះ អ្នកប្រើប្រាស់អាចជ្រើសរើសយកជម្រើសមួយដែលអាចធានាថាមណ្ឌលបោះឆ្នោតមានចម្ងាយយ៉ាងហោចណាស់ ¼ ម៉ាយពីកន្លែងមួយទៅកន្លែងមួយទៀត។ ប្រសិនបើរកឃើញថាមានការមិនយល់ស្របចំពោះចម្ងាយនោះ ទីតាំងដែលមានពិន្ទុខ្ពស់បំផុត ត្រូវបានជ្រើសរើស។

ដំណើរការអភិវឌ្ឍឧបករណ៍កំណត់ភាពសមស្របនៃទីតាំង (Site Suitability Tool) ត្រូវទទួលបានឥទ្ធិពលនិងវាយតម្លៃដោយក្រុមការងារគម្រោង VSAP និងគណៈកម្មាធិការ

ពិគ្រោះយោបល់។ អ្នកពិគ្រោះយោបល់ផ្នែកបច្ចេកទេស បានបង្ហាញគំរូសេណារីយោដល់ក្រុមការងារគម្រោង VSAP គណៈកម្មាធិការប្រឹក្សាយោបល់ និងគណៈកម្មាធិការប្រឹក្សាយោបល់ផ្នែកបច្ចេកទេស ហើយពួកគេមានឱកាសដើម្បីសិក្សាលម្អិតអំពីវិធីសាស្ត្រនិងផ្តល់ព័ត៌មានទាក់ទងនឹងការទាញយកហ្វ៊ូមលើផែនទី។

ការពិគ្រោះយោបល់ទាំងនេះ បាននាំឱ្យមានវិធីសាស្ត្រដែលបានព្រមព្រៀងគ្នាចំពោះសេណារីយ៉ូនៃការទាញយកហ្វ៊ូមលើផែនទី ដែលរាប់បញ្ចូលទាំងតម្រូវការគំរូនិងប៉ារ៉ាម៉ែត្រដែលនឹងអាចប្រើដើម្បីបង្កើតមណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍ចំនួន 1,000 ចុងក្រោយ។

Table 6. លក្ខណៈវិនិច្ឆ័យនៃការដាក់ពិន្ទុអគារនិងបន្ទប់

| សូចនាករអគារ | ពិន្ទុ | ចំណាត់ថ្នាក់ដាក់ពិន្ទុ |
|---|---|---|
| **ពិន្ទុទំហំបន្ទប់** | | |
| | 0 | តូច, <1,999 sq./ft |
| | 2 | មិនដឹង |
| **ទំហំ** | 3 | តូច/មធ្យម, 2,000 - 2,449 sq./ft |
| | 7 | មធ្យម, 2,450 - 3,849 sq./ft |
| | 9 | ធំ, > 3,850 sq./ft |
| **ពិន្ទុទំហំបន្ទប់សរុប** | 0-9 | តាមការរាយបញ្ជីខាងលើ |
| **ពិន្ទុអគារ** | | |
| **គុណភាពចំណតយានយន្ត** | 0-9 | សរុបចំណាត់ថ្នាក់ចំនួន 2៖ ចំណតយានយន្ត ADA; មិនមែនចំណតយានយន្ត ADA |
| | 2 | ឯកជន |
| | 5 | សាលារដ្ឋ K-12 |
| | 6 | មជ្ឈមណ្ឌលសិល្បៈនិងវប្បធម៌ និងមជ្ឈមណ្ឌលផ្សារទំនើប |
| **ប្រភេទអគារ** | 7 | មហាវិទ្យាល័យ/សាកលវិទ្យាល័យរដ្ឋ អគាររដ្ឋផ្សេងទៀត |
| | 9 | មជ្ឈមណ្ឌលសហគមន៍ បណ្ណាល័យ ឧទ្យាន និងកន្លែងកម្សាន្ត ជាដើម។ |
| **ភាពអាចប្រើបានតាមច្បាប់ ADA** | 0-9 | ផលបូក 4 ប្រភេទ៖ ជណ្តើរជម្រាល បន្ទប់ទឹកទំហំទទឹងផ្លូវធ្វើដំណើរ; កត្តាបន្ថែម |
| **ផ្សេងៗ** | 0-9 | ផលបូក 3 ប្រភេទ៖ បានណែនាំដោយសាធារណៈជន; អគារមានទ្វារចាក់សោរដើម្បីធានាសុវត្ថិភាព BMD; កត្តាបន្ថែម |
| **ពិន្ទុអគារសរុប** | 0-9 | មធ្យមភាគ 4 ប្រភេទ |

## 3.0 ការផ្តល់សេវាដល់សាធារណជន និងភាពជាដៃគូ

LA County RR/CC បានចូលរួមជាមួយសាធារណជននៅទូទាំងដំណើរការនៃការកំណត់ទីតាំងមណ្ឌលបោះឆ្នោតទាំងមូល ហើយនឹងបន្តសហការនៅពេលដែលគំរូបោះឆ្នោតថ្មី ត្រូវបានណែនាំដល់អ្នកបោះឆ្នោតនៅប៉ុន្មានឆ្នាំខាងមុខនេះ។ RR/CC បានសហការជាមួយកម្មវិធី PlaceWorks ដើម្បីជួយសម្រួលដល់ការផ្តល់សេវាដល់អ្នកពាក់ព័ន្ធជាច្រើននៅក្នុងការរៀបចំវិធីសាស្ត្រជាច្រើន។ អ្នកពាក់ព័ន្ធបានជួយបំពេញចន្លោះប្រហោងនៅក្នុងទិន្នន័យ និងផ្តល់ជូនការយល់ដឹងដ៏មានតម្លៃពីបទពិសោធន៍ផ្ទាល់ខ្លួនអំពីអគារនានា។

### 3.1 គណៈកម្មាធិការប្រឹក្សាយោបល់ VSAP

កម្មវិធី PlaceWorks បានសហការជាមួយគណៈកម្មាធិការដែលមានស្រាប់ ដែលបានផ្តល់ប្រឹក្សាយោបល់និងគាំទ្រយ៉ាងសកម្មដល់គម្រោង VSAP ។ គោលបំណងនៃគណៈកម្មាធិការប្រឹក្សាយោបល់ VSAP និងគណៈកម្មាធិការប្រឹក្សាយោបល់ផ្នែកបច្ចេកទេស គឺដើម្បីធានាថាដំណើរការសម្រាប់ការបង្កើតប្រព័ន្ធបោះឆ្នោតថ្មីមួយ ផ្តល់អាទិភាពដល់តម្រូវការរបស់អ្នកបោះឆ្នោតនៅពេលប្រើប្រាស់ទិន្នន័យត្រឹមត្រូវសម្រាប់ការធ្វើសម្រេចចិត្ត។ សម្រាប់ផ្នែកនៃគម្រោងការកំណត់ទីតាំងមណ្ឌលបោះឆ្នោត (VCPP) នៃគម្រោង VSAP នេះ គណៈកម្មាធិការនានាបានផ្លាស់ប្តូរការផ្តោតអារម្មណ៍លើបច្ចេកវិទ្យានិងការគិតពិចារណាអំពីភាពអាចប្រើបានចំពោះធាតុផ្សំទំហំដែលមានឥទ្ធិពលយ៉ាងខ្លាំងទៅលើលទ្ធភាពនៃមណ្ឌលបោះឆ្នោតដែលអាចសម្រេចបាន។

ដើម្បីទទួលបានមតិយោបល់ពីអ្នកជំនាញបច្ចេកទេសក្នុងវិស័យអ្នកបោះឆ្នោត និងឥរិយាបថអ្នកប្រើប្រាស់ តម្រូវការធ្វើដំណើរនិងការធ្វើដំណើរ ការវិភាគទំហំ និងវិទ្យាសាស្ត្រទិន្នន័យនោះ កម្មវិធី PlaceWorks បានធ្វើការជាមួយក្រុមការងារគម្រោង VSAP ដើម្បីរាប់បញ្ចូលជំនាញដែលពាក់ព័ន្ធជាច្រើនអំពីគណៈកម្មាធិការទាំងពីរ។ អ្នកជំនាញបច្ចេកទេសចំនួនប្រាំពីរនាក់មកពីសាកលវិទ្យាល័យរដ្ឋនិងការិយាល័យទិន្នន័យខោនធីត្រូវបានអញ្ជើញឱ្យចូលរួមក្នុងគណៈកម្មាធិការប្រឹក្សាយោបល់ផ្នែកបច្ចេកទេស VSAP ។ ស្មៀនក្រុងចំនួនប្រាំមួយនាក់ ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងគណៈកម្មាធិការប្រឹក្សាយោបល់ VSAP ផងដែរ។ លិខិតអញ្ជើញមានគោលបំណងរក្សាបានការធ្វើតំណាងតំបន់ភូមិសាស្ត្រនិងប្រជាជនចម្រុះប្រកបដោយសមភាព។

អ្នកពិគ្រោះយោបល់ផ្នែកបច្ចេកទេស បានជួបជាមួយគណៈកម្មាធិការទាំងនេះសរុបចំនួនប្រាំបួនដងក្នុងរយៈពេល 13 ខែ។ បន្ថែមពីលើគោលដៅរបស់គណៈកម្មាធិការដែលបានបង្កើតរួចហើយនេះ កម្មវិធី PlaceWorks បានពឹងផ្អែកលើសមាជិក៖

*គណៈកម្មាធិការប្រឹក្សាយោបល់ VSAP*

- ចែករំលែកការយល់ដឹងនិងការណែនាំសម្រាប់ការបង្កើតទីតាំងមណ្ឌលបោះឆ្នោត។
- កំណត់ឧបសគ្គភូមិសាស្ត្រឬប្រជាសាស្ត្រចំពោះការបោះឆ្នោតនៅទីតាំងនានាឬតាមរយៈប្រជាជនដែលងាយរងគ្រោះ។

*គណៈកម្មាធិការប្រឹក្សាយោបល់ផ្នែកបច្ចេកទេស VSAP*

- ពិនិត្យឡើងវិញ និងផ្តល់ប្រភពទិន្នន័យ។
- ពិនិត្យឡើងវិញនូវវិធីសាស្ត្រនៃការវិភាគទំហំ។
- ផ្តល់ទិន្នន័យបញ្ចូលនិងការណែនាំលើដំណើរការវិភាគអំពីតម្រូវការ។
- ផ្តល់ការណែនាំទូទៅទាក់ទងនឹងលក្ខណៈវិនិច្ឆ័យនៃមណ្ឌលបោះឆ្នោតនិងដំណើរការវាយតម្លៃ។

សូមមើលឧបសម្ព័ន្ធ C សម្រាប់ព័ត៌មានលម្អិតអំពីគណៈកម្មាធិការប្រឹក្សាយោបល់ផ្នែកបច្ចេកទេស និងគណៈកម្មាធិការប្រឹក្សាយោបល់ VSAP ។

#### 3.1.1 **សិក្ខាសាលាស្តីពីឧបករណ៍កំណត់ភាពសមស្របនៃទីតាំង**

បុគ្គលិកកម្មវិធី PlaceWorks និងអ្នកចុះឈ្មោះឬអ្នកកត់ត្រា/ស្មៀនខោនធី RR/CC បានរៀបចំសិក្ខាសាលាមួយដែលគណៈកម្មការទាំងពីរ ត្រូវបានអញ្ជើញឱ្យពិនិត្យឡើងវិញ និងផ្តល់មតិយោបល់លើវិធីសាស្ត្រនៃការអភិវឌ្ឍឧបករណ៍កំណត់ភាពសមស្របនៃទីតាំង។ សមាជិកគណៈកម្មាធិការ ក៏ត្រូវបានបង្ហាញផងដែរនូវសំណុំសេណារីយ៉ូដែលបានបង្ហាញពីការទាញយកហ្វ៊ីរ៉ូមលើផែនទីនៃឧបករណ៍ដែលអាចផ្តល់លទ្ធផលខុសៗគ្នានៅក្នុងការកំណត់ទីតាំងមណ្ឌលបោះឆ្នោតនៅទូទាំងខោនធី។ អ្នកពិគ្រោះយោបល់បានបង្ហាញនូវសេណារីយ៉ូ និងបានស្នើសុំមតិយោបល់អំពីការរៀបចំគំរូដែលពេញចិត្ត ដូចខាងក្រោម។

- ផ្ទត់គំនិតដែលមានស្រាប់។ សន្មតថាអ្នកបោះឆ្នោតនឹងបោះឆ្នោតនៅជិតផ្ទះរបស់ពួកគេ ហើយទាញយកហ្វ៊ីរ៉ូមលើផែនទីមានដង់ស៊ីតេប្រជាជនដែលមានច្រើនជាងមូលដ្ឋានទិន្នន័យដែលត្រូវការផ្សេងទៀត។
- ភាពងាយស្រួល។ សន្មតថាអ្នកបោះឆ្នោតនឹងបោះឆ្នោតនៅទីតាំងដែលងាយស្រួលបំផុត តាមបណ្តោយផ្លូវធ្វើដំណើរធម្មតារបស់ពួកគេទៅនិងមកពីកន្លែងធ្វើការ និងតាមទិសដៅផ្សេងទៀត។
- ការផ្តោតសំខាន់លើសេដ្ឋកិច្ចសង្គម។ ផ្តល់អាទិភាពដល់អគារនានានៅក្នុងតំបន់ដែលមានចំនួនប្រជាជនដែលជាក្រុមអ្នកតំណាងមិនគ្រប់គ្រាន់ជាប្រវត្តិសាស្ត្រ។

*លទ្ធផល*

ការផ្តល់អនុសាសន៍ដែលគួរឱ្យកត់សម្គាល់បំផុត ដែលទទួលបានពីសិក្ខាសាលានេះ បានលើកឡើងថាការទាញយកហ្វ៊ីរ៉ូមលើផែនទី ត្រូវបានកែសម្រួលដើម្បីកំណត់ទំហំតូចជាងចំពោះការទាញយកហ្វ៊ីរ៉ូមលើផែនទីនៃ “ទីតាំងស្នាក់នៅរបស់អ្នកបោះឆ្នោត” និងបង្កើនភាគរយការទាញយកហ្វ៊ីរ៉ូមលើផែនទីនៃ “ការបោះឆ្នោតមានកម្រិតទាបតាមការបោះឆ្នោតផ្ញើតាមប្រៃសណីយ៍” ។ ការកែសម្រួលនេះ នឹងផ្តោតការយកចិត្តទុកដាក់តិចតួចទៅលើការកំណត់ទីតាំងមណ្ឌលបោះឆ្នោតនៅជិតប្រជាពលរដ្ឋដែលរស់នៅ និងផ្តោតសំខាន់លើតំបន់នានាដែលអ្នកបោះឆ្នោតបានបង្ហាញចំណាប់អារម្មណ៍ក្នុងការបោះឆ្នោតដោយផ្ទាល់។ ការផ្តល់អនុសាសន៍នេះ ត្រូវបានអនុវត្ត ដែលជាលទ្ធផលនៅក្នុងបញ្ជីចុងក្រោយនៃទីតាំងមណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍។

### 3.2 ការស្ទង់មតិដែលមានសុពលភាពតាមស្ថិតិ និងក្រុមគោលដៅ

ក្រុមការងារគម្រោង VSAP បានសហការជាមួយអ្នកប្រឹក្សាយោបល់ផ្នែកយុទ្ធសាស្ត្រនិងស្រាវជ្រាវអំពីមតិយោបល់, សមាគម Fairbank, Maslin, Maullin, Metz & Associates (FM3) ដើម្បីធ្វើការសិក្សាមតិយោបល់សាធារណជនដែលអាចជួយបង្ហាញពីរបៀបដែលមណ្ឌលបោះឆ្នោតអាចត្រូវបែងចែកដោយស្មើភាពគ្នា នៅពេលបំពេញតាមចំណូលចិត្តអ្នកបោះឆ្នោតជាច្រើន។ ដំណាក់កាលនៃការចូលរួមនេះ មានគោលដៅដែលមានការស្ទង់មតិអ្នកបោះឆ្នោតដែលបានចុះឈ្មោះនៅខោនធី LA County និងការស្ទង់មតិលើកទីពីរក្នុងចំណោមប្រជាពលរដ្ឋដែលមិនបានចុះឈ្មោះ ដែលមានសិទ្ធិបោះឆ្នោត។

ការស្រាវជ្រាវនេះ បានស្វែងរកទីតាំងដែលប្រជាពលរដ្ឋរាយការណ៍ថាមានឆន្ទៈខ្ពស់ក្នុងការបោះឆ្នោត; ការសន្មតអំពីទីតាំងមណ្ឌលបោះឆ្នោតមួយ ដែលត្រូវបានចាត់ទុកថាមានសារៈសំខាន់បំផុត; ថ្ងៃប្រចាំសប្តាហ៍និងពេលវេលាប្រចាំថ្ងៃដែលប្រជាពលរដ្ឋនឹងអាចពេញចិត្តបោះឆ្នោត; និងនិន្នាការក្នុងចំណោមការបោះឆ្នោតអចិន្ត្រៃយ៍ដោយអ្នកបោះឆ្នោតផ្ញើតាមប្រៃសណីយ៍។

#### 3.2.1 **ក្រុមគោលដៅ**

ក្រុមគោលដៅត្រូវបានធ្វើឡើងនៅទីតាំងជាច្រើននៅទូទាំងខោនធី ដើម្បីទទួលបានមតិយោបល់ផ្សេងៗគ្នារបស់សហគមន៍ និងក្រុមខាងប្រជាសាស្ត្រផ្សេងៗគ្នា។ អ្នកពាក់ព័ន្ធផ្សេងៗគ្នាត្រូវបានគេស្វែងរក ដើម្បីផ្តល់ជូនព័ត៌មានទាក់ទងនឹងបទពិសោធន៍ និងចំណង់ចំណូលចិត្តនៃការបោះឆ្នោតរបស់ពួកគេ។

ក្រុមគោលដៅចំនួនប្រាំបី ត្រូវបានធ្វើឡើងនៅចន្លោះខែឧសភា និងខែមិថុនា ឆ្នាំ 2018។ ក្រុមចំនួនពីរត្រូវបានធ្វើឡើងក្នុងចំណោមអ្នកបោះឆ្នោតដែលមាននិន្នាការកម្រិតខ្ពស់; មួយក្រុមក្នុងចំណោមអ្នកបោះឆ្នោតដែលមាននិន្នាការកម្រិតទាប; មួយក្រុមក្នុងចំណោមអ្នកបោះឆ្នោតដែលមានអាយុពី 60 ដល់ 74 ឆ្នាំ; មួយក្រុមក្នុងចំណោមអ្នកបោះឆ្នោតដែលមានអាយុពី 18 ដល់ 30 ឆ្នាំ; មួយក្រុមក្នុងចំណោមអ្នកបោះឆ្នោតនិយាយភាសាអេស្ប៉ាញ; មួយក្រុមក្នុងចំណោមអ្នកបោះឆ្នោតនិយាយភាសាចិនកុកងឺ; និងមួយក្រុមក្នុងចំណោមប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត ប៉ុន្តែបច្ចុប្បន្នមិនបានចុះឈ្មោះនៅខោនធី Los Angeles County ។

#### 3.2.2 **ការស្ទង់មតិ**

ការស្ទង់មតិអ្នកបោះឆ្នោតត្រូវបានធ្វើឡើងនៅខែកក្កដា តាមគំរូចៃដន្យនៃអ្នកបោះឆ្នោតដែលបានចុះឈ្មោះចំនួន 2,414 នាក់ នៅក្នុងខោនធី Los Angeles County ។ ការស្ទង់មតិនានាត្រូវបានធ្វើឡើងតាមអ៊ីនធឺណិត និងតាមទូរស័ព្ទ (ទូរស័ព្ទចល័ត និងទូរស័ព្ទលើតុ) ហើយអាចមានជាភាសាអង់គ្លេស អេស្ប៉ាញ ចិន និងកូរ៉េ។ កម្រិតកំហុសសម្រាប់ការស្ទង់មតិនេះ គឺ ±2.6 ភាគរយ នៅក្នុងកម្រិតមានទំនុកចិត្ត 95 ភាគរយ។

ការស្ទង់មតិចំនួនប្រជាជនដែលមិនបានចុះបញ្ជីត្រូវបានធ្វើឡើងនៅចន្លោះខែសីហា និងខែកញ្ញាឆ្នាំ 2018 តាមការប៉ាន់ស្មានចំនួនប្រជាពលរដ្ឋនៅខោនធី 501 នាក់ នៅខោនធី Los Angeles County ដែលមានសិទ្ធិបោះឆ្នោត ប៉ុន្តែបច្ចុប្បន្នមិនបានចុះឈ្មោះ

បោះឆ្នោតទេ។ ការស្ទង់មតិនានាត្រូវបានធ្វើឡើងតាមអ៊ីនធឺណិត និងតាមទូរស័ព្ទ (ទូរស័ព្ទចល័ត និងទូរស័ព្ទលើតុ) ហើយអាចមានជាភាសាអង់គ្លេស អេស្ប៉ាញ ចិន និងកូរ៉េ។

### 3.2.3 **លទ្ធផល**

*បោះឆ្នោតនៅឯណា*

ក្រុមគោលដៅនិងការស្ទង់មតិបានបង្ហាញថាអ្នកបោះឆ្នោតភាគច្រើនចូលចិត្តបោះឆ្នោតនៅទីតាំងជិតផ្ទះ ប៉ុន្តែមានអ្នកបោះឆ្នោតជាច្រើនទៀត មិនជំទាស់នឹងការបោះឆ្នោតនៅទីតាំងផ្សេងទៀត ដែលនៅជិតកន្លែងដែលពួកគេទៅញឹកញាប់នោះទេ។ អ្នកបោះឆ្នោតដែលបានចុះឈ្មោះទាំងអស់ 77 ភាគរយនៅទូទាំងខោនធី មានបំណងទៅបោះឆ្នោត ឬទម្លាក់សន្លឹកឆ្នោតរបស់ពួកគេនៅទីតាំងមួយនៅជិតផ្ទះរបស់ពួកគេ (សូមមើលរូបភាព 12)។ ក្នុងចំណោមអ្នកបោះឆ្នោត 42 ភាគរយ បាននិយាយថាពួកគេនឹងគិតពីចារណាបោះឆ្នោតនៅជិតកន្លែងធ្វើការរបស់ពួកគេ ហើយ (ការស្ទង់មតិសរុប 25 ភាគរយ) ភាគច្រើនបាននិយាយថាការបោះឆ្នោតរបៀបនេះ គឺជាជម្រើសទីពីររបស់ពួកគេ។ ចំណុចស្រដៀងគ្នានេះដែរ អ្នកបោះឆ្នោត 37 ភាគរយ បាននិយាយថាពួកគេនឹងបោះឆ្នោតនៅកន្លែងមួយដែលនៅជិតកន្លែងដែលពួកគេទិញទំនិញ ឬដំណើរការនៅកន្លែងធ្វើកិច្ចការអ្វីមួយ ប៉ុន្តែពួកគេភាគច្រើនបានជ្រើសរើសការបោះឆ្នោតរបៀបនេះ គឺជាជម្រើសទីពីររបស់ពួកគេ។ មានអ្នកបោះឆ្នោតតិចតួចបានជ្រើសរើសនៅជិតកូនៗរបស់ពួកគេ ឬសាលារៀនផ្ទាល់ខ្លួនរបស់ពួកគេ ឬនៅជិតជម្រើសកន្លែងកម្សាន្តឬការសម្តែង។

Figure 12. ទីតាំងដែលមានបំណងចង់ទៅបោះឆ្នោត ឬការបោះឆ្នោតផ្ញើតាមប្រៃសណីយ៍ (បានចាត់ថ្នាក់ជាជម្រើសទីមួយនិងទីពីរ)




ជាទូទៅអ្នកបោះឆ្នោតក៏បានបង្ហាញពីបំណងចង់បន្តបោះឆ្នោតនៅតាមទីធ្លានានាដែលធ្លាប់ប្រើជាកន្លែងបោះឆ្នោតតាមទំនៀមទម្លាប់នាពេលកន្លងមក ដូចជាបណ្ណាល័យសាធារណៈ សាលារៀន មណ្ឌលសហគមន៍ ឬមណ្ឌលកម្សាន្ត និងសាលាក្រុង (មើលតារាង 7) ។ ទោះជាយ៉ាងណាក៏ដោយ ក៏អ្នកបោះឆ្នោតមិនជំទាស់ទាំងស្រុងចំពោះការបោះឆ្នោតនៅកន្លែងដែលមានការផ្លាស់ប្តូរច្រើនផងដែរ ដូចជាឧទ្យានសាធារណៈ រថយន្តក្រុងឬរថយន្តដឹកទំនិញប្រើជាមណ្ឌលបោះឆ្នោតចល័ត ឬនៅកន្លែងដែលពួកគេទិញទំនិញ។ ផ្នែកផ្សេងៗគ្នានៃចំនួនប្រជាពលរដ្ឋ មានលក្ខណៈបើកចំហគំនិតយោបល់កាន់តែច្រើនចំពោះការបោះឆ្នោតនៅទីតាំងជាក់លាក់នៅតាមកន្លែងផ្សេងៗទៀត។ ឧទាហរណ៍អ្នកបោះឆ្នោតដែលមានអាយុពី 18 ដល់ 49 ឆ្នាំ មានលក្ខណៈបើកចំហគំនិតយោបល់ជាងអ្នកដែលមានអាយុចាប់ពី 50 ឆ្នាំឡើងទៅ ដើម្បីបោះឆ្នោតនៅទីធ្លាតាមទំនៀមទម្លាប់តិចតួច ដូចជាមណ្ឌលបោះឆ្នោតចល័ត។

Table 7. ប្រភេទទីតាំងដែលមានបំណងចង់ទៅបោះឆ្នោត

| ទីកន្លែង | មានបំណងចង់បោះឆ្នោតនៅទីនេះ |
|---|---|
| បណ្ណាល័យសាធារណៈ | 91% |
| សាលាបឋមសិក្សា មធ្យមសិក្សា ឬវិទ្យាល័យនៅមូលដ្ឋាន | 88% |
| មជ្ឈមណ្ឌលសហគមន៍ ឬមជ្ឈមណ្ឌលកម្សាន្ត | 80% |
| មហាវិទ្យាល័យ ឬសាកលវិទ្យាល័យសហគមន៍ | 76% |
| សាលាក្រុងនៅមូលដ្ឋាន | 73% |
| ឧទ្យានសាធារណៈ | 71% |
| ទីធ្លា ឬទីលានសាធារណៈ | 70% |
| រថយន្តក្រុងឬរថយន្តដកទំនិញប្រើជាមណ្ឌលបោះឆ្នោតចល័ត | 70% |
| មជ្ឈមណ្ឌលទិញទំនិញ ឬផ្សារទំនើប | 69% |
| ផ្សារទំនើប | 69% |

បំណងចង់ទៅបោះឆ្នោតនៅកន្លែងទាំងនេះ ជាញឹកញាប់មិនជាប់ទាក់ទងថាតើអ្នកបោះឆ្នោតបានទៅមើលទីតាំងខាងក្រៅសម្រាប់ការបោះឆ្នោតញឹកញាប់ប៉ុណ្ណាទេ។ ឧទាហរណ៍សាលាក្រុងនៅមូលដ្ឋានជាទីកន្លែងមានប្រជាប្រិយភាព ដែលអ្នកបោះឆ្នោតមានចំណងចងទៅបោះឆ្នោត ប៉ុន្តែការស្ទង់មតិនិងអ្នកចូលរួមដែលជាក្រុមគោលដៅថាវាមិនមែនជាកន្លែងដែលគេទៅញឹកញាប់ទេ។ ហេតុផលដែលអ្នកបោះឆ្នោតជាទូទៅ ចូលចិត្តកន្លែងទាំង 10 ខាងលើនេះ អាចសន្មតថាមកពីសុវត្ថិភាពផ្ទាល់ខ្លួន សិទ្ធិឯកជនភាព ភាពអាចប្រើបានចំណតយានយន្ត និងការចូលប្រើសម្រាប់ប្រជាពលរដ្ឋដែលមានពិការភាព។

*បោះឆ្នោតនៅពេលណា*

អ្នកបោះឆ្នោតមានចំណូលចិត្តខុសៗគ្នាផងដែរចំពោះពេលវេលាដែលពួកគេបោះឆ្នោត ឬការបោះឆ្នោតផ្ញើតាមប្រៃសណីយ៍។ ទោះបីជាអ្នកបោះឆ្នោត 37 ភាគរយចង់បោះឆ្នោត ឬទម្លាក់សន្លឹកឆ្នោតរបស់ពួកគេនៅថ្ងៃបោះឆ្នោតក៏ដោយ ក៏អ្នកបោះឆ្នោត 63 ភាគរយចង់បោះឆ្នោតមុនថ្ងៃបោះឆ្នោតផងដែរ។ អ្នកបោះឆ្នោតខ្លះក៏មានបំណងចង់ទៅបោះឆ្នោតផងដែរ នៅអំឡុងពេលតាមទំនៀមទម្លាប់ ដូចជានៅពេលល្ងាចចន្លោះពីម៉ោង 8 និង 10 យប់ (សូមមើលរូបភាព 13)។

Figure 13. ថ្ងៃនិងពេលវេលាដែលពេញចិត្តទៅបោះឆ្នោត



**ម៉ោងដែលពេញចិត្ត***

| ម៉ោង | ប្រហែល % |
|---|---|
| 5 ព្រឹក–7 ព្រឹក | 29% |
| 7 ព្រឹក–8 ល្ងាច | 89% |
| 8 ល្ងាច–10 យប់ | 54% |
| 10 យប់–12 យប់ | 22% |
| 12 ព្រឹក–5 ព្រឹក | 11% |

** ទទួលយកការឆ្លើយតបជាច្រើន*

*និន្នាការប្រជាសាស្ត្រ*

ការសិក្សានេះ បានរកឃើញថាមានភាពខុសគ្នាបន្តិចបន្តួចចំពោះចំណូលចិត្តក្នុងការជ្រើសរើសទីតាំង ពេលវេលា និងលក្ខណៈពិសេសរវាងអ្នកបោះឆ្នោតដែលបានចុះឈ្មោះបច្ចុប្បន្ន និងបុគ្គលដែលមានសិទ្ធិបោះឆ្នោត ប៉ុន្តែបច្ចុប្បន្នមិនទាន់បានចុះឈ្មោះ។ អ្នកចូលរួមដែលមិនបានចុះឈ្មោះនឹងអ្នកបោះឆ្នោតដែលបានចុះឈ្មោះ បានជ្រើសរើសយកទីតាំងចំនួន 10 កន្លែងដូចគ្នា ដែលពួកគេទំនងជាទៅបោះឆ្នោតភាគច្រើន។ ភាពខុសគ្នាចម្បងៗរវាងចំនួនប្រជាជនទាំងពីរក្រុម គឺថាចំណាត់ថ្នាក់សម្រាប់ទីតាំង ពេលវេលា និងសារៈសំខាន់នៃលក្ខណៈពិសេស គឺមានសារៈសំខាន់តិចតួចក្នុងចំណោមអ្នកចូលរួមដែលមិនបានចុះឈ្មោះជាងអ្នកបោះឆ្នោតដែលបានចុះឈ្មោះ។

ទោះយ៉ាងណាក៏ដោយ ក៏គួរកត់សម្គាល់ថាអ្នកបោះឆ្នោតដែលមិនបានចុះឈ្មោះ បានបង្ហាញថាពួកគេទំនងជានឹងគិតពិចារណាចុះឈ្មោះបោះឆ្នោត ប្រសិនបើពួកគេដឹងថាមណ្ឌលបោះឆ្នោតនឹងផ្តល់ជូនការចុះឈ្មោះភ្លាមៗនៅនឹងកន្លែង ហើយថានឹងមានភាពបត់បែនកាន់តែច្រើនចំពោះពេលវេលានិងកន្លែងដែលពួកគេអាចបោះឆ្នោតបានដែលផ្ទុយពីការចុះឈ្មោះជាមុន ហើយមានពេលតែមួយថ្ងៃ ដើម្បីបោះឆ្នោត។

### 3.2.4 ការបង្ហាញពីលទ្ធផលពាក់ព័ន្ធ

លទ្ធផលស្ទង់មតិរបស់សហគមន៍បានដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រេចចិត្តលើការទាញយកហ្វ៊ុមលើផែនទីនៃមូលដ្ឋានទិន្នន័យដែលត្រូវការផ្សេងៗគ្នា ដែលបានប្រើប្រាស់ដើម្បីកំណត់ការបែងចែកមណ្ឌលបោះឆ្នោតប្រកបដោយសមធម៌ទូទាំងខោនធី Los Angeles County ។ មតិយោបល់ដែលបង្ហាញពីចំណូលចិត្តសម្រាប់ការបោះឆ្នោតនៅជិតផ្ទះ និងកន្លែងដែលធ្លាប់ស្គាល់ត្រូវបានអនុវត្ត ដើម្បីបង្កើតការទាញយកហ្វ៊ុមលើផែនទីនៅក្នុងឧបករណ៍កំណត់ភាពសមស្របនៃទីតាំង (Site Suitability Tool) ហើយត្រូវបានគិតពិចារណាអំពីពេលវេលាបង្កើតសេណារីយោគំរូដំបូង ដើម្បីបង្ហាញដល់គណៈកម្មាធិការប្រឹក្សាយោបល់ផ្នែកបច្ចេកទេស និងការប្រឹក្សាយោបល់ VSAP ។ ឧបសម្ព័ន្ធ D លទ្ធផលសំខាន់ៗអំពីក្រុមគោលដៅ និងការស្ទង់មតិ។

## 3.3 កិច្ចប្រជុំសហគមន៍នៅទូទាំងខោនធី

ភាពជាដៃគូជាមួយអ្នកប្រឹក្សាយោបល់អំពីការចូលរួមសហគមន៍និងដៃគូសហគមន៍ចំនួន 40, ក្រុមការងារគម្រោង VSAP បានរៀបចំការផ្សព្វផ្សាយនៅជុំទីពីរ ដែលជាលទ្ធផលបានទទួលពីកិច្ចប្រជុំជិត 70 នៅទូទាំងខោនធី។ កិច្ចប្រជុំទាំងនេះ មានគោលបំណងពន្យល់អំពីច្បាប់ VCA, គំរូមណ្ឌលបោះឆ្នោត និងប្រព័ន្ធថ្មីរបស់ខោនធីជូនដល់សាធារណជនទូទៅ។ ពួកគេបានអប់រំអ្នកបោះឆ្នោតដែលមានស្រាប់ និងអ្នកដែលមិនមានសិទ្ធិបោះឆ្នោតអំពីការលើកកម្ពស់បទពិសោធន៍អ្នកបោះឆ្នោត នឹងការបញ្ចូលទិន្នន័យដែលមានអត្ថន័យ ដើម្បីជូនដំណឹងដល់ដំណើរការវិភាគបច្ចេកទេស។

### 3.3.1 អង្គការដៃគូ

ការចូលរួមជាមួយសាធារណជនសម្រាប់គំនិតផ្តួចផ្តើមផ្សព្វផ្សាយជាលក្ខណៈទ្រង់ទ្រាយធំណាមួយ តម្រូវឱ្យមានវិធីសាស្ត្រជាច្រើន ដែលរួមមានការភ្ជាប់ទំនាក់ទំនងដែលមានអត្ថន័យដល់អ្នកដឹកនាំសហគមន៍និងអ្នករៀបចំ ដែលបានបង្កើតកេរ្តិ៍ឈ្មោះនិងការយល់ដឹងអំពីវប្បធម៌ទៅក្នុងលក្ខខណ្ឌនិងបញ្ហាបារម្ភនៅមូលដ្ឋាន។ RR/CC បានស្នើសុំការដាក់ពាក្យសុំពីដៃគូសហគមន៍មូលដ្ឋាន ដែលមានទំនាក់ទំនងយ៉ាងល្អនៅក្នុងសហគមន៍ និងមានចំណាប់អារម្មណ៍ក្នុងការស្វែងយល់អំពីច្បាប់ VCA និងគម្រោងកំណត់ទីតាំងមណ្ឌលបោះឆ្នោត។ ការដាក់ពាក្យសុំតាមអនឡាញអាចមាននៅលើគេហទំព័រ VSAP ដែលមានរយៈពេល 60 ថ្ងៃ។ នៅអំឡុងពេលនេះ អង្គការសហគមន៍ (CBOs) ជាច្រើន បានដាក់ពាក្យសុំដែលពិពណ៌នាអំពីគុណភាពដែលធ្វើឱ្យពួកគេទទួលបានភាពសមរម្យដើម្បីចូលរួម។ RR/CC បានពិនិត្យឡើងវិញនូវពាក្យសុំជិត 80 សម្រាប់ការផ្សព្វផ្សាយនៅជុំទីពីរ។ អ្នកដាក់ពាក្យសុំ តម្រូវឱ្យមានការពិពណ៌នាជាលាយលក្ខណ៍អក្សរ នឹងការធ្វើបទសម្ភាសន៍តាមទូរស័ព្ទជាបន្តបន្ទាប់ផងដែរ៖

- សេវាកម្ម បទពិសោធន៍ និងសមត្ថភាពរបស់អង្គការ
- ទំនាក់ទំនងជាមួយតំបន់សេវាកម្មភូមិសាស្ត្រ
- វិធីសាស្ត្រផ្សព្វផ្សាយ និងការជួបសហគមន៍
- បេសកកម្មនឹងអ្នកពាក់ព័ន្ធរបស់អង្គការ
- ទំនាក់ទំនងដែលមានស្រាប់ជាមួយដៃគូសហគមន៍ (រួមមាន RR/CC)

ដំណើរការនៃការដាក់ពាក្យសុំនឹងការធ្វើបទសម្ភាសន៍ បាននាំឱ្យមានការសហការជាមួយអង្គការសហគមន៍ចំនួន 40 CBOs ដែលមានទំហំខុសៗគ្នា ដោយគិតចាប់ពីក្រុមសហគមន៍មូលដ្ឋានរហូតដល់ក្រុមតស៊ូមតិថ្នាក់ជាតិធំៗ និងបេសកកម្មផ្សេងៗគ្នា ដែលរួមមានសិទ្ធិបោះឆ្នោត និងយុត្តិធម៌សាធារណៈ។ សូមមើលឧបសម្ព័ន្ធ E និង F សម្រាប់កម្រងសំណួរដៃគូ និងលិខិតអញ្ជើញ។

អង្គការដៃគូបានធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមការងារគម្រោង VSAP និងកម្មវិធី PlaceWorks ដើម្បីទទួលបានការបណ្តុះបណ្តាលនិងការណែនាំដែលនឹងរៀបចំឱ្យពួកគេបញ្ចូលទិន្នន័យស្មុគស្មាញ និងដំណើរការវាយតម្លៃនានាដល់សាធារណជនទូទៅ។ ដៃគូដែលបានជ្រើសរើស ត្រូវបានប្រគល់ជូនភារកិច្ចដូចខាងក្រោម៖

- អនុវត្តការផ្សព្វផ្សាយជាសាធារណៈដោយផ្តោតលើតំបន់សិក្សាដែលបានកំណត់។
- ប្រមូលផ្តុំដៃគូសហគមន៍ ដើម្បីចូលរួមកិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយ។
- ជ្រើសរើសទីកន្លែង និងរៀបចំ និងគ្រប់គ្រងរាល់ភស្តុភារកិច្ចប្រជុំទាំងអស់ ដែលរួមមាន ការរៀបចំនិងការបង្ហាញសេចក្តីពិស្តារ។
- ចូលរួមវគ្គបណ្តុះបណ្តាលជាក្រុមមួយ អំពីទិដ្ឋភាពទូទៅនៃគម្រោង ខ្លឹមសារបទបង្ហាញ ការផ្ញើសារ និងសម្ភារៈផ្សព្វផ្សាយ។
- កិច្ចប្រជុំសហគមន៍អំពីអគារ
- របាយការណ៍អំពីលទ្ធផលកិច្ចប្រជុំ។

អង្គការដៃគូបានទទួលថវិកាចំនួន $2,000 ដុល្លារនៅកិច្ចប្រជុំនីមួយៗសម្រាប់ការចំណាយនានា ដូចជាកម្លាំងពលកម្មបុគ្គលិក ការបោះពុម្ព អាហារសម្រន់និងភេសជ្ជៈ និងរង្វាន់ និងការចែកអំណោយ។ ដើម្បីកាត់បន្ថយការចំណាយរបស់អង្គការ ក្រុមការងារគម្រោង VSAP និងកម្មវិធី PlaceWorks បានផ្តល់ជូនសម្ភារៈបោះពុម្ព ការផ្តល់សិទ្ធិអនុញ្ញាតប្រើអគារដោយឥតគិតថ្លៃ បច្ចេកវិទ្យា និងការគាំទ្ររបស់បុគ្គលិកតាមការស្នើសុំ។ ក្រុមការងារគម្រោង VSAP បានភ្ជាប់ទំនាក់ទំនងតាមបណ្តាអង្គការជាដៃគូទៅនឹងស្មៀនក្រុង ដើម្បីផ្តល់ការគាំទ្រដល់បុគ្គលិកនិងការផ្សព្វផ្សាយបន្ថែម។

### 3.3.2 ការប្រើប្រាស់ភាសា

ដើម្បីធានាដល់ការទទួលបានដោយសមធម៌ទៅនឹងដំណើរការចូលរួមរបស់សហគមន៍នោះ ក្រុមការងារគម្រោង VSAP បានធ្វើការវិភាគលើការទទួលបានភាសានិងសេវាកម្មបកប្រែក្នុងពេលដំណាលគ្នា។ កម្មវិធី PlaceWorks បានធ្វើការវិភាគប្រជាសាស្ត្រដោយប្រើទិន្នន័យជំរឿន ដែលកំណត់អត្តសញ្ញាណសហគមន៍ដែលនៅឆ្ងាយពីគេ ដែលមានបញ្ហាភាសា។ តាមរយៈការវិភាគនេះ កម្មវិធី PlaceWorks បានដឹងថាចំនួនប្រជាពលរដ្ឋនិយាយភាសាអេស្ប៉ាញមានច្រើននៅខោនធីនោះ មានតម្រូវការខ្ពស់សម្រាប់ការបកប្រែភាសានៅទូទាំងតំបន់ បន្ទាប់មកមានភាសាចិន និងកូរ៉េ។

កិច្ចប្រជុំសហគមន៍នៅជុំទីមួយ បានផ្តល់ការបកស្រាយភាសាអេស្ប៉ាញក្នុងពេលដំណាលគ្នាជូនដល់ 12 តំបន់, ចិន 2 តំបន់ នឹងកូរ៉េ 1 តំបន់។ ការគាំទ្រភាសាផ្សេងទៀត ត្រូវបានផ្តល់ដោយបុគ្គលិកអង្គការសហគមន៍ CBOs ឬខោនធី ដែលបានធានាយ៉ាងហោចណាស់មានអ្នកសម្របសម្រួលកិច្ចប្រជុំម្នាក់ អាចនិយាយបានយ៉ាងស្ទាត់ជំនាញជាភាសានានាដែលបានរកឃើញនៅក្នុងការស្រាវជ្រាវនេះ។

សម្រាប់កិច្ចប្រជុំនៅជុំទីពីរ វិធីសាស្ត្រស្រាវជ្រាវត្រូវបានកែសម្រួល ដើម្បីបញ្ចូលមតិយោបល់ពីសមាជិកសហគមន៍ អង្គការដៃគូ និងបុគ្គលិកខោនធី ដែលមានបទ

ពិសោធន៍ក្នុងការចុះផ្សព្វផ្សាយទូទាំងខោនធី។ មតិយោបល់នេះ បានស្នើសុំការបកប្រែភាសាក្នុងពេលដំណាលគ្នាជាភាសាបន្ថែម ដើម្បីឈានដល់ការប្រើភាសាជនជាតិភាគតិច ដែលអាចមិនមាននៅអំឡុងពេលកិច្ចប្រជុំនៅជុំទីមួយទេ។ នៅអំឡុងពេលផ្សព្វផ្សាយនៅជុំទីពីរ ការបកប្រែភាសាក្នុងពេលដំណាលគ្នា ត្រូវបានផ្តល់ជូន 20 ភាសា ដែលបានបង្ហាញនៅក្នុងតារាង 8 ។ សូមមើលឧបសម្ព័ន្ធ G សម្រាប់វិធីសាស្ត្រចូលប្រើភាសា។



Table 8. បញ្ជីកិច្ចប្រជុំដែលបានអនុវត្ត

| អង្គការទទួលកិច្ចប្រជុំ | ទីកន្លែងប្រជុំ | ការបកប្រែភាសាក្នុងពេលដំណាលគ្នា |
|---|---|---|
| **កិច្ចប្រជុំលើកទី 1 (វិច្ឆិកា 16, 2018 - មករា 19, 2019)** | | |
| SBCC Thrive | Compton | Spanish |
| Neighborhood Empower LA/CA Common Cause | Granada Hills | N/A |
| Pacoima Beautiful | Pacoima | Spanish |
| CAUSE | Walnut | N/A |
| Neighborhood Empower LA/CA Common Cause | North Hollywood | Spanish |
| Neighborhood Empower LA/CA Common Cause | Los Angeles | N/A |
| California Common Cause | Sherman Oaks | Spanish |
| CAUSE | Artesia | Spanish |
| SBCC Thrive | Long Beach | N/A |
| California Common Cause | Redondo Beach | N/A |
| NALEO | Los Angeles | Spanish |
| Korean American Coalition | Los Angeles | Korean |
| California Common Cause | Inglewood | N/A |
| Coalition for Humane Immigrant Rights | Lancaster | N/A |
| Armenian National Committee-Pasadena Chapter | Pasadena | N/A |
| Armenian National Committee-Western | Glendale | N/A |
| Black Women for Wellness | Palmdale | Spanish |
| SBCC Thrive | Wilmington | N/A |
| Black Women for Wellness | Newhall | N/A |
| League of Women Voters-Los Angeles | Malibu | N/A |
| League of Women Voters-Los Angeles | Canoga Park | N/A |
| NALEO | Claremont | N/A |
| Black Women for Wellness | Los Angeles | Spanish |
| Armenian National Committee-Crescenta Valley | La Crescenta | N/A |
| California Common Cause | Pasadena | N/A |
| CAUSE | Arcadia | Spanish, Chinese |
| United Cerebral Palsy of Los Angeles, Ventura and Santa Barbara Counties | Culver City | N/A |
| Arts for LA | Los Angeles | Spanish |
| NALEO | Montebello | Spanish, Chinese |
| National Iranian American Council | Beverly Hills | N/A |
| League of Women Voters--Whittier | Whittier | N/A |
| Coalition for Humane Immigrant Rights | Huntington Park | Spanish |
| National Iranian American Council | Reseda | N/A |
| **កិច្ចប្រជុំលើកទី 2 (ឧសភា 2, 2019 - មិថុនា 29, 2019)** | | |
| League of Women Voters, Los Angeles | Porter Ranch | N/A |
| Disabled Resource Center | Long Beach | American Sign Language |
| Long Beach Gray Panthers | Long Beach | Khmer |
| League of Women Voters, Los Angeles | Santa Monica | N/A |
| Glassell Park Improvement Association | Los Angeles | Armenian |
| Black Women for Wellness | CA 90037 | N/A |
| Black Women for Wellness | Carson | Spanish |
| League of Women Voters, Torrance Area | Torrance | Japanese |
| United Cerebral Palsy of Los Angeles and Disability Rights California | Culver City | American Sign Language |
| Armenian National Committee of America, Crescenta Valley Chapter | Studio City | Thai |
| Southern California Resource Services for Independent Living | Hawaiian Gardens | Hindi |
| Pat Brown Institute for Public Affairs at Cal State LA | Downtown Los Angeles | តាហ្គាឡុក |
| NALEO Educational Fund | La Verne | N/A |
| Asian Americans Advancing Justice (AAAJ) & RR/CC | Covina | N/A |

| អង្គការទទួលកិច្ចប្រជុំ | ទីកន្លែងប្រជុំ | ការបកប្រែភាសាក្នុងពេលដំណាលគ្នា |
|---|---|---|
| Southern California Resource Services for Independent Living | Norwalk | N/A |
| Armenian National Committee of America, Western Chapter | Burbank | N/A |
| California Common Cause | San Gabriel | N/A |
| Armenian National Committee of America, Pasadena Chapter | Pasadena | Chinese<br>Spanish |
| California Common Cause | West Hollywood | Russian |
| NALEO Educational Fund | Los Angeles | Chinese<br>Vietnamese<br>Spanish |
| Monrovia Area Partnership (MAP) Program | Los Angeles | N/A |
| Black Women for Wellness | Palmdale | Spanish |
| First African Methodist Episcopal Church (FAME) and Alpha Kappa Alpha (AKA) | Los Angeles | Korean |
| League of Women Voters, Los Angeles | Calabasas | N/A |
| South Bay Counseling Center (SBCC) Thrive LA | Harbor City | N/A |
| Southeast Los Angeles (SELA) Collaborative | South Gate | Spanish |
| Black Women for Wellness | Santa Clarita | N/A |
| South Bay Counseling Center (SBCC) Thrive LA | Hawthorne | Spanish |
| FarsiVoter | Encino | Farsi |
| South Bay Counseling Center (SBCC) Thrive LA | North Hills | N/A |
| Lake Los Angeles Park Association | Littlerock | American Sign Language,<br>Spanish |
| Black Women for Wellness | Northridge | N/A |
| Pacoima Beautiful | Pacoima | Spanish |
| InnerCity Struggle | Los Angeles | Spanish |

### 3.3.3 **ការចូលរួមសហគមន៍នៅជុំទីមួយ**

កិច្ចប្រជុំសហគមន៍នៅជុំទីមួយ មានគោលបំណងពន្យល់អំពីច្បាប់ VCA និងគំរូមណ្ឌលបោះឆ្នោតថ្មី ក៏ដូចជាដើម្បីស្នើសុំមតិយោបល់អំពីអគារនៃមណ្ឌលបោះឆ្នោតដែលមានសក្តានុពល។ ទិន្នន័យត្រូវបានបង្ហាញដោយប្រើតារាងនិងផែនទីដែលងាយយល់។ អ្នកសម្របសម្រួលកិច្ចប្រជុំបានផ្តល់ការណែនាំអំពីការបង្រៀនប្រើប្រាស់វិបសាយតំណភ្ជាប់តាមអនឡាញ និងការសន្ទនាមួយទល់នឹងមួយ ដើម្បីឆ្លើយសំណួរណាមួយដែលមិនទាន់បានដោះស្រាយ។ អ្នកចូលរួមអាចផ្តល់មតិយោបល់នឹងសំណូមពរតាមតាមរយៈវិបសាយតំណភ្ជាប់អនឡាញ ឬតាមការប្រើកាតមតិយោបល់សរសេរជាលាយលក្ខណ៍អក្សរផងដែរ។ អ្នកចូលរួមត្រូវបានស្នើឱ្យបំពេញការស្ទង់មតិមួយ ដែលផ្តោតសំខាន់លើកន្លែងដែលអ្នកឆ្លើយសំណួរមានបំណងចង់ទៅបោះឆ្នោត នឹងរបៀបដែលពួកគេមានបំណងចូលទៅមណ្ឌលបោះឆ្នោតដែលពួកគេពេញចិត្ត។ សូមមើលឧបសម្ព័ន្ធ H សម្រាប់ព័ត៌មានលម្អិតស្តីពីលទ្ធផលនៃការចូលរួមនៅជុំទីមួយ។

*លទ្ធផលនៃការស្ទង់មតិ*

អ្នកចូលរួមភាគច្រើននៅកិច្ចប្រជុំទាំងនេះ (71 ភាគរយ) បានរាយការណ៍ថាពួកគេចង់បោះឆ្នោតនៅជិតផ្ទះ ហើយអ្នកចូលរួម 7 ភាគរយចង់ទៅបោះឆ្នោតនៅជិតកន្លែងធ្វើការរបស់ពួកគេ នឹងអ្នកចូលរួម 18 ភាគរយបើកចំហគំនិតយបល់បោះឆ្នោតនៅទីតាំងផ្សេងៗគ្នា ហើយអ្នកចូលរួម 4 ភាគរយចង់ទៅបោះឆ្នោតផ្ញើតាមប្រៃសណីយ៍។ វិធីដែលអ្នកចូលរួមនឹងចូលទៅទីតាំងបោះឆ្នោតគឺអ្នកចូលរួម 65 ភាគរយបានលើកឡើងថារថយន្តគឺជាមធ្យោបាយធ្វើដំណើរដែលពួកគេចង់បាន; 22 ភាគរយចូលចិត្តប្រើច្រើនមុខ ដូចជាកង់ រថភ្លើង រថយន្តក្រុង រថយន្ត និងការដើរ; 8 ភាគរយចូលចិត្តដើរ; និង 5 ភាគរយចូលចិត្តទាំងកង់ រថភ្លើង ឬរថយន្តក្រុង។

Figure 14. ទីកន្លែងបោះឆ្នោតដែលចង់បាន




Figure 15. ប្រភេទមធ្យោបាយធ្វើដំណើរដែលចង់បាន






*លក្ខណ:សហគមន៍*

អ្នកចូលរួមត្រូវបានអញ្ជើញឱ្យចូលរួមក្នុងសកម្មភាពមួយដែលស្វែងរកមតិយោបល់អំពីស្ថានភាពសហគមន៍ទូទៅ និងរបៀបដែលស្ថានភាពទាំងនោះ ដែលមានឥទ្ធិពលដល់កន្លែងដែលប្រពលរដ្ឋមានបំណងចង់ទៅបោះឆ្នោត។ អ្នកចូលរួមត្រូវបានគេស្នើសុំឱ្យគិតពិចារណាលើលក្ខណ:នានា ដូចជាភ្លើងបំភ្លឺ ផ្លូវធ្វើដំណើរដែលអាចចូលបាន ទីតាំងនៃកន្លែងប្រមូលផ្តុំពេញនិយម ស្ថានភាពចំណតយានយន្ត និងមានអ្វីជាច្រើនទៀត។

ពួកគេបានដាក់ស្ទិកឃ័រក្រដាសបិទពណ៌បៃតង និងក្រហម នៅកន្លែងដែលពួកគេនឹងអាចទៅបោះឆ្នោត ឬមិនមានអារម្មណ៍កក់ក្ដៅចំពោះការបោះឆ្នោតដោយផ្អែកលើលក្ខណៈទាំងនោះ។

ស្ទិកឃ័រក្រដាសបិទភាគច្រើនមានពណ៌បៃតង ហើយជាទូទៅត្រូវបានគាំទ្រជាអគារជាក់លាក់ ឬប្រភេទអគារ។ អគាររដ្ឋាភិបាល ឧទ្យាន និងកន្លែងកម្សាន្ត និងព្រះវិហារ ត្រូវបានគេប្រើជាទូទៅក្នុងចំណោមកន្លែងនានាដែលគាំទ្រដោយស្ទិកឃ័រក្រដាសបិទពណ៌បៃតង។ នៅកិច្ចប្រជុំជាច្រើន អ្នកចូលរួមបានដាក់ស្ទិកឃ័រក្រដាសបិទពណ៌ក្រហមនៅជិតសាលារៀនដែលមានចំនួនគួរឱ្យកត់សម្គាល់។ ស្ទិកឃ័រក្រដាសបិទទាំងនេះ បានគាំទ្រមតិយោបល់ដែលថាសាលារៀន មិនត្រូវបានគេចូលចិត្តធ្វើជាទីតាំងបោះឆ្នោតដោយសារតែមានបញ្ហាបារម្ភពីចំនួនប្រជាពលរដ្ឋដ៏ច្រើន និងសុវត្ថិភាព។ ស្ទិកឃ័រក្រដាសបិទពណ៌ក្រហមត្រូវបានកើតកត់សម្គាល់ផងដែរថា ស្ថិតនៅតំបន់នៃការកកស្ទះចរាចរណ៍ ដែលអាចទទួលស្គាល់បាន និងចំណតយានយន្តមានកំណត់ ដែលស្របតាមមតិយោបល់ជាលាយលក្ខណ៍អក្សរអំពីការជៀសវាងផ្លូវប្រសព្វនិងផ្លូវធំជាក់លាក់។ នៅទីបំផុតស្ទិកឃ័រក្រដាសបិទពណ៌ក្រហមត្រូវបានគេដាក់នៅជិត/នៅលើអគារដែលគ្រប់គ្រងកម្មសិទ្ធិឯកជន ដូចជាទីលានវាយកូនហ្គោលដោយស្របតាមមតិយោបល់ដែលបានបង្ហាញពីបញ្ហាបារម្ភអំពីចំនួនប្រជាពលរដ្ឋច្រើននៅតាមប្រភេទកន្លែងទាំងនេះ។




*មតិយោបល់សាធារណជន*

បន្ថែមលើការស្ទង់មតិសហគមន៍នោះ មតិយោបល់និងការផ្ដល់យោបល់អំពីទីតាំងនានាត្រូវបានទទួលពីសហគមន៍ ហើយត្រូវបានសង្ខេបជាអត្ថបទនៅក្នុងតារាង 9 និងផ្នែកខាងក្រោម។ ក្នុងករណីដែលមានការផ្ដល់មតិយោបល់នោះ មតិយោបល់ទាំងនេះត្រូវបានយកមកគិតពិចារណាដោយឯករាជ្យ។

Table 9. សេចក្ដីសង្ខេបមតិយោបល់សាធារណជន

| អត្ថបទមតិយោបល់ | ចំនួនមតិយោបល់ |
|---|---|
| **មតិយោបល់សរុប** | 597 |
| ***ការចូលប្រើ*** | 327 |
| ***ចំណតយានយន្ត*** | 101 |
| ***ការរៀបចំកម្មវិធី/ប្រតិបត្តិការ*** | 17 |
| ***សុវត្ថិភាព*** | 8 |
| ***ទំហំ*** | 43 |
| ***ការបោះឆ្នោតដែលពាក់ព័ន្ធ*** | 33 |
| ***ប្រភេទអគារ*** | 68 |
| **អគារនានាដែលត្រូវបានស្នើសុំនៅឯកិច្ចប្រជុំ** | 265 |
| **អគារនានាដែលត្រូវបានស្នើសុំតាមរបសាយតំណភ្ជាប់** | 41 |

**ការចូលប្រើ**

មតិយោបល់ទាំងនេះទាក់ទងនឹងទីតាំងនៃអគារ និងភាពងាយស្រួលស្វែងរក និងទៅដល់ទីតាំងនោះ។ ភាពងាយស្រួលអាចទាក់ទងទៅនឹងទស្សនៈវិស័យនៃភូមិសាស្ត្រផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ ស្ថានភាពចរាចរណ៍ ឬបញ្ហាចូលដំណើរការដែលបានដឹងផ្សេងទៀត។ មតិយោបល់ដែលបានទទួលនៅក្នុងប្រធានបទនេះ បង្ហាញពីវត្តមាននៃការឆ្លងកាត់ជាសាធារណៈ ការចូលប្រើកង់ និងអ្នកថ្មើរជើង ក៏ដូចជាភាពអាចប្រើបានតាមច្បាប់ ADA ផងដែរ។

**ចំណតយានយន្ត**

មតិយោបល់ទាក់ទងនឹងចំណតយានយន្ត បានផ្ដល់នូវមតិយោបល់ទាក់ទងទៅនឹងលក្ខខណ្ឌនិងភាពអាចមានជាទូទៅនៃកន្លែងចំណតយានយន្តដែលបានកំណត់ ចំណតយានយន្តនៅតាមផ្លូវ និងភាពអាចមានចំណតយានយន្តតាមច្បាប់ ADA ។

**ការរៀបចំកម្មវិធី/ប្រតិបត្តិការ**

មតិយោបល់ទាក់ទងនឹងភាពអាចមាននៃទីតាំងមួយ ដោយផ្អែកលើការរៀបចំកម្មវិធីឬប្រតិបត្តិការដែលកំពុងដំណើរការរបស់ខ្លួនបង្ហាញពីបញ្ហាបារម្ភអំពីការប្រើប្រាស់ទីតាំងនានាជាមណ្ឌលបោះឆ្នោតតាមរបៀបដែលមិនរំខានដល់កម្មវិធីកម្សាន្ត ថ្នាក់រៀន ឬប្រតិបត្តិការអាជីវកម្មធម្មតា។

**សុវត្ថិភាព**

មតិយោបល់ដែលទាក់ទងនឹងសុវត្ថិភាព ដោះស្រាយបញ្ហាបារម្ភនៃសុវត្ថិភាពដែលបានដឹងនៅទីតាំង។ បញ្ហាបារម្ភអាចរាប់បញ្ចូលទាំងអ្នកថ្មើរជើង/ហានិភ័យចរាចរណ៍ ឧក្រិដ្ឋកម្មនៅសហគមន៍ ឬលក្ខណៈទូទៅនៃការរើសអើង។

**ទំហំ**

មតិយោបល់ទាក់ទងនឹងទំហំផ្ដល់ជូនការយល់ដឹងអំពីលក្ខខណ្ឌផ្ទៃខាងក្នុងអគារ ដែលរួមមានទាំងទំហំបន្ទប់ ប្លង់ និងភាពអាចប្រើបាន។

**ការបោះឆ្នោតដែលពាក់ព័ន្ធ**

មតិយោបល់ទាក់ទងនឹងការបោះឆ្នោត មានទាក់ទងនឹងការចុះឈ្មោះអ្នកបោះឆ្នោតប្រតិបត្តិការបោះឆ្នោត និងសន្តិសុខបោះឆ្នោត។ មតិយោបល់ទាំងនេះ មិនផ្ដោតសំខាន់លើទីតាំងមណ្ឌលបោះឆ្នោតទេ ហើយត្រូវបានពិនិត្យឡើងវិញដោយបុគ្គលិកខោនធីដើម្បីរួមបញ្ចូលកន្លែងដែលសមស្រប។

**ប្រភេទអគារ**

មានមតិយោបល់ជាច្រើនបានលើកឡើងអំពីទីតាំង ហើយថាតើអ្នកបោះឆ្នោតមានអារម្មណ៍យ៉ាងណានៅពេលបោះឆ្នោតនៅទីនោះ។ មតិយោបល់ខ្លះសំដៅលើអគារជាក់លាក់ ហើយមតិយោបល់ផ្សេងទៀតផ្ដោតសំខាន់លើប្រភេទអគារទូទៅ។ ឧទាហរណ៍មានមតិយោបល់ជាច្រើនបានសម្ដែងការព្រួយបារម្ភអំពីការបោះឆ្នោតនៅតាមសាលារៀន ហើយអ្នកខ្លះទៀតបានសម្ដែងការរំភើបចំពោះការបោះឆ្នោតនៅតាមមណ្ឌលលក់រាយ។ មតិយោបល់ផ្សេងទៀតនៅក្នុងចំណាត់ថ្នាក់នេះ គ្រាន់តែបង្ហាញនូវការគាំទ្រ ឬកង្វះខាតកន្លែងប៉ុណ្ណោះ។

**ទីតាំងដែលបានស្នើសុំ**

នៅឯកិច្ចប្រជុំសហគមន៍ទាំងនេះ មានការផ្ដល់អនុសាសន៍អំពីចំនួនអគារសរុប 306 កន្លែង ក្នុងនោះអគារ 171 កន្លែង មិនស្ថិតក្រោមការពិនិត្យឡើងវិញដោយកម្មវិធី PlaceWorks ទេ ។ អគារទាំងនេះ បានទទួលការពិនិត្យឡើងវិញតាមកុំព្យូទ័រដេស៍ថប ហើយបានទទួលការបដិសេធ ឬការទទួលយកក្នុងដំណើរការសម្រាប់ការចុះពិនិត្យទីតាំ

ង។ ការផ្តល់យោបល់អំពីអគារនានាដែលស្ថិតនៅក្រោមការពិចារណា ត្រូវបានប្រើដើម្បីគាំទ្រដល់ការពិនិត្យឡើងវិញតាមកំរិតទីរដេសថប ហើយក្នុងករណីជាច្រើនបានផ្តល់ការយល់ដឹងទូលំទូលាយដែលជួយជំរុញឱ្យមានកន្លែងមួយចំពោះដំណាក់កាលនៃការវិភាគបន្ទាប់។

### 3.3.4 ការចូលរួមសហគមន៍នៅជំុទីពីរ

កិច្ចប្រជុំចូលរួមនៅជំុទីពីរបានផ្តល់ជូនចំណុចសំខាន់ៗ ដើម្បីជូនដំណឹងដល់សាធារណជនអំពីមណ្ឌលបោះឆ្នោតដែលមានសក្តានុពល ដែលបានផ្តល់អនុសាសន៍ចំនួន 2,000 កន្លែង។ ការចូលរួមនៅជំុនេះ មានការធ្វើទំនាក់ទំនងតិចតួច និងផ្តោតសំខាន់បន្ថែមទៀតលើការធានាថាអ្នកចូលរួមបានយល់ដាងច្បាស់អំពីការផ្លាស់ប្តូរទាំងអស់ ដែលភ្ជាប់ជាមួយគំរូបោះឆ្នោតថ្មី និងដើម្បីរាយការណ៍អំពីរបៀបដែលមតិយោបល់របស់ពួកគេត្រូវបានគិតពិចារណានិងអនុវត្តចំពោះការជ្រើសរើសទីតាំងដែលមានសក្តានុពល។ ទោះបីជាមិនមានសកម្មភាពផ្សព្វការណាមួយ ត្រូវបានធ្វើឡើងក៏ដោយ ក៏អ្នកចូលរួមនៅតែមានឱកាសផ្តល់មតិយោបល់ និងការណែនាំអំពីកន្លែងដែលមានសក្តានុពលផងដែរ។ នៅអំឡុងពេលជំុទីពីរនេះ បានទទួលមតិយោបល់តិចតួចបំផុត ហើយមតិយោបល់ទាំងនោះ ដែលបានដាក់ជូនពិនិត្យនោះ ទាក់ទងនឹងការចុះឈ្មោះអ្នកបោះឆ្នោត ប្រតិបត្តិការបោះឆ្នោត និងសន្តិសុខ។ ដូច្នេះមិនចាំបាច់មានការវិភាគលើមតិយោបល់ដែលបានដាក់ជូនពិនិត្យ ដើលចាំបាច់ដើម្បីជូនដំណឹងដល់ការជ្រើសរើសចុងក្រោយនៃទីតាំងមណ្ឌលបោះឆ្នោតឡើយ។

### 3.3.5 លទ្ធផល

ដៃគូសហគមន៍បានធ្វើការយ៉ាងខ្លាំង ដើម្បីចូលរួមជាមួយក្រុមអ្នកចូលរួមដែលមានលក្ខណៈប្រជាសាស្ត្រផ្សេងៗគ្នា និងអាចទាក់ទាញអ្នកចូលរួមជិត 2,300 នាក់ទៅកិច្ចប្រជុំនៅទូទាំងខោនធី។ កិច្ចប្រជុំនេះ មានតំបន់ភូមិសាស្ត្រចំនួន 30 ហើយកិច្ចប្រជុំបន្ថែមទៀតត្រូវបានធ្វើឡើង ដើម្បីជួបពលរដ្ឋដែលមានពិការភាព និងការឆ្លើយតបទៅនឹងសំណូមពររបស់ក្រុមសហគមន៍ដែលមានចំណាប់អារម្មណ៍ចង់ស្វែងយល់បន្ថែមអំពីគំរូមណ្ឌលបោះឆ្នោតនេះ។ កិច្ចខិតខំប្រឹងប្រែងដ៏រឹងមាំនេះ បាននាំឱ្យមានតម្រូវការរបស់សហគមន៍ប្រកបដោយអត្ថន័យ និងបានដើរតួជាកាតាលីករសម្រាប់ការពង្រឹងកិច្ចសហប្រតិបត្តិការនៅទូទាំងវិស័យសំខាន់ៗ។

# 4.0 ការផ្តល់អនុសាសន៍នៃមណ្ឌលបោះឆ្នោតនៅខោនធី LOS ANGELES COUNTY

បន្ទាប់ពីធ្វើការវិភាគទិន្នន័យទូលំទូលាយនិងការវិភាគនៅទីវាល និងការផ្សព្វផ្សាយដល់សាធារណជននោះ អ្នកពីគ្រោះយោបល់ផ្នែកបច្ចេកទេសបានបង្កើតការកំណត់ចុងក្រោយនៃការផ្តល់អនុសាសន៍នៃមណ្ឌលបោះឆ្នោតដែលមានសក្តានុពលចំនួន 2,000 កន្លែង ក្នុងនោះរាប់បញ្ចូលទាំងមណ្ឌលបោះឆ្នោតដែលល្អបំផុតចំនួន 1,000 កន្លែង បូកបន្ថែមមណ្ឌលបោះឆ្នោតដែលសក្តានុពលដែលល្អចំនួន 1,000 កន្លែង ដើម្បីប្រើប្រាស់ប្រសិនបើមណ្ឌលបោះឆ្នោតដែលល្អបំផុតចំនួន 1,000 កន្លែង មិនអាចប្រើប្រាស់ជាមណ្ឌលបោះឆ្នោតក្នុងការបោះឆ្នោតបឋមជ្រើសរើសប្រធានាធិបតីឆ្នាំ 2020 ។ អគារទាំងនេះនឹងត្រូវបានវិភាគបន្ថែមទៀតដោយបុគ្គលិកបោះឆ្នោតខោនធី Los Angeles County ដើម្បីធានាដល់ការគោរពច្បាប់ពេញលេញតាមច្បាប់ VCA តម្រូវការប្រតិបត្តិការ និងលក្ខខណ្ឌទីតាំង។

## 4.1 គំរូដែលបានផ្តល់អនុសាសន៍៖ លំនៅដ្ឋានជាប់នឹងកន្លែងធ្វើការ/កន្លែងធ្វើការ

គំរូដែលបានផ្តល់អនុសាសន៍ត្រូវបានប្រើដោយអ្នកស្រាវជ្រាវ ដើម្បីកំណត់ការផ្តល់អនុសាសន៍នៃមណ្ឌលបោះឆ្នោតចុងក្រោយត្រូវបានបង្កើតឡើងដោយមានការគាំទ្រពីគណៈកម្មាធិការប្រឹក្សាយោបល់ VSAP និងស្វែងរកវិធីសាស្ត្រប្រកបដោយតុល្យភាព ដើម្បីបំពេញតម្រូវការប្រតិបត្តិការ នៅខណៈពេលបំពេញតាមតម្រូវការនានារបស់អ្នកបោះឆ្នោតខោនធី Los Angeles County ។

គំរូនៃលំនៅដ្ឋានជាប់នឹងកន្លែងធ្វើការ/កន្លែងធ្វើការ គាំទ្រមតិយោបល់ដែលអ្នកបោះឆ្នោតមានភាពងាយស្រួលបំផុតក្នុងការបោះឆ្នោតនៅជិតផ្ទះ ឬកន្លែងធ្វើការរបស់ពួកគេ និងនៅកន្លែងដែលធ្លាប់ស្គាល់ ដូចជាអគារនិងសាលារៀនរដ្ឋ។ ដើម្បីបង្កើតគំរូដែលអាចកំណត់មណ្ឌលបោះឆ្នោតដែលល្អបំផុតនោះ ពិន្ទុបន្ទប់របស់មណ្ឌលនីមួយៗ ពិន្ទុអគារ និងពិន្ទុភាពសមស្រប ត្រូវបានគណនាទៅជាភាពស្មើគ្នានៃគំរូចុងក្រោយ និងមានចំណាត់ថ្នាក់ស្មើគ្នា។ ភាពស្មើគ្នានេះធានាថាលក្ខណៈជាក់ស្តែងរបស់ទីតាំង ត្រូវបានផ្តល់ជូនការទាញយកហ្សុំមលើផែនទីស្មើទៅនឹងកត្តាសេដ្ឋកិច្ចសង្គមនិងប្រជាសាស្ត្រ ដែលបានកំណត់ក្នុងពិន្ទុភាពសមស្រប។ បទបញ្ញាលេខ 1320 បានពន្យល់ក្នុងផ្នែកទី 2.3 ត្រូវបានប្រើដើម្បីធានាថាមណ្ឌលបោះឆ្នោតមានចម្ងាយយ៉ាងតិចមួយភាគបួនម៉ាយ។

តារាង 10 បង្ហាញពីមូលដ្ឋានទិន្នន័យនិងការទាញយកហ្សុំមលើផែនទីរៀងៗខ្លួន ដែលបានអនុវត្តក្នុងការជ្រើសរើសការផ្តល់អនុសាសន៍នៃមណ្ឌលបោះឆ្នោតចុងក្រោយ។

គំរូការរស់នៅ/ការងារ ត្រូវបានប្រើដើម្បីកំណត់ការផ្តល់អនុសាសន៍នៃមណ្ឌលបោះឆ្នោតដែលមានសក្តានុពលចំនួន 2,000 កន្លែង ដែលបានចាត់ថ្នាក់ដោយអគារដែលល្អបំផុតចំនួន 1,000 កន្លែង នឹងអគារដែលល្អចំនួន 1,000 កន្លែង។ មណ្ឌលបោះឆ្នោតដែលល្អបំផុតចំនួន 1,000 កន្លែង គឺជាអគារដែលបានណែនាំកម្រិតខ្ពស់បំផុត។ ប្រសិនបើទីតាំងដែលល្អបំផុតចំនួន 1,000 កន្លែង មិនអាចប្រើក្នុងការបោះឆ្នោតទេ មណ្ឌលបោះឆ្នោតដែលមានសក្តានុពលរដែលល្អចំនួន 1,000 កន្លែង នឹងផ្តល់ជម្រើសផ្សេងទៀតសម្រាប់ទីតាំងដែលសមរម្យ។

Table 10.ការបែងចែកការទាញយកហ្សុំមលើផែនទីដែលត្រូវការ

| មូលដ្ឋានទិន្នន័យដែលត្រូវការ | ភាគរយនៃការទាញយកហ្សុំមលើផែនទី |
|---|---|
| A. លំនៅដ្ឋានជាប់នឹងកន្លែងធ្វើការ/កន្លែងធ្វើការ - ទីតាំងលំនៅដ្ឋានរបស់អ្នកបោះឆ្នោត | 24 |
| B. លំនៅដ្ឋានជាប់នឹងកន្លែងធ្វើការ/កន្លែងធ្វើការ - ទីកន្លែងការងារ | 15 |
| C. លំនៅដ្ឋានជាប់នឹងកន្លែងធ្វើការ/កន្លែងធ្វើការ - ការបែងចែកស្មើគ្នា | 1 |
| D. សេដ្ឋកិច្ចសង្គម - សហគមន៍ដែលមានប្រាក់ចំណូលទាប | 5 |
| E. សេដ្ឋកិច្ចសង្គម - ម្ចាស់កម្មសិទ្ធិយានយន្តកម្រិតទាប | 5 |

| | |
|---|---|
| F. សេដ្ឋកិច្ចសង្គម - សហគមន៍ដាច់ស្រយាល | 5 |
| G. សេដ្ឋកិច្ចសង្គម - និយាយភាសាជនជាតិភាគតិច | 5 |
| H. លក្ខណៈអ្នកបោះឆ្នោត - អ្នកមានសិទ្ធិបោះឆ្នោតដែលមិនបានចុះឈ្មោះ | 7 |
| I. លក្ខណៈអ្នកបោះឆ្នោត - អ្នកបោះឆ្នោតដែលបានចុះឈ្មោះ មានទំនោរកម្រិតខ្ពស់ | 2 |
| J. លក្ខណៈអ្នកបោះឆ្នោត - អ្នកបោះឆ្នោតដែលបង្ហាញឱ្យឃើញ | 5 |
| K. លក្ខណៈអ្នកបោះឆ្នោត - ការបោះឆ្នោតផ្ញើតាមប្រៃសណីយ៍មានកម្រិតទាប | 10 |
| L. លក្ខណៈអ្នកបោះឆ្នោត - អ្នកបោះឆ្នោតដែលមានពិការភាព | 4 |
| M. មធ្យោបាយធ្វើដំណើរ - ការប្រើប្រាស់ការធ្វើដំណើរឆ្លងកាត់ | 5 |
| N. មធ្យោបាយធ្វើដំណើរ - ភាពអាចប្រើបានចំណតយានយន្ត | 2 |
| O. មធ្យោបាយធ្វើដំណើរ - ការស្ទះចរាចរណ៍ | 5 |
| **ភាគរយ** | **100** |

Figure 16. ការបោះឆ្នោតតាមទីតាំងបោះឆ្នោតផ្ញើតាមប្រៃសណីយ៍




## 4.2 ឧបសម្ព័ន្ធ I ការបោះឆ្នោតដែលបានផ្តល់អនុសាសន៍តាមទីតាំងបោះឆ្នោតផ្ញើតាមប្រៃសណីយ៍

ការផ្តល់អនុសាសន៍តាមទីតាំងបោះឆ្នោតផ្ញើតាមប្រៃសណីយ៍ ត្រូវបានបង្កើតតាមរយៈកំណត់ត្រាខោនធីនៃការបោះឆ្នោតដែលមានស្រាប់តាមទីតាំងបោះឆ្នោតផ្ញើតាមប្រៃសណីយ៍ ហើយនៅទីតាំងជាច្រើនទៀតនឹងនៅដដែល។ ទីតាំងបន្ថែមអាចទាញចេញពីទីតាំងមណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍ថាល្អចំនួន 1,000 កន្លែង។ អាគារដែលមិនមានបន្ទប់មានទំហំគ្រប់គ្រាន់ ដែលអាចមានសម្រាប់ការបោះឆ្នោតដែលបានផ្តល់ជូន ប៉ុន្តែមានលក្ខណៈដែលចង់បានផ្សេងទៀត នឹងរៀបចំការបោះឆ្នោតជាក់លាក់តាមទីតាំងបោះឆ្នោតផ្ញើតាមប្រៃសណីយ៍ ដែលអាចមានលទ្ធភាពផ្លាស់ប្តូរទៅជាមណ្ឌលបោះឆ្នោតដែលមានសេវាកម្មពេញលេញសម្រាប់ការបោះឆ្នោតនាពេលអនាគត។ បញ្ជីពេញលេញនៃការបោះឆ្នោតដែលបានណែនាំតាមរយៈទីតាំងបោះឆ្នោតផ្ញើតាមប្រៃសណីយ៍ ត្រូវបានផ្តល់ជូននៅឧបសម្ព័ន្ធ I ។

## 4.3 ទីតាំងមណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍

បញ្ជីពេញលេញនៃទីតាំងមណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍ចំនួន 2,000 កន្លែង ត្រូវបានផ្តល់ជូននៅក្នុងឧបសម្ព័ន្ធ J. អគារទាំងនេះគឺជាការផ្តល់អនុសាសន៍តែប៉ុណ្ណោះ; ហើយមិនត្រូវបានធានាថាក្លាយជាមណ្ឌលបោះឆ្នោតផ្លូវការទេ។ បុគ្គលិកបោះឆ្នោតខោនធី នឹងពិនិត្យឡើងវិញនូវកន្លែងនីមួយៗ ដើម្បីធានាបាននូវការការពារតាមច្បាប់ VCA និងតម្រូវការប្រតិបត្តិការនិងដឹកនាំកិច្ចខិតខំប្រឹងប្រែង ដើម្បីព្យាយាមផ្តល់ជំនួយដល់អគារនានា ដើម្បីកំណត់សមត្ថភាពអគារ ដើម្បីរៀបចំការបោះឆ្នោត។

កម្មវិធី PlaceWorks បានផ្តល់ជូន RR/CC នូវការណែនាំអំពីការថែរក្សាមូលដ្ឋានទិន្នន័យនៃទីតាំងដែលបានណែនាំកន្លងមក។ វិធីសាស្ត្រសកម្មនេះ ធានាថាមូលដ្ឋានទិន្នន័យដែលបានធ្វើបច្ចុប្បន្នភាព ត្រូវបានប្រើប្រាស់ដើម្បីកំណត់តម្រូវការភូមិសាស្ត្រសម្រាប់មណ្ឌលបោះឆ្នោត។ កម្មវិធី PlaceWorks ក៏បានរាយការណ៍អំពីមេរៀនដែលបានសិក្សានៅទូទាំងការវិភាគ ដើម្បីឱ្យបុគ្គលិកបោះឆ្នោតខោនធីអាចត្រៀមដោះស្រាយបញ្ហានានាចំពោះការជ្រើសរើសអគារនិងដំណើរការនៃអគារ។

ផ្នែកខាងក្រោមពិពណ៌នាអំពីវិធីដែលទីតាំងមណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍ដែលល្អបំផុតចំនួន 1,000 កន្លែង ត្រូវបានបែងចែកនៅទូទាំងខោនធី។ ផែនទីនីមួយៗបង្ហាញពីការបែងចែកមណ្ឌលបោះឆ្នោតដែលទាក់ទងនឹងតម្រូវការច្បាប់ VCA ដែលបានពិពណ៌នានៅក្នុងផ្នែក 2.2.2 ហើយបង្ហាញម្តងទៀតនៅក្នុងតារាង11 ។

Table 11.មូលដ្ឋានទិន្នន័យដែលតម្រូវឱ្យមានតាមច្បាប់ VCA

| ការគិតពិចារណាអំពីមណ្ឌលបោះឆ្នោតដែលត្រូវការអប្បបរមា និងការកំណត់ទីតាំងបោះឆ្នោតក្រោមច្បាប់ VCA |
|---|
| • នៅជិតមធ្យោបាយធ្វើដំណើរសាធារណៈ: |
| • ចម្ងាយនិងពេលវេលា ដើម្បីទៅដល់មណ្ឌលបោះឆ្នោត VC/ប្រអប់សន្លឹកបោះឆ្នោត ដោយរថយន្ត/ការធ្វើដំណើរឆ្លងកាត់សាធារណៈ: |
| • ការធ្វើចរាចរណ៍បង្ហាញឱ្យឃើញថាទៅផ្លូវណានៅជិតមណ្ឌលបោះឆ្នោត VC និងប្រអប់ឆ្នោត |
| • នៅជិតមជ្ឈមណ្ឌលប្រជាពលរដ្ឋ |
| • នៅជិតប្រជាពលរដ្ឋដាច់ស្រយាលតាមភូមិសាស្ត្រ |
| • នៅជិតសហគមន៍ដែលមានប្រាក់ចំណូលទាប |
| • នៅជិតអ្នកបោះឆ្នោតដែលមានពិការភាព |
| • នៅជិតសហគមន៍ដែលប្រើភាសាជនជាតិភាគតិច |
| • នៅជិតសហគមន៍ដែលមានកម្មសិទ្ធិយានយន្តកម្រិតទាប |
| • នៅជិតអ្នកមានសិទ្ធិបោះឆ្នោតដែលមិនបានចុះឈ្មោះ |
| • នៅជិតសហគមន៍ដែលមានការបោះឆ្នោតជាប្រវត្តិសាស្ត្រកម្រិតទាបតាមការបោះឆ្នោតផ្ញើតាមប្រៃសណីយ៍ |

Figure 17. ផែនទីមណ្ឌលបោះឆ្នោតដែលល្អបំផុតចំនួន 1,000 កន្លែង



Figure 18. ផែនទីមណ្ឌលបោះឆ្នោតដែលល្អចំនួន 2,000 កន្លែង



### *មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍នៅជិតមជ្ឈមណ្ឌលប្រជាពលរដ្ឋ*

គំរូនៃលំនៅដ្ឋានជាប់នឹងកន្លែងធ្វើការ/កន្លែងធ្វើការ ដែលបានប្រើប្រាស់ដើម្បីកំណត់ទីតាំងដែលសមស្របបំផុត ដែលផ្តោតលើការកំណត់មណ្ឌលបោះឆ្នោតនៅជិតផ្ទះ និងកន្លែងធ្វើការរបស់អ្នកបោះឆ្នោត។ រូបភាព 19 បង្ហាញពីទីតាំងមណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍ទាក់ទងនឹងមជ្ឈមណ្ឌលប្រជាពលរដ្ឋរស់នៅ។ ដូចដែលបានបង្ហាញនៅក្នុងសញ្ញាសម្គាល់លើផែនទីថា ពណ៌ងងឹតតំណាងឱ្យតំបន់នានាដែលមានដង់ស៊ីតេប្រជាជនខ្ពស់ជាងគេ។ ក្រុមចំណុចខ្មៅៗ បង្ហាញពីទីតាំងមណ្ឌលបោះឆ្នោតដែលមានសក្តានុពលទាក់ទងនឹងមជ្ឈមណ្ឌលប្រជាពលរដ្ឋទាំងនេះ។ មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍មានទំនោរទៅរកក្រុមនៅក្នុងតំបន់ដែលមានដង់ស៊ីតេប្រជាជនខ្ពស់ជាងគេ ប៉ុន្តែមិនត្រូវធ្វេសប្រហែសចំពោះតំបន់នៃខោនធីដែលមានប្រជាជនតិច។

ដូចបានបង្ហាញក្នុងតារាង 12, មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍មាន 33.5 ភាគរយ គឺស្ថិតនៅក្នុងតំបន់មានដង់ស៊ីតេប្រជាជនកម្រិតខ្ពស់ដោយប្រៀបធៀបនឹងតំបន់ដែលមានដង់ស៊ីតេប្រជាជនខ្ពស់ខ្លាំង រីឯមណ្ឌលបោះឆ្នោតមាន 39.1 ភាគរយ គឺស្ថិតនៅក្នុងតំបន់ដែលមានដង់ស៊ីតេទាបឬទាបបំផុត។ ដង់ស៊ីតេប្រជាជនបានបង្ហាញនិងចាត់ទុកថាជាតំបន់ដែលមានប្រជាជននៅក្នុងក្រុមប្លុកនីមួយៗ ហើយមិនរាប់បញ្ចូលក្រុមប្លុកដែលមានអ្នកមានសិទ្ធិបោះឆ្នោតតិចជាង 0.25 នាក់ក្នុងមួយអេកឃ័រ។

Table 12.មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍នៅជិតមជ្ឈមណ្ឌលប្រជាពលរដ្ឋ

| ដង់ស៊ីតេអ្នកមានសិទ្ធបោះឆ្នោតទាំងអស់ | ភាគរយសរុបនៃមណ្ឌលបោះឆ្នោត |
|---|---|
| **Very Low (≤ 5)** | 13.8 % |
| **Low (≤ 10)** | 25.3% |
| **Moderate (≤ 15)** | 27.4% |
| **High (≤ 20)** | 15.6% |
| **Very High (≤ 368)** | 17.9% |

### *មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍នៅជិតមជ្ឈមណ្ឌលការងារ*

ស្រដៀងគ្នានឹងរូបភាព 19 រូបភាព 20 ប្រើគំរូក្រុមលំនៅដ្ឋានជាប់នឹងកន្លែងធ្វើការ/កន្លែងធ្វើការផងដែរ ដើម្បីបង្ហាញទីតាំងមណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍ទាក់ទងនឹងមជ្ឈមណ្ឌលការងារ។ មជ្ឈមណ្ឌលការងារសំដៅទៅលើតំបន់នានាដែលក្នុងនោះមានកន្លែងការងារ ត្រូវបានរៀបចំ។ មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍មានទំនោរទៅរកក្រុមនៅជិតមជ្ឈមណ្ឌលការងារ នៅខណៈពេលដែលនៅតែផ្តល់ជូនចំនួនច្រើន (28%) នៃអគារនានានៅក្នុងតំបន់ដែលមានមជ្ឈមណ្ឌលការងារតិចជាង។ ដូចបានបង្ហាញក្នុងតារាង 13,

Figure 19. មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍នៅជិតមជ្ឈមណ្ឌលប្រជាពលរដ្ឋ



Figure 20. មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍នៅជិតមជ្ឈមណ្ឌលការងារ



មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍មាន 41.1 ភាគរយ គឺស្ថិតនៅក្នុងមជ្ឈមណ្ឌលការងារដែលមានដង់ស៊ីតេកម្រិតខ្ពស់ និងខ្ពស់ខ្លាំង រីឯ 31.7 ភាគរយ គឺស្ថិតនៅក្នុងមជ្ឈមណ្ឌលការងារដែលមានដង់ស៊ីតេកម្រិតទាបនិងទាបខ្លាំង។

Table 13.មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍នៅជិតមជ្ឈមណ្ឌលការងារ

| ដង់ស៊ីតេការងារ | ភាគរយសរុបនៃមណ្ឌលបោះឆ្នោត |
|---|---|
| **Very Low (≤ 2.6)** | 28.4% |
| **Low (≤ 2.8)** | 3.3% |
| **Moderate (≤ 5.4)** | 27.2% |
| **High (≤ 38.9)** | 37.8% |
| **Very High (≤ 474.2)** | 3.3% |

### *មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍នៅជិតសហគមន៍មានប្រាក់ចំណូលទាប*

ការកំណត់មណ្ឌលបោះឆ្នោតនៅជិតអ្នកដែលត្រូវបានផ្តល់ជូនក្រុមអ្នកតំណាងមិនគ្រប់គ្រាន់នៅក្នុងដំណើរការប្រជាធិបតេយ្យជាប្រវត្តិសាស្ត្រ ក៏ជាកត្តាសំខាន់មួយនៃគំរូមណ្ឌលបោះឆ្នោតថ្មីផងដែរ។ រូបភាព 21 បង្ហាញពីទីតាំងសហគមន៍មានប្រាក់ចំណូលទាបដែលទាក់ទងនឹងមណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍។

ក្រុមគ្រួសារដែលមានប្រាក់ចំណូលទាបត្រូវបានកំណត់ដោយក្រសួងអភិវឌ្ឍលំនៅដ្ឋាន និងទីក្រុង (HUD) ថាជាក្រុមគ្រួសារដែលមានប្រាក់ចំណូលមិនលើសពី 80 ភាគរយនៃប្រាក់ចំណូលគ្រួសារមធ្យមដែលមានចំនួនទឹកប្រាក់ $64,300 ដុល្លារសម្រាប់ខោនធី Los Angeles County ។ ដូចបានបង្ហាញក្នុងតារាង 13, មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍មាន 36 ភាគរយ គឺស្ថិតនៅក្នុងតំបន់មានការផ្តោតសំខាន់លើកម្រិតខ្ពស់ដល់ខ្ពស់ខ្លាំងនៃសហគមន៍មានប្រាក់ចំណូលទាប រីឯ 41.8 ភាគរយ គឺស្ថិតនៅក្នុងតំបន់មានការផ្តោតសំខាន់លើកម្រិតទាបខ្លាំងដល់កម្រិតទាបនៃសហគមន៍មានប្រាក់ចំណូលទាប។

Table 14.មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍នៅជិតសហគមន៍មានប្រាក់ចំណូលទាប

| ភាគរយនៃក្រុមគ្រួសារដែលមានចំណូលទាបក្នុងក្រុមប្លុកនីមួយៗ | ភាគរយសរុបនៃមណ្ឌលបោះឆ្នោត |
|---|---|
| **Very Low (≤ 14)** | 20.9% |
| **Low (≤ 23)** | 15.1% |
| **Moderate (≤ 38)** | 22.1% |
| **High (≤ 61)** | 27.8% |
| **Very High (≤ 100)** | 14.0% |

Figure 21. មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍នៅជិតសហគមន៍មានប្រាក់ចំណូល



## *មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍នៅជិត សហគមន៍មានម្ចាស់កម្មសិទ្ធិយានយន្តកម្រិតទាប*

នៅជិតមណ្ឌលបោះឆ្នោតដល់សហគមន៍ដែលមានម្ចាស់កម្មសិទ្ធិយានយន្តកម្រិតទាប ត្រូវបានគេវិភាគដើម្បីទទួលស្គាល់ឧបសគ្គនានានៃការចូលទៅកាន់មណ្ឌលបោះឆ្នោតដោយគ្មានយានយន្តផ្ទាល់ខ្លួន។ រូបភាព 22 បង្ហាញមណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍ទាក់ទងនឹងក្រុមលំនៅដ្ឋានដែលកាន់កាប់ដោយមិនមានការប្រើប្រាស់យានយន្តនៅក្នុងក្រុមប្លុកនីមួយៗ។ ដូចបានបង្ហាញក្នុងតារាង 15, មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍មាន 36.2 ភាគរយ គឺមានទីតាំងនៅជិតតំបន់ដែលមានអត្រាហេតុចំពោះអ្នកបោះឆ្នោតដែលមិនមានយានយន្តផ្ទាល់ខ្លួននោះ មានកម្រិតទាប។

Table 15.មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍នៅជិត សហគមន៍មានម្ចាស់កម្មសិទ្ធិយានយន្តកម្រិតទាប

| ភាគរយនៃក្រុមលំនៅដ្ឋានដែលកាន់កាប់ដោយគ្មានការចូលប្រើយានយន្ត | ភាគរយសរុបនៃមណ្ឌលបោះឆ្នោត |
|---|---|
| **Very Low (≤ 2)** | 15.1% |
| **Low (≤ 4)** | 21.1% |
| **Moderate (≤ 13)** | 33.1% |
| **High (≤ 35)** | 4.3% |
| **Very High (≤ 95)** | 30.7% |

Figure 22. មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍នៅជិត សហគមន៍មានម្ចាស់កម្មសិទ្ធិយានយន្តកម្រិតទាប



### *មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍នៅជិតប្រជាពលរដ្ឋដែលដាច់ស្រយាលតាមភូមិសាស្ត្រ*

ដើម្បីធានាថាអ្នកបោះឆ្នោតទាំងអស់មានឱកាសស្មើភាពគ្នាក្នុងការបោះឆ្នោតនោះ ត្រូវបានគិតពិចារណាយ៉ាងយកចិត្តទុកដាក់អំពីភាពនៅជិតមណ្ឌលបោះឆ្នោតសម្រាប់ប្រជាពលរដ្ឋដែលនៅដាច់ស្រយាលតាមភូមិសាស្ត្រ។ រូបភាព 23 ពិពណ៌នាអំពីមណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍ទាក់ទងទៅនឹងអ្នកបោះឆ្នោតនៅក្នុងសហគមន៍ដែលដាច់ស្រយាលតាមភូមិសាស្ត្រទាំងនេះ រួមទាំងអ្នកមានសិទ្ធិបោះឆ្នោតដែលមិនបានចុះឈ្មោះ។

វាក៏បង្ហាញពីតំបន់ទីក្រុងនៅខោនធី LA County និងចម្ងាយពីសហគមន៍ដែលដាច់ស្រយាលទៅផ្នែកដែលមានប្រជាជនច្រើននៃខោនធីផងដែរ។ ជាលទ្ធផលប្រជាជនប្រមាណ 48 ភាគរយនៃប្រជាពលរដ្ឋដែលដាច់ស្រយាលតាមភូមិសាស្ត្រ មានទីតាំងស្ថិតនៅចម្ងាយ 5 ម៉ាយពីមណ្ឌលបោះឆ្នោតមួយ។

ទីក្រុង Avalon ដែលមានទីតាំងស្ថិតនៅលើកោះកាតាលីនណា Catalina Island គឺនៅដាច់ឆ្ងាយពីដីគោកនៃខោនធី Los Angeles County ។ ដើម្បីជួយសម្រួលដល់អ្នកបោះឆ្នោតនៅក្នុងតំបន់ភូមិសាស្ត្រនេះ អ្នកចុះឈ្មោះឬអ្នកកត់ត្រា/ស្មៀនខោនធី RR/CC បានកំណត់ជាមុនថាមណ្ឌលបោះឆ្នោតមួយនឹងត្រូវដាក់នៅក្នុងសាលាក្រុង Avalon ហើយការវិភាគនៃតំបន់នេះ មិនត្រូវបានធ្វើឡើងទេ។

Figure 23. មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍នៅជិតប្រជាពលរដ្ឋដែលដាច់ស្រយាលតាមភូមិសាស្ត្រ




Voter Density in Isolated Populations
- Very Low
- Low
- Moderate
- High
- Very High

Distance from Isolated Populations (Miles)
- 0.25 - 1
- 1 - 5
- 5 - 10
- > 10

- Urban Areas
- • Best 1,000 Vote Centers

### *មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍នៅជិតសហគមន៍ដែលនិយាយភាសាជនជាតិភាគតិច*

ក្រោមគំរូមណ្ឌលបោះឆ្នោត អ្នកចុះឈ្មោះឬអ្នកកត់ត្រា/ស្មៀនខោនធី RR/CC នឹងបន្តផ្តល់ជូនការគាំទ្រភាសាជា 12 ភាសាបន្ថែមលើភាសាអង់គ្លេស។ ចំណាត់ថ្នាក់និងនិយមន័យនៃជំរឿនប្រជាជននៅសហរដ្ឋអាមេរិក ដែលបានប្រើប្រាស់ក្នុងការវិភាគនេះ កំណត់សហគមន៍និយាយភាសាជនជាតិភាគតិចថាជាការរៀបចំក្រុមួយសម្រាប់បុគ្គលដែលនិយាយភាសាផ្សេងទៀតក្រៅពីភាសាអង់គ្លេស ដែលមានកម្រិត "ល្អណាស់" និងនិយាយភាសាអង់គ្លេសដែលមានកម្រិត "មិនសូវល្អ"។

រូបភាព 24 បង្ហាញពីទីតាំងមណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍ទាក់ទងនឹងសហគមន៍និយាយភាសាជនជាតិភាគតិច។ ប្រជាពលរដ្ឋនិយាយភាសាជនជាតិភាគតិចសរុបប្រមាណជា 63 ភាគរយ មានទីតាំងស្ថិតនៅក្នុងចម្ងាយកន្លះម៉ាយពីមណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍។

Figure 24. មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍នៅជិតសហគមន៍ដែលនិយាយភាសាជនជាតិភាគតិច



### *មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍នៅជិតអ្នកមានសិទ្ធិបោះឆ្នោតដែលមិនបានចុះឈ្មោះ*

អ្នកចុះឈ្មោះឬអ្នកកត់ត្រា/ស្មៀនខោនធី RR/CC ទទួលស្គាល់សារៈសំខាន់នៃការចូលរួមជាមួយអ្នកមានសិទ្ធិបោះឆ្នោត ដែលមិនបានចុះឈ្មោះនាពេលបច្ចុប្បន្ន។ ដើម្បីលើកទឹកចិត្តឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធសំខាន់ៗទាំងនេះ ទីតាំងមណ្ឌលបោះឆ្នោតត្រូវមានភាពងាយស្រួលនិងមានប្រសិទ្ធភាពក្នុងការប្រើប្រាស់។

រូបភាព 25 បង្ហាញពីទីតាំងនៃអគារមណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍ទាក់ទងនឹងអ្នកមានសិទ្ធិបោះឆ្នោតដែលមិនបានចុះឈ្មោះ។ ការវិភាគបានកំណត់ក្រុមប្លុកដែលមានអ្នកមានសិទ្ធិបោះឆ្នោត
ដែលមិនបានចុះឈ្មោះមួយនាក់ឬច្រើននាក់។ អ្នកមានសិទ្ធិបោះឆ្នោត
ដែលមិនបានចុះឈ្មោះសរុបប្រមាណជា 60 ភាគរយ មានទីតាំងស្ថិតនៅក្នុងចម្ងាយកន្លះម៉ាយពីមណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍។

Figure 25. មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍នៅជិតអ្នកមានសិទ្ធិបោះឆ្នោតដែលមិនបានចុះឈ្មោះ



### *មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍នៅជិត តំបន់មានដង់ស៊ីតេអ្នកបោះឆ្នោតខ្ពស់*

ដើម្បីគាំទ្រតម្រូវការរបស់អ្នកបោះឆ្នោតដែលមាននិន្នាការយ៉ាងខ្លាំង ដើម្បីចូលរួមការបោះឆ្នោតនោះ មណ្ឌលបោះឆ្នោតត្រូវកំណត់នៅជិតតំបន់ដែលមានការចុះឈ្មោះអ្នកបោះឆ្នោតខ្ពស់។ រូបភាព 26 បង្ហាញពីមណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍ទាក់ទងទៅនឹងដង់ស៊ីតេអ្នកបោះឆ្នោតដែលមាននិន្នាការខ្ពស់ (អ្នកបោះឆ្នោតសកម្ម) ក្នុងមួយក្រុមប្លុក ដោយពណ៌នាតែក្រុមប្លុកមានអ្នកបោះឆ្នោតដែលមាននិន្នាការខ្ពស់មួយនាក់ឬច្រើននាក់ប៉ុណ្ណោះ។ អ្នកមានសិទ្ធិបោះឆ្នោតដែលបានចុះឈ្មោះសរុបប្រមាណជា 60 ភាគរយ មានទីតាំងស្ថិតនៅក្នុងចម្ងាយកន្លះម៉ាយពីមណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍។

Figure 26. មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍នៅជិត តំបន់មានដង់ស៊ីតេអ្នកបោះឆ្នោតខ្ពស់



### *មណ្ឌលបោះឆ្នោតដែលផ្ដល់អនុសាសន៍នៅជិត សហគមន៍ដែលមានការបោះឆ្នោតតាមការប្រើប៉ុស្តិ៍ប្រៃសណីយ៍មានកម្រិតទាបជាប្រវត្តិសាស្ត្រ*

ការកំណត់ទីតាំងមណ្ឌលបោះឆ្នោតនៅជិតប្រជាពលរដ្ឋប្រើប៉ុស្តិ៍ប្រៃសណីយ៍មានកម្រិតខ្ពស់ជាប្រវត្តិសាស្ត្រ ដើម្បីបង្កើនជម្រើសបោះឆ្នោត។ RR/CC ត្រូវស្វែងរកតុល្យភាពត្រឹមត្រូវ នៅពេលជ្រើសរើសមណ្ឌលបោះឆ្នោតផ្លូវការសម្រាប់ការបោះឆ្នោតដោយប្រជាពលរដ្ឋប្រើប៉ុស្តិ៍ប្រៃសណីយ៍។ តុល្យភាពនេះត្រូវផ្ដល់ជូនអគារសេវាកម្មពេញលេញគ្រប់គ្រាន់ នៅខណៈពេលផ្ដល់ជូនបោះឆ្នោតដែលមានគុណភាពខ្ពស់តាមទីតាំងបោះឆ្នោតប្រើប៉ុស្តិ៍ប្រៃសណីយ៍។

រូបភាព 27 បង្ហាញពីការបោះឆ្នោតប៉ាន់ស្មានតាមការប្រើប៉ុស្តិ៍ប្រៃសណីយ៍សម្រាប់ការបោះឆ្នោតឆ្នាំ 2020 នៅកម្រិតទីក្រុង (ការប៉ាន់ស្មាន បានផ្ដល់ជូនដោយ RR/CC)។ ដូចបានបង្ហាញក្នុងតារាង 16, មណ្ឌលបោះឆ្នោតដែលផ្ដល់អនុសាសន៍មាន 22.6 ភាគរយ គឺស្ថិតនៅក្នុងសហគមន៍ដែលមានអ្នកបោះឆ្នោតច្រើនជាង 55 ភាគរយ ប្រើប្រាស់ជម្រើសបោះឆ្នោតតាមប៉ុស្តិ៍ប្រៃសណីយ៍ រីឯ 15.1 ភាគរយ ស្ថិតនៅក្នុងសហគមន៍ដែលមានការបោះឆ្នោតតិចជាង 35 ភាគរយតាមការប្រើប៉ុស្តិ៍ប្រៃសណីយ៍។

Table 16.មណ្ឌលបោះឆ្នោតដែលផ្ដល់អនុសាសន៍នៅជិត សហគមន៍ដែលមានការបោះឆ្នោតតាមការប្រើប៉ុស្តិ៍ប្រៃសណីយ៍មានកម្រិតទាបជាប្រវត្តិសាស្ត្រ

| ភាគរយនៃការបោះឆ្នោតប៉ាន់ស្មានតាមរយៈការប្រើប៉ុស្តិ៍ប្រៃសណីយ៍ | ភាគរយសរុបនៃមណ្ឌលបោះឆ្នោត |
|---|---|
| **55.1% and Above** | 13.0% |
| **45.1%-55%** | 9.6% |
| **35.1%-45%** | 62.3% |
| **25.1%-35%** | 14.8% |
| **25% or Less** | 0.3% |

Figure 27. មណ្ឌលបោះឆ្នោត VC ដែលផ្ដល់អនុសាសន៍នៅជិត សហគមន៍ដែលមានការបោះឆ្នោតតាមការប្រើប៉ុស្តិ៍ប្រៃសណីយ៍មានកម្រិតទាបជាប្រវត្តិសាស្ត្រ



## *មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍នៅជិតអ្នកបោះឆ្នោតដែលមានពិការភាព*

គំរូមណ្ឌលបោះឆ្នោតថ្មី ត្រូវបានរៀបចំឡើងដើម្បីឱ្យអ្នកបោះឆ្នោតទាំងអស់អាចប្រើបាន ដោយធានាថាមណ្ឌលបោះឆ្នោតដែលអាចប្រើបានតាមច្បាប់ ADA មានទីតាំងស្ថិតនៅជិតអ្នកបោះឆ្នោតដែលមានពិការភាព។ រូបភាព 28 បង្ហាញពីលក្ខណៈទូទៅនៃអ្នកបោះឆ្នោតដែលមានពិការភាពក្នុងខិត្តប័ណ្ណជំរឿននីមួយៗដែលទាក់ទងនឹងមណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍។ អ្នកបោះឆ្នោតដែលមានពិការភាពប្រមាណជា 78 ភាគរយមានទីតាំងស្ថិតនៅក្នុងចម្ងាយកន្លះម៉ាយពីមណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍។

Figure 28. មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍នៅជិតអ្នកបោះឆ្នោតដែលមានពិការភាព



*មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍នៅជិតមធ្យោបាយធ្វើដំណើរសាធារណៈ:*

សហគមន៍ដែលមានប្រាក់ចំណូលទាប ជាញឹកញាប់ពឹងផ្អែកលើការប្រើប្រាស់ការធ្វើដំណើរឆ្លងកាត់ ហើយអ្នកបោះឆ្នោតដែលបង្ហាញឱ្យឃើញកំពុងបង្ហាញនូវចំណង់ចំណូលចិត្តចំពោះការប្រើប្រាស់ការធ្វើដំណើរឆ្លងកាត់តាមការជ្រើសរើសជាជាងតាមតម្រូវការ។ រូបភាព 29 បង្ហាញពីការប្រើប្រាស់ការធ្វើដំណើរឆ្លងកាត់ដែលចែកជាប្រភេទដូចខាងក្រោម:

- គ្មាន - កន្លែងស្ថិតនៅចម្ងាយលើសពី 0.5 ម៉ាយ នៃចំណតធ្វើដំណើរឆ្លងកាត់ណាមួយទេ
- ទាប - កន្លែងស្ថិតនៅចម្ងាយ 0.5 ម៉ាយ នៃចំណតធ្វើដំណើរឆ្លងកាត់ដែលមានគុណភាពទាប
- ល្អ – កន្លែងស្ថិតនៅចម្ងាយ 0.5 ម៉ាយ នៃចំណតធ្វើដំណើរឆ្លងកាត់ដែលមានគុណភាពខ្ពស់
- មធ្យម -កន្លែងស្ថិតនៅចម្ងាយ 0.25 ម៉ាយ នៃចំណតធ្វើដំណើរឆ្លងកាត់ដែលមានគុណភាពទាប
- ល្អ**ណាស់** – កន្លែងស្ថិតនៅចម្ងាយ 0.25 ម៉ាយ នៃចំណតធ្វើដំណើរឆ្លងកាត់ដែលមានគុណភាពខ្ពស់

និយមន័យអំពីចំណតធ្វើដំណើរឆ្លងកាត់ដែលមានគុណភាពខ្ពស់និងទាបត្រូវបានកំណត់នៅក្នុងផ្នែក 2.2.2 ។ ដូចបានបង្ហាញក្នុងតារាង 17, មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍មាន 48.2 ភាគរយ គឺស្ថិតនៅចម្ងាយមួយភាគបួនម៉ាយនៃចំណតធ្វើដំណើរឆ្លងកាត់ និងតិចជាង 2 ភាគរយ គឺស្ថិតនៅឆ្ងាយជាកន្លះម៉ាយនៃចំណតធ្វើដំណើរឆ្លងកាត់។

Table 17 មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍នៅជិតមធ្យោបាយធ្វើដំណើរសាធារណៈ:

| តំបន់ដែលមានចំណតធ្វើដំណើរឆ្លងកាត់ | ភាគរយសរុបនៃមណ្ឌលបោះឆ្នោត |
|---|---|
| **គ្មាន** | 1.7% |
| **ខ្សោយ** | 7.9% |
| **មធ្យម** | 42.2% |
| **ល្អ** | 24.9% |
| **ល្អណាស់** | 23.3% |

Figure 29. មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍នៅជិតមធ្យោបាយធ្វើដំណើរសា



## *ការស្ទះចរាចរណ៍នៅជិតមណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍*

មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍ត្រូវបានជ្រើសរើសដោយការគិតពិចារណាយ៉ាងខ្លាំងអំពីរបៀបដែលអ្នកបោះឆ្នោតអាចប្រើបានយ៉ាងងាយស្រួល និងប្រភេទឧបសគ្គផ្សេងៗដើម្បីចូលប្រើប្រាស់។

តាមរយៈការពិនិត្យចំនួនចរាចរណ៍ក្នុងមួយម៉ោងតាមដងផ្លូវក្នុងតំបន់វិភាគមធ្យោបាយធ្វើដំណើរនីមួយៗ (TAZ) អ្នកស្រាវជ្រាវបានកំណត់ការស្ទះចរាចរណ៍ដែលគួរឱ្យកត់សម្គាល់នឹងបានព្យាយាមចៀសវាងការកំណត់ទីតាំងមណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍នៅក្នុងតំបន់ដែលមានការកកស្ទះខ្លាំង។ ដោយសារតែមានលក្ខណៈកណ្តាលស្វ័យប្រវត្តិ និងផ្លូវកកស្ទះយ៉ាងខ្លាំងនៃខោនធី Los Angeles County វាមិនអាចចៀសវាងតំបន់ដែលមានការកកស្ទះខ្លាំងទាំងនេះបានគ្រប់ពេលវេលា នៅខណៈពេលកំពុងព្យាយាមកំណត់ទីតាំងនៅជិតកន្លែងដែលមានប្រជាជននិងមជ្ឈមណ្ឌលការងារច្រើន។ ដូចបានបង្ហាញក្នុងតារាង 18, មណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍មានប្រហែល 40 ភាគរយ គឺស្ថិតនៅក្នុងតំបន់មានការស្ទះចរាចរណ៍ខ្លាំងនិងខ្លាំងណាស់ ហើយ 35.1 ភាគរយ គឺស្ថិតនៅក្នុងតំបន់មានការស្ទះចរាចរណ៍ទាបនឹងទាបណាស់។

Table 18. ការស្ទះចរាចរណ៍នៅជិតមណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍

| ចំនួនចរាចរណ៍ក្នុងមួយម៉ោងតាមដងផ្លូវ | ភាគរយសរុបនៃមណ្ឌលបោះឆ្នោត |
|---|---|
| **Very Low (≤ 6,959)** | 23.3% |
| **Low (≤ 8,934)** | 11.8% |
| **Moderate (≤ 15,892)** | 25.9% |
| **High (≤ 40,401)** | 33.6% |
| **Very High (≤ 12,672)** | 5.3% |

Figure 30. ការស្ទះចរាចរណ៍នៅជិតមណ្ឌលបោះឆ្នោតដែលផ្តល់អនុសាសន៍



## 4.4 វិធានការជ្រើសរើសមណ្ឌលបោះឆ្នោតនាពេលអនាគត

ដោយសារគំរូបោះឆ្នោតថ្មី ត្រូវបានអនុវត្តនៅទូទាំងរដ្ឋនោះ ការអនុវត្តល្អបំផុតនឹងត្រូវបានកំណត់ដើម្បីជួយដល់ខោនធីនានាធ្វើឱ្យប្រសើរឡើងនូវដំណើរការជ្រើសរើសនិង ដំណើរការមណ្ឌលបោះឆ្នោតដែលអាចប្រើបាន និងមានប្រសិទ្ធភាព។ កម្មវិធី PlaceWorks បានផ្ដល់ជូនអ្នកចុះឈ្មោះឬអ្នកកត់ត្រា/ស្មៀនខោនធី RR/CC នូវអនុសាសន៍សម្រាប់ដំណើរការនិងការថែរក្សានាពេលអនាគត។

ការផ្ដល់អនុសាសន៍ទាំងនេះ ណែនាំអ្នកចុះឈ្មោះឬអ្នកកត់ត្រា/ស្មៀនខោនធី RR/CC តាមរយៈដំណើរការនៅពេលណា និងវិធីធ្វើបច្ចុប្បន្នភាពមូលដ្ឋានទិន្នន័យដែលត្រូវបានប្រើ ដើម្បីកំណត់ដង់ស៊ីតេប្រជាជន មជ្ឈមណ្ឌលការងារ លក្ខណៈសេដ្ឋកិច្ចសង្គម និងកត្តាផ្សេងៗទៀត ដែលបានប្រើដើម្បីកំណត់ភាពសមស្របនៃទីតាំងដើលមានសក្ដានុពល។ កម្មវិធី PlaceWorks ក៏បានផ្ដល់អនុសាសន៍ផងដែរ ដល់បុគ្គលិកចូលរួមរៀបចំបោះឆ្នោត ដើម្បីរាយការណ៍អំពីទីកន្លែងបន្ទាប់ពីការបោះឆ្នោត ដើម្បីបំពេញបន្ថែមនូវការវិភាគនៅនឹងកន្លែង ដែលធ្វើឡើងដោយអ្នកចុះឈ្មោះឬអ្នកកត់ត្រា/ស្មៀនខោនធី RR/CC ។